# ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០

## អាជ្ញាធរខេត្តកណ្តាល ពង្រឹងក្រុមការងារ ទទួលខុសត្រូវ និងដឹកជញ្ជូន ប្រជាពលរដ្ឋខ្មែរវិលត្រលប់ពីថៃ

http://kampucheathmey.com/ 31/3/2020 12:01 Pm

កណ្តាល ៖ លោក នៃ ចារី អភិបាលរង ខេត្តកណ្តាល បានរំលឹកឲ្យ អភិបាលស្រុក ក្រុង និងមន្ទីរពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់ខ្ពស់ ក្នុងការគ្រប់គ្រង និងដឹកជញ្ជូនបងប្អូនប្រជាពលរដ្ឋ ដែលត្រលប់មកពីប្រទេសថៃ ពីព្រំដែនមកកាន់លំនៅឋានរៀងៗខ្លួន។ លោករំលឹកបែបនេះ នៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារ ដើម្បីទទួលខុសត្រូវ ទទួល និងដឹកជញ្ជូនបងប្អូន ប្រជាពលរដ្ឋខ្មែរដែលវិលត្រលប់ពីប្រទេសថៃ កាលពីរសៀលថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ នៅសាលាខេត្តកណ្តាល។ លោកអភិបាលរងខេត្ត បានបន្តថា ដោយអនុវត្តតាមសេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃ លេខ១០០៧ សជណ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ និងតាមការណែនាំរបស់លោក គង់ សោភ័ណ្ឌ អភិបាលខេត្តកណ្តាល ខេត្តបានសម្រេចបង្កើតក្រុមការងារ ដើម្បីទទួលខុសត្រូវ ទទួល និងដឹកជញ្ជូនបងប្អូន ប្រជាពលរដ្ឋខ្មែរដែលវិលត្រលប់ពីប្រទេសថៃ។

លោកបញ្ជាក់ថា បន្ទាប់ពីមានការផ្ទុះជំងឺកូវីដ១៩ នៅក្នុងប្រទេសថៃ ហើយបានធ្វើការបិទព្រំដែនមក បងប្អូនខ្មែររស់នៅប្រទេសថៃបានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ តាមច្រកព្រំដែននានា ដែលតម្រូវឲ្យអាជ្ញាធរត្រូវធ្វើការត្រៀម មធ្យោបាយដឹកជញ្ជូនគាត់មកកាន់លំនៅឋានរៀងៗខ្លួន។ លោក បានស្នើដល់ដល់អាជ្ញាធរស្រុកក្រុង និងមន្ទីរពាក់ព័ន្ធ ត្រូវទំនាក់ទំនង និងចូលរួមសហការជាមួយរដ្ឋបាលខេត្តជាប់ព្រំដែនជាមួយប្រទេសថៃ ដើម្បីជួយឧបត្ថម្ភដោះស្រាយដល់ការដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរ ដែលមានលំនៅឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ពីព្រំដែនទៅកាន់ទៅកាន់លំនៅឋានរបស់ពួកគាត់។ ត្រូវចាត់ចែងមធ្យោបាយសមស្រប ដើម្បីដឹកជញ្ជូនប្រជាពលរដ្ឋដោយយកចិត្តទុកដាក់ អំពីសុវត្ថិភាព សុខភាព និងទ្រព្យសម្បត្តិរបស់ពួកគាត់ ព្រមទាំងរក្សាឲ្យបាននូវសណ្តាប់ធ្នាប់និងរបៀបរាបរយសាធារណៈ ពិសេសត្រូវជួយឧបត្ថម្ភនូវម្ហូបអាហារ ទឹក សម្ភារៈ និងថ្នាំពេទ្យ ជាងនេះអាជ្ញាធរភូមិ ឃុំ សង្កាត់ ត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ចុះត្រួតពិនិត្យជាប្រចាំ តាមផ្ទះរបស់ប្រជាពលរដ្ឋ ដើម្បីធានាថា បងប្អូនប្រជាពលរដ្ឋខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ អនុវត្តវិធានការណ៍ដាក់ខ្លួនឲ្យនៅដាច់ដោយឡែករយៈពេល១៤ថ្ងៃ បានត្រឹមត្រូវស្របតាមនីតិវិធីដែលកំណត់ដោយក្រសួងសុខាភិបាល ព្រមទាំងធ្វើការណែនាំដល់ក្រុមគ្រួសារ អំពីវិធីការការពារឆ្លងជំងឺកូវីដ១៩៕ មុនី

## លោក អម សុភា ចុះផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋដែលទើបវិលត្រឡប់មកពីក្រៅប្រទេស អំពីវិធានការ បង្ការទប់ស្កាត់ជំងឺវីរុសកូវីដ-១៩

https://grandnewsasia.com/ 31-03-2020

កំពង់ឆ្នាំង៖ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ លោក អម សុភា ប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជាខេត្តកំពង់ឆ្នាំង លោកស្រី ប៊ិន សុភី អនុប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមខេត្ត លោក ធិន ហ៊ុន ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លោក យង់ សៅរ៉ុឡឺ ប្រធានកិត្តិយសអនុសាខាស្រុក លោកស្រី អោក សុភារី សមាជិកអនុសាខាស្រុក មន្ត្រី និងយុវជនអនុសាខា រួមជាមួយអាជ្ញាធរឃុំ ភូមិ នាយប៉ុស្តិ៍នគរបាលឃុំជើងគ្រាវ បានចុះជួបសំណេះសំណាល និងផ្សព្វផ្សាយណែនាំការបង្ការ ទប់ស្កាត់ វីរុសកូវីដ ១៩ ដល់ប្រជាពលរដ្ឋដែលទើបវិលត្រលប់មកពីប្រទេសថៃ (ចំណាកស្រុក) ស្ថិតក្នុងភូមិសូភី ០៩នាក់ ភូមិត្រពាំងពពេល ០៥នាក់ និងភូមិដំណាក់កី ២៣នាក់ ក្នុងឃុំជើងគ្រាវ ស្រុករលាប្អៀរ។ ក្នុងឱកាសនោះ លោក អម សុភា ក៏បានមានមតិសំណេះសំណាល និងអប់រំផ្សព្វផ្សាយយ ណែនាំដល់ពួកគាត់ឲ្យដាក់ខ្លួននៅដាច់ដោយឡែកពីបងប្អូន ឪពុកម្តា

យ កូន ប្រពន្ធ ញាតិមិត្ត និងមិនអនុញ្ញាឲ្យចេញដើរ រហេតរហូតរយៈពេល១៤ថ្ងៃ ដើម្បីតាមដានអាការៈនៃជំងឺកូវីដ ១៩។ បន្ថែមពីនោះ លោក និងក្រុមការងារ ក៏បានអប់រំណែនាំអំពីរបៀបថែទាំសុខភាព ដូចជា៖

១. លាងដៃឲ្យបានញឹកញាប់ជាមួយសាប៊ូ និងទឹកស្អាត ឬទឹកអាល់កុលលាងដៃ ឬអាល់កុលជែល។

២. ខ្ទប់មាត់ និងច្រមុះ នៅពេលក្អក ឬកណ្តាស់ ដោយប្រើកែងដៃ ឬក្រដាសអនាម័យ រួចបោះចោលក្នុងធុងសំរាមឲ្យបានត្រឹមត្រូវ។

៣. ជៀសវាងប៉ះពាល់ជិតស្និទ្ធជាមួយអ្នកដែលមានគ្រុនក្តៅ ក្អក ឬផ្តាសាយ។

៤. ជៀសវាងប៉ះពាល់ភ្នែក ច្រមុះ ឬមាត់។

៥. បរិភោគអាហារដែលចម្អិនបានឆ្អិនល្អ។

៦. ស្វាគមន៍ដោយសំពះ ជំនួសការចាប់ដៃ។

៧.ត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល ជៀសវាងការទទួលពត៌មានពុំមានប្រភពមិនច្បាស់លាស់ និងភូតកុហក ៕

## ពលករប្រុស ស្រីជាង៣00នាក់នៅតែបន្តវិលពីប្រទេសថៃចូលមកកម្ពុជា តាមច្រករបៀងចំការគរ

http://nokorwatnews.com/ 01-04-2020

**ក្រុងប៉ោយប៉ែត៖** ពលករប្រុស ស្រីត្រូវបានគេដឹកតាមរថយន្តពីប្រទេសថៃមកទម្លាក់ចោលក្នុងភូមិទព័សៀម ស្រុកតាបប្រាយ៉ា(ថៃ)ទល់មុខច្រករបៀងចំការគ ក្នុងស្រុកស្វាយចេក ជាបន្តបន្ទាប់ដោយចាប់គិតពីថ្ងៃទី២៩ ខែរហូតមកដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ នេះមានចំនួន៣១៣នាក់។ ទាហ៊ានជួរមុខរបស់កម្ពុជាប្រាប់ថា ពលករប្រុសស្រីចំនួន៣១៣នាក់ នេះគឺមកពីប្រទេសថៃ ដោយចាប់គិតពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២០ មានចំនួន៧២នាក់ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ មានចំនួន១២៤នាក់ និងថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ចំនួន១១៧នាក់។ ដែលក្រុមទាហ៊ាននៅជួរមុខរបស់ពួកគាត់ទៅទទួលយកពីទីដីថៃ ដែលភាគីថៃដឹកមកដាក់នៅខាងទឹកដីរបស់គេ។ ដើម្បីងាយស្រួលដល់ការគ្រប់គ្រងក្នុងការតាមដានសុខភាពរបស់ពួកពលរដ្ឋទាំងនោះ និងក្រោមបទបញ្ជា និងការណែនាំ ពីឯកឧត្តម មេបញ្ជាការរង កងទ័ពជើងគោក មេបញ្ជាការ យោធភូមិភាគទី៥ លោកឧត្តមសេនីយ៍ទោ ឈុន ម៉ៅ មេបញ្ជាការរង យោធភូមិភាគទី៥ មេបញ្ជាការទិសទី១ បន្ទាយមានជ័យ ដឹកនាំកម្លាំងចុះសហការ បានចុះធ្វើការអប់រំណែនាំបងប្អូនប្រជាពលរដ្ឋខ្មែរ ដែលទើបតែត្រឡប់មកពីប្រទេសថៃអោយយល់ដឹងអំពីវិធីការពារ ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។ បន្ទាប់ពីប្រមូលជុំគ្នាពលករទាំងអស់នោះដឹកមកពិនិត្យសុខភាពនៅមណ្ឌលសំណាតក្រុងប៉ោយប៉ែត។

លោកអភិបាលខេត្តបន្ទាយមានជ័យ អ៊ុំ រាត្រី មានប្រសាសន៍ថា ចំពោះភាគីថៃគាត់មិនបានបិទទេ ហើយសំរាប់ពលករខាងអាជ្ញាធរថៃគាត់មានការសម្របសម្រួលឲ្យមានរយៈពេល៦ខែ តែគាត់មិនអាចនៅបានព្រោះកន្លែងការងារនៅតាមបណ្តាលក្រុមហ៊ុន រម្មណីយដ្ឋាន រោងចក្រ និងកន្លែងការងារមួយចំនួននៅក្នុងប្រទេសថៃ ត្រូវបានផ្អាក ដូច្នេះពួកគាត់ត្រូវសម្រេចចិត្តត្រូវតែវិលត្រលប់មកស្រុកកំណើតរបស់គាត់វិញ។ លោកបន្ថែមថា៖ក្នុងនាមអាជ្ញាធរ និងជាបងប្អូនខ្មែរដូចគ្នាគឺត្រូវតែទទួលទោះមានការនើយហត់យ៉ាងណាក៏ដោយ។លោកផ្តែផ្តាំពលករក៏ដូចជាពលរដ្ឋនៅក្នុងមូលដ្ឋានសូម ស្តាប់តាមការណែនាំរបស់អាជ្ញាធរមូលដ្ឋានដើម្បីចូលរួមទប់ស្កាត់ការរីករាល់ដាលជំងឺកូវីដ១៩ និងសុខភាព សុវត្ថិភាពខ្លួន ៕ វណ្ណា

## ពលករដែលត្រឡប់មកពី ប្រទេសថៃឡង់ដ៍ តាមច្រកចំការគរ ខេត្តបន្ទាយមានជ័យ មានចំនួន ១៥៥នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 31-03-2020

នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង៣០នាទី មានពលករដែលត្រឡប់មកពី ប្រទេសថៃឡង់ដ៍ តាមច្រកចំការគរ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ មកដាក់ត្រួតពិនិត្យសុខភាព នៅមណ្ឌលសុំចតដីថ្មី មានចំនួន ១៥៥នាក់។ បន្ទាប់ពីត្រួតពិនត្យសុខភាពរួចរាល់ ដោយមិនឃើញមានអ្វីគួរកត់សំគាល់នោះទេ ហើយឲ្យវិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរចូល ប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន មានចំនួន ១៤នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 31-03-2020

នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរចូល ប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន មានចំនួន ១៤នាក់។ ក្រុមចត្តាឡីស័ក បានវាស់កំដៅ ពុំមានសញ្ញាអ្វីគួរឲ្យកត់សំគាល់ឡើយ បន្ទាប់មកបានធ្វើការអប់រំ ណែនាំដល់ពួកគាត់ ពីវិធីបង្ការ ទប់ស្កាត់ ក្នុងការចម្លងមេរោគកូវីដ១៩ រួច ក៏ឲ្យប្រជាពលរដ្ឋទាំងនោះ វិលទ្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន ដោយខ្សែកមធ្យោបាយ ទំនិញ ចូល-ចេញ ពុំមានចរាចរទេ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រែកចាក បានទទួលពលរដ្ឋខ្មែរ ចំនួន ០៣នាក់ ពីប៉ុស្តិ៍វរៈយោធាការពារព្រំដែន សា សៀ ប្រទេសវៀតណាម

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 31-03-2020

នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ១១និង០០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រែកចាក បានទទួលពលរដ្ឋខ្មែរ ចំនួន ០៣នាក់ ពីប៉ុស្តិ៍វរៈយោធាការពារព្រំដែន សា សៀ ប្រទេសវៀតណាម។ នគរបាលអន្តោប្រវេសន៍ប៉ុស្តិ៍ បានឲ្យដឹងថា ពលរដ្ឋខ្មែរទាំង ០៣នាក់នេះ មាន ១. ឈ្មោះ ចាប សៅ ភេទប្រុស អាយុ ២៧ឆ្នាំ ទីលំនៅភូមិបរក្នុង សង្កាត់កពង់ត្រាច ខេត្តកំពត, ២. ឈ្មោះ លេង សីណា ភេទប្រុស អាយុ ៣០ឆ្នាំ ដែលមានទីលំនៅជាមួយគ្នា និង៣. ឈ្មោះ លេង ណាក់ ភេទប្រុស អាយុ ២៥ឆ្នាំ។

ក្រោយមកមន្ត្រីចត្តាឡីស័ក វាស់កំដៅ គឺធម្មតា និងបានសាកសួរសាមីខ្លួន បញ្ជាក់ថា បានធ្វើដំណើរចេញពីប្រទេសកម្ពុជា កាលពីថ្ងៃ ៣០ ខែមីនា ឆ្នាំ ២០២០ តាមសមុទ្រ (ក្រៅរង្វង់ភូមិសាស្ត្រ ប៉ុស្តិ៍ច្រកទ្វារព្រែកចាក) ដើម្បីដឹកមឹកទៅលក់នៅប្រទេសវៀតណាម ពេលនោះត្រូវយោធាការពារព្រំដែនវៀតណាម ឃាត់ខ្លួន នៅវេលាម៉ោង ១២និង០០នាទី ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០។

កម្លាំងនគរបាលប៉ុស្តិ៍បានការអប់រំ និងណែនាំសាមីខ្លួន បានទទួលកំហុស ស្តីពីការធ្វើដំណើរឆ្លងដែនដោយខុសច្បាប់ និងបានធ្វើកិច្ចសន្យា ឈប់ប្រព្រឹត្តសកម្មភាពខាងលើ រួចបានអនុញ្ញាតឲ្យវិលត្រឡប់ ទៅលំនៅដ្ឋាន ដើម្បីប្រកបមុខរបរធម្មតាវិញ៕

# ថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០

## ពលរដ្ឋខេត្តកំពតមកពីថៃ ជាច្រើននាក់ ចែករំលែកបទពិសោធន៍រស់នៅដាច់ដោយឡែក ១៤ថ្ងៃ

http://bayontv.com.kh/ 01/04/2020

កំពត ៖ ពលរដ្ឋរស់នៅស្រុកឈូក ខេត្តកំពត ជាច្រើននាក់ ដែលទើបត្រឡប់មកពីប្រទេសថៃ យល់ឃើញថា ការរស់នៅដាច់ដោយឡែករយៈ១៤ថ្ងៃ គឺដើម្បីបង្ការការឆ្លងរាលដាលជំងឺកូវីដ១៩ ជារឿងល្អប្រសើរ ហើយ ពួកគេពេញចិត្ត ក្នុងការអនុវត្ត ព្រមទាំងបានចែករំលែកនូវបទពិសោធន៍មួយចំនួន និងបានស្នើឲ្យពលរដ្ឋ ដែលទើបត្រ

ឡប់មកពីក្រៅប្រទេសទាំងអស់ រួមគ្នាអនុវត្តវិធានការនេះដែរ។ ប្រជាពលរដ្ឋ ដែលទើបមកពីថៃ រស់នៅភូមិខ្នាច រមាស ឃុំនារាយណ៍ ស្រុកឈូក ខេត្តកំពត បានឲ្យដឹងថា នៅពេលដែលពួកគេ បានត្រឡប់មកដល់ស្រុកកំណើត ភ្លាម អាជ្ញាធរមូលដ្ឋាន គ្រូពេទ្យ បានចុះ មកសួរសុខទុក្ខដល់ផ្ទះ ហើយបានពិនិត្យកម្ដៅខ្លួន និងណែនាំឲ្យរស់នៅ ដាច់ដោយឡែកពីគ្រួសារ មិនឲ្យ ប៉ះពាល់សាច់ញាតិ ឬធ្វើដំណើរទៅណាមកណាឡើយ។ ពលរដ្ឋ បានបញ្ជាក់ថា ពួកគេ បានសម្រេចចិត្តរស់នៅដាច់ដោយឡែក ពេញចិត្តក្នុងការអនុវត្ត និងបានស្នើដល់ពលរដ្ឋផ្សេងទៀត ដែល ទើបមកពីក្រៅប្រទេស ត្រូវយកចិត្តទុកដាក់ និងអនុវត្តតាមការ ណែនាំ របស់អាជ្ញាធរ ដើម្បីបញ្ចៀសការឆ្លងរាល ដាលកូវីដ១៩ដោយថាហេតុ។

លោកមេឃុំនារាយណ៍ ស្រុកឈូក បានឲ្យដឹងថា នៅក្នុងឃុំលោក មានពលរដ្ឋដែលទើបមកពី ប្រទេសថៃ តែពាក់កណ្ដាលប៉ុណ្ណោះ បានស្ម័គ្រចិត្តអនុវត្តវិធានការប្រយុទ្ធនឹងជំងឺកូវីដ១៩ ដោយការរស់នៅដាច់ដោយឡែក រយៈពេល១៤ថ្ងៃ ស្របពេលអ្នកផ្សេងទៀត កំពុងតែអនុវត្តវិធានការអនាម័យ រស់នៅ ស្អាត ឧស្សាហ៍លាងដៃញឹ កញាប់នឹងអាល់កុល សាប៊ូ និងពាក់ម៉ាស់ ជាដើម។

ប្រជាពលរដ្ឋស្ម័គ្រចិត្តរស់នៅដាច់ដោយឡែក បានថ្លែងថា រយៈពេល១៤ថ្ងៃ វាមិនយូរទេ ពួកគេទាំងអស់គ្នា អាចធ្វើបាន ព្រោះដើម្បីសុខភាពញាតិមិត្តក្នុងភូមិស្រុក ម្យ៉ាងពួកគេ ក៏មិនបានដឹងច្បាស់ថា ខ្លួនមានឬគ្មានជំងឺកូវីដ ១៩ មួយរយភាគរយនោះដែរ។ ប្រជាពលរដ្ឋ មានការយល់ដឹងច្រើន ក៏ដោយសារ តែអាជ្ញាធរភូមិឃុំ បានយកចិត្ត ទុកដាក់ ចុះណែនាំផ្សព្វផ្សាយបន្ថែម អំពីវិធានការការពារ ទប់ស្កាត់ការឆ្លង រាតត្បាត នៃជំងឺកូវីដ១៩៕

## ពលករមានស្រុកកំណើតក្នុងខេត្តត្បូងឃ្មុំ ថ្លែងអំណរគុណសម្ដេចតេជោ និងរដ្ឋបាលខេត្ត ចាត់ក្រុមការងារ ទៅដឹកជញ្ជូនយកមកដោយផ្ទាល់ ពីច្រកទ្វារព្រំដែនខេត្ត៦ជាប់ព្រំដែនថៃ

http://www.freshnewsasia.com/ 2020-04-01

(ត្បូងឃ្មុំ)៖ ក្រោយពីប្រទេសថៃបានបិទច្រកទ្វារព្រំដែន ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ បាន ធ្វើឲ្យពលករកម្ពុជា បានធ្វើដំណើរត្រឡប់ចូលមកស្រុកកំណើតរបស់ខ្លួនវិញ តាមច្រកព្រំដែននានា ដែលជាប់នឹង ប្រទេសថៃ។ ជាមួយគ្នានោះ លោក ជាម ច័ន្ទសោភ័ណ អភិបាលខេត្តត្បូងឃ្មុំ បានបែងចែកក្រុមការងារ ដោយចាត់ វិធានការនានាយ៉ាងម៉ត់ចត់បំផុត ដើម្បីគ្រប់គ្រងសភាពការណ៍ បង្ការ ទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ក្នុង ភូមិសាស្ត្រខេត្តត្បូងឃ្មុំ។ ដោយក្នុងនោះអ្នកផ្ទុកវីរុសកូវីដ១៩ ចំនួន០៤នាក់ ក៏បានជាសះស្បើយទាំង០៤នាក់ផង ដែរ ដោយទទួលបានការព្យាបាលយ៉ាងយកចិត្តទុកដាក់បំផុត ពីសំណាក់មន្ត្រីសុខាភិបាល ក្រោមកិច្ចគាំទ្រយ៉ាង ពេញទំហឹង ពីសំណាក់លោកអភិបាលខេត្ត។ ទន្ទឹមនឹងនេះ លោក ជាម ច័ន្ទសោភ័ណ បានចាត់បែងចែកក្រុម ការងារ ឲ្យធ្វើដំណើរទៅកាន់ខេត្តចំនួន០៦រួមមាន ខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ ប៉ៃលិន និងខេត្តកោះកុង ដែលមានព្រំដែនជាប់ប្រទេសថៃ ដើម្បីទៅទទួលពលករដោយផ្ទាល់ មានផ្ទះសម្បែង និង ស្រុកកំណើតក្នុងខេត្តត្បូងឃ្មុំ ដោយចូលរួមសហការយ៉ាងល្អជាមួយអាជ្ញាធរ មន្ត្រីជំនាញ សមត្ថកិច្ចពាក់ព័ន្ធ នៅ ខេត្ត ទាំង០៦។

កាលពីពេលកន្លងទៅ ក្នុងកិច្ចប្រជុំបែងចែកក្រុមការងារដែលចុះទៅដឹកជញ្ជូនដោយផ្ទាល់នេះ លោក ជាម ច័ន្ទសោភ័ណ បានលើកឡើងពីគោលបំណងរួម ដើម្បីសម្រួលថ្លៃធ្វើដំណើររបស់បងប្អូនពលករ ដោយរដ្ឋបាលខេត្ត ជាអ្នកធានារ៉ាប់រងលើការចំណាយទាំងអស់, ធ្វើការបញ្ជ្រាបការយល់ដឹង វិធានការនានាពាក់ព័ន្ធនឹងជំងឺកូវីដ១៩, ងាយស្រួលធ្វើតេស្តសុខភាពភ្លាមៗស្វែងរកសញ្ញាណនៃរោគសញ្ញាជំងឺកូវីដ១៩, បើសិនធ្វើតេស្តមានវិជ្ជមាន ងាយ ស្រួលក្នុងការទប់ស្កាត់ឲ្យបានទាន់ពេលវេលា ក្នុងការឆ្លងបន្តក្នុងការធ្វើដំណើរ ក៏ដូចជានៅឯស្រុកកំណើត, ងាយ

ស្រួលតាមសង្កេតពលករចំពោះការដាក់ឲ្យនៅដាច់ដោយឡែកចំនួន១៤ថ្ងៃ រាប់ចាប់ពីថ្ងៃចូលមកកម្ពុជាវិញ ក៏ដូចជាបន្តតាមដានសុខភាពរបស់ពួកគាត់នៅភូមិឋានដែលរស់នៅ។

ជាការឆ្លើយតប បងប្អូនពលករទាំងអស់ បានសម្តែងក្តីរំភើបរីករាយ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះសម្តេចតេជោ ហ៊ុនសែន ប្រមុខនៃកម្ពុជា ថ្នាក់ដឹកនាំជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា រដ្ឋបាលខេត្តត្បូងឃ្មុំ និងក្រុមការងារទាំងអស់ ដែលបានរួមសហការទទួលយ៉ាងកក់ក្តៅបំផុតតាំងពីច្រកទ្វារព្រំដែន រហូតដល់ភូមិឋាននាស្រុកកំណើតរបស់ខ្លួន នាខេត្តត្បូងឃ្មុំ។

ដោយឡែកនាយប់ថ្ងៃទី០១នេះ ខែមេសា ឆ្នាំ២០២០នេះ លោក ចេង ប៊ុណ្ណារ៉ា អភិបាលរងខេត្តត្បូងឃ្មុំ បានចុះសំណេះសំណាល និងទទួលការមកដល់របស់ បងប្អូនពលករមកពីប្រទេសថៃ នៅស្រុកអូររាំងឪផងដែរ។ សូមជម្រាបថា៖ គិតត្រឹមយប់ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០នេះ ពលករវិលត្រឡប់ពីក្រៅប្រទេសមកកម្ពុជា ចូលមកខេត្តត្បូងឃ្មុំ សរុបមានចំនួន ១,៨៨២នាក់ ស្រី៧៩៧នាក់ កើនលើសម្សិលមិញ ៩៣នាក់។ ក្នុងនោះមកពីប្រទេសថៃចំនួន ១,៥៥៣នាក់ ស្រី៦៥២នាក់, ម៉ាឡេស៊ីចំនួន ១៩២នាក់ ស្រី៧៧នាក់, ប្រទេសកូរ៉េ ចំនួន៥០នាក់ ស្រី១៦នាក់ និងប្រទេសចិន ចំនួន៤០នាក់ ស្រី៣៣នាក់៕

## អាជ្ញាធរក្រុងសិរីសោភ័ណ អញ្ជើញចុះសាកសុខទុកបងប្អូនខ្មែរដែលទើបត្រលប់មកពីប្រទេសថៃ និងនាំយកអំណោយប្រគល់ជូនគ្រួសារក្រីក្រ ៦គ្រួសារ នៅសង្កាត់ទឹកថ្លា

https://gdlf-kh.com/ 2020/04/01/ Kim Sopha បន្ទាយមានជ័យ

បន្ទាយមានជ័យ ៖ អនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម នាយឧត្តមសេនីយ៍ កែ គឹមយ៉ាន ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តបន្ទាយមានជ័យ ដោយមានកាបញ្ជាផ្ទាល់ពី ឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្ត ។

នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ លោក ហ៊ីល រ៉ាយ៉ា អភិបាលក្រុងសិរិសោភ័ណ លោក អ៊ុង ស៊ីផាន ប្រធានពន្ធនាគារខេត្ត រួមនឹងក្រុមការងាចុះជួយសង្កាត់ អញ្ជើញចុះសាកសួរសុខទុកបងប្អូនពលករខ្មែរ ១៧នាក់ ដែលទើបនឹងត្រឡប់មកពីធ្វើការនៅប្រទេសថៃ នៅភូមិបាណយ សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ។ មុនពេលពួកគាត់ត្រលប់ស្រុកកំណើតវិញតាមច្រកចំការគ ស្រុកស្វាយចេក ពួកគាត់ទាំងអស់គ្នា ក៏បានឆ្លងកាត់ការពិនិត្យសុខភាព និងវាស់កំដៅយ៉ាងត្រឹមត្រូវ និងមានលិខិតបញ្ជាក់ពីការពិនិត្យផងដែរទើបអាជ្ញាធរអនុញ្ញាតមកស្រុកកំណើតបាន។ នាឱកាសនោះ លោក ហ៊ីល រ៉ាយ៉ា អភិបាលក្រុង ក៏បានធ្វើការណែនាំដល់បងប្អូនដែលទើបត្រលប់មកពីធ្វើការនៅប្រទេសថៃទាំងអស់ សូមចូលរួមថែរក្សាសុខភាពឲ្យបានល្អ ពិសេសត្រូវអនុវត្តទៅតាមសេចក្តីណែនាំរស់ក្រសួងសុខាភិបាល ដោយតម្រូវឲ្យបងប្អូនដាក់ខ្លួនឲ្យនៅដាច់ដោយឡែករយៈពេល១៤ថ្ងៃសិន ដើម្បីធ្វើការតាមដានសុខភាពខ្លួនឯង បើសិនក្នុងករណីមិនស្រួលខ្លួន ឬសង្ស័យអាចទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដើម្បីពិនិត្យ។

ម្យ៉ាងវិញទៀត លោកអភិបាលក្រុង ក៏បានធ្វើការអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ ត្រូវចូលរួមអនុវត្តវិធានការ អនាម័យទាំងអស់គ្នា ឲ្យបានជាប្រចាំ ការពារពីឆ្លងមេរោគផ្សេងៗ ពិសេសវីរុស កូវីដ -១៩។ ក្នុងនោះដែរលោក ហ៊ីល រ៉ាយ៉ា រួមនឹងក្រុមការងារ ក៏បាននាំយកអំណោយរបស់ ឯកឧត្តម នាយឧត្តមសេនីយ៍ កែ គឹមយ៉ាន និងលោកជំទាវ ប្រគល់ជូនគ្រួសារក្រីក្រ និងចាស់ជរា ចំនួន៦គ្រួសារ នៅក្នុងសង្កាត់ទឹកថ្លា ។ ដែលក្នុងមួយគ្រួសារទទួលបាន អង្ករ២៥គីឡូក្រាម ទឹកត្រី ១យួ ទឹកស៊ីអ៊ីវ១យួរ មី ១កេស ត្រីខ១យួរផងដែរ៕

## អាជ្ញាធរខេត្តក្រចេះត្រៀមរួចរាល់លើមធ្យោបាយដឹកជញ្ជូនពលករខ្មែរចេញពីប្រទេសថៃ ដោយតាមដានត្រួតពិនិត្យសុខភាពជាចម្បង

https://grandnewsasia.com/ 01-04-2020

ក្រចេះ៖ នៅរសៀលថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០នេះ លោក ប៉ែន លីណាត អភិបាលរងខេត្តក្រចេះ អញ្ជើញដឹកនាំកិច្ចប្រជុំ ស្តីពីត្រៀមលក្ខណៈក្នុងការទំនាក់ទំនងជាមួយបណ្តាខេត្តដែលជាព្រំប្រទល់ប្រទេសថៃ ដើម្បីស្រង់នូវស្ថិតិ និងដឹកជញ្ជូនបងប្អូនប្រជាពលរដ្ឋក្នុងខេត្តក្រចេះ ដែលទៅស៊ីឈ្នួលជាពលករនៅប្រទេសថៃ មកប្រទេសកម្ពុជាវិញ។ តាមការបញ្ជាក់របស់របស់អភិបាលរងខេត្ត៖ គិតមកទល់ពេលនេះ មានបងប្អូនពលករវិលចូលស្រុកចំនួន ២៥៦នាក់ ហើយអាជ្ញាធរ បានដាក់ពួកគាត់ឲ្យរស់នៅដាច់ដោយឡែកពីគេ និងកំពុងតែធ្វើការតាមដានសុខភាពផងដែរ។ ហើយនិងកំពុងបន្តត្រៀមស្វែងរកបន្ថែម និងធ្វើការតាមដានត្រួតពិនិត្យពីស្ថានភាពសុខភាពតាមរយៈមធ្យោបាយដឹកជញ្ជូនពួកគាត់វិលចូលស្រុក នាឱកាសបុណ្យចូលឆ្នាំប្រពៃណីខ្មែរខាងមុខ។ លោក អភិបាលរងខេត្ត បានស្នើឱ្យអាជ្ញាធរស្រុក-ក្រុងទាំង៦ នៃខេត្តក្រចេះ ត្រូវបន្តចុះធ្វើការតាមដាន និងពង្រឹងការចុះអប់រំផ្សព្វផ្សាយពាក់ពន្ធ័ នឹងការទប់ស្កាត់ការពារ ការរីករាលដាលឆ្លងមេរោគកូវីដ-១៩ ទៅដល់ប្រជាពលរដ្ឋគ្រប់រូបនៅតាមគ្រប់មូលដ្ឋាន ជាពិសេសអ្នកដែលធ្វើដំណើរមកពីក្រៅប្រទេសវិលចូលមកស្រុកកំណើតរបស់ខ្លួន ដែលត្រូវយកចិត្តទុកដាក់ជាខ្លាំងចំពោះបញ្ហាសុខភាព និងស្ថានភាពជីវភាពប្រចាំថ្ងៃរបស់ពួកគាត់ ដើម្បីរាយការណ៍ជូនខេត្ត ឬកាកបាទក្រហម ផ្តល់ជំនួយជូនតែមិនតម្រូវឱ្យមានការប្រមូលផ្តុំនោះទេ។

ម្យ៉ាងវិញទៀត ចំពោះបងប្អូនដែលទើបវិលចូលស្រុក ត្រូវរស់នៅឱ្យដាច់ដោយឡែកពីក្រុមគ្រួសារ ឬអ្នកដទៃក្នុងរយៈពេល ១៤ថ្ងៃ ដើម្បីខាងសុខាភិបាលធ្វើការតាមដានរករោគសញ្ញាមេរោគកូវីដ-១៩ និងត្រូវអនុវត្តជាប្រចាំក្នុងធ្វើអនាម័យ ដោយត្រូវលាងដៃ និងសាប៊ូ ឬទឹកអាកុលឱ្យបានញឹកញាប់ ត្រូវពាក់ម៉ាស ឬក្រម៉ា ខ្ទំច្រមុះ និងមាត់ ហើយបើសិនជាមានការក្អក ឬកណ្តាស់សូមឱ្យមានការខ្ទប់មាត់ ឬក៏យកកែងដៃខ្ទប់មាត់ ការធ្វើបែបនេះគឺក្នុងន័យបង្ការកុំឱ្យមានឆ្លងរីករាល់ដាលមេរោគ (វីរុសកូវីដ-១៩)៕

## អភិបាលខេត្តកំពត ណែនាំអាជ្ញាធរតាមមូលដ្ឋាន ត្រូវតាមដាន និងចុះពិនិត្យជាប្រចាំ ពលករវិលត្រឡប់មកពីបរទេស ការពារ COVID-19

http://www.freshnewsasia.com/ 2020-04-02

(កំពត)៖ លោក ជាវ តាយ អភិបាលខេត្តកំពត នាថ្ងៃទី២ ខែមេសា ឆ្នាំ២០២០ បានបើកកិច្ចប្រជុំបន្ទាន់មួយ លើការងារត្រៀមគ្រប់គ្រងពលរដ្ឋខ្មែរដែលត្រឡប់ពីប្រទេសថៃ និងប្រទេសផ្សេងទៀត ដើម្បីបង្កាទប់ស្កាត់ជំងឺវិញជំងឺឆ្លងកូវីដ-១៩។ អភិបាលខេត្ត ជាវ តាយ បានបញ្ជាក់ថា មន្រ្តីទាំងអស់ត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងមហាផ្ទៃ ស្តីពីវិធានការគ្រប់គ្រងប្រជាពលរដ្ឋខ្មែរ ដែលវិលត្រឡប់ពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ឲ្យប្រកបដោយសណ្តាប់ធ្នាប់ និងសុវត្ថិភាពល្អប្រសើរ។ រដ្ឋបាលខេត្តកំពត បានប្រាប់បណ្តាថ្នាក់ដឹកនាំ មន្ទីរអង្គភាព អាជ្ញាធរ ក្រុង ស្រុក ដែលជាក្រុមការងារត្រូវតែចូលរួមយកចិត្តទុកដាក់សហការគ្នា ក្នុងការដឹកជញ្ជូនពលរដ្ឋខ្មែរទាំងអស់នោះ ដែលមកពីប្រទេសថៃ ដោយទទួលខុសត្រូវខ្ពស់ទាំងសុវត្ថិភាព សុខភាព ទ្រព្យសម្បត្តិ និងរក្សាឲ្យបាននូវសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈក៏ដូចជា ជីវភាពរស់នៅខ្វះខាតសម្រាប់ពលរដ្ឋទាំងអស់នោះពេលមកកាន់មូលដ្ឋានរៀងៗខ្លួន។

អភិបាលខេត្ត ក៏បានណែនាំ និងផ្តាំផ្ញើអាជ្ញាធរក្រុង ស្រុក ត្រូវតាមដាន និងគាំទ្រដល់អាជ្ញាធរឃុំ-សង្កាត់ និងភូមិឲ្យមានកិច្ចសហការល្អជាមួយសមត្ថកិច្ចពាក់ព័ន្ធ ចុះត្រួតពិនិត្យជាប្រចាំ ដើម្បីធានាថា ពលរដ្ឋខ្មែរ វិលត្រ

ឡប់មកពីប្រទេសថៃ ឬប្រទេសផ្សេងទៀត ដោយអនុវត្តនូវវិធានការការពារខ្លួនឱ្យបាន តាមវិធានការណែនាំរបស់ក្រសួងសុខាភិបាលឲ្យមានប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនេះ លោកអភិបាលខេត្ត ក៏បានផ្តាំផ្ញើដល់អាជ្ញាធរក្រុង ស្រុក ឃុំ សង្កាត់រហូតដល់ភូមិ ឱ្យមានកិច្ចសហការគ្នាបង្កើនសកម្មភាពបិទផ្សាយផ្ទាំងរូបភាព និងចាក់មេក្រូផ្សាយជាសំឡេងអប់រំ របស់គណៈកម្មការជាតិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ នៅមូលដ្ឋានរៀងៗខ្លួន។ ពិសេសភូមិ ឃុំ សង្កាត់ ដែលមានបងប្អូនប្រជាពលរដ្ឋច្រើនទើបវិលត្រឡប់មកពីប្រទេសថៃ៕

## អភិបាលខេត្តបន្ទាយមានជ័យ ស្នើសុំអភិបាលខេត្តស្រះកែវ ២ ចំណុចសំខាន់ ដើម្បីសម្រួលដល់ប្រជាពលរដ្ឋ និងរួមសហការគ្នា ទប់ស្កាត់ជំងឺកូវីដ ១៩

https://dap-news.com/national/ BySS107 Posted on April 1, 2020

បន្ទាយមានជ័យ៖ លោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ អញ្ជើញដឹកនាំប្រតិភូកងកម្លាំងអាជ្ញាធរមានសមត្ថកិច្ច ក្នុងភូមិសាស្ត្រខេត្ត និងបន្ទាត់ព្រំដែនកម្ពុជា-ថៃ ជួបប្រជុំពិភាក្សា ដោះស្រាយការងារបន្ទាន់មួយចំនួន ជាមួយអភិបាលខេត្តស្រះកែវ ព្រះរាជាណាចក្រថៃ លោក វ៉ាផាន់ សុវាណុន Mr.WORAPHAN SUWANNUS នៅស្នាក់ការគយថៃ ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ក្លងឡឹក នារសៀលថ្ងៃទី០១ មេសា ឆ្នាំ ២០២០ ។ ក្នុងកិច្ចប្រជុំ លោកអភិបាលខេត្តបន្ទាយមានជ័យ បានស្នើសុំជាគោលការណ៍រួមទៅ ០២ចំណុច ដល់លោកអភិបាលខេត្តស្រះកែវ :

១.ស្នើសុំជួយសម្រួលដល់បងប្អូនប្រជាពលករខ្មែរ ដែលត្រូវបានអាជ្ញាធរថៃ បញ្ជូនមកជារាល់ថ្ងៃ សូមមានកិច្ចសហការ និងកំណត់យកទីតាំងច្រក ណាមួយសមរម្យផ្លូវ ដូចជាច្រកបឹងត្រកួនជាអាទ៍ ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យ ការពារជំងឺកូវីត១៩ តែកន្លែងមកបញ្ជូនមកតែតាមច្រករបៀង ចំការគរ ។

២.ស្នើឲ្យមានការជួយសម្រួលការចេញចូលដឹកតំឡូងមីរបស់ប្រជាកសិករ ដើម្បីជំរុញសេដ្ឋកិច្ចនៃប្រទេសទាំងពីរ ដូចជា នៅច្រកបឹងត្រកួន ច្រកម៉ាឡៃ និងច្រកប៉ោយប៉ែត ជាដើម។

ក្រោយពីការជជែកពិភាក្សាយ៉ាងយកចិត្តទុកដាក់រវាង ភាគីទាំងពីរ តាមសំណើសុំរបស់ លោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ ដើម្បីសហការ សម្របសម្រួលជួយដល់ប្រជាពលករខ្មែរ និងដើម្បីរួមសហការគ្នាទប់ស្កាត់ និងប្រយុទ្ធនឹងជំងឺកូវីត១៩ ។

លោក វ៉ាផាន់ សុវាណុន Mr.WORAPHAN SUWANNUS អភិបាលខេត្តស្រះកែវ និងកងកម្លាំងប៉ូលីសថៃ បានឯកភាពជាគោលការណ៍រួម:

១.កំណត់យកទីតាំងច្រកអូរបីជាន់ គោកធ្លុង ជាកន្លែងតែមួយគត់ ដើម្បីសម្របសម្រួលដល់ពលករ ដែលអាជ្ញាធរបញ្ជូនមក ដើម្បីងាយស្រួលទាំងខាងថៃ និងកម្ពុជា ដើម្បីរួមគ្នាពិនិត្យសុខភាព មុនអនុញ្ញាតិឲ្យចេញ។ ជាមួយនោះបន្តសហការទប់ស្កាត់ការលួចចេញតាមច្រករបៀងផ្សេងទៀត។

២.តាមសំណើរសុំរបស់ លោកអភិបាលខេត្តបន្ទាយមានជ័យ សម្រួលចេញជំឡូវមី ទំនិញ ចេញតាមច្រកតំបន់ផ្លូវការណាមួយនោះ រដ្ឋបាលខេត្តស្រះកែវនឹងធ្វើរបាយការណ៍សុំគោលក្រសួងពាណិជ្ជកម្មថៃ ដើម្បីសម្រួលជូន និងផ្តល់ដំណឹងជម្រាបជូនតាមក្រោយ ។

## ដំណឹងល្អ! ថៃអនុញ្ញាតឲ្យពលករចំណាកស្រុកជាប់គាំង មកពីកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា អាចស្នាក់នៅ និងបន្តធ្វើការរធម្មតារហូតព្រំដែនបើកឡើងវិញ

https://www.cen.com.kh/ April 2, 2020

ប្រទេសថៃ៖ ក្រសួងការងារថៃ កាលពីថ្ងៃទី១ ខែមេសា បានអនុញ្ញាតឲ្យពលករដែលជាប់គាំង មកពីប្រទេសឡាវ កម្ពុជា និងមីយ៉ាន់ម៉ា ស្នាក់នៅ និងធ្វើការលើសពីថ្ងៃផុតកំណត់របស់ពួកគេ ដោយសារការបិទព្រំដែន

របស់ពួកគេ នាពេលថ្មីៗនេះ។ រដ្ឋមន្ត្រីក្រសួងការងារ លោក Mom Ratchawongse Chatumongol Sonakul បានឲ្យដឹងថាពលករចំណាកស្រុកត្រូវបានអនុញ្ញាតឱ្យបន្តការងារ របស់ពួកគេ រហូតដល់ព្រំដែនបើកជាថ្មី។ រដ្ឋមន្ត្រីខាងលើក៏បានបញ្ជាក់ឲ្យដឹងដែរថា "សេចក្តីសម្រេចនេះនឹងផ្តល់អត្ថប្រយោជន៍ ដល់ពលករចំណាកស្រុកចំនួន ១០៨.៥៨៦នាក់។ មានកម្មករចំនួន ៤៤,២២២ នាក់ ដែលត្រូវបានគេនាំចូលពីប្រទេសទាំងនេះ មកធ្វើការរយៈពេល ៤ឆ្នាំ នៅក្នុងប្រទេសថៃដោយផ្អែកលើអនុស្សរណៈនៃការយោគយល់គ្នា ជាមួយប្រទេសជិតខាង និងកម្មករចំនួន ៦៤.៣៦៤ នាក់ដែលមានប័ណ្ណព្រំដែនចេញចូល និងធ្វើការនៅតាមតំបន់ព្រំដែនជារៀងរាល់ថ្ងៃតាមរដូវ៕

ប្រែសម្រួល៖ លឹម ហុង (ប្រភព៖ Bangkok Post)

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃ ចំនួន ០២នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 01-04-2020

នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៦និង១៥នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃ ចំនួន ០២នាក់។ នគរបាលអន្តោប្រវេសន៍ប៉ុស្តិ៍ បានឲ្យដឹងថា ពលករខ្មែរទាំង ០២នាក់នេះ មាន ១. ឈ្មោះ សំ ទិត្យ ភេទប្រុស អាយុ ៣៦ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ស្ថិតក្នុងភូមិតាមូង ឃុំកំពែងស្រុកព្រៃកាបាស់ ខេត្តតាកែវ និង២. ឈ្មោះ ញ៉ែម ភិរម្យ ភេទប្រុស អាយុ ៣៨ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ស្ថិតក្នុងភូមិមួយ ឃុំដងទង់ ស្រុកស្មាច់មានជ័យ ខេត្តកោះកុង។ ក្នុងនេះក៏មានការចូលរួមពីមន្ត្រីចត្តាឡីស័ក្ត ត្រួតពិនិត្យសុខភាពផងដែរ និងបានធ្វើការអប់រំ ណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ពលរដ្ឋខ្មែរ ចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ មានចំនួន ០៦នាក់ ស្រី ០២នាក់ និងក្មេង ០១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 01-04-2020

នៅព្រឹកថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ ច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន នៅបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរ មធ្យោបាយ និងទំនិញ ចូល-ចេញ ឆ្លងកាត់ បានឡើយ។ ដោយឡែកមានពលរដ្ឋខ្មែរ ចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ មានចំនួន ០៦នាក់ ស្រី ០២នាក់ និងក្មេង ០១នាក់ បន្ទាប់មកក្រុមចត្តាឡីស័ក វាស់កំដៅពុំមានសញ្ញាអ្វី គួរឲ្យកត់សំគាល់ ព្រមទាំងបានធ្វើការអប់រំ ណែនាំដល់ពួកគាត់ ពីវិធីបង្ការ ទប់ស្កាត់ ក្នុងការចម្លងមេរោគកូវីដ១៩ រួច ក៏ឲ្យប្រជាពលរដ្ឋទាំងនោះ វិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៥០នាក់ ស្រី ១៨៩នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 01-04-2020

នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៤និង៣០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៥០នាក់ ស្រី ១៨៩នាក់៕

# ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០

## សម្តេចតេជោ ហ៊ុន សែន ៖ ពលករខ្មែរជិត ៦ម៉ឺន នាក់ បានត្រឡប់មកពីថៃ

http://www.rasmeinews.com/ April 5, 2020, 12:14 PM

ដោយៈមុនីរ័ត្ន/ភ្នំពេញៈលោកហ៊ុន ម៉ាណែត មេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក និងក្រុមការងារចំរុះ បានចុះសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋ ដែលទើបត្រលប់ពីប្រទេសថៃ ត្រូវបានរៀបចំឲ្យសម្រាកបណ្តោះអាសន្នក្នុងរយៈពេលខ្លីនៅមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីពិនិត្យសុខភាព និងអប់រំផ្សព្វផ្សាយ វិធីបង្ការ ការឆ្លងជំងឺ កូវីដ១៩ ។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានបញ្ជាក់ថា មកដល់ពេលនេះ ពលករខ្មែរជិត ៦ម៉ឺននាក់ បានត្រឡប់មកពីថៃ នឹងមានជាបន្តបន្ទាប់ទៀត ប៉ុន្តែពួកគេមិនទាន់បង្កហានិភ័យនៅក្នុងសហគមន៍នៅឡើយទេហើយមកដល់ពេលនេះ មិនទាន់មានអ្នកណាស្លាប់ទេ។ "...យើងបញ្ចេញកម្លាំងទាងអស់ដើម្បីធ្វើកិច្ចការងារ ដើម្បីជាផលប្រយោជន៍របស់ប្រជាជនយើង កុំទុកឲ្យប្រជាពលរដ្ឋណាម្នាក់ស្លាប់ ដោយយើងមិនបានដឹង ហើយមិនបានដោះស្រាយ ។ នេះគឺជាបញ្ហាធំ បញ្ហាគ្រាន់តែបញ្ហាកូវីដទេ ក៏ប៉ុន្តែយើងក៏ត្រូវពិនិត្យមើលចំពោះប្រជាជនយើងដែលខ្វះខាតស្បៀង ត្រូវផ្តល់ស្បៀងឲ្យពួកគាត់បានបន្ទាន់ បានឆាប់ កុំឲ្យពួកគាត់ខ្វះស្បៀងអាហារឲ្យសោះ ក្នុងពេលដែលសភាពការណ៍មានការប្រែប្រួលនៅក្រៅប្រទេស និងនៅក្នុងប្រទេស យើងត្រូវគ្រប់គ្រងអ្វីៗដែលមាននៅក្នុងប្រទេសរបស់យើងននឹងចាត់ចែងប្រើប្រាស់ធនធាន ដែលមានរបស់យើងសម្រាប់បម្រើប្រជាជនរបស់យើង" ។

សម្តេចតេជោបានសង្កត់ធ្ងន់ថា "... យើងជាប្រទេសក្រ ក៏ប៉ុន្តែយើងមិនក្រខាងចិត្តគំនិតនោះទេ ។យើងចេះគ្រប់គ្រងប្រជាពលរដ្ឋរបស់យើង មកដល់ម៉ោងនេះ មិនទាន់មានអ្នកណាមួយស្លាប់នោះទេ ។ លទ្ធផលថ្ងៃនេះ (៤ មេសា) គឺល្អប្រសើរណាស់ គ្មានអ្នកឆ្លង ហើយអ្នកដែលជាសះស្បើយរហូតទៅដល់ ១៥នាក់ ក្នុងពេលដែលអ្នកសរសេរកាសែតពីបរទេស ប្រទេសគេស្លាប់មួយថ្ងៃៗ រាប់រយ នឹងឡើងដល់ពាន់ ប៉ុន្តែគេបែរជាមកប្រដៅយើងថា យើងជាប្រទេសដែលមានហានិភ័យធំណាស់ បន្តិចទៀតខ្ញុំនឹងឲ្យហ្វេសប៊ុយករបស់ខ្ញុំបង្ហោះនូវរូបភាពមួយស្តីពីជនជាតិខ្មែរម្នាក់ត្អូញត្អែរនៅឯប្រទេសក្រៅ អំពីសេវាសុខភាពរបស់ប្រទេសក្រៅវាយ៉ាងម៉េច ប្រៀបធៀបទៅ និងសេវាសុខភាពរបស់ប្រជាជនកម្ពុជាដែលយើងក្រ ។ បញ្ហាវាមិនស្ថិតនៅត្រង់ថាសេវារបស់អ្នកឯងពូកែ ឬក៏មិនពូកែទេ វាស្ថិតនៅត្រង់ថា មេដឹកនាំណាពូកែពិតប្រាកដ។ សម្ភារៈទំនើបវាចេះតែទំនើបប៉ុន្តែមនុស្សវាមិនទំនើប វាក៏នៅតែមិនទំនើបចឹងដែរ វានៅតែងាប់ ។ យើងមិនទំនើប ក៏ប៉ុន្តែយើងមានវិធានការជាក់ស្តែងរបស់យើង យើងនៅតែអាចស្រោចស្រង់នឹងដោះស្រាយប្រជាពលរបស់យើងមិនឲ្យធ្លាក់ទៅក្នុងការភ័យខ្លាច ដែលគេតែងតែនិយាយថា លោកហ៊ុន សែន ហាក់ដូចជាខ្វះការយកចិត្តទុកដាក់ ក៏ប៉ុន្តែគេមិនស្គាល់នូវសិល្បៈ នៃការចាត់ចែង នឹងដោះស្រាយបញ្ហាបែបដោះស្រាយនោះទេ"៕ សរន

## សម្តេច ហ៊ុន សែន ចេញបញ្ជាបន្ថែមដោះស្រាយជូនពលករដែលមកពីប្រទេសថៃ

http://kleykley.sabay.com.kh/ 06-04-2020 ម៉ោង 07:08

សម្តេច ហ៊ុន សែន កាលពីថ្ងៃទី៤ ខែមេសា ឆ្នាំ២០២០ បានចេញបញ្ជាណែនាំបន្ថែមក្នុងការដោះស្រាយជូនពលករដែលបានវិលត្រឡប់មកពីប្រទេសថៃកន្លងមកចំនួនប្រមាណ ៥ម៉ឺននាក់ ហើយដែលចំនួននេះនឹងមានមកជាបន្តបន្ទាប់ទៀត ដែលអាចនឹងកើនទៅដល់៦ម៉ឺននាក់។ ក្នុងនាមជាប្រធានគណៈកម្មការជាតិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ សម្តេចតេជោ បានណែនាំទៅក្រសួងសុខាភិបាលថា៖ «ត្រូវតាមដានត្រួតពិនិត្យនៅតាមទល់ដែនអោយបានហ្មត់ចត់ ហើយក្នុងនោះត្រូវត្រៀមរៀបចំបំពាក់សម្ភារៈបរិក្ខារពេទ្យ និងរៀបចំទីកន្លែងពិនិត្យសុខភាពអោយបានល្អដល់ពលករ។ ក្រសួងសុខាភិបាលត្រូវធ្វើជាម្ចាស់ការលើការងារនេះ ហើយសហការជាមួយក្រុមការងារនៅ

តាមព្រំដែនទាំងអស់។ ទន្ទឹមនឹងនេះ គឺត្រូវត្រៀមទិញមុង, ភួយ, កន្ទេល, ខ្នើយ, ក្រមា សម្រាប់ប្រគល់ជូនបងប្អូនកូនក្មួយពលករដែលត្រូវដាក់អោយស្នាក់នៅដាច់ដោយឡែកបណ្តោះអាសន្នចំនួន១៤ថ្ងៃ ដូចជានៅតាមសាលារៀន តាមសហគម ឬនៅតាមលំនៅដ្ឋានជាមួយក្រុមគ្រួសារជាដើម»។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ផងដែរថាៈ «ពេលណាបងប្អូនចាកចេញពីទីនោះ គឺសូមប្រគល់សំម្ភារៈទាំងនោះជូនទៅគាត់យកទៅប្រើប្រាស់តែម្តង។ ចំពោះមធ្យោបាយសម្រាប់ដឹកជញ្ជូនបងប្អូនកូនក្មួយពលករវិញ គឺត្រូវប្រើប្រាស់រថយន្តកងទ័ពមកពីកងពលលេខ៩០ និង កងពលលេខ៩៩ ដែលត្រូវរៀបចំដាក់ដំបូលអោយបានស្រួល។ មកទល់ពេលនេះ បងប្អូនកូនក្មួយពលករទាំងអស់ដែលបានវិលត្រឡប់មកប្រទេសវិញ គឺមិនមានបង្កហានិភ័យណាមួយនៅតាមសហគមនៅឡើយទេ»។ សម្តេច ហ៊ុន សែន បានអបអរសាទរ និងកោតសរសើរដល់ថ្នាក់ភូមិ, ថ្នាក់ឃុំ, ស្រុក និងថ្នាក់ជាតិ ដែលបានចុះជួយនៅតាមមូលដ្ឋាន ក្នុងនោះរួមទាំងការអប់រំឃោសនា ផ្សព្វផ្សាយណែនាំទប់ស្កាត់ជំងឺឆ្លងកូវីដ-១៩ ដែលធ្វើឱ្យកម្ពុជា គ្រប់គ្រងស្ថានការណ៍បានល្អមកទល់ពេលនេះ៕

## រាជរដ្ឋាភិបាលឲ្យក្រសួងត្រៀមសម្ភារៈជូនពលករមកពីថៃ ខណៈចំនួនអាចកើនដល់៦ម៉ឺននាក់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០២០ ម៉ោង ០៩:១៨ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ សម្តេចតេជោ ហ៊ុន សែន បញ្ជាអោយក្រសួងសុខាភិបាលត្រៀមរៀបចំកន្លែងពិនិត្យសុខភាព និងត្រៀមបម្រុងសម្ភារៈគ្រប់គ្រាន់ជូនពលករមកពីប្រទេសថៃ ដែលត្រូវដាក់អោយនៅដាច់ដោយឡែក១៤ថ្ងៃ ។ យោងតាមបណ្តាញសង្គមហ្វេសប៊ុកចេញផ្សាយនៅយប់ថ្ងៃទី៥ មេសា សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បានចេញបញ្ជាណែនាំបន្ថែមក្នុងការដោះស្រាយជូនបងប្អូន កូនក្មួយពលករដែលបានវិលត្រឡប់មកពីប្រទេសថៃកន្លងមកចំនួនប្រមាណ៥ម៉ឺននាក់ ហើយដែលចំនួននេះនឹងមានមកជាបន្តបន្ទាប់ទៀត ដែលអាចនឹងកើនទៅដល់៦ម៉ឺននាក់ ។

ក្នុងនាមជាប្រធានគណៈកម្មការជាតិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីឌ-១៩ សម្តេចតេជោ បានណែនាំក្រសួងសុខាភិបាល «ត្រូវតាមដានត្រួតពិនិត្យនៅតាមទល់ដែនអោយបានហ្មត់ចត់ ហើយក្នុងនោះត្រូវត្រៀមរៀបចំបំពាក់សម្ភារៈបរិក្ខារពេទ្យ និងរៀបចំទីកន្លែងពិនិត្យសុខភាពអោយបានល្អដល់ពលករ ។ ក្រសួងសុខាភិបាលត្រូវធ្វើជាម្ចាស់ការលើការងារនេះ ហើយសហការជាមួយក្រុមការងារនៅតាមព្រំដែនទាំងអស់ ។ ទន្ទឹមនឹងនេះ គឺត្រូវត្រៀមទិញមុង, ភួយ, កន្ទេល, ខ្នើយ, ក្រមា សម្រាប់ប្រគល់ជូនបងប្អូនកូនក្មួយពលករដែលត្រូវដាក់អោយស្នាក់នៅដាច់ដោយឡែកបណ្តោះអាសន្នចំនួន១៤ថ្ងៃ ដូចជា នៅតាមសាលារៀន តាមសហគម ឬនៅតាមលំនៅដ្ឋានជាមួយក្រុមគ្រួសារជាដើម» ។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ផងដែរថា «ពេលណាបងប្អូនចាកចេញពីទីនោះ គឺសូមប្រគល់សំម្ភារៈទាំងនោះជូនទៅគាត់យកទៅប្រើប្រាស់តែម្តង ។ ចំពោះមធ្យោបាយសម្រាប់ដឹកជញ្ជូនបងប្អូនកូនក្មួយពលករវិញ គឺត្រូវប្រើប្រាស់រថយន្តកងទ័ពមកពីកងពលលេខ៩០ និងកងពលលេខ៩៩ ដែលត្រូវរៀបចំដាក់ដំបូលអោយបានស្រួល» ។ មកទល់ពេលនេះ បងប្អូនកូនក្មួយពលករទាំងអស់ដែលបានវិលត្រឡប់មកប្រទេសវិញ គឺមិនមានបង្ករហានិភ័យណាមួយនៅតាមសហគមនៅឡើយទេ ។ សម្តេចតេជោ ហ៊ុន សែន បានអបអរសាទរ និងកោតសរសើរដល់ថ្នាក់ភូមិ, ថ្នាក់ឃុំ, ស្រុក និងថ្នាក់ជាតិ ដែលបានចុះជួយនៅតាមមូលដ្ឋាន ក្នុងនោះរួមទាំងការអប់រំឃោសនាផ្សព្វផ្សាយណែនាំទប់ស្កាត់ជំងឺឆ្លងកូវីឌ-១៩ ដែលធ្វើអោយយើងគ្រប់គ្រងស្ថានការណ៍បានល្អមកទល់ពេលនេះ៕

## អាជ្ញាធរស្រុក ឃុំបានយកចិត្តទុកដាក់ដល់បងប្អូនចំណាកស្រុកដែលកំពុងនៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃនៅស្រុកព្រះស្ដេច

https://gdlf-kh.com/ Kim Sopha ព្រៃវែង 05-04-2020

ព្រៃវែង ៖ អាជ្ញាធរស្រុកព្រះស្ដេច រួមនឹងអាជ្ញាធរឃុំបាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះបងប្អូនប្រជាពលរដ្ឋដែលគាត់ចំណាកស្រុកធ្វើការនៅឯក្រៅប្រទេស ហើយបានវិលត្រឡប់មកស្រុកកំណើតវិញត្រូវបានអាជ្ញាធរដាក់គាត់ឲ្យនៅកន្លែងដាច់ដោយឡែករយៈពេល ១៤ថ្ងៃ ដើម្បីការពារ និងទប់ស្កាត់កុំឱ្យមានការរីករាលដាលនៃជម្ងឺ Covid 19 ដែលកំពុងតែគំរាមកំហែងដល់អាយុជីវិតមនុស្ស ស្ទើរទូទាំងពិភពលោកនេះ។ ចំពោះបងប្អូនដែលកំពុងតែនៅដាច់ដោយឡែករយៈពេល ១៤ ថ្ងៃនេះមានចំនួន ១៣នាក់ ក្នុងនោះស្រី ៦ នាក់ ដែលស្ថិតនៅក្នុង សាលាបឋមសិក្សាបឹងដោល ឃុំបឹងដោល ស្រុកព្រះស្ដេច ខេត្តព្រៃវែង ចំពោះពួកគាត់ ដែលកំពុងតែនៅដាច់ដោយឡែកនេះគឺគាត់ចំណាកស្រុក ដែលទៅធ្វើការនៅឯប្រទេសថៃ ហើយក៏បានវិលត្រឡប់មកស្រុកកំណើតវិញដោយគិតចាប់ពីថ្ងៃដែលគាត់វិលត្រឡប់ រហូតមកដល់ថ្ងៃនេះគឺបានជាង ៧ ថ្ងៃមកហើយ នៅក្នុងចំណោម បងប្អូនពលករចំណាកស្រុកដែលកំពុងដាច់ថ្លៃចំនួន ១៣នាក់នេះផងដែរក៏មានជនជាតិជប៉ុនម្នាក់ស្រី ដែលកំពុងតែនៅដាច់ដែរឡែក។

លោកស្រី ថុង គន្ធា ជំទុបឃុំទី១ នៃឃុំបឹងដោល ស្រុកព្រះស្ដេច បានលើកឡើងដែរថា ចំពោះបងប្អូនចំណាកស្រុក ទាំង ១៣ នាក់នេះ គឺអាជ្ញាធរឃុំ ស្រុក បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការមើលថែទាំនិងតាមដាននូវសុខភាពរបស់ពួកគាត់ ដែលកំពុងតែនៅដាច់ដោយឡែកអស់រយៈពេល ១៤ ថ្ងៃនេះ។ នៅក្នុងដែរ លោកស្រីក៏បានលើកឡើងបន្តទៀតថាចំពោះសុខភាពរបស់ពួកគាត់គឺពុំមានអ្វីប្រែប្រួលគួរឲ្យកត់សម្គាល់នោះទេ ក៏ប៉ុន្តែយើងនៅតែតាមដានសុខភាពរបស់គាត់ ឱ្យគ្រប់ចំនួន ១៤ ថ្ងៃសិនទើបអនុញ្ញាតឲ្យគាត់ត្រឡប់ទៅផ្ទះវិញ។

សូមបញ្ជាក់ផងដែរថានៅក្នុងស្រុកព្រះស្ដេច អាជ្ញាធរស្រុកបានរៀបចំកន្លែងសម្រាប់ដាក់ដាច់ដោយឡែកមានចំនួន ១២ កន្លែងសរុបមានចំនួន ៤៨ បន្ទប់ ហើយក្នុងនោះដែរក្នុងមួយបន្ទប់យើងអាចគេងបាន ៤ នាក់៕

## អាជ្ញាធរស្រុកនាំយកអំណោយរបស់លោកជំទាវ លីប លឿង អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជូនបងប្អូនពលករដែលត្រឡប់មកពីប្រទេសថៃ

https://gdlf-kh.com/ Sam Sophearum កំពង់ឆ្នាំង 2020/04/05

ខេត្តកំពង់ឆ្នាំង ៖ រសៀលថ្ងៃទី៥ ខែមេសា ឆ្នាំ២០២០ លោក ឃឹម ផល្លា ក្រុមការងារស្រុក និងអាជ្ញាធរមូលដ្ឋានបាននាំយកអំណោយរបស់លោកជំទាវ លីប លឿង អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជូនបងប្អូនពលករដែលត្រឡប់មកពីប្រទេសថៃ ដែលកំពុងស្នាក់នៅដាច់ដោយឡែកនៅសាលាបុណ្យភូមិថ្មី ឃុំតាំងក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ ក្នុងឱកាសនោះក្រុមការងារបានពាំនាំការផ្តាំផ្ញើរបស់លោកជំទាវ សាកសួរសុខទុក្ខ និងណែនាំការក្សាសុខភាព អនាម័យដល់បងប្អូនទាំងអស់ដែលស្នាក់នៅទីនោះ អំណោយរួមមាន៖ មីចំនួន៥កេស ត្រី២០ឡូ និងទឹកសុទ្ធ១០យួរ ៕

## ពលករចំណាកស្រុក៣នាក់ ត្រូវបានដាក់ឲ្យនៅធម្មតាវិញ, ៧នាក់ ដាក់ឲ្យនៅដាច់ដោយឡែក

---

http://kampucheathmey.com/ 6/4/2020 7:06 Am

ព្រះសីហនុ ៖ ពលករចំណាកស្រុក និងចំណូលថ្មីចំនួន១០នាក់ ត្រូវបានអភិបាលរងខេត្តសៀមរាប តំណាងលោក គួច ចំរើន ចុះសួរសុខទុក្ខ ក្នុងនោះ ពលករ៣នាក់ ត្រូវបានដាក់ឲ្យនៅធម្មតាវិញ, ១នាក់ ស្ថិតក្នុង

ការតាមដានរយៈពេល១៤ថ្ងៃ និងប្រជាពលរដ្ឋចំណូលថ្មីមួយគ្រួសារចំនួន៦នាក់ ត្រូវបានណែនាំឲ្យនៅដាច់ដោយឡែក។ នេះបើតាមការបញ្ជាក់របស់រដ្ឋបាលខេត្តព្រះសីហនុ កាលពីល្ងាចថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២០។

រដ្ឋបាលខេត្តឆ្នេរសមុទ្រដ៏មានសក្តានុពលទេសចរមួយនេះ បានបញ្ជាក់ដូច្នេះថា ៖ «រសៀលថ្ងៃអាទិត្យ ១៣កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២០ លោក គង់ វិតាណៈ អភិបាលរងខេត្ត តំណាងឯកឧត្តម គួច ចំរើន អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ បានអញ្ជើញចុះសួរសុខទុក្ខប្រជាពលរដ្ឋចំណាកស្រុក និងចំណូលថ្មី ចំនួន១០នាក់ ដែលក្នុងនោះគ្រួសារចំណូលថ្មីដែលបានដាក់ឲ្យនៅដាច់ដោយឡែករយៈពេល១៤ថ្ងៃ ចំនួន៣នាក់ ស្រី២ ត្រូវបានដាក់ឲ្យនៅធម្មតាវិញ និងផ្តល់ជូននូវអង្ករ១បាវ ស្មើនឹង៥០គីឡូ ត្រីខ៣យួរ ទឹកសុទ្ធ៣យួរ ថវិកាក្នុងម្នាក់ៗ៥០.០០០រៀល រីឯប្រជាពលរដ្ឋចំណាកស្រុក១នាក់ ស្ថិតក្នុងការតាមដានរយៈពេល១៤ថ្ងៃ ត្រូវបានផ្តល់ជូននូវអង្ករចំនួន២៥គីឡូ ទឹកសុទ្ធ២យួរ ត្រីខ២យួរ និងថវិកា៥០.០០០រៀល»។

រដ្ឋបាលខេត្តព្រះសីហនុ បានបញ្ជាក់ទៀតថា ៖ «ដោយឡែកប្រជាពលរដ្ឋចំណូលថ្មីមួយគ្រួសារចំនួន៦នាក់ ស្រី៤នាក់ ដែលទើបមកដល់មូលដ្ឋានកាលពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ត្រូវបានអាជ្ញាធរមូលដ្ឋាន និងចត្តាឡីស័ក បានចុះធ្វើការណែនាំឲ្យរស់នៅដាច់ដោយឡែករយៈពេល១៤ថ្ងៃ និងបានផ្តល់ជូននូវអង្ករ១បាវ ស្មើនិង៥០គីឡូ ទឹកសុទ្ធ២យួរ ត្រីខ៣យួរ និងថវិកា២០០.០០០រៀលផងដែរ»៕

## មតិពលរដ្ឋរឿងផលប៉ះពាល់សេដ្ឋកិច្ចបន្ទាប់ពីកូនអត់ការធ្វើនៅប្រទេសថៃ ដោយសារជំងឺកូវីដ-១៩

https://www.rfa.org/khmer/ ដោយ ម៉ៅ សុជានី 2020-04-04

គ្រួសាររបស់ពលករខ្មែរធ្វើការនៅប្រទេសថៃមួយចំនួនចាប់ផ្តើមត្អូញត្អែរអំពីជីវភាពខ្វះខាត បន្ទាប់ពីកូននិងប្តីនៅក្រៅប្រទេសអត់ការងារធ្វើជាច្រើនថ្ងៃ ហើយគ្មានប្រាក់ផ្ញើទៅផ្ទះដោយសារជំងឺកូវីដ-១៩។ តើសាច់ញាតិរបស់ពលករខ្មែរទាំងនោះជួបការលំបាកយ៉ាងណាបន្ទាប់ពីកូន និងប្តីបាត់បង់ការងារនៅប្រទេសថៃមួយរយៈមកនេះ។

ប្រជាពលរដ្ឋដែលមានកូន និងប្តីធ្វើការងារនៅប្រទេសថៃលើកឡើងស្រដៀងគ្នាថា ពួកគាត់ព្រួយបារម្ភខ្លាចគ្មានអង្ករច្រកឆ្នាំងនៅពេលខាងមុខ ព្រោះសព្វថ្ងៃគ្មានប្រាក់ចំណូលដោះស្រាយជីវភាពគ្រួសារនោះទេ។ប្រជាពលរដ្ឋម្នាក់នៅរស់នៅខេត្តសៀមរាបលោកស្រី រើង សឿន ថ្លែងនៅថ្ងៃទី៤ មេសា ថាកូនរបស់លោកស្រីចំនួន៣នាក់បានត្រឡប់មកដល់ស្រុកកំណើតវិញប្រមាណ ៣សប្តាហ៍ហើយ ដោយសារថៅកែរបស់ពួកគេផ្អាកការងារមួយរយៈព្រោះខ្លាចឆ្លងជំងឺរលាកផ្លូវដង្ហើមថ្មីកូវីដ១៩។ លោកស្រីបន្ថែមថា សព្វថ្ងៃចាប់ផ្តើមគ្មានប្រាក់ចំណូលបង់ធនាគារ និងប្រាក់ចាយវាយក្នុងគ្រួសារហើយ ដោយសារនៅផ្ទះគ្មានមុខរបររកប្រាក់ចំណូលពីព្រោះកន្លងទៅ ពឹងផ្អែកទាំងស្រុងទៅលើប្រាក់ចំណូលរបស់កូនធ្វើការនៅប្រទេសថៃ៖ «កាន់តែយ៉ាប់ហើយខ្ញុំកាលកូននៅថៃ មានហូបចុកបានគ្រប់គ្រាន់ ដល់ពេលឥឡូវនេះសូម្បីតែប្រាក់ទិញម្សៅស៊ុប ក៏គ្មានដែរ។ បើរកការងារមិនបានធ្វើមិនដឹងថា គិតធ្វើយ៉ាងម៉េចទេ គិតភ័យខ្លាចអត់មានលុយបង់ធនាគារ ប្រសិនជាធនាគារគេពន្យារបានខ្លះមកល្អ ដល់យើងអត់ការងារធ្វើរកប្រាក់ណាបង់ធនាគារបាន»។

ស្រដៀងគ្នានេះដែរប្រជាពលរដ្ឋនៅខេត្តបន្ទាយមានជ័យលោកស្រី សូត្រ មុំ រៀបរាប់ថា កូនរបស់លោកស្រី២នាក់ ធ្វើការនៅហាងលក់បាយម្ហូបនៅខេត្តជាប់ទីក្រុងបាងកកប្រទេសថៃ ត្រូវបានថៅកែផ្អាកការងារជាងកន្លះខែហើយ ដោយសារខ្លាចឆ្លងជំងឺកូវីដ-១៩។ លោកស្រីបញ្ជាក់ថា ចាប់តាំងពីកូនអត់ការងារធ្វើមកបានប៉ះពាល់យ៉ាងខ្លាំងដល់គ្រួសារនៅស្រុកកំណើត ជាពិសេសគ្មានប្រាក់ទិញអង្កច្រកឆ្នាំង ហើយថាលោកស្រីមានជំងឺប្រចាំកាយដូច្នេះមិនអាចធ្វើការងារធ្ងន់បានឡើយ៖ «ខ្ញុំពិបាកណាស់ដល់ពេលនិយាយដល់កន្លែងហ្នឹង ខ្ញុំចង់តែយំទេ ដោយសារខ្ញុំអត់ពេក និយាយទៅវាលំបាកក្នុងរស់នៅបណ្តោយ។ ម្យ៉ាងទៀតខ្ញុំភ័យលើសុវត្ថិភាពកូននៅក្រៅប្រទេសខ្ញុំ

ទូរស័ព្ទសួរកូនថា ថៅកែអត់ទានឱ្យចេញទៅណាទេឱ្យនៅថៃសិន ក្រែងជំងឺបានធូរស្រាលវិញគាត់នឹងអាចបានការងារធ្វើវិញប៉ុន្តែបើសិនជំងឺមិនបានធូរស្រាលទេតើឱ្យខ្ញុំសង្ឃឹមអ្វីហើយកូនរបស់ខ្ញុំក៏ប្រឈមនឹងដាច់បាយដែរ»។

ចំណែកឯពលរដ្ឋនៅខេត្តកំពង់ធំគឺលោកស្រី ថាល សីន វិញ បានឱ្យដឹងដែរថា ប្ដីរបស់លោកស្រីធ្វើការនៅលើទូកនេសាទថៃ គឺត្រូវបានថៅកែថៃផ្អាកការងារជិត១០ថ្ងៃហើយដែរ ដើម្បីការពារកុំឱ្យឆ្លងជំងឺកូវីដ-១៩។ លោកស្រីបន្តថា ក្នុងខែនេះប្ដីរបស់ខ្លួនមិនបានផ្ញើប្រាក់មកឱ្យគ្រួសារនៅផ្ទះនោះទេ ព្រោះដើម្បីសន្សំប្រាក់ទុកចាយវាយនៅក្រៅប្រទេសអំឡុងពេលអត់ការងារធ្វើ៖ «ខ្ញុំដេកចាំតែលុយប្ដីផ្ញើមក បើប្ដីអត់ការងារមិនដឹងគិតយ៉ាងណាទេ។ ណាមួយគាត់ថា នៅប្រទេសថៃក៏អត់មានការងារធ្វើហើយដេកស៊ីដែរ បើដេកស៊ីទាំងសង្វាងអីចឹងមិនដឹងទៅថ្ងៃមុខទៅ គ្រួសារខ្ញុំមិនដឹងទៅយ៉ាងម៉េច បើប្ដីក៏រកមិនបានហើយខ្ញុំនៅផ្ទះមើលកូនតូចគ្មានការងារអីធ្វើអីចឹង»។

កាលពីថ្ងៃទី៩ មីនា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានណែនាំឱ្យធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុពិចារណាបន្ធូរបន្ថយលក្ខខណ្ឌនៃការសងត្រឡប់ទៅស្ថាប័នទាំងនោះវិញ ចំពោះកម្មករ ដែលជួបបញ្ហាដូចជារោងចក្របិទបណ្ដោះអាសន្ន ឬព្យួរការងារជាដើម។

ប្រធានផ្នែកពលករចំណាកស្រុកនៃអង្គការសិទ្ធិការងារសង់ត្រាល់ លោក ឌី ថេហូយ៉ា (Central) មានប្រសាសន៍ថា ពលករខ្មែរធ្វើការនៅប្រទេសថៃមួយចំនួនធំ អាចនឹងនាំគ្នាត្រឡប់ទៅកម្ពុជាវិញ នៅពេលខាងមុខប្រសិនបើជំងឺកូវីដ១៩បន្តអូសបន្លាយពេលយូរទៅមុខទៀត ដោយសារនៅប្រទេសថៃអត់ការងារធ្វើហើយគ្មានប្រាក់បង់ចាយវាយប្រចាំថ្ងៃ និងប្រាក់បង់ថ្លៃបន្ទប់ជួល។

របាយការណ៍របស់ក្រសួងការងារបង្ហាញថា ពលករខ្មែរកំពុងធ្វើការប្រទេសថៃមានជាង ១ លាន ១ សែននាក់(១.១០០.០០០)។ ប៉ុន្តែរបាយការណ៍របស់អង្គការសង់ត្រាល់ឱ្យដឹងថា មានពលករខ្មែរស្របច្បាប់និងខុសច្បាប់ប្រមាណ ២លាននាក់(២.០០០.០០០)កំពុងធ្វើនៅប្រទេសថៃ៕

## សហគមន៍ជនសហជីពបារម្ភពីផលប៉ះពាល់សេដ្ឋកិច្ចលើពលករនិងកម្មកររោងចក្រដោយកូវីដ១៩

https://khmer.voanews.com/ 04 មេសា 2020 ម៉ែន គឹមសេង

វ៉ាស៊ីនតោន៖ ពលករចំណាកស្រុកជាច្រើនម៉ឺននាក់ដែលបានវិលត្រឡប់ចូលក្នុងប្រទេសកម្ពុជា និងអ្នកដែលកំពុងរស់នៅក្នុងប្រទេសថៃ នឹងប្រឈមការលំបាកផ្នែកសេដ្ឋកិច្ចដែលបង្កឡើងដោយវីរុសកូរ៉ូណាប្រសិនបើស្ថានភាពមិន បានល្អប្រសើរក្នុងរយៈពេលដ៏ខ្លីខាងមុខនេះទេ។ នេះបើតាមការលើកឡើងរបស់អ្នកជំនាញពលករចំណាកស្រុក។មានពលករកម្ពុជាដែលធ្វើការនៅប្រទេសថៃជាង ៥០.០០០នាក់ បានវិលត្រឡប់មកប្រទេសវិញក្នុងរយៈពេលប៉ុន្មានសប្ដាហ៍ចុងក្រោយនេះ ស្របពេលដែលប្រទេសថៃរងផលប៉ះពាល់ដោយទណ្ឌកម្មសេដ្ឋកិច្ចមួយផ្នែកតូចពីសហរដ្ឋអាមេរិក និងការរាតត្បាតពីជំងឺកូវីដ១៩ ដែលបង្កឡើងដោយវីរុសកូរ៉ូណាថ្មី។ ដំណើរមាតុភូមិនិវត្តន៍យ៉ាងតក់ក្រហល់នេះ បណ្ដាលឱ្យពួកគេប្រឈមនឹងការបាត់បង់ការងារ និងហានិភ័យសុខភាពផងដែរ។

លោក មឿន តុលា នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស (ហៅកាត់ថាសង់ត្រាល់) បានបញ្ជាក់ប្រាប់វីអូអេថា ថៅកែរោងចក្រមួយចំនួនបានព្រមានពលករដែលចង់ធ្វើដំណើរមកប្រទេសកំណើតវិញថា រោងចក្រនឹងមិនធានាផ្ដល់ការងារដល់ពួកគេធ្វើទេ នៅពេលវិលត្រឡប់ទៅវិញ ហើយបើទោះបីទទួលយកធ្វើការវិញ ក៏ពួកគេត្រូវនៅដាច់ដោយឡែកពីគេចំនួន១៤ថ្ងៃដែរ ដោយសារតែព្រួយបារម្ភពីការឆ្លងជំងឺកូវីដ១៩ ក្នុងពេលធ្វើដំណើរនិងស្នាក់នៅប្រទេសកំណើត។ ពួកគេក៏ប្រឈមនឹងការបាត់បង់អត្ថប្រយោជន៍ផ្សេងៗ រួមទាំងអតីតភាពការងារផងដែរ។ សម្រាប់ពលករស្របច្បាប់ដែលសម្រេចចិត្តបន្តស្នាក់នៅថៃ គឺអ្នកខ្លះអាចទទួលបានផលប្រយោជន៍ខ្លះពីថៅកែ ដោយនៅបន្តទទួលបានប្រាក់ឧបត្ថម្ភពាក់កណ្ដាល បើសិនជារោងចក្រផ្អាកដំណើរការ។

ប៉ុន្តែផលប៉ះពាល់នឹងមានខ្លាំងលើពលករ ដែលមិនមានច្បាប់ត្រឹមត្រូវ ដែលធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះផ្នែកសេដ្ឋកិច្ចខ្លាំងជាងគេ។ នេះបើតាមការបញ្ជាក់របស់លោក មឿន តុលា។

លោក មឿន តុលា បានបន្ថែមថា៖ «ក៏ប៉ុន្តែដោយឡែកពលករដែលអត់មានឯកសារ គឺពលករដែលខុសច្បាប់ហ្នឹងគាត់អត់មានបណ្ណធានារ៉ាប់រងសង្គមគឺគាត់អត់ទទួលបានអត្ថប្រយោជន៍ហ្នឹងទេ។ អីចឹងអ្វីដែលរដ្ឋត្រូវពិចារណាហ្នឹងគឺជីវភាពរបស់ពួកគាត់ហ្នឹង ព្រោះពួកគាត់ពេលហ្នឹងអត់មានចំណូលហើយត្រូវចំណាយច្រើនរួមទាំងចំណាយលើផ្ទះជួលនិងលើម្ហូបអាហារជាដើម»។ ក្រុមសកម្មជនសិទ្ធិពលករបានវាយតម្លៃថា មានពលករខ្មែរចំនួន ២លាននាក់ ដែលធ្វើការនៅប្រទេសថៃទាំងស្របច្បាប់និងមិនស្របច្បាប់ ហើយពួកគេនឹងងាយរងគ្រោះខ្លាំង ក្នុងគ្រាមានវិបត្តិសុខភាពសាកលដែលកំពុងតែរាតត្បាតនៅប្រទេសថៃ។ លោក មឿន តុលា បានសង្កត់ធ្ងន់លើផលប៉ះពាល់សេដ្ឋកិច្ចរបស់ពលករទាំងនោះ ដែលរដ្ឋាភិបាលកម្ពុជាគួរតែជួយគិតគូរដោះស្រាយ។ «ខ្ញុំជឿថាអាចនឹងមានផលប៉ះពាល់លើចំណូល ជាពិសេសនោះ គឺយើងដឹងហើយថា ពលករដែលទៅធ្វើការនៅក្រៅនោះសុទ្ធតែស្ពាយបំណុលជាប់បំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ។ល។និង។ល។» ប្រទេសថៃបានបិទច្រកប៉ោយប៉ែតតាំងពីថ្ងៃទី២៣ ខែមីនា រហូតដល់ថ្ងៃទី៥ ខែមេសា ដើម្បីទប់ស្កាត់ការឆ្លងវីរុសកូរ៉ូណា។ ប៉ុន្តែលទ្ធភាពនៃការបើកឡើងវិញពិតប្រាកដនៅមិនទាន់ជាក់លាក់នៅឡើយទេ ដោយសារតែប្រទេសថៃបានឆ្លងវីរុសដ៏ប្រល័យនេះកាន់តែច្រើន។ រហូតមកដល់ថ្ងៃព្រហស្បតិ៍ ប្រទេសថៃមានអ្នកឆ្លងរហូតដល់ជិត១.៩០០ករណី។

គណបក្សប្រឆាំងក៏បានរិះគន់រដ្ឋាភិបាលកម្ពុជាចំពោះការយឺតយ៉ាវ ក្នុងការចាត់វិធានការជាមុនជាមួយនឹងរដ្ឋាភិបាលថៃ ដើម្បីបញ្ចៀសការធ្វើមាតុភូមិនិវត្តន៍យ៉ាងតក់ក្រហល់ និងការបរាជ័យក្នុងការចាត់វិធានការសុខាភិបាល ដើម្បីពិនិត្យសុខភាពពលករទាំងនោះ នៅពេលដែលពួកគេឆ្លងចូលក្នុងប្រទេសវិញដើម្បីបង្ការការឆ្លងទៅក្នុងស្រុក ឬរងការរើសអើងខ្លាចអារពីពលរដ្ឋនៅក្នុងប្រទេស។ អ្នកស្រី មូរ សុខហួរ អនុប្រធានគណបក្សសង្គ្រោះជាតិ បានបញ្ជាក់ប្រាប់វីអូអេថា៖ «បើសិនជាយកសិទ្ធិពលករចំណាកស្រុកជាធំរឿងនេះ ក្រសួងការងារនិងក្រសួងការបរទេសត្រូវគិតទុកមុនថា ច្បាស់ហើយថា បើប្រទេសថៃមិនបញ្ជូនមក ក៏យើងត្រូវនិយាយជាមួយរាជរដ្ឋាភិបាលថៃ ឱ្យគេរក្សាការពារ ជាពិសេសសុខភាពពលករចំណាកស្រុករបស់យើងនៅប្រទេសថៃ ឱ្យទទួលយកពលករយើង ដូចជាប្រទេសថៃដែរ។ នេះបើបានជជែកគ្នារាប់ខែមុន»។ ពលករកម្ពុជាដែលបានវិលត្រឡប់មកប្រទេសវិញមិនត្រូវបានពិនិត្យសុខភាពរកវីរុសកូរ៉ូណាទេ ហើយរដ្ឋាភិបាលកម្ពុជា ក៏មិនបានដាក់ឱ្យពលករទាំងនោះនៅដាច់ពីគេដែរ ដោយគ្រាន់តែលើកទឹកចិត្តពួកគេឱ្យនៅដាច់ដោយឡែកពីគេមួយរយៈពេលខ្លីតែប៉ុណ្ណោះ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងនៅក្នុងសន្និសីទសារព័ត៌មានកាលពីដើមសប្តាហ៍នេះការពារចំណាត់ការរបស់រដ្ឋាភិបាលលោកថា៖ «យើងមិនអាចប្រមូលផ្តុំបងប្អូនទាំង ៥ម៉ឺននាក់នេះទៅទុកនៅកន្លែងដាក់ដោយឡែកអស់បានទេ ប៉ុន្តែយើងត្រូវពិនិត្យគ្រប់គ្រងគោលដៅទាំងអស់ ភូមិទាំងអស់ដែលមានបងប្អូនមកពីប្រទេសថៃឬមកពីប្រទេសក្រៅ»។

ប្រទេសកម្ពុជាមានអ្នកឆ្លងវីរុសកូរ៉ូណាជាង ១០០នាក់ ដែលកើតឡើងភាគច្រើនលើជនបរទេស។ ប៉ុន្តែគ្រប់ករណីទាំងអស់ពាក់ព័ន្ធនឹងការធ្វើដំណើរមកពីក្រៅប្រទេស ដោយមិនទាន់មានការឆ្លងនៅកម្រិតសហគមន៍នៅឡើយទេ។ នេះបើតាមការអះអាងរបស់ក្រសួងសុខាភិបាល។ មានមេដឹកនាំពិភពលោកជាច្រើននាក់បានប្រកាសដាក់ប្រទេសក្នុងគ្រាមានអាសន្ន ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩។ ដោយឡែក កម្ពុជាមិនទាន់ប្រកាសស្ថានភាពនេះនៅឡើយទេ។ ប៉ុន្តែវិបត្តិសុខភាពពិភពលោកនេះបានផ្តល់អំណាចបន្ថែមទៀតដល់រដ្ឋាភិបាលរបស់លោកនាយករដ្ឋមន្ត្រីហ៊ុន សែន។ គណៈរដ្ឋមន្ត្រីបានអនុម័តសេចក្តីព្រាងច្បាប់ស្តីពី «ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន» កាលពីថ្ងៃអង្គារ។ មន្ត្រីនានាអះអាងថា វាជាស្ថានការណ៍មួយដែលជៀសមិនរួច បើសិនជាត្រូវទប់ស្កាត់ការឆ្លងរាលដាល។

គណបក្សសង្គ្រោះជាតិបានរិះគន់ចំណាត់ការយឺតយ៉ាវ និងបានអំពាវនាវឱ្យប្រកាសអាសន្នលើបញ្ហាសុខភាព ដោយហាមការជួបជុំមនុស្សជាច្រើនរយនាក់បិទរោងចក្រកាត់ដេរ និងផ្សារជាដើម ក៏ប៉ុន្តែក៏បានសម្តែងការព្រួយបារម្ភពីការប្រើប្រាស់ជ្រុលរហូតដល់មានការបិទការបញ្ចេញមតិរបស់ពលរដ្ឋ។ នៅមុនសេចក្តីព្រាងច្បាប់នេះត្រូវបានគណៈរដ្ឋមន្ត្រីអនុម័តគឺលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានព្រមានចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្សកម្ពុជាដ៏ល្បីល្បាញម្នាក់ គឺលោក អ៊ុំ សំអាត អនុប្រធានអង្គការសិទ្ធិមនុស្សលីកាដូ ដោយសារតែបានចោទប្រកាន់ថាលោកបានការពារអ្នកលក់ដូរតាមអនឡាញដែលលក់ផលិតផលមិនត្រឹមត្រូវ ហើយបំប្លែងថាជាការបញ្ចេញមតិតាមបណ្តាញសង្គម។

បើទោះបីជាបានដាក់ចេញវិធានការតឹងរ៉ឹងមួយចំនួន ក្នុងនោះមានការរៀបចំច្បាប់ដាក់ប្រទេសក្នុងគ្រាមានអាសន្នប៉ុន្តែលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅតែបដិសេធមិនបិទរោងចក្រនៅឡើយទេ។ ការណ៍នេះដោយសារតែលោកមើលឃើញថា ស្ថានភាពវិបត្តិសុខភាពពិភពលោកនឹងជៀសមិនរួចពីមានផលប៉ះពាល់ដល់វិស័យកាត់ដេរទេ។ លោក ហ៊ុន សែន បានបញ្ជាក់ថា រហូតមកដល់ពេលនេះមានរោងចក្រចំនួន៥០នៅកម្ពុជាបានបិទដោយសារតែខ្វះវត្ថុធាតុដើម និង៧ទៀតបានបិទដោយសារតែខ្វះអ្នកបញ្ជាទិញ។ លោក ហ៊ុន សែន បានបន្ថែមថា៖ «អីចឹងមានហានិភ័យនៃបញ្ហាឧស្សាហកម្មវាយនភណ្ឌ។មិនថាកម្ពុជាមិនថាវៀតណាម មិនថាថៃបង់ក្លាដែស ឥណ្ឌា ភូមាឡាវទេ វាស៊ីសងលើប្រាក់ចំណូលនៅអាមេរិកប្រាក់ចំណូលនៅ អឺរ៉ុប វាធ្លាក់ចុះ។ វាមិនខុសពីវិបត្តិសេដ្ឋកិច្ចឆ្នាំ ២០០៨ទេ។ ពេលនោះយើងក៏បិទរោងចក្ររាប់សិបរោងចក្រដែរ»។

វិស័យឧស្សាហកម្មកាត់ដេរកម្ពុជាផ្តល់ការងារដល់ពលរដ្ឋកម្ពុជាជាង ៧៥០.០០០នាក់។ ភាគច្រើនគឺជាស្ត្រីវ័យក្មេងដែលមកពីជនបទ។ សមាគមកាត់ដេរកម្ពុជាបានអំពាវនាវ កាលពីថ្ងៃព្រហស្បតិ៍ដល់ក្រុមហ៊ុនបញ្ជាទិញ ឱ្យគោរពតាមកិច្ចសន្យាទទួលយកទំនិញដែលផលិតហើយនិងទូទាត់ថវិកា ដើម្បីជួយដល់កម្មករទាំងនោះ។ ក្រុមហ៊ុនធំៗដែលលក់សម្លៀកបំពាក់ នៅសហរដ្ឋអាមេរិក បានផ្អាកការងារបុគ្គលិកជាង ៦០០.០០០នាក់ដោយសារតែវីរុសកូរ៉ូណា។ អ្នកសេដ្ឋកិច្ចព្យាករណ៍ថា ពលរដ្ឋចំនួនរហូតដល់ ៤០លាននាក់ អាចនឹងបាត់បង់ការងារ។

ប្រទេសថៃនិងកម្ពុជានឹងធ្វើបុណ្យចូលឆ្នាំថ្មី នៅពាក់កណ្តាលខែមេសា ដែលជាការព្រួយបារម្ភថានឹងធ្វើឱ្យកម្រិតនៃការឆ្លងរាលដាលនៃជំងឺកូវីដ១៩ កាន់តែខ្លាំង ដោយសារតែពលរដ្ឋដែលទៅធ្វើការនៅតាមទីក្រុងនានាត្រូវវិលត្រឡប់ទៅផ្ទះវិញ ដែលនឹងជំរុញឱ្យមានការឆ្លងកម្រិតសហគមន៍កាន់តែច្រើន ដោយសារបទពិសោធន៍នេះបានកើតមានឡើងនៅក្នុងប្រទេសចិន។

សកម្មជនសហជីពបន្តអំពាវនាវឱ្យយកចិត្តទុកដាក់លើសុខភាពរបស់កម្មករកម្មការិនីរោងចក្រ និងគិតគូរដល់ស្ថានភាពសេដ្ឋកិច្ច ដែលនឹងប៉ះពាល់លើពួកគេ នៅពេលដែលមានការបិទរោងចក្រ។ លោក អាត់ ធន ប្រធានសហព័ន្ធការងារកម្ពុជាបានបន្ថែមថា៖ «ខ្ញុំគិតថាប្រសិនបើគាត់បាត់បង់ប្រាក់ចំណូលគាត់អាចនឹងមានបញ្ហាប្រឈមនឹងបញ្ហាប្រចាំថ្ងៃនិងការបង់ទៅលើការស្នាក់នៅ ឬក៏ការរៀនសូត្ររបស់កូនចៅឬក៏អាចឈានទៅដល់ការបង់ទៅធនាគារដែលគេមានការខ្ចីប្រាក់ពីធនាគារច្រើន»។

លោក សុខ ឈុនអៀង អនុប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ បានបញ្ជាក់ថាផលប៉ះពាល់បានកើតមានឡើងលើអ្នកប្រកបអាជីវកម្មតូចតាចជាច្រើន និងអំពាវនាវឱ្យមានអន្តរាគមន៍ពីរដ្ឋាភិបាលទៅផ្នែកធនាគារនិងស្ថាប័នមីក្រូហិរញ្ញវត្ថុ ដើម្បីពន្យារពេលសងបំណុល។

ការអំពាវនាវរបស់ពួកគេត្រូវបានគណបក្សសង្គ្រោះជាតិយល់ស្រប។ អ្នកស្រី មូរ សុខហួរ នៃគណបក្សសង្គ្រោះជាតិបានបន្ថែមថា រដ្ឋត្រូវតែបញ្ចេញថវិកាជួយ បើសិនជាប្រកាសដាក់ប្រទេសក្នុងគ្រាមានអាសន្ន។ «បើសិនជាប្រកាសអាសន្នហើយគឺថវិកាត្រូវតែយកមកផ្ទុក។ ដំបូងបំផុតត្រូវតែធានាពលរដ្ឋយើងឱ្យមានថវិកាចំណូលប្រចាំថ្ងៃ។ បំណាច់បិទរោងចក្រហើយតើឱ្យកម្មករយើងរស់នៅ ដោយរបៀបណារួមទាំងក្មួយៗពលករដែលបាន

អញ្ជើញមកផ្ទះសម្បែងហើយ តើគាត់រស់ដល់ពេលណាពីព្រោះគាត់សង្ឃឹមថាវិលត្រឡប់ទៅ ប្រទេសថៃវិញតើឱ្យគាត់រស់ដោយរបៀបណា?»។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា រដ្ឋាភិបាលកម្ពុជាគ្រោងនឹងជួយស្តារសហគ្រាសខ្នាតតូច និងធនាគារ ដោយត្រៀមថវិកាចំនួនរហូតដល់ចំនួន ៦០០លានដុល្លារ សម្រាប់វិស័យធនាគារដើម្បីជួយសម្រួលដល់អ្នកខ្ចីប្រាក់ និងបន្ថយការប្រាក់។ ប៉ុន្តែលោកមិនទាន់បង្ហាញផែនការណា ដើម្បីជួយអន្តរាគមន៍ដោយផ្ទាល់លើជីវភាពកម្មកររោងចក្រទាំងអស់ និងពលករនៅឡើយទេ៕

### ពលរដ្ឋខ្មែរ ចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន មានចំនួន ៥១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI

នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២០ ច្រកទ្វារព្រំដែនអន្តរជាតិព្រំ នៅបន្តបិទ មិនអនុញ្ញាតឲ្យអ្នកដំណើរ មធ្យោបាយ និងទំនិញចូល-ចេញ ឆ្លងកាត់ច្រកទ្វារនេះបាន។ ដោយឡែកមានពលរដ្ឋខ្មែរ ចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន មានចំនួន ៥១នាក់ ស្រី ២០នាក់ ក្មេងចំនួន ០៨នាក់ បន្ទាប់មកក្រុមចត្តាឡីស័ក វាស់កំដៅ ពុំមានសញ្ញាអ្វីគួរឲ្យកត់សំគាល់ ព្រមទាំងបានធ្វើការអប់រំ ណែនាំដល់ពួកគាត់ ពីវិធីបង្ការ ទប់ស្កាត់ក្នុងការចម្លងមេរោគកូវីដ១៩ រួចក៏ឲ្យប្រជាពលរដ្ឋទាំងនោះ វិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន៕

### ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៦៥នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration-GDI April 4 at 5:12 PM

នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៤និង៣០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៦៥នាក់ ស្រី ៩៧នាក់៕

### នគរបាលច្រកទ្វារពរំដែនអន្តរជាតិជាំ នាថ្ងៃទី០៤ខែមេសា ឆ្នាំ២០២០ បានទទួលពលរដ្ឋខ្មែរ ចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial/ General Department of Immigration-GDI April 4 at 5:00 PM

ប៉ុស្តិ៍នគរបាលច្រកទ្វារពរំដែនអន្តរជាតិជាំ នាថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២០ បានទទួលពលរដ្ឋខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទឆ្លងដែនខុសច្បាប់ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

### ពលរដ្ឋខ្មែរ ចូលប្រទេសតាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ មានចំនួន ២០នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration-GDI April 4 at4:22 PM

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រំ នាថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២០ បានបន្តបិទ មិនអនុញ្ញាតឲ្យអ្នកដំណើរ មធ្យោបាយ និងទំនិញ ចូល-ចេញ ឆ្លងកាត់ច្រកនេះបាន។ ដោយឡែកមានពលរដ្ឋខ្មែរ ចូលប្រទេស

តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ មានចំនួន ២០នាក់ ស្រី ១៤នាក់ ក្មេងចំនួន ០៣នាក់ បន្ទាប់មកក្រុមចត្តាឡីស័ក វាស់កំដៅពុំមានសញ្ញាអ្វី គួរឲ្យកត់សំគាល់ ព្រមទាំងបានធ្វើការអប់រំ ណែនាំដល់ពួកគាត់ ពីវិធីបង្ការ ទប់ស្កាត់ ក្នុងការចម្លងមេរោគកូវីដ១៩ រួចក៏ឲ្យប្រជាពលរដ្ឋទាំងនោះ វិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ បានទទួលពលរដ្ឋខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial/ General Department of Immigration-GDI April 4 at 4:10 PM

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ នាថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២០ បានទទួលពលរដ្ឋខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទឆ្លងដែនខុសច្បាប់ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៣០នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration-GDI April 3 at 4:19 PM

នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៤និង៣០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៣០នាក់ ស្រី ២១០នាក់៕

## លោក អ៊ុក សោភ័ណ៖ «ពលករខ្មែរនៅថៃ មានស្ថានភាពល្អប្រសើរ ខណៈថៃ ដាក់ប្រទេសក្នុងគ្រាអាសន្ននៃកូវីដ១៩»

http://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ: 02/04/2020 - 13:15 ដោយ៖ញឹម សុផល

ប្រទេសថៃកាលពីសប្តាហ៍មុនបានដាក់ប្រទេសឲ្យនៅក្នុងស្ថានភាពអាសន្ន ដែលធ្វើឲ្យថៃបិទច្រកព្រំដែនអន្តរជាតិជាមួយកម្ពុជា។ ពលករខ្មែរប្រមាណជាង៥ម៉ឺននាក់ ដែលធ្វើការនៅប្រទេសថៃ បានសម្រុកវិលត្រលប់មកប្រទេសកំណើតរបស់ខ្លួនវិញ ក៏ប៉ុន្តែមានពលករខ្មែរជាច្រើនទៀតកំពុងរស់នៅ និងធ្វើការនៅក្នុងប្រទេសថៃនៅឡើយ។ លោក អ៊ុក សោភ័ណ ឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសថៃ ថ្លែងថាស្ថានទូតកម្ពុជា បានចូលរួមជាមួយអាជ្ញាធរថៃ និងអ្នកគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនថៃ បានមើលការខុសត្រូវយ៉ាងល្អដល់ពលករខ្មែរ។ រាជទូតខ្មែររូបនេះបញ្ជាក់ថា រហូតមកដល់ពេលនេះ មិនមានពលករខ្មែរណាម្នាក់បានឆ្លងវីរុសកូវីដ១៩ឡើយ ខណៈថៃបានឆ្លងជំងឺនេះ ឡើងដល់ជិត២ពាន់នាក់ទៅហើយ។

## ពលករខ្មែរស្លាប់ និង របួសជាច្រើននាក់ ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ នៅខេត្តនន់ថៈបុរី

http://kampucheathmey.com/ 2/4/2020 2:33 Pm

ប្រទេសថៃ ៖ យ៉ាងហោចណាស់ក៏មានពលការិនី ចំនួន២នាក់ដែរ ដែលបានបាត់បង់ជីវិត នៅក្នុងចំណោមពលករខ្មែរដែលរងរបួសជាច្រើននាក់ ខណៈដែលមានករណីគ្រោះថ្នាក់ចរាចរណ៍មួយ បានកើតឡើងនៅក្នុងខេត្តន

ន់ថៈបុរី ប្រទេសថៃ កាលពីយប់មិញនេះ។ យោងតាមការបង្ហោះព័ត៌មានរបស់ក្រុមហ៊ុនមូលនិធិ « រួមកតញ្ញូ នន់ថៈបុរី » បានបញ្ជាក់ថា ឧបទ្ទវហេតុនេះបានកើតឡើងកាលពីវេលាម៉ោង១១យប់ ថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ តាមបណ្តោយផ្លូវកានចាក់ណា ភិសែក ក្បែរផ្លូវរថភ្លើង ត្រង់ចំណុចផ្លូវចូលវត្តសិរីប្រវត្តិ ក្នុងឃុំប្លាយបាង ស្រុកបាងគ្រួយ ខេត្តនន់ថៈបុរី ប្រទេសថៃ។

នៅកន្លែងកើតហេតុ គេសង្កេតឃើញថា មានមនុស្សស្លាប់ចំនួន៣នាក់ ព្រមទាំងមានអ្នករងរបួស ជាច្រើននាក់ផងដែរ ដោយអ្នកស្លាប់ គឺស្ថិតក្នុងសភាពជាប់ក្នុងរថយន្តតែម្តង ដែលតម្រូវឲ្យក្រុមតម្រួត យកឧបករណ៍មកកាត់ជញ្ជាំងរថយន្តដើម្បីយកសពចេញមកខាងក្រៅ។ ដោយឡែករថយន្តដែលដឹកពលករខ្មែរនោះម៉ាក តូរីស ពណ៌ស ពាក់ស្លាកលេខ បាងកក ៤០៧៥។ ចំណែករថយន្តធុនធំដែលមានដឹកសសរគ្រឹះពេញ ពាក់ស្លាកលេខ ប៉ាធុំថានី ៧០-៣៩២៤។

លោក ស៊ុំ យ៉ុត អាយុ៥០ឆ្នាំ ជាអ្នកបើកបររថយន្តធំ បានរៀបរាប់ថា លោកបានដឹកសសរគ្រឹះនេះ មកពីខេត្តប៉ាធុំថានី ដោយយកមកទម្លាក់នៅកោះក្លាង ដើម្បីបុកគ្រឹះធ្វើស្ពានថ្មល់ ដោយលោកបានបើកភ្លើងវិល( ភ្លើងស៊ីរ៉ែន ) តាមផ្លូវមករហូត។ លុះមកដល់ត្រង់ចំណុចកើតហេតុ ក៏ស្រាប់តែរថយន្តតូរីសនេះ បើកលឿនមកពីខាងស្តាំ ហើយក៏បានបុកនឹងកន្ទុយរថយន្តរបស់លោកយ៉ាងពេញទំហឹងតែម្តង ដោយសារតែឃើញមានអ្នកស្លាប់ផងនោះ ទើបលោកបានទូរសព្ទហៅប៉ូលិសតែម្តង។

ក្រោយពេលសមត្ថកិច្ចថៃចុះមកដល់ គេសង្កេតឃើញថា មានអ្នកស្លាប់ចំនួន៣នាក់ ដោយមានសភាពជាប់ក្នុងរថយន្តផង ម្នាក់ គឺជាអ្នកបើកបររថយន្តឈ្មោះ សុភក្រ្ត ព្រុំចាន់ អាយុ៤៧ឆ្នាំ និង នារី២នាក់ គឺជាពលការិនីខ្មែរ អាយុប្រហែល៣០ឆ្នាំដែលធ្វើការនៅក្នុងប្រទេសថៃ ព្រមទាំងមានអ្នករងរបួសមួយចំនួនទៀត ក៏ជាពលករខ្មែរដែរ។ ក្រោយពេលកើតហេតុ សមត្ថកិច្ចកំពុងរកមើលកាមេរ៉ាសុវត្ថិភាពនៅតាមដងផ្លូវដើម្បីពិនិត្យ ប៉ុន្តែសមត្ថកិច្ចបានសន្និដ្ឋានបឋមថា អ្នកបើកបររថយន្តតូច អាចបើកទាំងងងុយដេក ព្រោះនៅលើផ្លូវគ្មានស្លាកស្នាមហ្វ្រាំងបន្តិចទាល់តែសោះ៕

## ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០

### សម្តេចតេជោ ហ៊ុន សែន អរគុណបងប្អូនពលករដែលបានដាក់ខ្លួនឲ្យនៅដាច់ដោយឡែកពីក្រុមគ្រួសារ១៤ថ្ងៃ

http://www.rasmeinews.com/ April 6, 2020, 5:04 PM

ដោយៈតារាទិទ្ធ(ភ្នំពេញ) ៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានអរគុណបងប្អូននិងកូនក្មួយពលករដែលទើបបានវិលត្រឡប់មកពីប្រទេសថៃនិងពីប្រទេសដទៃៗទៀតដែលយល់ដឹងពីការទប់ស្កាត់នៃការរីករាលដាលជំងឺឆ្លងកូវីដ-១៩ ដោយបានដាក់ខ្លួននិងក្រុមគ្រួសារអោយនៅដាច់ដោយឡែកចំនួន ១៤ ថ្ងៃ ក្នុងពេលដែលរង់ចាំលទ្ធផលនៃការពិនិត្យសុខភាព ។ នៅក្នុងសារក្នុងបណ្តាញសង្គមហ្វេសបុកនារសៀលថ្ងៃទី ៦ ខែមីនា ២០២០ នេះសម្តេចតេជោ ហ៊ុន សែនបានសរសេរថា៖«អរគុណបងប្អូននិងកូនក្មួយពលករដែលទើបបានវិល ត្រឡប់មកពីប្រទេសថៃនិងពីប្រទេសដទៃៗទៀតដែលយល់ដឹងពីការទប់ស្កាត់នៃការរីករាលដាលជំងឺឆ្លងកូវីដ-១៩ ដោយបានដាក់ខ្លួននិងក្រុមគ្រួសារអោយនៅដាច់ដោយឡែកចំនួន១៤ ថ្ងៃ ក្នុងពេលដែលរង់ចាំលទ្ធផលនៃការពិនិត្យសុខភាព »។ សម្តេចបានបន្តថា៖ «ការដាក់ខ្លួនអោយនៅដាច់ដោយឡែកជាបណ្តោះអាសន្នមួយរយៈនេះគឺដើម្បីសុខភាពផ្ទាល់ខ្លួនផងនិងដើម្បីទប់ស្កាត់និងកាត់បន្ថយការរីករាលដាលនៃការឆ្លងមេរោគពីគេមកយើងផង នឹងពីយើងទៅគេផង » ។សូមបន្តធ្វើតាមការណែនាំរបស់ក្រសួងសុខាភិបាល និងសហការជាមួយមន្ទីរពេទ្យក្នុងករណីមានការសង្ស័យណាមួយសូមទូរស័ព្ទទៅលេខ ១១៥ ៕ BR

## ក្រោយពិភាក្សាគ្នានឹងខេត្តស្រះកែវថៃបង្វែរពលករខ្មែរបន្តវិលត្រឡប់ ឱ្យចូលមកកម្ពុជាតាមច្រកអូរបើជាន់

http://www.rasmeinews.com/ April 7, 2020, 4:38 AM

ដោយៈភ្នំស្វាយ/បន្ទាយមានជ័យៈក្រោយពិភាក្សាគ្នានឹងខេត្តស្រះកែវថៃបានយល់ព្រមបង្វែរពលករខ្មែរដែលបន្តវិលត្រឡប់ក្រោយបិទព្រំដែនឱ្យចូលមកកម្ពុជាតាមច្រកអូរបើជាន់ស្រុកអូរជ្រៅខេត្តបន្ទាយមានជ័យ។ទោះយ៉ាងណានៅច្រករបៀងផ្សេងក៏នៅមានពលករប្រោលចេញដែរគិតត្រឹមថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០។ លោកអ៊ុំរាត្រី អភិបាលខេត្តបន្ទាយមានជ័យ និងមន្ត្រីអាជ្ញាធរកងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធបានទៅទទួលនិងអប់រំណែនាំពលករដែលវិលត្រឡប់មកពីប្រទេសថៃ។ចេញលើកទី១តាមច្រករបៀងអូរបើជាន់កាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០២០។ នាឱកាសនោះលោកអភិបាលខេត្ត និងមន្ត្រីបានប្រគល់អាលកុល១ធុងធំ ម៉ាស់៥០០ កូនកន្សែង៥០ ថវិការ២លានរៀលសម្រាប់ក្រុមការងារចម្រុះ។ នគរបាលទាហ៊ានអាវុធហត្ថគ្រូពេទ្យដែលប្រចាំការនៅមណ្ឌលជួរមុខនៃគណៈកម្មការទទួលពលករត្រឡន់ពីបរទេសរបស់ខេត្តបន្ទាយមានជ័យនៅទីនោះ។ បន្តមកក្រុមការងារបានដឹកពលករទាំងនោះទៅមណ្ឌលសំចតនៅក្រុងប៉ោយប៉ែតដើម្បីអនុវត្តវិធានដូចដែលបានអនុវត្តកន្លងមក ។

ចំណែកលោកវេជ្ជបណ្ឌិតកែវសុភ័ក្រ្តា ប្រធានមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យឱ្យដឹងថា ៖ ពេលទៅដល់ក្រុមគ្រូពេទ្យបានត្រួតពិនិត្យកម្តៅនិងឆែកសុខភាពរួមMass Screening លើបងប្អូនពលករដែលត្រឡប់ពីថៃ។ ដើម្បីចាប់យកករណីសង្ស័យ COVID-19 មកធ្វើវិភាគជំនាញចត្តាឡីស័កនៅមន្ទិរពេទ្យបង្អែកក្រុងប៉ោយប៉ែត (QuarantineatRHPoipet)។ យកសំណាកពីបងប្អូនដើម្បីកាត់បន្ថយទប់ស្កាត់ការចម្លងចូលក្នុងមូលដ្ឋាន។ លោកបន្តថាៈកិច្ចការនេះដើម្បីសុវត្ថិភាពសុខភាពក្នុងសហគមន៍នាពេលនោះមានពលករជាង១០០នាក់បានវិលត្រឡប់៕

## ដាច់ការងារហើយត្រូវគេទារថ្លៃខ្ពស់ពេលធ្វើដំណើរចេញពីថៃមកដល់ខ្មែរឆ្ងួរចិត្តវិញ

http://www.rasmeinews.com/ April 6, 2020, 5:56 PM

ដោយៈប.ជ័យ/បន្ទាយមានជ័យៈ សារចំហររបស់ពលករខ្មែរ ដែលបាននឹងកំពុងវិលត្រឡប់មកប្រទេសកំណើតឯកម្ពុជាវិញបានសរសេរ.ហើយកាសែតរស្មីកម្ពុជាក៏ទទួលបានឱ្យដឹងថា"សូមអស់លោកមន្ត្រីបើកភ្នែកមើលផងទាន។ឱជីវិតពលករចំណាកស្រុករស់ពិបាកជាងស្លាប់"។ ពលករទាំងនោះបានឱ្យដឹងកាលពីព្រឹកថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ខណៈពួកគេឆ្លងកាត់ព្រំដែនថៃកម្ពុជាតាមច្រករបៀង(កូនច្រកដែលខុសច្បាប់)។ពលករបានបន្តថាៈ ការចំណាយគឺទី១.ថ្លៃឡានពីថៃទៅដល់ព្រំដែនខ្មែរ+ថៃក្នុងម្នាក់២.០០០បាតប្រាក់ថៃ(ជាង២៦ម៉ឺនរៀលប្រាក់ខ្មែរ)។ ២.ថ្លៃអ្នកនាំដើរឆ្លងចូលទៅព្រំដែនខ្មែរ(មេខ្យល់)ម្នាក់៣០០បាត។ សរុបទៅទម្រាំដល់ស្រុកកំណើតដាច់បាយហើយ។

រថយន្តជនជាតិថៃដឹកពលករខ្មែរត្រូវទម្លាក់ពលករនៅត្រឹមថ្នល់ខ្មៅ ជាថ្នល់យុទ្ធសាស្ត្រការពារព្រំដែនថៃ។ កងកម្លាំងថៃមិនឱ្យដឹកមកដល់ច្រករបៀងដែលជាច្រកចេញពលករដែលភាគីទាំង២បានឯកភាពគ្នាដូចជាច្រកអូរបើជាន់នៅស្រុកអូរជ្រៅខេត្តបន្ទាយមានជ័យជាដើម។ ចុះពីរថយន្តពលករខ្មែរត្រូវដើរកាត់វាលស្រែចម្ការនិងព្រៃរបោះតាមរយៈមេខ្យល់ជូន។មេខ្យល់នោះចង់ឬមិនចង់ត្រូវបានបង់លុយសុំផ្លូវទៅឱ្យកងកម្លាំងថៃឈរជើងតាមព្រំដែនដែរ។ គឺវាដូចគ្នានឹងរថយន្តថៃដឹកពលករខ្មែរដែលយកថ្លៃខ្ពស់ក៏អាចមកពីគេខ្លាចរអារនឹងមេរោគកូវីត១៩។ ពេលបានដឹកក៏ត្រូវបង់លុយថ្លៃត្រួតពិនិត្យនិងថ្លៃឆ្លងកាត់ចំណុចត្រួតពិនិត្យចាស់និងថ្មីឬភាសាថៃហៅថាៈដានកងថាប់និងដានកងតម្រួតជាច្រើនកន្លែងផងដែរ។ហេតុនេះហើយលើតម្លៃចំណាយរបស់ពលករមិនអាចជៀសរួចពីទឹកភ្នែកនោះឡើយ។

ចំណែកអង្គការដៃគូអភិវឌ្ឍន៍នានាមានអង្គការនិសន្តប្រវេសន៍អន្តរជាតិIOMអង្គការសាម៉ារីតាន់ភឺសសង្គ្រោះអន្តរជាតិ។ អង្គការមិត្តសំឡាញ់ហ្វ្រែនក្រោមមូលនិធីអង្គការយូនីសេហ្វជាដើមបានជួយលើអាហារសម្រន់ សេវា

សង្គមកិច្ចនិងការគាំពារស្ត្រីមានផ្ទៃពោះស្ត្រីកូនតូចនិងកុមារ ។ សូមបញ្ជាក់ថាពលករខ្មែរក្រុមថ្មីៗបានបន្តវិលត្រឡប់មកកាន់មាតុប្រទេសវិញ ដោយសារតែកន្លែងការងារពួកគេត្រូវបានបិទឬផ្អាកព្រោះអាជ្ញាធររដ្ឋាភិបាលថៃបានបន្តរឹតបន្តឹងប្រទេស។ដើម្បីប្រយុទ្ធប្រឆាំងនឹងមេរោគកូវីត១៩ដែលរីករាលដាលខ្លាំងឡើងៗនោះ។មន្ត្រីអាជ្ញាធរដែនដីជំនាញ និងមន្ត្រីស្ថានកុងស៊ុលកម្ពុជានៅខេត្តស្រះកែវ និងស្ថានទូតកម្ពុជានៅក្រុងបាងកកក៏បានទាក់ទងសហប្រតិបត្តិការអន្តរាគមន៍បន្តបន្ទាប់ទៅសមភាគីថៃលើករណីទុក្ខលំបាកពលករខ្មែរ ដែលវិលមកកម្ពុជាក្នុងសភាពការណ៍កូវីត១៩នេះ៕ទS/

## ពលករខ្មែរជាង ១ម៉ឺននាក់ ទើបត្រឡប់មកពីថៃ និងមួយចំនួនស្ម័គ្រចិត្ត ដាក់ខ្លួនឯងនៅដាច់ដោយឡែកពីគ្រួសារ និងសហគមន៍ ចំនួន ១៤ថ្ងៃ

https://www.cen.com.kh/ April 7, 2020

បាត់ដំបង៖ ពលករខ្មែរជាង ១ម៉ឺននាក់ បានត្រឡប់ពីថៃ មកស្រុកកំណើត និងមួយចំនួនស្ម័គ្រចិត្តដាក់ខ្លួនឯង នៅដាច់ដោយឡែកពីគ្រួសារ និងសហគមន៍ចំនួន១៤ថ្ងៃ ខណៈដែលអាជ្ញាធរថៃ សម្រេចបិទច្រកព្រំដែន ជាប់ខេត្តបាត់ដំបង ក្នុងឡុងខែមីនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៥ ខែមេសា ឆ្នាំ២០២០។ លោក សៀម ប៊ុនរិទ្ធ អភិបាលរងខេត្តបាត់ដំបង និងជាអ្នកនាំពាក្យសាលាខេត្តបាត់ដំបង បានមានប្រសាសន៍ឲ្យដឹងថា ក្រៅពីការពិនិត្យសុខភាព នៅតាមច្រកព្រំដែន ដែលពួកគាត់បានចេញមក។ អាជ្ញាធរខេត្ត បានចុះទៅតាមខ្នងផ្ទះរបស់ពួកគាត់អប់រំបន្ថែម ចំពោះពលករខ្មែរទាំងអស់នោះ ពីការបង្ការមិនឲ្យឆ្លងជំងឺកូវីដ១៩ ។ ក្រោយពីបានយល់ដឹងពីការបង្ការ និងមិនឲ្យមានការរីករាលដាលជំងឺកូវីដ១៩ មានពលករខ្មែរ នៅតាមស្រុកខ្លះមានចំនួន ៣០នាក់ បានសម្រេចដាក់ខ្លួនឯង នៅដាច់ដោយឡែក និងមានពលករខ្លះទៀត ដែលទើបមកពីប្រទេសថៃ បានសរសេរអក្សដាក់នៅមុខផ្ទះថាពួកគាត់ឬគ្រួសាររបស់ពួកគាត់ ទើបមកពីប្រទេសថៃ ដែលបញ្ហានេះ កាន់តែធ្វើឲ្យអាជ្ញាធរឬមន្ត្រីសុខាភិបាលងាយស្រួលចុះទៅសួរសុខទុក្ខពួកគាត់ ក៏ដូចជាអនុវត្តនូវយន្តការការពារ មិនឲ្យមានការរាតត្បាតជំងឺកូវីដ១៩ នៅក្នុងសហគមន៍ ។

គួរបញ្ជាក់ផងដែរថា បើតាមសេចក្ដីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល បានឲ្យដឹងថា នៅខេត្តបាត់ដំបងក្នុងចំណោមពលរដ្ឋខ្មែរឆ្លងជំងឺកូវីដ១៩ មានចំនួន៨នាក់ (ស្រី២នាក់) ក្នុងនោះមានចំនួន៤នាក់ (ស្រីម្នាក់) បានជាសះស្បើយនិងបានអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញហើយ ខណៈដែលអ្នកជំងឺ ៤នាក់ទៀត គឺមានសុខភាពល្អ ៕ ដោយៈអ៊ុងសារុំ

## ពលករខ្មែរនៅប្រទេសថៃជាច្រើននាក់ដាច់ស្បៀង បន្ទាប់ពីថៅកែផ្អាកការងារដោយជំងឺកូវិដ១៩

https://www.rfa.org/khmer/news/ ដោយ មាន ឫទ្ធិ 2020-04-05

ពលករខ្មែរធ្វើការងារនៅប្រទេសថៃមួយចំនួន ចាប់ផ្ដើមដាច់ស្បៀងបណ្ដើរៗ ហើយ និងមួយចំនួនទៀតប្រឈមនឹងដាច់ស្បៀងនៅពេលដ៏ខ្លីខាងមុខ។ ពួកគាត់អះអាងថា មូលហេតុដែលនាំឱ្យដាច់ស្បៀងនេះ គឺដោយសារអត់ការងារជាច្រើនថ្ងៃហើយ បន្ទាប់ពីថៅកែបានផ្អាកការងារដោយសារខ្លាចឆ្លងជំងឺកូវិត១៩។

ពលករខ្មែរធ្វើការនៅខេត្តជាប់ទីក្រុងបាងកកម្នាក់ លោក ជិន រិទ្ធ ថ្លែងនៅថ្ងៃទី៥ មេសាថា លោកពុំមានប្រាក់ចាយវាយប្រចាំថ្ងៃ និងបង់ថ្លៃបន្ទប់ជួល និងប្រាក់ទិញស្បៀងអាហារហូបចុកប្រចាំថ្ងៃនោះទេ ពីព្រោះថៅកែបានផ្អាកការងារប្រមាណ ២សប្ដាហ៍មកហើយ។ លោកបន្តថា នៅពេលនេះលោកចង់ទៅផ្ទះវិញក៏ទៅមិនបាន ព្រោះគ្មានប្រាក់ធ្វើដំណើរ ហើយម្យ៉ាងទៀត អាជ្ញាធរកម្ពុជាថៃក៏បានបិទព្រំដែនរួមមកហើយដែរ ដូច្នេះលោកសម្រេចចិត្តស្នាក់នៅក្នុងបន្ទប់ជួល ២នាក់ពលករខ្មែរមានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ៖ «ខ្ញុំនិយាយការពិតហ្នឹងឯង ព្រោះអីបើខ្ញុំអត់មានអីហូបមែន ហើយខ្ញុំទៅខ្ចីប្រាក់អ្នកណាបាន បើសុទ្ធតែអ្នកអត់ដូចគ្នា។ បើយើង

ទៅផ្ទះក៏ទៅមិនរួច ព្រោះអីបើគេបិទច្រកអស់ហើយ បើទៅមានតែគេឃាត់ទុក ១៤ថ្ងៃបានគេឱ្យទៅបាន អីចឹងបានខ្ញុំមិនហ៊ានទៅ។ ខ្ញុំមិនដឹងគិតយ៉ាងម៉េចទេ បើយើងអត់លុយ ហើយម្ចាស់បន្ទប់ជួលក៏គេមិនលើកលែងឱ្យយើងដែរ។ ខ្ញុំអត់មានអីហូបអីចឹង មានអារម្មណ៍ថា ទៅមុខទៀតអាចនឹងស្លាប់ដោយសារដាច់បាយ»។

ស្រដៀងគ្នានេះពលករខ្មែរធ្វើការនៅផ្សារទំនើបនៅប្រទេសថៃមួយចំនួនទៀត ឱ្យដឹងថា ពួកគាត់ក៏គ្មានប្រាក់ចំណូលសម្រាប់ចាយវាយនៅពេលខាងមុខនេះដែរ ហើយនាំគ្នាស្នាក់នៅតែក្នុងបន្ទប់ជួល ដោយពុំហ៊ានចេញទៅខាងក្រៅឡើយ ព្រោះខ្លាចឆ្លងជំងឺកូវិដ១៩។ ប្រភពដដែលបន្ថែមទៀតថា សព្វថ្ងៃពួកគាត់នៅសល់អង្ករប្រមាណ ៥គីឡូក្រាម និងមី ១០កញ្ចប់ សម្រាប់ហូបចុកប្រចាំថ្ងៃ៖ «ចាប់ពីគេបិទខ្ញុំដេកក្រោកៗ រហូត អ្នកផ្សេងក៏ដូចគ្នាដែរ មានរាប់រយនាក់ ប៉ុន្តែអ្នកខ្លះទៅផ្ទះ អ្នកខ្លះមិនបានទៅទេ។ ខ្ញុំដាច់ការងារ២អាទិត្យហើយ ដោយសារថៅកែបិទហាងព្រោះលក់មិនដាច់ ខ្ញុំទៅមុខទៀតក៏គ្មានអីហូប ទៅផ្ទះក៏មិនរួចចេះខ្ញុំភ័យណាស់ បើគេបិទមិនឱ្យដើរហើយ។ ខ្ញុំមិនដឹងទៅខ្ចីប្រាក់ពីណាទេ បើពីមុនចេះតែជួយគ្នាបាន ដល់ពេលនេះអត់ការងារដូចគ្នាមិនដឹងជួយយ៉ាងណាទេ យករួចតែខ្លួន»។ ក្រុមពលករទាំងនេះបន្តថា ពលករខ្មែរនៅតំបន់ដទៃទៀត ចាប់ផ្ដើមដាច់ស្បៀង និងខ្លះទៀតនៅសល់ប្រាក់ចន្លោះពី ៥០០បាតទៅ ១ពាន់បាត ឬប្រមាណ ៣០ដុល្លារអាមេរិកប៉ុណ្ណោះ ដោយសារអត់ការងារធ្វើជាច្រើនថ្ងៃហើយ ស្របពេលដែលប្រាក់ខែធ្វើការកន្លងមកមួយចំនួនផ្ញើទៅឱ្យឪពុកម្ដាយនៅស្រុកកំណើត និងមួយទៀតបង់ថ្លៃបន្ទប់ជួល និងចាយវាយអំឡុងពេលអត់ការងារធ្វើនៅក្រៅប្រទេស។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកកទទួលបន្ទុកផ្នែកពលករ លោក គឹម ចំរើន និងអ្នកនាំពាក្យក្រសួងការងារលោក ហេង សួរ ដើម្បីសុំអត្ថាធិប្បាយជុំវិញបញ្ហាប្រឈមរបស់កម្មករទាំងនេះបានទេ នៅថ្ងៃទី៥ មេសា ដោយទូរស័ព្ទចូលជាច្រើនដងពុំមានអ្នកទទួល។

ថ្មីៗ នេះ ស្ថានទូតខ្មែរប្រចាំប្រទេសថៃបានចេញសេចក្ដីជូនដំណឹងអំពី បម្រាមគោចរទូទាំងប្រទេសថៃ ចាប់ពីម៉ោង ១០យប់ ដល់ម៉ោង ៤ព្រឹក ដើម្បីទប់ទល់ការរីករាលដាលនៃជំងឺកូវីដ-១៩។ បម្រាមនេះចូលជាធរមាន ពីយប់ថ្ងៃទី៣ ខែមេសា រហូតដល់ស្ថានការណ៍វិលមកប្រក្រតីឡើងវិញ។ ជនណាល្មើសបម្រាមនេះ នឹងត្រូវជាប់ពន្ធនាគារពីរឆ្នាំ និង/ឬពិន័យជាប្រាក់ ៤ម៉ឺនបាត ឬស្មើនឹងជាង ១.២០០ដុល្លារ។ ក្នុងករណីពលរដ្ឋខ្មែរនៅថៃមានបញ្ហា អាចទំនាក់ទំនងមកស្ថានទូតកម្ពុជាប្រចាំទីក្រុងបាងកកតាមរយៈហ្វេសប៊ុកផេករបស់ស្ថានទូត ឬទូរស័ព្ទលេខ ០៩២ ៨០ ៥០ ៥៦១ និងលេខ ០៩៤ ០៩២ ៥៩ ០៥។

ប្រធានផ្នែកពលករចំណាកស្រុកនៃអង្គការសិទ្ធិការងារសេង់ត្រាល់ (CENTRAL) លោក ឌី ថេហូយ៉ា មានប្រសាសន៍ថា ពលករខ្មែរធ្វើការនៅប្រទេសថៃ ដែលជួបការលំបាកខ្លាំងជាងគេ គឺពលករធ្វើការខុសច្បាប់ និងពលករដែលមិនបានចុះកិច្ចសន្យាអត្ថប្រយោជន៍ការងារ។ លោកបន្ថែមថា បញ្ហាអាជ្ញាធរកម្ពុជាគួរតែជួយដល់ពលករខ្មែរទាំងនោះជាបន្ទាន់ ធ្វើយ៉ាងណាឱ្យពួកគាត់មានស្បៀងអាហារហូបចុកក្នុងពេលស្នាក់នៅប្រទេសថៃ ពីព្រោះប្រសិនបើពុំដូច្នោះទេ ពួកគាត់នឹងវិលត្រឡប់ទៅកម្ពុជា ហើយធ្វើឱ្យកកស្ទះនៅតំបន់ព្រំដែននៅពេលដ៏ខ្លីខាងមុខ៖ «ប្រសិនបើវាឈានដល់វិបត្តិធ្ងន់ធ្ងរ ដែលគាត់មិនអាចរស់បានមែននោះ ចង់មិនចង់ទោះបីបិទព្រំដែនយ៉ាងណា ក៏បិទមិនជិតដែរ គាត់ត្រូវត្រឡប់ទៅខ្មែរហើយ។ បើសិនមិនចង់ឱ្យវាកើតវិបត្តិហ្នឹងរដ្ឋាភិបាលថៃនិងកម្ពុជាគួរសហការគ្នាជានាបាននូវស្បៀង ដែលគាត់អាចរស់នៅបាននៅក្នុងប្រទេសថៃ»។

របាយការណ៍អង្គការសេង់ត្រាល់ឱ្យដឹងថា សព្វថ្ងៃមានពលករខ្មែរប្រមាណ ២លាននាក់(២.០០០.០០០) ធ្វើការនៅប្រទេសថៃ។ កាលពីថ្មីៗ នេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា ទើបតែមានពលករខ្មែរធ្វើការនៅប្រទេសថៃជាង ៥ម៉ឺន (៥០.០០០) ប៉ុណ្ណោះ ដែលបានត្រឡប់មកដល់ស្រុកកំណើតវិញ អំឡុងពេលរាតត្បាតជំងឺកូវិដ១៩៕

## ពលករខ្មែរជាច្រើននាក់ត្រូវបានរថយន្តឈ្នួលថៃដឹកយកទៅចាក់ចោលនៅតាមចំការនានារបស់ប្រជាពលរដ្ឋថៃ

https://www.facebook.com/LABOURKHMER/ 07-04-2020

ពលករខ្មែរជាច្រើននាក់ ត្រូវបានរថយន្តឈ្នួលថៃដឹកយកទៅចាក់ចោលនៅតាមចំការនានារបស់ប្រជាពលរដ្ឋថៃ ដែលក្បែរបន្ទាត់ព្រំដែនច្រកព្រំដែនទ្បែម ស្ថិតក្នុងខេត្តចាន់បុរី ប្រទេសថៃ បន្ទាប់ពីពលករខ្មែរទាំងអស់នោះព្យាយាមធ្វើដំណើរវិលត្រឡប់ទៅស្រុកកំណើតវិញ ទាំងស្ថានភាពប្រទេសថៃ កំពុងរីករាតត្បាតនៃការឆ្លងជំងឺកូវីដ១៩ និងកំពុងស្ថិតក្នុងការដាក់ប្រទេសក្នុងគ្រាអាសន្ន។ UPDATE NEWS: 07.04.20

## ម៉ាឡេស៊ី ស្ទាក់ចាប់ទូកដឹកជនភៀសខ្លួនរ៉ូហ៊ីងយ៉ាជាង ២០០នាក់ ដោយសង្ស័យថា រត់ពន្ធមនុស្ស

https://dap-news.com/international/ ByKD102 Posted on April 6, 2020

កូឡាឡាំពួរ៖ ផ្នែកឆ្មាំឆ្នេរសមុទ្រម៉ាឡេស៊ីបានឲ្យដឹងថា ខ្លួនបានស្ទាក់ចាប់ទូកដឹកមនុស្សចំនួន ២០២ នាក់ ដែលគេជឿថា ជាជនភៀសខ្លួនរ៉ូហ៊ីងយ៉ា មកពីប្រទេសមីយ៉ាន់ម៉ា កាលពីព្រឹកថ្ងៃអាទិត្យម្សិលមិញនេះ។ លោក Zulinda Ramly អនុប្រធានទីភ្នាក់ងារពង្រឹងដែនសមុទ្រម៉ាឡេស៊ី បានឲ្យដឹងនៅក្នុងសេចក្តីថ្លែងការណ៍មួយថា ក្រុមនេះមានបុរស ១៥២ នាក់ ស្ត្រី ៤៥ នាក់ និងកុមារ ៥ នាក់ត្រូវបានប្រគល់ទៅឱ្យអាជ្ញាធរអន្តោប្រវេសន៍ ដើម្បីដំណើរការខណៈពួកគេបានចូលទៅក្នុងប្រទេសដោយខុសច្បាប់។ ទូកនោះត្រូវបានគេរកឃើញ នៅឆ្ងាយពីច្រាំងនៃកោះរមណីយដ្ឋាន Langkawi ដោយបន្ថែមថា អាជ្ញាធរកំពុងស្វែងរកអ្នកបើក និងនាវិកពីរនាក់ដែលសង្ស័យថា មកពីក្រុមរត់ពន្ធមនុស្ស។ យោងតាមជនជាតិរ៉ូហ៊ីងយ៉ា បុរសទាំងនោះបានរត់គេចខ្លួន ពេលពួកគេកំពុងនៅលើសមុទ្រ៕ ដោយ ឈូក បូរ៉ា

## ពលរដ្ឋខ្មែរ ចូលប្រទេសតាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ មានចំនួន ០៩នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration-GDI 06-04-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រំ នាថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ បានបន្តបិទ មិនអនុញ្ញាតឲ្យអ្នកដំណើរ មធ្យោបាយ និងទំនិញ ចូល-ចេញ ឆ្លងកាត់ច្រកនេះបាន។ ដោយឡែកមានពលរដ្ឋខ្មែរ ចូលប្រទេសតាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ មានចំនួន ០៩នាក់ ស្រី ០៣នាក់ ក្មេងចំនួន ០២នាក់ បន្ទាប់មកក្រុមចត្តាឡីស័កវាស់កំដៅពុំមានសញ្ញាអ្វី គួរឲ្យកត់សំគាល់ ព្រមទាំងបានធ្វើការអប់រំ ណែនាំដល់ពួកគាត់ ពីវិធីបង្ការ ទប់ស្កាត់ ក្នុងការចម្លងមេរោគកូវីដ១៩ រួចក៏ឲ្យប្រជាពលរដ្ឋទាំងនោះ វិលទ្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន៕

## មានករណីបាក់ល្ពៅដីសង្កត់បុរសពលករខ្មែរម្នាក់ស្លាប់យ៉ាងអាណោចអាធ័ម

https://www.facebook.com/LABOURKHMER/ 07-04-2020

ករណីនេះបានកើតឡើងកាលនៅរសៀលថ្ងៃច័ន្ទទី០៦ ខែមេសាឆ្នាំ២០២០ ចំណុចកើតហេតុនៅម្តុំតំបន់អេកការម៉ៃ ស្ថិតកណ្តាលទីក្រុងបាងកក ប្រទេសថៃ ជនរងគ្រោះឈ្មោះ សុខ ជា ភេទ អាយុប្រហែល ៣៥ឆ្នាំ សញ្ជាតិខ្មែរ បានស្លាប់បាត់បង់ជីវិតនៅនឹងកន្លែងកើតហេតុ រីឯជនជនរងគ្រោះម្នាក់ទៀតជាជនជាតិភូមារងរបួសធ្ងន់។ យោងតាមរបាយការណ៍បានអោយដឹងថា ខណៈពេលកើតហេតុជនរងគ្រោះ និងអ្នកស្លាប់កំពុងធ្វើការចងដែកក្នុងរណ្តៅដី ដែលមានជំម្រៅប្រម៉ាណ៣ម៉ែត្រ ស្រាប់តែអាច៏ដីនៅក្បែរុន្ធរណ្តៅនោះបានស្រុតមកសង្កត់អ្នកស្លាប់ជនរងគ្រោះតែម្តង ក្រោយពេលកើតកម្លាំងសមត្ថកិច្ចថៃចុះអន្តរាគមន៍ជួយសង្គ្រោះបានជនជាតិភូមាម្នាក់ រីឯពលករខ្មែរបានស្លាប់បាត់បង់ជីវិត។

# ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០

## សម្តេច ហ៊ុន សែន៖ ពលករជាង ៦ម៉ឺននាក់មកថៃ មិនទាន់មាននរណាម្នាក់ឆ្លងជំងឺកូវីដ១៩ ឡើយ

http://kleykley.sabay.com.kh/ ម្សិលមិញ ម៉ោង 14:53

សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា បងប្អូនពលករជាង ៦ម៉ឺននាក់ដែលមកពីប្រទេសថៃ ដែលបានការពារខ្លួន បានដាក់ខ្លួននៅដាច់ដោយឡែក ១៤ថ្ងៃ ដែលរហូតមកដល់ពេលនេះ មិនទាន់មានបងប្អូនពលករណាម្នាក់ឆ្លងជំងឺកូវីដ១៩ ឡើយ។ ការលើកឡើងនេះ នៅក្នុងពិធីធ្វើសន្និសីទសារព័ត៌មាន ពាក់ព័ន្ធបច្ចុប្បន្នភាពនៃជំងឺកូវីឌ-១៩ នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០នេះ នៅវិមានសន្តិភាព។ សម្តេច ហ៊ុន សែន បានបន្តថាពេលនេះកំពុងទប់ទល់ជាមួយនៃជំងឺកូវីដ១៩ ដែលជាសង្គ្រាមឥតស្រមោល ហើយសង្គ្រាមនេះគឺកម្ពុជា មិនអាចយកឈ្នះបានទេ គឺបានត្រឹមតែទប់ទល់តែប៉ុណ្ណោះ។ សម្តេច ក៏បានចាត់ទុកថាការទប់ទល់ជាមួយសង្គ្រាមនេះ គឺត្រូវប្រើយុទ្ធសាស្ត្រទប់ទល់រយៈពេលវែង ពីព្រោះរហូតមកដល់ពេលនេះ អង្គការសុខភាពពិភពលោក នៅមិនទាន់មានថ្នាំបង្ការ និងទប់ស្កាត់នៅឡើយទេ ដូច្នេះកម្ពុជាត្រូវដាក់ផែនការទប់ទល់រយៈពេលវែង។

ទន្ទឹមនឹងនោះ សម្តេចក៏បានបញ្ជាក់ថាមិនបណ្តោយអោយគ្រូពេទ្យរបស់កម្ពុជាបាត់បង់ជីវិតឡើយនិងបានអរគុណកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលបានចូលរួមសហការ និងអរគុណប្រជាពលរដ្ឋទាំងអស់ដែលចូលរួមទប់ស្កាត់ជំងឺកូវីដ១៩ និងបានកោតសរសើរគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ដែលបានចូលរួមប្រយុទ្ធប្រឆាំងជំងឺនេះ៕

## លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន អំពាវនាវដល់ពលករខ្មែរឱ្យបន្តស្នាក់នៅប្រទេសថៃ កុំវិលមកស្រុកកំណើតនាឱកាសបុណ្យចូលឆ្នាំថ្មីនេះ ដើម្បីបង្ការការឆ្លងរីករាលនៃជម្ងឺកូវីដ-១៩

https://grandnewsasia.com/ 07-04-2020

ប្រសិនបើមានការងារធ្វើ ឬកន្លែងស្នាក់នៅត្រឹមត្រូវ សូមទាន់កុំត្រឡប់មកកម្ពុជាវិញនាឱកាសបុណ្យចូលឆ្នាំថ្មីនេះ ពីព្រោះបើទោះជាមកកម្ពុជាក៏ត្រូវតែដាក់ឱ្យនៅដោយ ឡែក ១៤ថ្ងៃ ហើយពេលចេញទៅប្រទេសថៃវិញក៏គង់តែគេតម្រូវឱ្យនៅរយៈពេល ១៤ថ្ងៃ ទៀតដែរ។ នេះជាសារអំពាវនាវរបស់លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ដែលបានថ្លែងទៅកាន់ពលករខ្មែរនៅប្រទេសថៃ។ លោកបានសំណូមពរយ៉ាងដូច្នេះនៅក្នុងសន្និសីទព័ត៌មានពាក់ព័ន្ធនឹងបច្ចុប្បន្នភាពនៃជំងឺកូវីដ១៩ នាថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០ នៅវិមានសន្តិភាព។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានឱ្យដឹងថា រាជរដ្ឋា ភិបាលកម្ពុជាពិតជាមានកង្វល់ចំពោះសុខភាព សុវត្ថិ ភាព និងការធ្វើដំណើរចល័តរបស់ពលករដែលមកពីប្រទេសថៃ ទោះបីថាពលករជាង ៦ម៉ឺននាក់ ដែលចូលមកកម្ពុជាហើយនោះ មានការគ្រប់គ្រងបានល្អយ៉ាង ណាក៏ដោយ ប៉ុន្តែសម្រាប់ពលករដែលបន្តចូលមក និងគ្រោងចូលមកកម្ពុជាទៀតនោះ គឺពិតជាមានការព្រួយ បារម្ភណាស់ដែរ។ ដូច្នេះហើយ បានជារាជរដ្ឋាភិបាលសូមអំពាវនាវដល់ប្រជាពលករខ្មែរដែលកំពុងធ្វើការ និងស្នាក់នៅប្រទេសថៃ ប្រសិនបើនៅមានការងារធ្វើ មានកន្លែងស្នាក់នៅត្រឹមត្រូវនៅទីនោះ សូមកុំទាន់ត្រឡប់មកកម្ពុជាវិញអី ដើម្បីការពារការឆ្លងជំងឺកូវីដ១៩ ពីព្រោះប្រសិនបើចូលមកដល់មាតុភូមិវិញ ក៏គង់តែត្រូវដាក់ខ្លួនឱ្យនៅដាច់ដោយឡែក ១៤ថ្ងៃ ហើយដល់ពេលត្រូវត្រលប់ទៅធ្វើការនៅថៃវិញក៏គង់តែត្រូវគេដាក់ឱ្យនៅដាច់ដោយឡែក ១៤ថ្ងៃ ដូចគ្នាដែរ សរុបគឺមិនមែនជាការងាយស្រួលនោះឡើយ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបន្តថា ទោះបីមានការព្រួយបារម្ភចំពោះការចល័តរបស់ប្រជាពលករខ្មែរមកពីថៃយ៉ាងនេះក្តី ក៏រាជរដ្ឋាភិបាលកម្ពុជាមិនអាចបិទព្រំដែនមិនឱ្យប្រជាជនចូលមកក្នុងប្រទេសវិញនោះទេ តែត្រូវមានវិធានការកុំឱ្យជំងឺនេះឆ្លងមកដល់ក្នុងប្រទេស និងក្រុមគ្រួសាររបស់ខ្លួន ពិសេសអាជ្ញាធរត្រូវក្តាប់ស្ថានការណ៍របស់ពលករមួយចំនួន ដែលចេញចូលតាមច្រករបៀងផ្សេងៗ៕

## សម្តេច ស ខេង សង្កេតឃើញថា ពលរដ្ឋខ្មែរទើបមកពីក្រៅប្រទេស សហការល្អជាមួយអាជ្ញាធរ ដើម្បីពិនិត្យ សុខភាព

https://dap-news.com/national/ BySS107 Posted on April 7, 2020

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានសង្កេតឃើញថា ប្រជាពលរដ្ឋខ្មែរ ទើបមកពីក្រៅប្រទេស សហការល្អជាមួយអាជ្ញាធរ និងក្រុមគ្រូពេទ្យ ដើម្បីពិនិត្យតាមដានសុខភាព និងចូលរួមបញ្ចៀសការឆ្លងជំងឺ កូវីដ-១៩ ជាយថាហេតុ។ នេះបើយោងតាមគេហទំព័រហ្វេសប៊ុករបស់សម្តេច ស ខេង ។ ក្នុងជំនួបសំណេះសំណាលជាមួយក្រុមគ្រូពេទ្យ និងប្រជាពលរដ្ឋ ដែលមានការសង្ស័យ ពិសេសពលរដ្ឋដែលទើបវិលត្រឡប់មកពីក្រៅប្រទេស ហើយត្រូវបានដាក់ឱ្យនៅដោយឡែករយៈពេល១៤ថ្ងៃក្រោមការតាមដានសុខភាពពីក្រុមគ្រូពេទ្យ នៅខេត្តព្រៃវែង នាថ្ងៃទី៧ ខែមេសា ឆ្នាំ២០២០ សម្តេចក្រឡាហោម ស ខេង កោតសរសើរក្រុមគ្រូពេទ្យ ដែលបានខិតខំបំពេញភារកិច្ចប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ក្នុងការពិនិត្យតាមដានសុខភាពពលរដ្ឋ។

សម្តេច សម្តែងការលើកទឹកចិត្តខ្ពស់ដល់អាជ្ញាធរមូលដ្ឋាន ដែលបានរួមសហការគ្នាចុះទាំងការអប់រំផ្សព្វផ្សាយ និងណែនាំបងប្អូនប្រជាពលរដ្ឋដែលមានការសង្ស័យ ឬទើបវិលមកពីក្រៅប្រទេស ឱ្យមកពិនិត្យសុខភាព និងចូលរួមអនុវត្តវិធានណែនាំដោយក្រសួងសុខាភិបាល។ សម្តេច ស ខេង មានប្រសាសន៍ថា "រំភើបរីករាយបន្ទាប់ពីបានសង្កេតឃើញថាបងប្អូនប្រជាពលរដ្ឋ ពិសេសប្រជាពលរដ្ឋដែលទើបវិលមកពីក្រៅប្រទេស មានស្មារតីចូលរួមសហការជាមួយអាជ្ញាធរ និងក្រុមគ្រូពេទ្យ ដើម្បីពិនិត្យតាមដានសុខភាពខ្លួនឯងផង និងចូលរួមបញ្ចៀសការឆ្លងជំងឺកូវីដ១៩ជាយថាហេតុណាមួយដល់ក្រុមគ្រួសារសាច់ញាតិ និងបងប្អូនក្នុងភូមិ"។ សម្តេច បានចាត់ទុកការការចូលរួមសហការគ្នានេះថាផ្នែកមួយដ៏សំខាន់នៃការទប់ស្កាត់ការរាតត្បាតជំងឺកូវីដ១៩នៅកម្ពុជា និងនៅលើពិភពលោក៕ ដោយ អេង ប៊ូឆេង

## ថ្ងៃស្អែកអាជ្ញាធរថៃមិនអនុញ្ញាត ឱ្យមនុស្សឆ្លងកាត់ព្រំដែនអូរស្មាច់ទៀតទេ

http://www.freshnewsasia.com/ 2020-04-07

**(ឧត្តរមានជ័យ)៖** លោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ បានឱ្យដឹងនៅយប់ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០នេះថា ចាប់ពីថ្ងៃទី០៨ ខែមេសា ស្អែកនេះ អាជ្ញាធរថៃមិនអនុញ្ញាតឱ្យមនុស្សឆ្លងកាត់ព្រំដែនអូរស្មាច់-ឆងចម ស្ថិតក្នុងក្រុងសំរោង ខេត្តឧត្តរមានជ័យទៀតនោះឡើយ។ លោក ប៉ែន កុសល្យ បានប្រាប់ Fresh News ថា នៅថ្ងៃទី០៧ ខែមេសា នេះ លោកបានជួបពិភាក្សាការងារជាមួយអភិបាលខេត្តសុរិន្ទ លោក កៃសន កងឆ្លាត ដើម្បីរិះរកវិធីដោះស្រាយបញ្ហាប្រឈមមួយចំនួនសម្រាប់ខេត្តទាំងពីរក្នុងពេលជួបវិបត្តិដោយសារជំងឺកូវីដ១៩។ ក្នុងជំនួបនេះភាគីថៃបានជម្រាបពីចំណាត់ការរបស់អាជ្ញាធរថៃក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ហើយតម្រូវឱ្យបិទព្រំដែនជាមួយប្រទេសកម្ពុជា។ អភិបាលខេត្តសុរិន្ទ បានបញ្ជាក់ថា ការបិទព្រំដែនរវាងខេត្តសុរិន្ទ និងខេត្តឧត្តរមានជ័យ ចាប់ផ្តើមពីថ្ងៃទី០៨ ខែមេសា តទៅ។ បើទោះបីជាយ៉ាងណាលោកអភិបាលខេត្តសុរិន្ទ បានបញ្ជាក់ដែរថា ក្នុងករណីមានប្រជាពលរដ្ឋ និងពលករខ្មែរដែលមកខកដំណើរនៅព្រំដែន ឬក្បែរតំបន់ព្រំដែន អាជ្ញាធរខេត្តទាំងពីរ

ត្រូវជួបពិភាក្សាគ្នារកដំណោះស្រាយជាក់ស្តែងជាបន្ទាន់ជាថ្មីភ្លាម។ រីឯការដឹកទំនិញពាណិជ្ជកម្ម ដើម្បីរក្សាសុវត្ថិភាព ក៏ដូចជាទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ ការដឹកទំនិញឆ្លងដែន ត្រូវប្រគល់សមត្ថកិច្ចឱ្យគយប្រចាំច្រកនៃភាគីទាំងពីរពិភាក្សាលម្អិតអំពីនីតិវិធីនៃការផ្ទេរទំនិញជាក់ស្តែង។

បើតាមលោក ប៉ែន កុសល្យ នៅក្នុងជំនួបនេះលោកបានលើកសំណើមួយចំនួនទៅកាន់ភាគីថៃ ដើម្បីរួមគ្នាទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩។ លោកអភិបាលខេត្ត ក៏បានស្នើភាគីថៃ បន្តជួយរក្សាសុខ សុវត្ថិភាព និងសុខមាលភាពជូនពលរដ្ឋខ្មែរដែលកំពុងស្នាក់នៅក្នុងប្រទេសថៃ។ ពិសេសអ្នកដែលអាចស្នាក់នៅហួសទិដ្ឋាការកំណត់ក្នុងអំឡុងពេលនៃវិបត្តិជាសកលដ៏អាក្រក់នេះ។ លោកអភិបាលខេត្ត ក៏បានស្នើថៃជួយថែរក្សា និងការពាររាល់ទ្រព្យសម្បត្តិ និងកម្មសិទ្ធិឯកជនស្របច្បាប់របស់ប្រជាពលរដ្ឋ អាជីវករ ពាណិជ្ជករ និងពលករខ្មែរដែលកំពុងស្ថិតនៅក្នុងប្រទេសថៃ។ លោកក៏បានស្នើថៃ បន្តទាក់ទងគ្នាជាប់ជាប្រចាំ និងសហប្រតិបត្តិការល្អ ពិសេសជូនព័ត៌មានគ្នាទៅវិញទៅមកពេលមានការវិវត្តប្រែប្រួលនានាឲ្យបានទាន់ពេលវេលា។ លោក ប៉ែន កុសល្យ បានលើកឡើងផងដែរថា ក្នុងអំឡុងពេលស្ថានភាពដ៏លំបាកនៃការប្រយុទ្ធប្រឆាំងមេរោគកូវីដ១៩នេះ អាចនឹងមានប្រជាពលរដ្ឋ និងពលករខ្មែរមួយចំនួនក្តាប់មិនបានពីគោលការណ៍ និងវិធានការសន្តិសុខរបស់រាជរដ្ឋាភិបាលថៃ។ លោកបានស្នើថា ប្រសិនបើកើតមានករណីនេះសូមអាជ្ញាធរថៃមានការយោគយល់ និងអធ្យាស្រ័យក្នុងន័យមនុស្សធម៌ខ្ពស់។

សូមបញ្ជាក់ថា នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០នេះ តាមរយៈច្រកព្រំដែនអន្តរជាតិអូរស្មាច់ និងច្រកព្រំដែនអន្តរជាតិដា មានប្រជាពលរដ្ឋខ្មែរចេញមកពីប្រទេសថៃចំនួន ១,២៥០នាក់ នារី ៥៦៦នាក់។ ប្រជាពលរដ្ឋឆ្លងដែននេះ អ្នកនៅខេត្តឧត្តរមានជ័យ ១២០នាក់ ក្រៅពីនោះមានស្រុកកំណើតនៅខេត្តដទៃ។ លោក ប៉ែន កុសល្យ បានឱ្យដឹងថា អ្នកឆ្លងដែន ១,២៥០នាក់នេះ មានមនុស្ស៥នាក់ ត្រូវបានយកសំណាកទៅពិនិត្យរកជំងឺកូវីដ១៩។ មនុស្សទាំង៥នាក់ ដែលបានយកសំណាកទៅពិនិត្យនេះ មានអ្នកខេត្តឧត្តរមានជ័យ១នាក់ បន្ទាយមានជ័យ៣នាក់ និងខេត្តបាត់ដំបង១នាក់។

សូមបញ្ជាក់ដែរថា ដើម្បីទប់ស្កាត់ការចម្លងមេរោគកូវីដ១៩នោះ លោកទេសរដ្ឋមន្ត្រី គន់ គីម ប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តឧត្តរមានជ័យ ក៏បានដឹកនាំក្រុមការងារឈរជើងនៅតាមច្រកព្រំដែន ដើម្បីពិនិត្យសុខភាពរបស់ប្រជាពលរដ្ឋ និងបានណែនាំឱ្យពួកគេដាក់ខ្លួននៅដាច់ដោយឡែករយៈពេល១៤ថ្ងៃ ការពារកុំឱ្យមានការចម្លងមេរោគទៅក្រុមគ្រួសារ និងអ្នកនៅក្នុងភូមិជាមួយគ្នា។ លោកទេសរដ្ឋមន្ត្រី ក៏បាននាំក្រុមបច្ចេកទេសរៀបចំថ្នាំបាញ់សម្លាប់មេរោគនៅច្រកព្រំដែនអូរស្មាច់ និងបានចែកម៉ាសដល់ពលរដ្ឋខ្មែរចេញពីថៃផងដែរ៕

## អាជ្ញាធរស្រុក ចុះពិនិត្យទីតាំងចំនួន២កន្លែង គឺនៅក្នុងឃុំព្រៃគ្រី និងឃុំពាមឆ្កោក ក្នុងស្រុកជលគិរី សម្រាប់ពលករចំណាក់ស្រុក មកពីក្រៅប្រទេសស្នាក់នៅ

https://gdlf-kh.com/ Sam Sophearum កំពង់ឆ្នាំង 2020/04/07

ខេត្តកំពង់ឆ្នាំង ៖ រសៀលថ្ងៃអង្គារ ១៥កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹង ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២០ លោក ហៃ មនោរម្យ អភិបាលស្រុក និងក្រុមការងារថ្នាក់ស្រុក បានចុះពិនិត្យទីតាំងចំនួន២កន្លែង គឺនៅក្នុងឃុំព្រៃគ្រី និងឃុំពាមឆ្កោក ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង សម្រាប់ពលករចំណាក់ស្រុក មកពីក្រៅប្រទេស អោយគាត់ស្នាក់នៅដាច់ដោយឡែករយៈ១៤ថ្ងៃសិន។ លោកអភិបាលស្រុក បានមានប្រសាសន៍ៈ ណែនាំបន្ថែមអំពីការទប់ស្កាត់មេរោគកូរ៉ូណា យ៉ាងម៉ឺងម៉ាត់ តាមការណែរបស់ក្រសួងសុខាភិបាល ដល់ក្រុមការងារអាជ្ញាធរភូមិ ឃុំ និងលោកគ្រូអ្នកគ្រូពេទ្យ អោយយកចិត្តទុកដាក់ខ្ពស់ចំពោះការត្រួតពិនិត្យ និងតាមដានសុខភាពរបស់ពលករដែលបានត្រឡប់ចូលមកស្រុកកំណើតវិញ ៕

## កិច្ចប្រជុំសម្រាប់គោលដៅ ត្រៀមសម្រាប់ទទួលបងប្អូន ប្រជាពលរដ្ឋខ្មែរ ដែលត្រឡប់ពីប្រទេសថៃមកខេត្តព្រៃវែង

https://gdlf-kh.com/ Kim Sopha ព្រៃវែង 2020/04/07

ព្រៃវែង ៖ ដោយមានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីអាជ្ញាធរខេត្តដែលមាន ឯកឧត្តម ជា សុមេធី អភិបាលខេត្ត បានដឹកនាំកិច្ចប្រជុំសម្រាប់ដាក់គោលដៅ ដល់ក្រុមការងារគណៈកម្មការប្រយុទ្ធប្រឆាំង Covid 19 សម្រាប់ត្រៀម ទទួលបងប្អូនប្រជាពលរដ្ឋខ្មែរ ដែលគាត់ទៅប្រទេសថៃ និងបានវិលត្រឡប់មកខេត្តព្រៃវែងវិញ តាមខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តប៉ៃលិន។ ដែលកិច្ចប្រជុំនេះនៅព្រឹកថ្ងៃទី៧ ខែមេសា ឆ្នាំ ២០២០ នៅសាលប្រជុំសាលាខេត្ត។ នៅក្នុងកិច្ចប្រជុំនោះផងដែរក៏បានសម្រេចបែងចែកចេញជា ៣ ក្រុម ដែលក្នុងមួយក្រុមៗ មានគ្នា ៨ នាក់ ដោយបែងចែកទៅតាមគោលដៅនៃខេត្តនីមួយៗរៀងៗខ្លួន ដើម្បីចាំទទួលដឹកជញ្ជូនបងប្អូនប្រជាពលរដ្ឋខ្មែរ ដែលគាត់ទៅប្រទេសថៃ ហើយវិលត្រឡប់មកខេត្តព្រៃវែង។ នៅក្នុងនោះដែរ ឯកឧត្តម ជា សុមេធី អភិបាលខេត្តក៏បានឲ្យក្រុមការងារសម្រាប់គោលដៅ ដែលប្រចាំការទទួល និងដឹកជញ្ជូនប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃមកខេត្តព្រៃវែង នោះត្រូវមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

-ត្រូវធ្វើទំនាក់ទំនង និងចូលរួមជាមួយរដ្ឋបាលខេត្តជាប់ព្រំដែនជាមួយប្រទេសថៃ ដើម្បីជួយឧបត្ថម្ភដោះស្រាយ ដល់ការដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរដែលមានលំនៅដ្ឋានក្នុងខេត្តព្រៃវែង ពីព្រំដែនមកកាន់លំនៅឋានរបស់ពួកគាត់។

–ត្រូវចាត់ចែងមធ្យោបាយសមស្រប ដើម្បីដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរ ពីព្រំដែនមកកាន់លំនៅឋានរបស់ពួកគាត់ រួមទាំងជួយឧបត្ថម្ភនូវម្ហូបអាហារ ទឹក សម្ភារៈ និងថ្នាំពេទ្យ។

-ក្នុងការដឹកជញ្ជូនបងប្អូនប្រជាពលរដ្ឋខ្មែរនេះ ត្រូវយកចិត្តទុកដាក់ អំពីសុវត្ថិភាព សុខភាព និងទ្រព្យសម្បត្តិរបស់ពួកគាត់ ព្រមទាំងត្រូវរក្សាឲ្យបាននូវសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ។

–ត្រូវរាយការណ៍ជាប្រចាំអំពីដំណើរការនៃការទទួល និងដឹកជញ្ជូនបងប្អូនប្រជាពលរដ្ឋខ្មែរ ដែលវិលត្រឡប់ពីប្រទេសថៃ ជូនថ្នាក់ដឹកនាំខេត្ត និងក្រសួងមហាផ្ទៃ ។

-អនុវត្តកិច្ចការផ្សេងទៀត តាមការចាំបាច់។

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧៥១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration-GDI 07-04-2020

នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៤និង៣០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧៥១នាក់ ស្រី ២៧១នាក់៕

## ពលរដ្ឋខ្មែរ ចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន មានចំនួន ១៥នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration-GDI 07-04-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រំ នាថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០ នៅតែបន្តបិទច្រក មិនអនុញ្ញាតឲ្យអ្នកដំណើរ មធ្យោបាយ និងទំនិញ ចូល-ចេញ ឆ្លងកាត់ច្រកទ្វារនេះបានឡើយ។ ដោយឡែកមានពលរដ្ឋខ្មែរ ចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន មានចំនួន ១៥នាក់ ស្រី ០៧នាក់ ក្មេងចំនួន ០៤នាក់ បន្ទាប់មកក្រុមចត្តាឡីស័ក វាស់កំដៅពុំមានសញ្ញា អ្វីគួរឲ្យកត់សំគាល់ ព្រមទាំងបានធ្វើការអប់រំ ណែនាំដល់ពួកគាត់ ពីវិធីបង្ការ ទប់ស្កាត់ ក្នុងការចម្លងមេរោគកូវីដ១៩ រួចក៏ឲ្យប្រជាពលរដ្ឋទាំងនោះ វិលទ្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន៕

## ទោះថៃបិទច្រកព្រំដែន ក៏នៅតែហូរចូលពលករខ្មែរ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០២០ ម៉ោង ១០:០៧ ប៊ុន ធឿន

ខេត្តបន្ទាយមានជ័យ ៖ ក្រោយពេលដែលភាគីថៃបិទច្រកព្រំដែនមែន ប៉ុន្តែភាគីថៃនៅតែបន្តដឹកបញ្ជូនពលករខ្មែរឱ្យមកប្រទេសវិញតាមច្រកអូរបីជាន់ដែលក្នុង១ថ្ងៃជិត២០០នាក់ ហើយត្រូវបានមន្ត្រីខ្មែរឱ្យធ្វើការត្រួតពិនិត្យមើលសុខភាពការពារទប់ស្កាត់វីរុសកូវីដ១៩ ក្រែងលោ វាមកតាមខ្លួនពលករខ្មែរ ។

គួររំលឹកថា ក្រោយពេលដែលរាជរដ្ឋាភិបាលថៃ បានបិទច្រកទ្វារព្រំដែនកម្ពុជា-ថៃ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០កន្លងទៅ ដើម្បីការពារទប់ស្កាត់ការឆ្លងវីរុសកូវីដ១៩ តែអាចអនុញ្ញាតឱ្យរថយន្តដឹកទំនិញថៃចេញចូលប៉ុណ្ណោះ ទោះបីជាបែបណា គេនៅតែឃើញមានពលករខ្មែរ បានធ្វើដំណើរមកដល់ព្រំដែន ក្នុង១ថ្ងៃមិនតិចជាង ១០០នាក់នោះទេ អាចលើស២០០នាក់ក៏មាន ដែលធ្វើដំណើរមកស្រុកកំណើតតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ដើម្បីមកចូលរួមបុណ្យចូលឆ្នាំ ។

ទោះជាបែបនេះក្តី កាលពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ ប្រតិភូខេត្តបន្ទាយមានជ័យ បានជួបប្រជុំគ្នាជាមួយភាគីថៃ នៅស្នាក់ការគយនិងរដ្ឋាករច្រកខ្លងលឹកប្រទេសថៃ ដោយអភិបាលខេត្តបន្ទាយមានជ័យ ឯកឧត្តម អ៊ុំ រាត្រី បានស្នើសុំទៅភាគីថៃ២ចំណុច គឺចំណុចទី១-ជួយសម្របសម្រួលដល់ប្រជាពលរដ្ឋកម្ពុជា ដែលភាគីថៃចាប់បញ្ជូនមកវិញ ក្នុងសហប្រតិបត្តិការគ្នាល្អទប់ស្កាត់វីរុសកូវីដ១៩ សុំឱ្យយកទៅដាក់នៅច្រកតំបន់បឹងត្រកួន ក្នុងស្រុកថ្មពួក ឬដាក់នៅច្រកតំបន់ម៉ាឡៃស្រុកម៉ាឡៃ ដើម្បីងាយស្រួលធ្វើការពិនិត្យសុខភាពដោយមន្ត្រីជំនាញ ។ និងចំណុចទី២-សុំឱ្យភាគីថៃសម្រួលការដឹកកសិផលរបស់ប្រជាពលរដ្ឋជាប់ជាយដែនដូចច្រកព្រំដែនបឹងត្រកួនស្រុកថ្មពួករឺដាក់នៅច្រកព្រំដែនម៉ាឡៃ ស្រុកម៉ាឡៃ។ ជាការឆ្លើយតបរបស់ភាគីថៃឃើញថា កំណត់យកច្រកអូរបីជាន់ស្រុកអូរជ្រៅជាច្រកចូលពលករខ្មែរចាប់ពីថ្ងៃទី២ ខែមេសា ឆ្នាំ២០២០ រហូតមករយៈពេលជិត១សប្តាហ៍នេះក្នុង១ថ្ងៃភាគីថៃដឹកជញ្ជូនពលករខ្មែរប្រមាណជិត២០០នាក់ ចូលតាមច្រកអូរបីជាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅស្រុកគោកធ្លុង។ ការហូរចូលរបស់ពលករត្រូវបានមន្ត្រីជំនាញធ្វើការពិនិត្យដឹកជញ្ជូនទៅមណ្ឌលសំចតក្រុងប៉ោយប៉ែត ដោយបានការយកចិត្តទុកដាក់ណែនាំពីឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ និងលោកឧត្តមសេនីយ៍ទោ ឈុន ម៉ៅ មេបញ្ជាការរងយោធភូមិភាគទី៥ និងជាមេបញ្ជាការទីសទី១បន្ទាយមានជ័យ ដើម្បីពិនិត្យសុខភាពគ្រប់គ្នាមិនឱ្យរបូតទេ ៕

# ពលករខ្មែរមកពីថៃ ខ្លះដាក់ខ្លួននៅដោយឡែក ខ្លះមិនចេញពីផ្ទះ ដើម្បីសុវត្ថិភាពគ្រួសារនិងអ្នកភូមិ

https://thmeythmey.com/ 08, Apr 2020 , 11:38 am ដោយ: ប៉ូ សាគុន

ភ្នំពេញ៖ ពលករខ្មែរមួយចំនួនដែលមកពីប្រទេសថៃ បានរស់នៅដាច់ដោយឡែកពីគ្រួសារ ពីសាច់ញាតិជិតឆ្ងាយ និងពីញាតិក្នុងភូមិផងដែរ បើទោះបីជាពួកគេ មិនមានរោគសញ្ញានៃជំងឺកូវីដ១៩ក្តី។ ការធ្វើបែបនេះ ក៏ធ្វើឱ្យពួកគេហាក់មានអារម្មណ៍ឯកាបន្តិចដែរ។ តែទោះជាយ៉ាងណា ដើម្បីសុវត្ថិភា ពនិងសេចក្តីសុខយូរអង្វែង ពលករទាំងនោះ សុខចិត្តសម្របខ្លួនក្នុងស្ថានភាពលំបាក នៅក្នុងរយៈពេលខ្លី។ សារព័ត៌មានថ្មីៗបានសម្ភាសន៍ពលករមួយចំនួន ដែលត្រឡប់ពីប្រទេសថៃមកកម្ពុជាវិញ ក្នុងអំឡុងពេលមានការរីករាលដាលនៃជំងឺកូវីដ-១៩។ ពលករទាំងនោះ បានប្រាប់ពីស្ថានភាពរស់នៅ ក៏ដូចជាអារម្មណ៍របស់ខ្លួន នៅពេលដែលពួកគេដាក់ខ្លួននៅដោយឡែកពីសមាជិកគ្រួសារ និងអ្នកភូមិដើម្បីចូលរួមការពារការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលពិភពលោកកំពុងតែព្រួយបារម្ភនេះ។

ជាពលករទៅធ្វើការនៅប្រទេសថៃ អស់រយៈពេលជិត៧ឆ្នាំ លោក ប៉ក់ សំណាង ដែលមានអាយុ៣៣ឆ្នាំ បានសម្រេចចិត្តត្រឡប់មកប្រទេសកំណើតវិញ ដើម្បីមើលថែប្រពន្ធដែលមានកូនខ្ចី។ លោក សំណាង បានមកដល់ស្រុកកំណើតនៅខេត្តតាកែវ ក្នុងអំឡុងថ្ងៃទី១០ ខែមីនា ប៉ុន្តែរហូតមកដល់ពេលនេះ លោកនៅមិនទាន់ហ៊ានស្និទ្ធស្នាលជាមួយគ្រួសារឡើយ។ ខុសពីសព្វមួយដងការត្រឡប់ចូលស្រុកលើកនេះ លោក ប៉ក់ សំណាង ហាក់មានអារម្មណ៍កណ្តោចកណ្តែង ព្រោះមិនមានញាតិមិត្តជិតឆ្ងាយ ឬមិត្តភ័ក្តិ អាចមកសួរសុខទុក្ខដូចគ្រាមុននោះ។ «ខ្ញុំមកស្រុកលើកនេះ មិនមានការជួបជុំមិត្តភ័ក្តិដូចពីមុនឡើយ ព្រោះអ្នកភូមិគេខ្លាច គេមិនមកជិតទេ។ ពីមុនពេលខ្ញុំមក គេដើរទៅមកឃើញគេសួរ ហើយមិត្តភ័ក្តិគេមកជួបជុំហូបស្រា តែម្តងនេះ មិនមានមកក្បែរទេ។ មានអារម្មណ៍អន់ចិត្តដែរ តែបន្ទោសគេក៏មិនកើត ធម្មតា ទាំងគេទាំងយើង គឺខ្លាចដូចតែគ្នា។ តាំងពីខ្ញុំមក ខ្ញុំមិនទាន់បានកាន់ ឬពរកូនបន្តិចទេ»។ បើទោះបីជាក្រសួងសុខាភិបាល បានណែនាំឱ្យពលករដាក់ខ្លួននៅដាច់ដោយឡែក ឱ្យបាន១៤ថ្ងៃក៏ពិតមែន តែលោក សំណាង អះអាងថា លោកនឹងនៅតែដាក់ខ្លួននៅតែឯងឱ្យបានយូរជាងនេះ ដើម្បីឱ្យប្រាកដថា លោកមិនបានចម្លងជំងឺ ដល់អ្នកជាទីស្រឡាញ់ដោយអចេតនា បើទោះបីជាពេលនេះ លោកមិនមានសញ្ញានៃជំងឺនោះក្តី។ បុរសកូន២ ដែលធ្លាប់ទៅធ្វើការនៅខេត្តឈុនបុរី ប្រទេសថៃរូបនេះ ប្រាប់ពីស្ថានភាពរស់នៅរបស់ខ្លួនក្នុងអំឡុងពេលដាក់ខ្លួននៅដោយឡែកដូច្នេះ។ «ខ្ញុំមកនៅផ្ទះមួយតែឯងនៅក្រៅភូមិ។ ប្រពន្ធរបស់ខ្ញុំ នៅផ្ទះជាមួយម៉ែនៅក្នុងភូមិ។ ខ្ញុំដាំបានហូបដោយខ្លួនឯង ម្ហូបជួនកាលកូនដាក់ថង់យកមកឱ្យ ហើយពេលដែលខ្ញុំត្រូវការអ្វីខ្ញុំប្រាប់ទៅ គាត់យកមកឱ្យ»។

ចំណែកអ្នកស្រី ឡិន ជឿន ដែលចំណាកស្រុកទៅធ្វើការក្នុងប្រទេសថៃ ទើបតែបាន៣ខែនោះ ក៏បានមកដល់ប្រទេសកម្ពុជា ក្នុងអំឡុងថ្ងៃទី១០ មីនាដែរ។ មានអាយុ៤៨ឆ្នាំ អ្នកស្រី ជឿន មិនបានដាក់ខ្លួននៅដោយឡែកពីគ្រួសារឡើយ ដោយអ្នកស្រីអះអាងថា ខ្លួនបានពិនិត្យជាញឹកញាប់ ក្នុងការរកជំងឺកូវីដ-១៩ តែមិនមានរោគសញ្ញាអាក្រក់នោះ។ អ្នកស្រីបញ្ជាក់ដូច្នេះ៖«ខ្ញុំមិនបានដាក់ខ្លួននៅដោយឡែកពីគ្រួសារទេ ព្រោះពេលខ្ញុំធ្វើការនៅក្នុងប្រទេសថៃ ពេលចូលធ្វើការគេពិនិត្យ ពេលចេញពីធ្វើការគេពិនិត្យ។ ពេលខ្ញុំចេញមកស្រុកគេពិនិត្យឱ្យទៀត ហើយពេលមកដល់ទល់ដែន ក៏គេពិនិត្យឱ្យ។ បើពិនិត្យឃើញមានរោគ ក៏ខ្ញុំមិនមកនៅជាមួយគ្រួសារដែរ តែពិនិត្យមិនឃើញ ទើបខ្ញុំហ៊ានមកនៅជួបជុំជាមួយកូន»។ បើទោះបីជាអ្នកស្រី ជឿន ពិនិត្យមិនឃើញសញ្ញាវិជ្ជមាននៃកូវីដ-១៩ក្តី ក៏ស្ត្រីសម្តីរដឺនដែលជាអ្នកស្រុកលើរូបនេះ មិនចេញក្រៅផ្ទះ ជួបជុំជាមួយអ្នកភូមិតាមទម្លាប់ចាស់ដែរ ហើយអ្នកស្រីពន្យល់ដូច្នេះ។ «ខ្ញុំមកបាន១៥ថ្ងៃហើយ។ ពិនិត្យតែរឿយៗ ពេទ្យគេមកពិនិត្យក្នុងភូមិ ៤ទៅ៥ថ្ងៃគេមកពិនិត្យម្តង។ ពិនិត្យទាំងតូចទាំងធំ អ្នកមកពីថៃ គេពិនិត្យទាំងអស់គ្នា។ គេគ្រាន់តែវាស់កំដៅ។ ខ្ញុំនៅធ្វើការ នៅក្នុងផ្ទះ

រាល់ថ្ងៃ ខ្ញុំមិនសូវហ៊ានដើរផ្ទះគេទេ គឺនៅតែក្នុងផ្ទះខ្លួនឯង។ ខ្ញុំទៅធ្វើការនៅថៃ បានប្រាក់បន្តិចបន្តួច ក៏ទម្លាក់ឱ្យយាយឱ្យតាចាយខ្លះផង ព្រោះគ្រួសាររបស់ខ្ញុំមានសមាជិកច្រើនណាស់»។

រីឯអ្នកស្រី សារឿន ស្រីយ៉ាំ អាយុ៣៦ឆ្នាំ ដែលមានកូន៣នាក់ បានទៅធ្វើការនៅក្នុងប្រទេសថៃ ផ្នែកលក់ម្ហូបអាហារ ឯទីក្រុងបាងកក។ ទើបតែធ្វើការបាន៩ខែ អ្នកស្រីក៏ត្រូវត្រឡប់មកស្រុកកំណើតវិញ ព្រោះហេតុផលដូចគ្នាគឺកូវីដ-១៩។ ក្រោយពីពិនិត្យមិនឃើញពាគសញ្ញាអ្នកស្រី សារឿន ស្រីយ៉ាំ ដែលរស់នៅខេត្តឧត្តរមានជ័យ បានត្រឹមដាក់ខ្លួននៅដាច់ដោយឡែកពីអ្នកភូមិប៉ុណ្ណោះ។ «ខ្ញុំមកដល់ជាយដែន មានគេនៅចាំពិនិត្យនៅទល់ដែន ហើយពេលមកដល់ផ្ទះខ្ញុំទៅពិនិត្យបាន២ដង។ មេភូមិប្រាប់ថាបើសិនជាមានអ្នកដែលមកក្រោយខ្ញុំ ត្រូវទុកពួកគាត់នៅតាមសាលារៀន ដែលកូនសិស្សឈប់សម្រាករៀន ដើម្បីឱ្យនៅដោយឡែកសិន។ ប៉ុន្តែនៅក្នុងជំនាន់ដែលមកជាមួយខ្ញុំ មិនបាច់ដាក់ដោយឡែកទេ»។

លោក ម៉ុន ហៃ ដែលជាមេភូមិក្រសាំង សង្កាត់បុស្សូវ ក្រុងសំរោង ខេត្តឧត្តរមានជ័យ បានបញ្ជាក់ប្រាប់សារព័ត៌មានថ្មីៗថា ពលករដែលមកពីធ្វើការនៅប្រទេសថៃ ប្រសិនបើមិនមានអាការសង្ស័យណាមួយទេនោះ គឺត្រូវបានអនុញ្ញាតឱ្យនៅជាមួយគ្រួសារ។ «គេដាក់នៅតាមផ្ទះរបស់គាត់ លុះត្រាណាតែមានអាការមិនស្រួលខ្លួន ទើបបានគេយកទៅពេទ្យ។ អ្នកមកពីថៃនៅភូមិរបស់ខ្ញុំ ប្រហែលជាចូលជិត៣០នាក់។ អ្នកខ្លះគាត់មកពីថ្ងៃទី១៦ នោះគឺគម្រប់១៤ថ្ងៃហើយ។ ដូច្នេះវាផុតហើយ។ ហើយអ្នកមកនៅថ្ងៃទី២០ គឺមិនមានគ្រុនរងាអ្វីទេ។ ប៉ុន្តែប្រសិនបើមានឈឺក្រសួងសុខាភិបាលខេត្តក្រុង ឬមណ្ឌលសុខភាព គាត់ឱ្យយើងតាមដានជាប់ ហើយត្រូវចាក់មេក្រូប្រចាំ ដើម្បីផ្សព្វផ្សាយឱ្យគាត់យល់»។ ក៏មានស្រុកកំណើត នៅខេត្តឧត្តរមានជ័យដែរ អ្នកស្រី ឡិន ជឿន អះអាងថា អ្នកស្រីនឹងត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញ នៅពេលដែលជំងឺឆ្លងនេះ ផុតរលត់ទៅ។ «បើជំងឺសះស្បើយពេលណា ក៏គេឱ្យខ្ញុំត្រឡប់ទៅវិញ។ គេឱ្យលេខទូរសព្ទមក ដើម្បីឱ្យហៅទៅរក ហើយខ្ញុំក៏ឱ្យលេខទូរសព្ទរបស់ខ្ញុំ ទៅគេវិញដែរ»៕

## ទូតកម្ពុជា ប្រចាំម៉ាឡេស៊ី អំពាវនាវឲ្យ ពលករ នៅម៉ាឡេស៊ី កុំព្យាយាមរកមធ្យោបាយ ត្រឡប់មកកម្ពុជាវិញ ក្នុងអំឡុង កូវីដ-១៩ កំពុងរីករាលដាល

https://dap-news.com/national/ BySS107 Posted on April 7, 2020

ភ្នំពេញ ៖ ស្ថានឯកអគ្គរាជទូតនៃកម្ពុជា ប្រចាំម៉ាឡេស៊ី បានអំពាវនាវជាថ្មីម្តងទៀតទៅដល់ ប្រជាពលរដ្ឋ ពលករ-ពលការិនី សិស្ស-និស្សិត កំពុងស្នាក់នៅ ធ្វើការ និងសិក្សា នៅ ម៉ាឡេស៊ី កុំព្យាយាមរកមធ្យោបាយ វិលត្រឡប់ទៅកម្ពុជាវិញ ក្នុងអំឡុងពេល ជំងឺកូវីដ-១៩ កំពុងរីករាលដាល ដើម្បីការពារសុវត្ថិភាពផ្ទាល់ខ្លួន។ ទូតកម្ពុជាប្រចាំម៉ាឡេស៊ី អំពាវនាវបែបនេះក្រោយ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃកម្ពុជា បានមានប្រសាសន៍ក្នុងសន្និសីទសារព័ត៌មាន នាថ្ងៃទី៧ ខែមេសា ឆ្នាំ២០២០ នៅ វិមានសន្តិភាព ថា សំណូមពរ ដល់ប្រជាពលរដ្ឋខ្មែរនៅម៉ាឡេស៊ី ដែលរស់នៅកន្លែងណា ត្រូវរស់នៅកន្លែងនោះជាធម្មតាសិន កុំមានចលនាទៅណាឲ្យសោះ ដើម្បីទប់ស្កាត់ កូវីដ-១៩។

យោងតាមសេចក្តីជូនដំណឹងរបស់ ស្ថានឯកអគ្គរាជទូតនៃកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី នៅថ្ងៃទី៧ មេសានេះ បានឲ្យដឹងថា «សូមអំពាវនាវជាថ្មីម្តងទៀតដល់ ប្រជាពលរដ្ឋ ពលករ-ពលការិនី សិស្ស-និស្សិតកម្ពុជា ដែលកំពុងស្នាក់នៅ ធ្វើការ និងសិក្សា នៅក្នុងប្រទេសម៉ាឡេស៊ី សូមមេត្តាកុំព្យាយាមរកមធ្យោបាយវិលត្រឡប់ទៅកម្ពុជាវិញ ក្នុងអំឡុងពេលនេះ និងសូមមេត្តាអត់ធ្មត់បន្តស្នាក់នៅជាបណ្តោះអាសន្ននៅទីកន្លែងដែល ខ្លួនកំពុងស្នាក់នៅ ដើម្បីសុវត្ថិភាពផ្ទាល់ខ្លួនរបស់បងប្អូន រហូតដល់មានការជូនដំណឹងជាថ្មី ពីស្ថានទូត»។ ស្ថានទូតម៉ាឡេស៊ី បន្តថា ទន្ទឹមនឹងនេះដែរ នៅក្នុងអំឡុងពេលនៃការអនុវត្តបទបញ្ជាត្រួត ពិនិត្យការធ្វើដំណើររបស់រដ្ឋាភិបាលម៉ាឡេស៊ី ដែលកំពុងស្ថិតនៅជាធរមានរហូតដល់ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០ ប្រជាពលរដ្ឋទាំងអស់ ប្រកាន់ខ្ជាប់ការថែរក្សាអនា

ម័យផ្ទាល់ខ្លួនឲ្យបាន ខ្ទប់ខ្លួន ដោយត្រូវលាងដៃនឹងសាប៊ូ ឬទឹកអាល់កុលអនាម័យឲ្យបានញឹកញាប់ សូមពាក់ម៉ាស់ការពារនៅពេលចេញក្រៅ ត្រូវរក្សាគម្លាតសុវត្ថិភាពយ៉ាង ១ម៉ែត្រ ពេលនៅក្នុងចំណោម មនុស្សនៅកន្លែងផ្សារណាធារណៈ និងមិនត្រូវធ្វើដំណើរទៅទីកន្លែងដែលអាជ្ញាធរម៉ាឡេស៊ី បានហាមឃាត់ជាបណ្ដោះអាសន្ន៕

# ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០

## ថ្ងៃនេះពលរដ្ឋខ្មែរមកពីថៃ តាមច្រកព្រំដែនក្នុងខេត្តឧត្តរមានជ័យ ជិត២ពាន់នាក់

http://www.freshnewsasia.com/ 2020-04-08

(ឧត្តរមានជ័យ)៖ អភិបាលខេត្តឧត្តរមានជ័យ លោក ប៉ែន កុសល្យ បានឱ្យដឹងថា នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០នេះ មានប្រជាពលរដ្ឋខ្មែរធ្វើការនៅថៃប្រមាណ ១,៨៥៩នាក់ បាននាំគ្នាសម្រុកចូលមកប្រទេសកម្ពុជាវិញ តាមច្រកព្រំដែនអូរស្មាច់ ក្នុងក្រុងសំរោង និងច្រកជាំ ក្នុងស្រុកអន្លង់វែង។ បើតាមលោក ប៉ែន កុសល្យ នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០នេះ អាជ្ញាធរក្នុងខេត្តសុរិន្ទ របស់ថៃ មិនអនុញ្ញាតឱ្យពលរដ្ឋឆ្លងកាត់ព្រំដែនរវាងខេត្តសុរិន្ទ របស់ថៃ និងខេត្តឧត្តរមានជ័យ របស់កម្ពុជានោះឡើយ ដើម្បីអនុវត្តន៍តាមវិធានការរបស់រាជរដ្ឋាភិបាលថៃ ទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩។ តែដោយឃើញពលរដ្ឋខ្មែរមកកកកុញនៅតាមព្រំដែន លោក ប៉ែន កុសល្យ ក៏បានទាក់ទងអភិបាលខេត្តសុរិន្ទ ដើម្បីសម្រួលបើកច្រកព្រំដែន ឱ្យពលរដ្ឋខ្មែរទាំងនេះបានចូលមកប្រទេសកម្ពុជា។ ប្រជាពលរដ្ឋដែលសម្រុកចូលតាមច្រកព្រំដែនទាំងពីរនៅក្នុងខេត្តឧត្តរមានជ័យ មិនមែនមានតែពលរដ្ឋរស់នៅក្នុងខេត្តឧត្តរមានជ័យនោះឡើយ គឺមានមកពីតាមបណ្ដាខេត្តផ្សេងៗទៀតផងដែរ។ ដោយយោងតាមព័ត៌មានពីខាងអភិបាលខេត្តសុរិន្ទនោះ លោក ប៉ែន កុសល្យ បានឱ្យដឹងថា ការដែលប្រជាពលរដ្ឋខ្មែរធ្វើការនៅថៃ មកសម្រុកឆ្លងព្រំដែននៅក្នុងខេត្តឧត្តរមានជ័យនេះ ដោយសារព្រំដែននៅតាមខេត្តដទៃនៃប្រទេសទាំងពីរ គឺមិនអនុញ្ញាតឱ្យចូលមកប្រទេសកម្ពុជានោះឡើយ។

ទន្ទឹមនឹងការសម្រុកចេញចូលរបស់ប្រជាពលរដ្ឋមកពីប្រទេសថៃនេះ លោកទេសរដ្ឋមន្ត្រី គន់ គីម ប្រធានក្រុមការងារចុះជួយខេត្តឧត្តរមានជ័យ និង លោក ប៉ែន កុសល្យ អភិបាលខេត្ត ក៏បានរៀបចំក្រុមគ្រូពេទ្យប្រចាំការនៅច្រកព្រំដែន ដើម្បីពិនិត្យសុខភាពរបស់ប្រជាពលរដ្ឋឆ្លងព្រំដែនមកពីថៃ ហើយបានរៀបចំប្រព័ន្ធបាញ់ថ្នាំសម្លាប់មេរោគមុនពេលចូលមកដល់ដីកម្ពុជាផងដែរ។ មុននឹងអនុញ្ញាតឱ្យទៅតាមគោលដៅរបស់ពួកគេនោះ ក្រុមគ្រូពេទ្យប្រចាំនៅច្រកព្រំដែន បានពិនិត្យសុខភាព និងណែនាំដល់ពួកគេឱ្យអនុវត្តន៍តាមវិធានទាំងឡាយរបស់ក្រសួងសុខាភិបាល ដើម្បីបង្ការការចម្លង និងឆ្លងជំងឺកូវីដ១៩។ ជាពិសេសបានណែនាំពួកគេឱ្យដាក់ខ្លួននៅដាច់ដោយឡែករយៈពេល១៤ថ្ងៃពេលទៅដល់ផ្ទះ ដើម្បីបញ្ចៀសការចម្លងជំងឺកូវីដ១៩ ទៅក្រុមគ្រួសារក្នុងករណីពួកគេមានជំងឺនោះ។

សូមបញ្ជាក់ផងដែរថា ក្នុងចំណោមប្រជាពលរដ្ឋឆ្លងដែនជិតពីរពាន់នាក់នេះ មានប្រជាពលរដ្ឋពីរនាក់ដែលជាអ្នករស់នៅក្នុងស្រុកត្រពាំងប្រាសាទ និងអន្លង់វែង ខេត្តឧត្តរមានជ័យ មានបញ្ហាសុខភាព។ ពួកគេត្រូវបានយកសំណាកផ្សេងៗទៅពិនិត្យរកជំងឺកូវីដ១៩ផងដែរ៕

## អភិបាលខេត្តព្រៃវែង ចុះសួរសុខទុក្ខដល់អ្នកដែលនៅដាច់ដោយឡែក នៅស្រុកកំចាយមារ ស្រុកពោធិ៍រៀង និងស្រុកពាមជរ

http://www.freshnewsasia.com/ 2020-04-08

(ព្រៃវែង)៖ លោក ជា សុមេធី អភិបាលខេត្តព្រៃវែង បាននិងកំពុងខិតខំយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការចុះសួរសុខទុក្ខដល់បងប្អូន ប្រជាពលរដ្ឋដែលកំពុងតែនៅដាច់ដោយឡែក រយៈពេល ១៤ ថ្ងៃ ដែលគាត់បានវិលត្រឡប់មកពីក្រៅប្រទេស មានដូចជាប្រទេសថៃជាដើម។ លោកអភិបាលខេត្ត សូមឲ្យបងប្អូនប្រជាពលរដ្ឋដែលកំពុងស្នាក់នៅដាច់ដោយឡែកនេះ ត្រូវអត់ធ្មត់ និងកុំគិតថា មានការរើសអើងអ្វីឲ្យសោះ ទាំងនេះគឺជាការគិតគូររបស់អាជ្ញាធរ ខេត្ត ស្រុក ក្នុងការទប់ស្កាត់មិនឲ្យមានរីករាលដាលទៅអ្នកដ៏ទៃ។ លោកក៏បានបន្តទៀតថា ចំពោះដាក់ឲ្យនៅដាច់ដោយឡែកនេះគឺមិនមែនចោទថា បងប្អូនមានផ្ទុកនៅជំងឺ Covid19 នេះទេ គឺសូមឲ្យបងប្អូននៅដាចដោយឡែកសិន ដើម្បីឲ្យគ្រូពេទ្យពិនិត្យ តាមដានរយៈពេល១៤ សិន។ ក្នុងនោះលោកសូមផ្តាំផ្ញើដល់ប្រជាពលរដ្ឋដែលកំពុងនៅដាចដោយឡែកនេះ ត្រូវធ្វើអនាម័យខ្លួនប្រាណឲ្យបានជាប្រចាំ ប្រសិនបើមានអាការៈ ដូចជាក្អក ពិបាកដកដង្ហើម ឬបញ្ហាផ្សេងទៀត ត្រូវរាយការណ៍ដល់ក្រុមការងារ ឬក្រុមគ្រូពេទ្យប្រចាំការនៅទីនោះ ដើម្បីព្យាបាលឲ្យបានទាន់ពេលវេលា។

ក្នុងការចុះសួរសុខទុកនោះផងដែរ នៅស្រុកកំចាយមារ មានប្រជាពលរដ្ឋ ស្នាក់នៅដាចដោយឡែក ចំនួន៣២នាក់ និងនៅស្រុកពោធិ៍រៀង ចំនួន២២នាក់ និងនៅស្រុកពាមជរចំនួន ១៧នាក់។

**ក្នុងការចុះជួបសំណេះសំណាលសួរសុខទុក្ខបងប្អូនដែលកំពុងដែលកំពង់នៅដាច់ដោយឡែកនោះផងដែរ លោកមកបានឧបត្ថម្ភសម្ភារដល់ស្រុក សម្រាប់ប្រើប្រាស់ និងប្រតិបត្តិការងាររួមមាន៖**

*ទឹកអាល់កុល ១០L *ម៉ាស់ ៥ ប្រអប់ ស្មើនឹង២៥០បន្ទះ *សាប៊ូ ៣០ដុំ *ទឹកសុទ្ធ ២០ កេស *មីយើង ៣ កេស *អង្ករ ២៥០ គីឡូក្រាម *ថវិកាចំនួន៥០០ដុល្លារ ឧបត្ថមដល់គណៈកម្មការប្រឆាំងជម្ងឺកូវីដ-១៩ ស្រុកពោធិ៍រៀង។ ចំពោះអ្នកនៅដាចដោយឡែកក្នុងម្នាក់ៗ ទទួលបានថវិកា ៥ម៉ឺនរៀល និងគ្រូពេទ្យប្រចាំការ ជំទប់ និងមេប៉ុស្តិ៍ ១ក្រុមៗ ទទួលបានថវិកា ចំនួន ២០ម៉ឺនរៀលនោះផងដែ៕

## រដ្ឋបាលខេត្តស្វាយរៀង បញ្ជូនក្រុមការងារ ទទួលពលករ មកពីប្រទេសថៃ និងត្រៀមធ្វើចត្តាឡីស័ក ចំពោះពលករ ដែលវិលមកដល់ ស្រុកកំណើតវិញ

https://dap-news.com/national/ ByPH104 Posted on April 8, 2020

ស្វាយរៀង ៖ លោក តូច ប៉ូលីវ៉ា អភិបាលរងខេត្តស្វាយរៀង និងជាអនុប្រធានគណៈកម្មការ ប្រយុទ្ធប្រឆាំងនឹងជំងឺCovid-19ខេត្ត និងជាប្រធានក្រុមការងារ ទទួលខុសត្រូវ សម្របសម្រួល ក្នុងការដឹកនាំក្រុមការងារ ទទួលប្រជាពលរដ្ឋ មានទីលំនៅ នៅខេត្តស្វាយរៀង ដែលវិលត្រលប់មកពីប្រទេសថៃ តំណាងលោកអភិបាល ខេត្តស្វាយរៀង បានដឹកនាំកិច្ចប្រជុំពិភាក្សាការងារ ប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ និងការងារទទួលបងប្អូន ប្រជាពលរដ្ឋខ្មែរវិលត្រឡប់មកពីប្រទេសថៃ។ ការដឹកនាំកិច្ចប្រជុំពីលោក តូច ប៉ូលីវ៉ា នេះបានធ្វើឡើង កាលពីរសៀលថ្ងៃទី៧ ខែមេសា ឆ្នាំ២០២០ ដោយមានការចូលរួមពីលោក លោកស្រីអនុប្រធានអចិន្ត្រៃយ៍ អនុប្រធាន សមាជិក សមាជិកាគណៈកម្មការ នៅសាលប្រជុំនន្ទីរ អគារ ខ សាលាខេត្តស្វាយរៀង ។

លោក តូច ប៉ូលីវ៉ា បានថ្លែងថា កិច្ចប្រជុំនេះផ្តោតសំខាន់ទៅលើការធ្វើចត្តាឡីស័កនូវការដាក់ពលករដាច់ដោយឡែក១៤ថ្ងៃដោយស្ម័គ្រចិត្តខ្លួនឯង និងដាច់ដោយឡែកនៅមណ្ឌលចត្តាឡីស័ក នៅថ្នាក់ខេត្ត និងថ្នាក់ក្រុងស្រុក សម្រាប់ប្រជាពលរដ្ឋដែលវិលត្រឡប់មកពីក្រៅប្រទេស។ លោកបានបន្តថា នៅព្រឹកថ្ងៃទី៨ ខែមេសានេះបានចាត់ និងបញ្ជូនក្រុមការងារ បីក្រុមទីសដៅ៤ខេត្ត ដើម្បីទៅទទួលពលករ ដែលវិលត្រលប់មកពីប្រទេសថៃ គឺចាំ

ទទួលនៅខេត្តប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ និងឧត្តរមានជ័យ ហើយការបញ្ជូនក្រុមការងារនេះដែរ គឺបានធ្វើឡើងម្តងរួចមកហើយ តែដោយពលករតិចពេកទើបវិលមកវិញ តែវគ្គនេះគឺពលករមកច្រើន ទើបមានការបញ្ជូនក្រុមការងារ សារជាថ្មី។ លោកបានបន្ថែមទៀតថា ទី១យើងបង្កើតការិយាល័យ ធ្វើចត្តាឡីស័កថ្នាក់ខេត្ត ថ្នាក់ស្រុកក្រុង ដើម្បីពិនិត្យសុខភាពកម្មករ និងកន្លែងដាក់ដាច់ដោយឡែកចំនួន១៤ថ្ងៃ ពលរដ្ឋដែលមកពីក្រៅប្រទេស ទី២រៀបចំក្រុមការងារ ដឹកជញ្ជូនពលករបន្ថែមទៀត នៅទីសខេត្តដែលជាប់និងទល់ដែនថៃ ។ ដែលផែនការទាំងអស់នេះ គឺដើម្បីបង្ការទប់ស្កាត់ នៅពេលមានករណីគំហុគកម្មករ ឆ្លងដែនចូលមកស្រុកវិញ ច្រើនរួមទាំងវិធានការតាមវត្តអារាម ក្នុងពេលជិតចូលឆ្នាំមិនឲ្យមានការជួបជុំគ្នា និងណែនាំពួកគាត់ឲ្យ ធ្វើអានាម័យជាប្រចាំ ។ ហើយអាជ្ញាធរថ្នាក់ខេត្ត ថ្នាក់ស្រុក ក្រុងគឺបានត្រៀម គ្រប់មធ្យោបាយទាំងអស់ គឺដើម្បីអន្តរគមន៍ឲ្យ បានទាន់ពេលវេលារាល់មានករណីពលរដ្ឋណាម្នាក់ មានផ្ទុកជំងឺកូវីដ១៩នេះ ដោយយើងមានកន្លែងដាក់ នៅដាច់ដោយឡែក ក្នុងការព្យាបាលអ្នកជំងឺផងដែរ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៣០នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration-GDI 08-04-2020

នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៤និង៣០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៣០នាក់ ស្រី ២១០នាក់៕

## ពលរដ្ឋខ្មែរ ចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន មានចំនួន ១៧នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration-GDI 08-04-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រំ នាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ នៅតែបន្តបិទច្រក មិនអនុញ្ញាតឲ្យអ្នកដំណើរ មធ្យោបាយ និងទំនិញ ចូល-ចេញ ឆ្លងកាត់ច្រកទ្វារនេះបានឡើយ។ ដោយឡែកមានពលរដ្ឋខ្មែរ ចូលប្រទេស តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន មានចំនួន ១៧នាក់ ស្រី ០៧នាក់ ក្មេងចំនួន ០៣នាក់ បន្ទាប់មកក្រុមចត្តាឡីស័ក វាស់កំដៅពុំមានសញ្ញា អ្វីគួរឲ្យកត់សំគាល់ ព្រមទាំងបានធ្វើការអប់រំ ណែនាំដល់ពួកគាត់ ពីវិធីបង្ការ ទប់ស្កាត់ ក្នុងការចម្លងមេរោគកូវីដ១៩ រួចក៏ឲ្យប្រជាពលរដ្ឋទាំងនោះ វិលទ្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន៕

## ឃាត់ខ្លួនពលករខ្មែរ ០៩នាក់ បំពានសេចក្តីប្រកាសរបស់រដ្ឋាភិបាលខេត្តស្រះកែវ

https://www.facebook.com/LABOURKHMER/ ពលករ 08-04-2020

យោងតាមរបាយការណ៍ពីខេត្តស្រះកែវប្រទេសថៃ កាលពីថ្ងៃអង្គារទី០៧ ខែមេសា ឆ្នាំ២០២០ ម្សិលមិញនេះបានអោយដឹងថា កម្លាំងសមត្ថកិច្ចចម្រុះថៃ បានធ្វើការរថយន្តឈ្នួលដឹកពលករខ្មែរ ចំនួន ០៩នាក់ និងជនជាតិថៃម្នាក់ មកពីតំបន់មីនបុរី ទីក្រុងបាងកក ប្រទេសថៃ គោលដៅឆ្ពោះដំណើរទៅព្រំដែន ដោយអ្នកបើកបររថយន្តបានបំពានសេចក្តីប្រកាសរបស់រដ្ឋាភិបាលខេត្តស្រះកែវ បានចេញសេចក្តីប្រកាសហាម ចល័តពលករបរទេសចូល

មកក្នុងទឹកដីខេត្តស្រះកែវ តាមមធ្យោបាយធ្វើដំណើរផ្សេងៗ។ បច្ចុប្បន្នសមត្ថកិច្ចថៃបាននាំខ្លួនពលករខ្មែរនិងអ្នកបើកបររថយន្តទៅកាន់អធិការដ្ឋានតម្រួតប៉ុស្តិ៍ខ្លងហាត ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ។ UPDATE:08.04.20

## កម្ពុជា-ថៃ ពិភាក្សាពីការបើកច្រកព្រំដែនបន្ថែមទៀត ដើម្បីបង្កើនការនាំចេញទំនិញ

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 09 April 2020 | 09:18 ICT

**បន្ទាយមានជ័យ:** កម្ពុជា ស្នើឲ្យភាគីថៃ បើកច្រកចេញ-ចូល តាមព្រំដែនបន្ថែមទៀត ដើម្បីទទួលកសិផលរបស់ខ្មែរ ខណៈប្រទេសនេះក៏បានស្នើឲ្យកម្ពុជាទទួលយកទំនិញផ្សេងទៀតបន្ទាប់ពីព្រំដែនមួយចំនួនបានបិទ និងហាមការចេញ-ចូល ដើម្បីទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ១៩។ ការស្នើទៅវិញទៅមកបែបនេះបានធ្វើឡើងកាលពីថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០២០ នៅក្នុងកិច្ចប្រជុំរកដំណោះស្រាយរួមគ្នាដែលដឹកនាំដោយលោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យលោក ពេជ្រ វណ្ណា នាយករងទីចាត់ការការងារព្រំដែន និងភាគីថៃមានលោក វ៉ាផាន់ សុវាណុន អភិបាលខេត្តស្រះកែវរួមទាំងស្ថាប័នពាក់ព័ន្ធរបស់ថៃនាភូមិខ្លងលឹក ស្រុកអរញ្ញជាប់ព្រំប្រទល់ក្រុងប៉ោយប៉ែត។ លោក ពេជ្រ វណ្ណា បានប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញថា បើទោះជាក្នុងអំឡុងពេលនេះថៃប្រកាសបិទព្រំដែន ប៉ុន្តែការចរាចរទំនិញរវាងប្រទេសទាំង ២ គឺនៅតែដំណើរការជាធម្មតាតាមរយៈសកម្មភាពនៃការដោះដូរទំនិញជាលក្ខណៈដឹកតាមរថយន្តប្រភេទធំៗ ខណៈដែលការដឹកទំនិញតូចតាចតាមរយៈរទេះជាដើមនោះគឺត្រូវបានផ្អាក។ លោកបន្តថា ដោយសារតែការដោះដូរទំនិញ និងកសិផលនានាបានធ្វើឡើងនៅតាមច្រកព្រំដែនមួយចំនួនដូចជាអូរស្មាច់ច្រកប៉ោយប៉ែត និងច្រកព្រំដែនដូង ដែលនាំឲ្យប្រជាពលរដ្ឋមួយចំនួនមានការលំបាកក្នុងការដឹកទំនិញ ព្រោះមានចម្ងាយឆ្ងាយពីលំនៅឋានរបស់ពួកគេ។ លោកបន្ថែមថា តាមរយៈនេះយើងស្នើឲ្យភាគីថៃបើកច្រកព្រំដែនបន្ថែមទៀត ដូចជាច្រកអន្តរជាតិភ្នំដី ច្រកម៉ាឡៃ និងច្រកព្រំដែនអូរស្មួត ដើម្បីទទួលទំនិញរបស់ប្រជាពលរដ្ឋកម្ពុជាដែលផ្តោតជាសំខាន់គឺកសិផលដំឡូង។

លោកបញ្ជាក់ថា៖ «កន្លងមកថ្នាក់លើរបស់គាត់ (ថៃ) បានប្រកាសបិទគ្រប់ច្រកទាំងអស់ដោយឡែកច្រកអន្តរជាតិប៉ោយប៉ែត និងច្រកព្រំដែនដែលបើក គឺអាចដឹកទំនិញចេញ-ចូលបានជាធម្មតា។ ច្រកអន្តរជាតិប៉ោយប៉ែតកន្លងទៅ មិនធ្លាប់ដឹកដំឡូងចេញនោះទេ ព្រោះវាមានចម្ងាយឆ្ងាយពីតំបន់ពលរដ្ឋរស់នៅ ហើយច្រកដែលធ្លាប់ចេញ-ចូលនូវដំណាំកសិផលនេះ គឺភាគច្រើននៅច្រកភ្នំដី និងច្រកម៉ាឡៃជាដើម។ សព្វថ្ងៃនេះច្រកអន្តរជាតិដូងនិងឡែម គឺមានការចេញ-ចូលជាធម្មតា ប៉ុន្តែការចេញ-ចូល វាឆ្ងាយពេកទើបពួកគាត់ស្នើឲ្យបើកច្រកផ្សេងទៀតដូចជា សំពៅលូនដែរ»។ លោកបញ្ជាក់ទៀតថា៖ «មុនបិទច្រកព្រំដែនហ្នឹង យើងបានចេញ-ចូលចរាចរណ៍ជាធម្មតាដល់ពេលបិទអ៊ីចឹងទៅក៏មានការកកស្ទះ ដូចជាដំឡូងអីហ្នឹង។ យើងក៏សំណូមពរខាងថៃ ដើម្បីសម្រួលខាងច្រកដែលអាចចេញចូលបាន (បន្ថែមទៀត) ជួយសម្រួលខាងកសិផលដូចជាដំឡូងហ្នឹង។ ប៉ុន្តែសំណើនេះភាគីថៃមិនទាន់មានការសម្រេចយ៉ាងណានោះទេ ខណៈដែលសំណើរបស់ថៃស្នើនាំចូលផលិតផលផ្សេងៗ ដូចជាការនាំចូលជ្រូក (មកកម្ពុជា) នោះក៏កម្ពុជាមិនទាន់សម្រេចដែរ ដោយរង់ចាំការជួបចរចាជាថ្មី»។ លោក ពេជ្រ វណ្ណា ឲ្យដឹងថាចំពោះការនាំកសិផលដំឡូងមីចូលក្នុងប្រទេសថៃតាមសំណើរបស់កម្ពុជាគឺភាគីថៃ នឹងជូនដំណឹងទៅក្រសួងពាណិជ្ជកម្មរបស់ខ្លួនរួចជូនដំណឹងមកកម្ពុជាវិញនៅពេលក្រោយ ខណៈកម្ពុជាក៏មិនទាន់សម្រេចចំពោះសំណើរបស់ភាគីថៃផងដែរ។

លោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យប្រាប់អ្នកសារព័ត៌មានក្រោយបញ្ចប់កិច្ចប្រជុំកាលពីថ្ងៃទី ៧ ខែមេសាថា ក្នុងនោះភាគីថៃបានស្នើសុំសម្របសម្រួលដល់បងប្អូនពលករខ្មែរ ដែលអាជ្ញាធរថៃបញ្ជូនមកកម្ពុជាជាបន្តបន្ទាប់រាល់ថ្ងៃដោយកំណត់យកទីចតសំណាក់មួយ។ លោកបញ្ជាក់ថា ទីសំណាក់សមរម្យនោះមានដូចជា៖ «ច្រកបឹងត្រកួន ច្រកអូរ ៣ ជាន់ ដើម្បីងាយស្រួលពិនិត្យដើម្បីការពារវីរុស COVID-19។ ភាគីថៃបានឯកភាពលើគោល

ការណ៍រួមកំណត់យកទីតាំងអូរ ៣ ជាន់ ស្រុកអូជ្រៅ ជាប់ព្រំប្រទល់ភូមិគោកធ្លុង ប្រទេសថៃ ជាកន្លែងតែមួយគត់សម្រាប់ពលករខ្មែរចូលមកកម្ពុជា ដើម្បីរួមគ្នាទប់ស្កាត់វីរុស COVID-19»។

បើតាមលោក ពេជ្រ វណ្ណា គិតត្រឹមថ្ងៃទី ៧ ខែមេសា ពលករខ្មែរដែលវិលត្រឡប់ពីប្រទេសថៃតាមច្រកព្រំដែនមានជាង ៦ ម៉ឺននាក់ហើយក្នុងនោះ ភាគីថៃនៅតែបន្តបើកឲ្យពលករខ្មែរអាចវិលត្រឡប់មកប្រទេសកម្ពុជាវិញ ខណៈភាគីថៃបានស្នើឲ្យកម្ពុជាពង្រឹងវិធានការបន្ថែមទៀតឲ្យបានតឹងរ៉ឹងក្នុងករណីនេះ។

លោក ស៊ុំ ច័ន្ទគា មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុកខេត្តបន្ទាយមានជ័យរំពឹងថាការចរចានេះនឹងទទួលបានអត្ថប្រយោជន៍ស្មើគ្នារវាងប្រទេសទាំង ២ ខណៈលោកមើលឃើញថាក្នុងរយៈពេលចុងក្រោយនេះបើទោះបីជាមានការបិទព្រំដែនប្រទេសទាំង ២ ក៏នៅតែមានការដោះដូរទំនិញរវាងគ្នាទៅវិញទៅមក ប៉ុន្តែភាគីថៃនៅតែមានប្រៀបជាង។ លោកបន្ថែមថា៖ «សុំឲ្យគិតទាំងអស់គ្នាឡើងវិញ ព្រោះថាការអាចធ្វើឲ្យសេដ្ឋកិច្ចរីកចម្រើនទាំងអស់គ្នាបានគឺការដោះដូរគ្នាបាន ព្រោះបើមិនអាចដោះដូរបានចុះប្រជាពលរដ្ឋបានអីរស់? ថៃនាំទំនិញចូលមកខ្មែរបានច្រើន និងសេរីជាង ឃើញថាការដោះដូរនេះគឺភាគីថៃមានភាពទូលំទូលាយជាង បើខ្មែរយើងពេលនាំចូលមានការរឹតបន្តឹងច្រើន។ ខ្ញុំសូមឲ្យមានការនាំចេញទំនិញរវាងភាគីទាំង ២ មានសមភាព។ គេមិនឲ្យយើងចូល ប៉ុន្តែគេនាំចូលមកយើងបានគិតយ៉ាងណាដែរ?»។ ជាមួយនឹងការមើលឃើញបែបនេះលោក ច័ន្ទគា រំពឹងថារដ្ឋាភិបាលកម្ពុជានឹងព្យាយាមធ្វើយ៉ាងណា ក្នុងអំឡុងពេលនេះឲ្យភាគីថៃអាចផ្តល់សិទ្ធិច្រើនជាងនេះ ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរដែលពឹងអាស្រ័យលើការនាំទំនិញ ឬកសិផលចេញទៅប្រទេសថៃអាចរស់បានដោយគ្មានការភ័យខ្លាច៕

## ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០

## ឧត្តមសេនីយ៍ទោ ហ៊ុល សំអុន ដឹកនាំកម្លាំងកងទ័ព បញ្ជូនរថយន្តដុងហ្វឹង ចំនួន៥០គ្រឿង ដើម្បីដឹកជញ្ជូនបងប្អូនពលករខ្មែរ ត្រឡប់មកពីប្រទេសថៃ

https://dap-news.com/national/ ByVNT108 Posted on April 10, 2020

ភ្នំពេញ៖ ឧត្តមសេនីយ៍ទោ ហ៊ុល សំអុន មេបញ្ជាការកងពលតូច ដឹកជញ្ជូនលេខ៩៩ នៅព្រឹកថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០នេះ បានដឹកនាំកម្លាំងកងទ័ព បញ្ជូនរថយន្តដុងហ្វឹងចំនួន៥០គ្រឿង ដើម្បីដឹកជញ្ជូនបងប្អូនពលករខ្មែរ ដែលត្រឡប់មកពីប្រទេសថៃ ហើយត្រូវដាក់ ឲ្យនៅដាច់ដោយឡែករយៈពេល១៤ថ្ងៃ។ បេសកកម្មនេះ ធ្វើឡើងដោយគោរព តាមប្រសាសន៍បញ្ជាណែនាំ របស់សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តីនៃកម្ពុជា និងថ្នាក់ដឹកនាំក្រសួងការពារជាតិ។ សម្ដេចតេជោ ហ៊ុន សែន នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០២០ បានចេញបញ្ជាណែនាំ ដល់ក្រសួងសុខាភិបាល ត្រូវរៀបចំក្នុងការដោះស្រាយ ជូនបងប្អូនពលករខ្មែរ ដែលបាន វិលត្រឡប់មកពីប្រទេសថៃ ដែលត្រូវដាក់ ឲ្យនៅដាច់ដោយឡែក១៤ថ្ងៃ ចំពោះមធ្យោបាយដឹកជញ្ជូន គឺត្រូវប្រើប្រាស់រថយន្តកងទ័ព មកពីកងពលលេខ៩០ និងកងពលតូចដឹកជញ្ជូនលេខ៩៩៕

## ប្រធានគណៈកម្មការប្រយុទ្ធនឹងជំងឺ COVID-19 ខេត្តប៉ៃលិន ជំរុញឲ្យអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ ត្រូវគ្រប់គ្រងពលករ ដែលទើបបម្លាស់ទីមកស្រុកកំណើត ឲ្យបានច្បាស់លាស់

http://www.freshnewsasia.com/ 2020-04-10

(ប៉ៃលិន)៖ ក្នុងកិច្ចប្រជុំគណៈកម្មការប្រយុទ្ធ នឹងជំងឺ COVID-19 ខេត្ត នាថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ លោក ផាន់ ចាន់ធុល អភិបាលខេត្តប៉ៃលិន បានជំរុញ និងដាក់ចេញនូវវិធានការយ៉ាងម៉ឺងម៉ាត់ ដល់អាជ្ញាធរ មូលដ្ឋាន គ្រប់ជាន់ថ្នាក់ ត្រូវគ្រប់គ្រងពលករ ដែលទើបត្រលប់មកពីក្រៅប្រទេស ឲ្យបានច្បាស់លាស់ ជាពិសេស ត្រូវ

អប់រំ ណែនាំ និងតាមដានសុខភាពរបស់ពួកគាត់ឲ្យបានជាប្រចាំ។ លើសពីនោះទៀត ត្រូវបន្តយុទ្ធនាការចុះផ្សព្វផ្សាយនៅតាមមូលដ្ឋាន ចាប់ពីប្រជុំជន រហូតដល់ជនបទ ខណៈប្រមុខរាជរដ្ឋាភិបាលសម្តេចតេជោ សែន បានចេញសេចក្តីប្រកាស ឲ្យផ្អាកពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣ និងមន្ត្រីរាជការមិនអនុញ្ញាតឱ្យឈប់សម្រាកនោះទេ ដើម្បីរួមគ្នា បង្ការ និងទប់ស្កាត់ ការ រីករាលដាលនៃជំងឺ COVID-19 នៅក្នុងប្រទេសកម្ពុជា ស្របពេលដែលពិភពលោក មានអ្នកកើតជំងឺ និងស្លាប់ ដោយសារវីរុសនេះ រាប់ម៉ឺននាក់។ លោក ផាន់ ចាន់ធុល បានលើកឡើងថា នៅក្នុងប្រទេសកម្ពុជា ត្រូវបានគេរកឃើញមានអ្នកឆ្លងជំងឺ COVID-19 នេះក៏ដោយ ប៉ុន្តែសម្រាប់ខេត្តប៉ៃលិន រហូតមកដល់ពេលនេះ នៅមិនទាន់រកឃើញ មានអ្នកឆ្លងជំងឺនេះនៅឡើយទេ ប៉ុន្តែរយៈពេលកន្លងមកនេះ មានពលករចំណាកស្រុកទាំងក្នុង និងក្រៅប្រទេស បានវិលត្រឡប់ចូលមកកាន់ស្រុកកំណើតវិញ ដោយមិនបានដឹងថា ក្នុងចំណោម មនុស្សទាំងអស់នោះ មានអ្នកផ្ទុកមេរោគ COVID-19 ឬអត់នោះទេ។

លោកថា ដូច្នេះដើម្បីទប់ស្កាត់កុំឲ្យមានការចម្លងជំងឺនេះ ក៏ដូចជាដើម្បីជួយសង្គ្រោះ និងព្យាបាលដល់ជនរងគ្រោះដែលមានផ្ទុកជំងឺនេះ ឲ្យបានទាន់ពេលវេលា គណៈកម្មការប្រយុទ្ធ នឹងជំងឺ COVID-19 ខេត្តប៉ៃលិន បានដាក់ចេញនូវវិធានការយ៉ាងម៉ឺងម៉ាត់ ដើម្បីអនុវត្តន៍តាមការណែនាំរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា និងក្រសួងសុខាភិបាល ដោយទាំងអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ មន្ត្រីជំនាញពាក់ពន្ធ និងកងកម្លាំងប្រដាប់អាវុធទាំងអស់ ត្រូវរួមគ្នា ចុះផ្សព្វផ្សាយនៅតាមភូមិ និងតាមខ្នងផ្ទះ ដើម្បីឲ្យប្រជាពលរដ្ឋបានយល់ដឹង និងចូលរួមបង្ការ និងទប់ស្កាត់ជំងឺ COVID-19 នេះទាំងអស់គ្នា។ លោកប្រធាន បាន បញ្ជាក់ថា ដោយសារការព្រួយបារម្ភជាខ្លាំង ចំពោះជំងឺកូវីត-១៩ ធ្វើឲ្យក្រុមហ៊ុន សហគ្រាស និងកន្លែងការងារមួយចំនួន ត្រូវបានបិទទ្វារ បណ្តាលឲ្យប្រជាពលរដ្ឋមួយចំនួនអត់ការងារធ្វើ ហើយពលរដ្ឋខ្លះ ដែលធ្វើជាពលករនៅក្រៅប្រទេស ត្រូវបង្ខំចិត្តវិលត្រឡប់មកកាន់ស្រុកកំណើត និងលំនៅដ្ឋានវិញ ដូច្នេះធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចក្រុមគ្រួសារ ហើយជាក់ស្តែងកន្លងមក គណៈកម្មការប្រយុទ្ធ នឹងជំងឺ COVID-19 ខេត្ត បាននាំយកអំណោយស្បៀងមកឧបត្ថម្ភ ដល់បងប្អូននៅតាមខ្នងផ្ទះ ចំនួន២ជំហ៊ាន មកហើយ គឺបានចំនួន៥៥១គ្រួសារ ព្រោះមិនអាចធ្វើការប្រមូលផ្តុំមនុស្សច្រើនបាន ហើយនឹងគ្រោង ឧបត្ថម្ភស្បៀងជំហ៊ានទី៣បន្តទៀត ចាប់ពីថ្ងៃទី១៣ ដល់១៦ ខែមេសា ឆ្នាំ២០២០ខាងមុខ។

នៅក្នុងឱកាសនោះដែរ លោក ផាន់ ចាន់ធុល ក៏បានអំពាវនាវឲ្យបងប្អូនប្រជាពលរដ្ឋអនុវត្តន៍ ឲ្យបានម៉ឺងម៉ាត់តាមសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល ដោយពេលចេញទៅខាងក្រៅត្រូវពាក់ម៉ាស់ ឬរុំក្រមាជានិច្ច និងលាងសម្អាតដៃជាប្រចាំ ជាមួយអាល់កុល ឬសាប៊ូ ហើយត្រូវទៅជួបគ្រូពេទ្យជាបន្ទាន់ ប្រសិនបើមានអាការៈគួឲ្យសង្ស័យ ដូចជា៖ ក្តៅខ្លួន ក្អក និងពិបាកដកដង្ហើមជាដើម ហើយក្នុងករណីមានប្រជាពលរដ្ឋណា ដែលទើបត្រឡប់ពីបរទេសត្រូវរាយការណ៍ ទៅអាជ្ញាធរភ្លាមៗ ដើម្បីធ្វើការពិនិត្យជៀសវាងការឆ្លងជំងឺកូវីដ-១៩ នៅក្នុងសហគមយើង។

សូមបញ្ជាក់ថា ចាប់ពីថ្ងៃទី២២ ខែមីនា រហូតដល់ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ នៅខេត្តប៉ៃលិន មានពលករទើបត្រលប់មកពីក្រៅប្រទេសសរុប ចំនួន៩០៧នាក់ ស្រី ៤៣៤នាក់ ដោយក្នុងនោះ ក្រុងប៉ៃលិន ចំនួន ៣៨០នាក់ ស្រី ១៨៧នាក់ និងស្រុកសាលាក្រៅ ចំនួន ៥២៧នាក់ ស្រី ២៤៧នាក់៕

## ពលករខ្មែរមួយចំនួនដែលទើបត្រឡប់ពីថៃត្អូញត្អែរជួបការលំបាកព្រោះគ្មានការងារធ្វើ

https://www.rfa.org/khmer/ ដោយ សេក បណ្ឌិត 2020-04-09

ពលករខ្មែរមួយចំនួន ដែលទើបត្រឡប់មកពីប្រទេសថៃ ចាប់ផ្តើមជួបបញ្ហាសេដ្ឋកិច្ចនៅក្នុងគ្រួសារ ដោយសារនៅក្នុងស្រុកអត់ការងារធ្វើ។ ពលករទាំងនោះព្រួយបារម្ភថា ប្រសិនបើស្ថានការណ៍រាតត្បាតជំងឺកូវីដ១៩ចេះតែអូសបន្លាយយូរទៀតនោះជីវភាពរបស់ពួកគេកាន់តែជុនដាបខ្លាំងជាមិនខាន។ មន្ត្រីសង្គមស៊ីវិលយល់ថា

បញ្ហានេះរដ្ឋាភិបាលគួរតែបញ្ចេញកញ្ចប់ថវិកាជាតិជួយដល់ពលករដើម្បីសម្រាលទុក្ខលំបាករបស់ពួកគាត់។ ពលករម្នាក់មានស្រុកកំណើតនៅស្រុកបារាយ ខេត្តកំពង់ធំ លោក ជា ខន ប្រាប់អាស៊ីសេរីថា លោកត្រឡប់មកពីប្រទេសថៃកាលពីថ្ងៃទី៥ មីនា តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ។ បុរសវ័យ៣៦ឆ្នាំរូបនេះបន្តថា មូលហេតុដែលលោកសម្រេចចិត្តត្រឡប់មកស្រុកកំណើតអំឡុងពេលនេះ ដោយសារថៅកែបានផ្អាកការងារដោយពុំមានថ្ងៃកំណត់ ដើម្បីការពារខ្លាចឆ្លងជំងឺកូវីដ១៩ តាមសេចក្តីប្រកាសរបស់រដ្ឋាភិបាលថៃ។ ពលករធ្វើការផ្នែកដឹកជញ្ជូនត្រីនៅលើទូកនេសាទថៃរូបនេះបន្តថា ចាប់តាំងពីថៅកែផ្អាកការងារមក គឺលោកពុំមានប្រាក់ចំណូលដោះស្រាយជីវភាពគ្រួសារនោះទេ ហើយសព្វថ្ងៃនេះលោកនៅផ្ទះជាមួយក្រុមគ្រួសារនៅស្រុកកំណើត ដោយពុំបានការងារធ្វើអ្វីឡើយ។ លោកបន្តថា ថវិកាដែលលោកធ្វើការងារនៅប្រទេសថៃកន្លងទៅនោះ មួយចំនួនត្រូវបង់រំលោះធនាគារនិងមួយចំនួនទៀតលោកផ្ញើឱ្យប្រពន្ធ និងឪពុកម្តាយចាយវាយដូច្នេះនៅពេលនេះលោកមិនមានប្រាក់សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃនោះទេ៖ «ថ្ងៃខ្លះក៏ចាយតិច ថ្ងៃខ្លះក៏ចាយច្រើនទៅព្រោះត្រូវការទិញនេះទិញនោះយកមកហូប។ ខ្ញុំមានជំពាក់គេនៅថៃខ្ញុំចងការប្រាក់គេយកមកឱ្យប្រពន្ធលក់ចាប់ហួយ ទូកចតនៅមួយកន្លែងចេះមិនដឹងយ៉ាងណាទេ ហើយខ្ញុំក៏មិនដឹងថានិយាយយ៉ាងណាប្រាប់គេដែរ។ ឥឡូវចាប់ហួយក៏លក់មិនដាច់ ប៉ុន្តែបើទិញទំនិញគេនៅផ្សារកាន់តែឡើងថ្លៃ»។

ស្រដៀងគ្នានេះដែរប្រជាពលរដ្ឋនៅស្រុកអង្គរជុំខេត្តសៀមរាបលោក សឿន រ៉ាន់ រៀបរាប់ថា កូនរបស់លោកចំនួន៣នាក់ត្រឡប់មកពីប្រទេសថៃប្រមាណ៣សប្តាហ៍ហើយ ដោយសារនៅក្រៅប្រទេសអត់ការងារផង និងខ្លាចឆ្លងជំងឺរលាកផ្លូវដង្ហើមកូវីដ១៩ផង ទើបលោកហៅកូនឱ្យត្រឡប់មកផ្ទះ។ លោកបន្តថា នៅពេលនេះកូនរបស់លោកទាំង ៣នាក់នៅផ្ទះជុំគ្នា និងពុំមានការងារធ្វើរកប្រាក់ចំណូលឡើយ ហើយធ្វើឱ្យជីវភាពគ្រួសារកាន់តែក្រីក្របន្ថែមទៀត។ លោកបន្ថែមថា សព្វថ្ងៃគ្រួសាររបស់លោកជំពាក់ប្រាក់ធនាគារជាង១ម៉ឺនដុល្លារអាមេរិក ដែលបានខ្ចីគេធ្វើដើមទុនដាំដុះ និងទិញគោយន្តសម្រាប់ភ្ជួរហើយពេលនេះលោកពុំមានប្រាក់សងគេវិញនៅឡើយទេ។ លោកថា កន្លងមកបានប្រាក់របស់កូនផ្ញើពីប្រទេសថៃមកសងធនាគារនិងចាយវាយប្រចាំថ្ងៃ ក៏ប៉ុន្តែនៅពេលនេះ ពួកគេអត់ការងារធ្វើ បានប៉ះពាល់យ៉ាងខ្លាំងដល់ក្រុមគ្រួសារ។ លោកបន្ថែមថា ចាប់តាំងពីកូនមកដល់ផ្ទះមក ពុំមានអាជ្ញាធរណាមកអើពើជួយដល់ក្រុមគ្រួសាររបស់លោកនៅឡើយទេ៖ «ខ្ញុំអត់មានអីចាយទេអង្គុយមើលមុខគ្នាពិគ្រោះយោបល់គ្នាថា ទៅណានៅឯថៃ ក៏បិទដែរនោះ។ អីចឹងហើយបានថាខ្ញុំចង់សំណូមពរឱ្យរដ្ឋាភិបាលលោក ហ៊ុន សែន ហ្នឹងជួយពន្យារពេលបង់ការប្រាក់ធនាគារបើអូសបន្លាយទៅមុខយូរ កាន់តែយ៉ាប់ណាស់ខ្មែរយើងមិនអាចរស់បានទេ គឺថាកញ្ជ្រោលងាប់បណ្តោយអត់មានអីហូបទេ។ បើគេបិទ៥ខែកន្លះឆ្នាំអីមិនស្រេចរកប្រាក់ណាបានទិញអំបិលម្សៅស៊ុបបើអីចេះបើរដ្ឋាភិបាលមិនជួយដោះស្រាយយ៉ាប់មែនទែនកូនខ្មែរ»។

ចំណែកពលករនៅខេត្តបន្ទាយមានជ័យលោក រាំ ប៊ូរា រិញថ្លែងថា លោកបាននាំប្រពន្ធនិងកូនត្រឡប់មកពីប្រទេសថៃ កាលពីថ្ងៃទី២០ ខែមីនា ដោយសារនៅក្រៅប្រទេសអត់ការងារធ្វើ។ ពលករធ្វើការផ្នែកកាត់ដេររូបនេះបន្តថា អំឡុងពេលធ្វើការនៅប្រទេសថៃគ្រួសាររបស់លោករកប្រាក់ចំណូលបានប្រមាណ ២ម៉ឺនបាត(២០,០០០) ឬប្រហែល៦០០ដុល្លារអាមេរិកក្នុងមួយខែ ក៏ប៉ុន្តែនៅពេលនេះលោកមិនមានប្រាក់ចំណូលដូចពេលមុនឡើយ។ លោកថា ប្រសិនបើស្ថានការណ៍អូសបន្លាយទៅមុខទៀតគ្រួសារលោកប្រឈមនឹងដាច់ស្បៀង ពីព្រោះលោកគ្មានផ្ទះស្នាក់នៅ ហើយសព្វថ្ងៃជួលផ្ទះគេស្នាក់បណ្តោះអាសន្ន និងត្រៀមវិលត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញ៖ «និយាយទៅប៉ះពាល់ចំណូលច្រើនបង ព្រោះអីខ្ញុំត្រូវចំណាយច្រើនដល់ពេលអីចឹងប៉ះពាល់ដល់ក្រុមគ្រួសារត្រូវខ្វះខាតលុយកាក់ចាយហើយ។ ពិបាកហ្នឹងការរកប្រាក់បង់ថ្លៃបន្ទប់ខ្ញុំមិនបានហូបចុកដូចមុនទេឥឡូវត្រូវតឹងតៀតខុសគ្នាឆ្ងាយណាស់ បើប្រៀបពីមុន ហើយប្រពន្ធខ្ញុំអត់ធ្វើការអីទេមើលកូន»។

កាលពីថ្មីៗនេះនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា រដ្ឋាភិបាលរបស់លោកបានត្រៀមថវិកា៨០០លានដល់ ២ ពាន់លានដុល្លារអាមេរិកដើម្បីប្រើប្រាស់ក្នុងពេលប្រទេសមានបញ្ហាដោយសារជំងឺកូវីដ១៩។លោកក៏បានអំពាវនាវដល់ស្ថាប័នធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ឱ្យពន្យារពេលដល់ពលរដ្ឋក្នុងការសងបំណុល និងមិនឱ្យរឹបអូសទ្រព្យពីអ្នករងគ្រោះដោយសារតែជំងឺលោកផ្លូវដង្ហើមថ្មីនេះស្របពេលពួកគាត់កំពុងគ្មានការងារធ្វើ៖ «វិធានការខាងផ្នែកធនាគារបានធ្វើច្រើនហើយ ក៏ប៉ុន្តែសុំបន្តធ្វើតទៅទៀតបង្ហាញពីការយោគយល់ឧទាហរណ៍ពន្យារការសង់ ឬពន្យារការសងអត្រា ការប្រាក់មិនផាកពិន័យ។ ព្រោះធនាគារគេមានបែបបទរបស់គេ បើអ្នកឯងមិនបានសងគេហ្នឹងផាកពិន័យពីលើហ្នឹង។ ឥឡូវសុំឱ្យយោគយល់គ្នានៅក្នុងកាលទេសនេះ តែនេះមិនមែនជាបទបញ្ជាទេជាការអំពាវនាវរបស់រដ្ឋាភិបាលចំពោះវិស័យឯកជនដែលសុំឱ្យយោគយល់»។ លោក ហ៊ុន សែន បន្ថែមថា អំឡុងពេលនេះជាឱកាសល្អរបស់កសិករដើម្បីរកប្រាក់ចំណូលនៅក្នុងគ្រួសារហើយលោកក៏បានជំរុញឱ្យក្រសួងកសិកម្មណែនាំដល់ប្រជាកសិករបង្កើនការដាំដុះផលដំណាំឱ្យបានច្រើន ដើម្បីផ្គត់ផ្គង់ទីក្នុងស្រុក៖ «កន្លងទៅកំណើនក្នុងវិស័យឧស្សាហកម្មវិស័យសេវាកើនខ្ពស់វិស័យកសិកម្មកើនទាបនៅពេលខាងមុខនេះកំណើនក្នុងវិស័យឧស្សាហកម្មនិងសេវាធ្លាក់ចុះកំណើតក្នុងវិស័យកសិកម្មហ្នឹងហក់ឡើងតែម្ដង។នេះជាឱកាសដែលយើងអាចមើលឃើញតាំងពីឥឡូវអីចឹងយើងត្រូវកិច្ចការងារនេះជាមួយគ្នា»។

ប្រធានអង្គការសង់ត្រាល់លោក មឿន តុលា មានប្រសាសន៍ថា ពលករខ្មែរដែលត្រឡប់ទៅស្រុកកំណើតភាគច្រើនជាពលករធ្វើការក្រៅប្រពន្ធ័ដែលពួកគេពុំបានទទួលប្រាក់ឧបត្ថម្ភ៥០ភាគរយពីរដ្ឋាភិបាលថៃអំឡុងពេលថៅកែផ្អាកការងារនោះឡើយ។ លោកបន្ថែមថា រដ្ឋាភិបាលគួរតែបញ្ចេញប្រាក់៨០០លានដុល្លារ និងប្រាក់ខែដែលមន្ត្រីរាជការបានធ្វើវិភាគទានចូលរួមប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ ជួយដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជំងឺលោកផ្លូវដង្ហើមនេះ៖ «អីចឹងបានខ្ញុំថា ប្រទេសយើងវាពិបាកត្រង់ថាយើងអត់មានប្រព័ន្ធគាំពារសង្គមហ្នឹង វាអត់ទាន់បានទូលំទូលាយទេ នៅគេមានប្រព័ន្ធគាំពារសង្គមរបស់គេគ្រាន់បើនៅពេលពលរដ្ឋអត់ការងារធ្វើគេត្រូវប្ដឹងទៅអាជ្ញាធរ ដើម្បីយកប្រាក់ឧបត្ថម្ភសម្រាប់អត់ការងារធ្វើហ្នឹងតែនៅស្រុកយើងវាអត់ទាន់មានប្រាក់ហ្នឹង។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំឃើញមានខ្ទង់មួយបេឡាជាតិរបបសន្តិសុខសង្គមដែលពលរដ្ឋបានប្រាក់កន្លងមកតាមរយៈក្រុមហ៊ុនគួរតែអាចពិចារណាយកកញ្ចប់ណាមួយយកមកប្រើដែរ ក្នុងដំណាក់កាលដែលពេលកំពុងមានវិបត្តិអីចឹង»។ របាយការណ៍របស់អង្គការសង់ត្រាល់ឱ្យដឹងថា ពលករខ្មែរធ្វើការនៅប្រទេសថៃស្របច្បាប់និងមិនស្របច្បាប់មានប្រមាណ២លាន់នាក់(២០.០០០.០០០)។

លោក ហ៊ុន សែន បានប្រកាសកាលពីថ្ងៃទី៧ មីនាថា មកទល់ពេលនេះមានពលករខ្មែរជាង ៦ម៉ឺននាក់ហើយបានត្រឡប់ទៅកម្ពុជាវិញ។

លោក មឿន តុលា ព្រួយបារម្ភថា ប្រសិនបើស្ថានការណ៍នៅតែបន្តអូសបន្លាយទៅមុខទៀត ដូច្នេះនឹងមានពលកររាប់ម៉ឺននាក់បន្ថែមទៀតត្រឡប់ទៅកម្ពុជាវិញ ពីព្រោះពួកគេអត់ការងារធ្វើ គ្មានប្រាក់បង់ថ្លៃបន្ទប់ជួលនិងប្រាក់ចាយវាយប្រចាំថ្ងៃ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុស ច្បាប់ ពីសមត្ថកិច្ចថៃ ចំនួន ០៤នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 09-04-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង១៧ និង ៤០នាទី ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុស ច្បាប់ ពីសមត្ថកិច្ចថៃ ចំនួន ០៤នាក់។ នគរបាលអន្តោប្រវេសន៍ប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៤នាក់ ស្រី ០៣នាក់ មាន ១. ឈ្មោះ បាត លី ភេទប្រុស អាយុ ២១ឆ្នាំ មានទី

លំនៅ បច្ចុប្បន្នស្ថិតក្នុងភូមិ៤ ឃុំដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង, ២. ឈ្មោះ ញ៉េន សុខលា ភេទស្រី អាយុ ២២ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ភូមិបែកក្អម ឃុំគោកគង ស្រុកកញ្ច្រៀច ខេត្តព្រៃវែង, ៣. ឈ្មោះ ហ៊ាន សុខា ភេទស្រី អាយុ ២៤ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ភូមិដូង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង និង៤. ឈ្មោះ អ៊ឹម ស្រីភា ភេទស្រី អាយុ ៣១ឆ្នាំ មានទីលំនៅ បច្ចុប្បន្ន ភូមិ១ ឃុំស្មាច់មានជ័យ ខេត្តកោះកុង។ ក្នុងនេះក៏មានការចូលរួមពី មន្ត្រីចត្តាឡីស័កត្រួតពិនិត្យសុខភាពផងដែរ បន្ទាប់មក កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២១១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 09-04-2020

នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៤និង៣០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២១១នាក់ ស្រី ១០៣នាក់៕

## អាជ្ញាធរថៃចាប់ពលករខ្មែរជាច្រើននាក់ដែលធ្វើដំណើរត្រឡប់មកកម្ពុជាបំពានបម្រាមប្រកាសអាសន្ន

https://www.rfa.org/khmer/ ដោយ មាន ឫទ្ធិ 2020-04-09

អាជ្ញាធរខេត្តស្រះកែវរបស់ថៃចាប់ខ្លួនពលករខ្មែរជិត ១០នាក់ ក្នុងពេលពួកគេធ្វើដំណើរឆ្លងកាត់ខេត្តនេះឆ្ពោះទៅព្រំដែនកម្ពុជាថៃដើម្បីត្រឡប់ទៅស្រុកកំណើតវិញ នៅព្រឹកថ្ងៃទី៩ មេសា។ អាជ្ញាធរថៃបានចោទប្រកាន់ពលករទាំងនោះពីបទបំពានបម្រាមប្រកាសអាសន្ន។ អាជ្ញាធរស្រុកគោកស៊ូង (Kouk Sung) ខេត្តស្រះកែវ (Sra Keo) ប្រទេសថៃ ចាប់ខ្លួនពលករខ្មែរចំនួន៧នាក់ ជាពលករធ្វើការងារស្របច្បាប់ មានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ធំ។ នេះបើតាមសេចក្តីរាយការណ៍របស់កាសែតថៃ ផ្សាយនៅថ្ងៃទី៩ មេសា។ ប្រភពដដែលបន្ថែមថា ពួកគេបានជួលរថយន្ត ១គ្រឿងតម្លៃ ៥៣ពាន់បាត ឬប្រមាណ១៧០ដុល្លារអាមេរិកធ្វើដំណើរពីខេត្តជាប់ទីក្រុងបាងកក ត្រឡប់ទៅផ្ទះវិញ ដោយសារនៅប្រទេសថៃគ្មានការងារធ្វើបណ្តាលមកពីផលប៉ះពាល់ជំងឺកូវីដ១៩។ បច្ចុប្បន្ន អាជ្ញាធរថៃបានបញ្ជូនពលករទាំងនោះទៅតុលាការដើម្បីចាត់វិធានតាមច្បាប់ ពីព្រោះពួកគេបានល្មើសបម្រាមប្រកាសអាសន្ន។

អាជ្ញាធរខេត្តស្រះកែវ (Srakao) បានចេញសេចក្តីប្រកាសកាលពីថ្ងៃទី៥ មេសា ហាមឃាត់រថយន្តដឹកពលករបរទេសគ្រប់ប្រភេទឆ្លងកាត់ខេត្តមួយនេះ ២៤ម៉ោង ដើម្បីទប់ស្កាត់ការឆ្លងរាលដានជំងឺរលាកផ្លូវដង្ហើមថ្មី។ ប្រសិនបើជនណាល្មើសបម្រាមនេះនឹងត្រូវពិន័យដាក់គុក ១ឆ្នាំ និងពិន័យជាប្រាក់១០ម៉ឺនបាត ឬប្រមាណ៣ពាន់ដុល្លារអាមេរិក។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក ទទួលបន្ទុកផ្នែកពលករ លោក គឹម ចំរើន និង អ្នកនាំពាក្យក្រសួងការបរទេសលោក កុយ គួង ដើម្បីសុំអត្ថាធិប្បាយជុំវិញបញ្ហាបានទេ នៅថ្ងៃទី៩ មេសា ដោយទូរស័ព្ទជាច្រើនដងពុំមានអ្នកទទួល។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) ខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា មានប្រសាសន៍ថា ករណីនេះអាជ្ញាធរខ្មែរគួរតែទំនាក់ទងទៅភាគីថៃ ដើម្បីសុំឱ្យដោះលែងពលករខ្មែរទាំងនោះត្រឡប់មកប្រទេសកំណើតវិញ ពីព្រោះរឿងនេះពុំមែនជាកំហុសរបស់ពួកគេឡើយ។ លោកបន្តថា ពលករខ្មែរត្រឡប់ទៅផ្ទះដើម្បីរត់គេចពីជំងឺកូវីដ១៩ផង និងដោយសារនៅក្រៅប្រទេសគ្មានការងារធ្វើផង ទើបពួកគេបង្ខំចិត្តត្រឡប់ទៅផ្ទះវិញ ដើម្បីសុវត្ថិភាពផ្ទាល់ខ្លួន៖ «អ្វីដែលសំខាន់គឺពួកគាត់រត់ត្រឡប់មកវិញ ដើម្បីភាពរស់រានមានជីវិត អីចឹងមិនមែនជាកំហុសអីធ្ងន់ធ្ងរទេ។ អីចឹងរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធគួរតែប្រឹងប្រែងធ្វើម៉េចដោះស្រាយឱ្យពួកគាត់ហ្នឹងបានចេញមកជួបប្រពន្ធកូន បានមកជួបបងប្អូនញាតិមិត្ត ឱ្យរួចផុយពីជំងឺរាតត្បាត និងដើម្បីឱ្យពលករខ្មែរដទៃទៀតដែលត្រឡប់មកពីប្រទេសថៃឱ្យរួចផុតពីការជាប់គុកជាប់ច្រវាក់នៅក្នុងគ្រាមានអាសន្ននេះ»។

កាលពីថ្ងៃទី៧ មេសា អាជ្ញាធរថៃចាប់ពលករខ្មែរចំនួន៩នាក់រួចមកហើយដែរ ដោយសារតែពួកគេធ្វើដំណើរត្រឡប់ទៅកម្ពុជាវិញ ហើយឆ្លងកាត់ខេត្តមួយនេះ បំពានបម្រាមប្រកាសអាសន្នរបស់ថៃ។ ចាប់តាំងពីជំងឺកូវីដ១៩រាតត្បាតនៅក្នុងប្រទេសថៃ មានពលករខ្មែរជាង ៦ម៉ឺននាក់ ហើយបានត្រឡប់ទៅស្រុកកំណើតវិញ។

លោក ស៊ុំ ច័ន្ទគា ព្រួយបារម្ភថា នៅពេលខាងមុខនឹងមានពលករខ្មែរជាច្រើននាក់ផ្សេងទៀតត្រូវចាប់ខ្លួននៅក្នុងប្រទេសថៃ ប្រសិនបើរដ្ឋាភិបាលខ្មែរមិនជួយអន្តរាគមន៍ដល់ពួកគេនោះ ដោយសារពួកគេមិនមានស្បៀងអាហារហូបចុក និងគ្មានប្រាក់បង់ថ្លៃបន្ទប់ជួលក្នុងពេលស្នាក់នៅក្រៅប្រទេស៕

## ឃាត់ខ្លួនពលករខ្មែរ ០៧នាក់និងថៃម្នាក់ ពីបទបំពានសេចក្តីប្រកាសរដ្ឋបាលខេត្តស្រះកែវ

https://www.facebook.com/LABOURKHMER/ ពលករ 10-04-2020

យោងតាមរបាយការណ៍ពីខេត្តស្រះកែវកាលពីថ្ងៃព្រហស្បតិ៍ ទី០៩ ខែមេសា ឆ្នាំ២០២០ ម្សិលមិញនេះ បានអោយដឹងថាកម្លាំងសមត្ថកិច្ចទាហានថៃបានឃាត់រថយន្តឯកជនមួយគ្រឿងដែលដឹកពលករខ្មែរចំនួន០៧នាក់មកពីខេត្តសាមុតសាខន គោលដៅទៅច្រកព្រំដែន ប៉ុន្តែត្រូវបានសមត្ថកិច្ចប្រចាំកុងត្រូលធ្វើត្រួតពិនិត្យរកឃើញពលករខ្មែរចំនួន ០៧នាក់ នៅក្នុងរថយន្តខាងលើ ។ តាមការបញ្ជាក់របស់សមត្ថកិច្ចថៃម្ចាស់រថយន្តខាងលើនិងពលករទាំងអស់បានបំពានសេចក្តីប្រកាសរបស់រដ្ឋបាលខេត្តស្រះកែវ ត្រូវមានទោសជាប់ពន្ធនាគារមិនល្មើសពី ០១ ឆ្នាំ និងផាកពិន័យជាទឹកប្រាក់មិនលើសពី ១សែនបាត ។ UPDATED:10.04.20

## អភិបាលខេត្តសុរិន្ទ ចេញសេចក្តីប្រកាសហាមមិនអនុញ្ញាតអោយរថយន្តសារធារណៈ រថយន្តឯកជននិងមធ្យោបាយធ្វើដំណើរផ្សេងៗ ដឹកជញ្ជូនពលករបរទេសធ្វើដំណើរឆ្លងកាត់ខេត្តសុរិន្ទ

https://www.facebook.com/ Prak Pheaktra 10-04-2020

ថ្ងៃនេះខ្ញុំមានដំណឹងមកជំរាបជូនបងប្អូនពលករខ្មែរក្នុងប្រទេសថៃទាំងអស់ដែលមានបំណងធ្វើដំណើរវិលត្រឡប់ទៅផ្ទះតាមច្រកព្រំដែនអូរស្មាច់ អោយដឹងថានៅថ្ងៃសុក្រ ទី១០ ខែមេសា ឆ្នាំ២០២០នេះ អភិបាលខេត្តសុរិន្ទបានចេញសេចក្តីប្រកាសហាមឃាត់មិនអនុញ្ញាតអោយរថយន្តសារធារណៈ រថយន្តឯកជននិងមធ្យោបាយធ្វើដំណើរផ្សេងៗ ដឹកជញ្ជូនពលករបរទេសធ្វើដំណើរឆ្លងកាត់ខេត្តសុរិន្ទជាដាច់ខាត ។ ក្នុងករណីល្មើសច្បាប់៖

-ត្រូវមានទោសជាប់ពន្ធនាគារមិនលើសពី ១ ឆ្នាំ

-ផាកពិន័យជាទឹកប្រាក់មិនលើស ១០ ម៉ឺនបាត

*ដូច្នេះសូមបងប្អូនពលករខ្មែរក្នុងប្រទេសថៃទាំងអស់មេត្តាជ្រាបជាដំណឹង ។ 10.04.20 ភក្ត្រា ពលករខ្មែរ

# ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០

## សម្តេច ស ខេង អគុណចំពោះសប្បុរសធម៌ ដែលបានកាត់ប្រាក់ខែរបស់ខ្លួន ចូលរួមបរិច្ចាគ ទប់ស្កាត់ការរីករាលដាល នូវមេរោគកូវីដ-១៩

http://bayontv.com.kh/ 13/04/2020

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអរគុណចំពោះមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់រូប ដែលបានសម្រេចកាត់ប្រាក់ខែរបស់ខ្លួនទៅតាមលទ្ធភាពចូលរួមបរិច្ចាគ ដើម្បីទប់ស្កាត់ការរីករាលដាលនូវមេរោគកូវីដ១៩។ ថ្លែងនៅក្នុងពិធីអញ្ជើញប្រគល់រថយន្ត ម៉ាស់ និងអាល់កុលដល់សមត្ថកិច្ចព្រំដែនដើម្បីធ្វើប្រតិបត្តិការទប់ទល់នៃការរីករាលដាលនូវមេរោគកូវីដ១៩ នាព្រឹកថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០នេះនៅក្រសួងមហាផ្ទៃ សម្តេចក្រឡាហោម បានលើកឡើងថា សកម្មភាពរបស់សប្បុរសធម៌នានា ជាពិសេសមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលបានសម្រេចចិត្ត កាត់ប្រាក់ខែរបស់ខ្លួនចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការទប់ស្កាត់ និងព្យាបាលមេរោគកូវីដ១៩នេះ គឺជាសកម្មភាពមនុស្សធម៌មួយរបស់ខ្មែរក្នុងការសាមគ្គីភាពគ្នា។

សម្តេចក្រឡាហោម ស ខេង បានបន្តទៀតថា បញ្ហាមេរោគកូវីដ១៩នេះ គឺ វាបានកំពុងវាយលុកយ៉ាងខ្លាំងនៅទូទាំងពិភពលោក ហើយប្រទេសកម្ពុជា ក៏កំពុងបន្តឆ្លងផងដែរ តែទោះជាយ៉ាងណាខ្មែរយើងពុំទាន់មានករណីធ្ងន់ធ្ងរដូចបណ្តាប្រទេសធំៗ នៅលើពិភព លោកនោះទេ ប៉ុន្តែយើងត្រូវតែបន្តទប់ស្កាត់ និងអនុវត្តឲ្យបានម៉ឺងម៉ាត់បំផុតចំពោះបទបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល ដែលបានចេញពីកន្លងទៅទាក់ទងនឹងបញ្ហានេះ។ ជាមួយគ្នានោះដែរសម្តេចក្រឡាហោម ស ខេង ក៏បានបន្តអំពាវនាវដល់មន្ត្រីថ្នាក់ក្រោមជាតិ និងតាមបណ្តាព្រំដែនទាំងអស់បន្តអនុវត្តឲ្យបានល្អប្រសើរបន្ថែមទៀតចំពោះវិធានការដល់បងប្អូនពលករខ្មែរ និងពលរដ្ឋខ្មែរដែលបានចាកចេញពីភ្នំពេញ ឬតាមបណ្តាខេត្តនានា ទៅកាន់ស្រុកកំណើត ត្រូវទុកពួកគាត់ដោយឡែករយៈពេល១៤ថ្ងៃ ដើម្បីបង្ការ និងទប់ស្កាត់ការរីករាលដាល់នូវមេរោគកូវីដ១៩នេះ៕

## ពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃ ចាប់បញ្ជូនមក មានចំនួន ១៩នាក់

*https://www.facebook.com/GDIOfficial/* General Department of Immigration - GDI 12-04-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ អាជ្ញាធរថៃ នៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឲ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា ។ ដោយឡែកពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃ ចាប់បញ្ជូនមក មានចំនួន ១៩នាក់ ស្រី ០៨នាក់ និងកុមារ ០៤នាក់៕

## ពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៩នាក់

*https://www.facebook.com/GDIOfficial/* General Department of Immigration - GDI 12-04-2020

នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹម

ត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៩នាក់ ស្រី ០៩នាក់៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៧នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 11-04-2020

នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៧នាក់ ស្រី ១៥នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃ ចំនួន ០២នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 10-04-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៦និង២០នាទី ថ្ងៃទី១០ ខែមេសា ឆ្នាំ ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃ ចំនួន ០២នាក់។ នគរបាលអន្តោប្រវេសន៍ប៉ុស្តិ៍ បានឲ្យដឹងថា ពលករខ្មែរទាំង ០២នាក់ មាន ១. ឈ្មោះ ឈាន ឈាវ ភេទប្រុស អាយុ ១៨ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ស្ថិតក្នុងភូមិបែកក្អម ឃុំគោកគង ក្រុងកញ្ច្រៀច ខេត្តព្រៃវែង និង២. ឈ្មោះ រុន ឈីន ភេទប្រុស អាយុ ២៧ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ភូមិត្រពាំងព្រីង ឃុំសង្កែ ស្រុកកំពតខេត្តកំពត។ ក្នុងនេះក៏មានការចូលរួមពី មន្ត្រីចត្តាឡីស័កត្រួតពិនិត្យសុខភាពផងដែរ បន្ទាប់មក កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៣៤នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 10-04-2020

នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៤និង៣០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៣៤នាក់ ស្រី ៣០៨នាក់៕

## មកទល់ពេលនេះ ពលករបន្តវិលត្រឡប់ពីថៃកាន់តែច្រើនឡើង

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០២០ ម៉ោង ១៥:៤៦ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ បើទោះជាប្រទេសថៃប្រកាសដាក់ប្រទេសក្នុងគ្រាអាសន្ន ហើយរាជរដ្ឋាភិបាលកម្ពុជាក៏ចាប់ផ្តើមប្រកាសមិនឲ្យប្រជាពលរដ្ឋធ្វើដំណើរឆ្លងពីខេត្តមួយទៅខេត្តមួយ ព្រោះដើម្បីបង្ការទប់ស្កាត់ការរីករាលដាលនៃវីរុសកូវីដ១៩ ប៉ុន្តែពលករវិលត្រឡប់ពីថៃនៅបន្តកើតមាននិងកាន់តែមានចំនួនកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ ក្រុមពលករបាននិយាយថា ដោយសារនៅប្រទេសថៃបានផ្អាកការងារស្ទើរគ្រប់ទីកន្លែង ម្យ៉ាងពេលនេះជិតដល់ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ជាពិសេសពួកគេព្រួយបារម្ភពីការឆ្លងជំងឺកូវីដ១៩ផង ទើបនាំគ្នាត្រឡប់មកស្រុកកំណើតវិញ ។

នៅព្រឹកថ្ងៃទី១០ មេសានេះ ពលករវិលត្រឡប់ពិថៃតាមច្រករបៀងអូរបីជាន់និងច្រកតំបន់ម៉ាឡៃត្រូវគេយកទៅដាក់នៅទីតាំទទួលពលករមួយកន្លែងនៅចំណុចស្ថានីយរថភ្លើងក្នុងភូមិ និងសង្កាត់ក្រុងប៉ោយប៉ែតដែលទីតាំងមួយនេះអាជ្ញាធរ ទើបបង្កើតឡើងថ្មីនៅព្រឹកថ្ងៃនេះតែម្តង ។ មិនតែប៉ុណ្ណោះទីតាំងមួយនេះគឺមានដាក់ឈ្មោះខេត្តនីមួយៗ ហើយក្រុមពលករពេលចុះពីរថយន្តត្រូវដើរចូលតាមទីតាំងដែលមានតាំងឈ្មោះខេត្តរៀងខ្លួនៗ ។

តាមប្រភពព័ត៌មានបានឱ្យដឹងថា ពលករទាំងអស់ក្រោយចូលដល់ទីតាំងខាងលើ និងក្រោយមន្ត្រីជំនាញពិនិត្យកំដៅនិងតាមដានសុខភាពរួច ត្រូវគេដឹកតាមរថយន្តស្លាកលេខខេមរភូមិន្ទទៅតាមបណ្តាខេត្តរៀងខ្លួនៗ ដោយមានអាជ្ញាធរមូលដ្ឋានរបស់ពលកររស់នៅមកទទួលផងដែរ។ ទោះបីជាយ៉ាងណា ចំនួនពលករវិលត្រឡប់ពីថៃតាមខេត្តបន្ទាយមានជ័យ គិតទាំងច្រកទ្វារអន្តរជាតិ ច្រកតំបន់ម៉ាឡៃ ច្រកតំបន់បឹងត្រកួន និងច្រករបៀងអូរបីជាន់ចាប់ពីថ្ងៃទី២៣ មីនា ឆ្នាំ២០២០ ក្រោយភាគីថៃបិទព្រំដែនមកទល់និងថ្ងៃទី១០ មេសានេះ មានចំនួនសរុប៤១៨៦នាក់ ស្រី១៦៥៤នាក់ និងកុមា៣២៨នាក់។

ដោយឡែកថ្ងៃទី១០ មេសានេះ ចំនួនពលករចូលដល់ទីតាំងទទួលពលករនៅស្ថានីយរថភ្លើងក្នុងក្រុងប៉ោយប៉ែត តាមប្រភពព័ត៌មានថាជាង២០០នាក់ គិតត្រឹមវេលាម៉ោង១២ថ្ងៃត្រង់ថ្ងៃដដែល ដោយ១៤៥នាក់ដឹកមកពីច្រករបៀងអូរបីជាន់ ក្រៅពីនេះគឺបញ្ជូនពីច្រកតំបន់ម៉ាឡៃ ៕ (កែសម្រួលដោយ ៖ ធីតា)

## ឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត បញ្ជាឲ្យអាជ្ញាធរខេត្តបាត់ដំបង យករថយន្តកងទ័ព៥០គ្រឿង ដឹកពលករខ្មែរ ចេញពីប្រទេសថៃវិលត្រឡប់មកស្រុកកំណើត ចូលតាមច្រកទ្វារអន្តរជាតិដូង

https://www.cen.com.kh/ April 11, 2020

បាត់ដំបង:ឯកឧត្តម ងួន រតនៈ អភិបាលខេត្តបាត់ដំបង បានមានប្រសាសន៍ថា អាជ្ញាធរខេត្តបាត់ដំបងទទួលរថយន្តកងទ័ពចំនួន ៥០គ្រឿងដែលស្ថិតក្រោមការបញ្ជាផ្ទាល់ពីឯកឧត្តមឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក ដើម្បីត្រៀមបម្រុងដឹកជញ្ជូនបងប្អូនប្រជាពលករខ្មែរ ដែលចេញពីប្រទេសថៃវិលត្រឡប់ទៅស្រុកកំណើតតាមបណ្តារាជធានី ខេត្តរបស់ខ្លួនវិញ និងពិនិត្យទីតាំងដាក់ម៉ាស៊ីនស្កេនកំដៅស្វ័យប្រវត្តនិងពិនិត្យទីកន្លែង សម្រាប់ពិនិត្យ ព្យាបាល។ ឯកឧត្តម ងួន រតនៈ អភិបាលខេត្តបាត់ដំបង បានពិនិត្យមើលទីតាំងរៀបចំគ្រោងបំពាក់នូវម៉ាស៊ីនស្វ័យប្រវត្តិសម្រាប់ធ្វើការស្កេនកំដៅនៅមាត់ច្រកទ្វារអន្តរជាតិដូង ម៉ាស៊ីនស្កេននេះ កំពុងតែដំណើរការសាងសង់។ ឯកឧត្តម ងួន រតនៈ បានជំរុញឲ្យអ្នកបច្ចេកទេស ខិតខំពន្លឿនការសាងសង់តម្លើងម៉ាស៊ីនស្កេនកម្តៅនេះឲ្យបានឆាប់ ដើម្បីដំណើរការបានទាន់ពេលវេលា។រថយន្តដែលគ្រោងនិងដឹកបងប្អូនពលករខ្មែរនេះគឺជារថយន្តរបស់ កងយោធពលខេមរភូមិន្ទដែលស្ថិតក្រោមការបញ្ជាផ្ទាល់ពីឯកឧត្តមឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក។

បើតាមការអះអាងពីមន្ត្រីចត្តាឡីស័កដែលប្រចាំការនៅច្រកទ្វារអន្តរជាតិដូង បានប្រាប់ឲ្យដឹងថា ការសាងសង់កន្លែងស្នាក់នៅស្វ័យប្រវត្តិនេះ អាចនិងរួចស្រាច់ រយៈពេល ២ថ្ងៃទៀត។ក្រុមជាងសាងសង់ បានធ្វើការសាងសង់ទាំងថ្ងៃ ទាំងយប់ រហូតដល់ម៉ោង១២យប់ ទើបក្រុមជាង ឈប់សម្រាក។

ឯកឧត្តម ងួន រតនៈ អភិបាលខេត្តបាត់ដំបង និងប្រតិភូអមដំណើរ បានបន្តដំណើរពិនិត្យមើលទីតាំង២កន្លែងផ្សេងទៀត ដែលត្រៀមបម្រុង ដើម្បីរៀបចំទទួលនិងពិនិត្យព្យាបាលតាមដានពីសុខភាពរបស់បងប្អូនពលករខ្មែរទាំងនោះគឺទីតាំងទី១ នៅមាត់ច្រកទ្វារព្រំដែនស្ថិតក្នុងកាស៊ីណូអ៊ីហ្គល(Eagle Casino)សម្រាប់ទទួលពលករខ្មែរដែលចូលតាមច្រកទ្វារព្រំដែនអន្តរជាតិដូងនិងទីតាំងទី២ ស្ថិតនៅមណ្ឌលសុខភាពឃុំត្រាងស្រុកកំរៀង រៀបចំសម្រាប់ពិនិត្យនិងព្យាបាលនៅទីនោះ ក្នុងករណីសង្ស័យមានផ្ទុកមេរោគកូវីដ ១៩៕ដោយៈអ៊ុងសារុំ

## ពលករខ្មែរ ទើបត្រលប់មកពីប្រទេសថៃ ទទួលបានការយកចិត្តទុកដាក់ពី អាជ្ញាធរខេត្តសៀមរាប

---

http://camnewsonline.com/ April 10, 2020 គិន លីថូ

នៅថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០២០ នេះ បើយោងតាមរយៈហ្វេសប៊ុកផេក "BTV Cambodia" បានប្រាប់ឲ្យដឹងថា៖ "បងប្អូនពលករដែលទើបត្រលប់មកពីប្រទេសថៃ ទទួលបានការយកចិត្តទុកដាក់ពី អាជ្ញាធរខេត្តសៀមរាប តាមរយៈ ក្រុមការងារ ទៅទទួលដល់ព្រំដែន ហើយដឹកជញ្ជូន ចូលមកក្នុងខេត្តសៀមរាប ដើម្បីធ្វើតេស្តពិនិត្យរកមេរោគកូវីដ១៩ និងណែនាំ អោយរស់នៅដាច់ដោយឡែករយៈពេល១៤ថ្ងៃ មុនចូលទៅរស់នៅជាមួយសមាជិកក្នុងក្រុមគ្រួសារ៕

ក្នុងនោះផងដែរ បើយោងតាមរយៈហ្វេសប៊ុកផេក "ទូរទស្សន៍ជាតិកម្ពុជា ទទក – TVK" ក៏បានបញ្ជាក់បន្ថែមថាទៀតថា "រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃទី១០ ខែមេសានេះបានត្រៀមគ្រែ និងប៉ោអឺ រួចជាស្រេចនៅសាលាគរុកោសល្យខេត្ត សម្រាប់ដាក់ពលករខ្មែរទើបវិលត្រលប់មកពីប្រទេសថៃ ដែលមានរង្វង់ប្រមាណ ១០០នាក់។ អ្នកទាំងនោះនឹងត្រូវដាក់នៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃដើម្បីការពារការឆ្លង Covid-19 ទើបអនុញ្ញាតឱ្យវិលទៅកាន់លំនៅឋានវិញ។"៕

## ដឹកពលករខ្មែរមកដល់បាត់ដំបងទាំងយប់ ដើម្បីពិនិត្យសុខភាព មុននឹងដឹកជូនទៅស្រុកកំណើត

https://www.cen.com.kh/ April 11, 2020

បាត់ដំបងៈរថយន្តកងពលតូចជើងជញ្ជូនលេខ៩៩ បានដឹកជញ្ជូនពលករខ្មែរចេញពីប្រទេសថៃតាមច្រកទ្វារអន្តរដូងត្រឡប់មកកម្ពុជាវមកដល់ទីតាំងពិគ្រោះនិងពិនិត្យក្នុងបរិវេណវិទ្យាល័យព្រះមុនីវង្សទាំងយប់ ដើម្បីពិនិត្យសុខភាពមុននឹងដឹកជូនទៅស្រុកកំណើតឬតាមបណ្តាខេត្តផ្សេងៗដែលជាទីកន្លែងរស់នៅ និងកន្លែងស្រុកកំណើតរបស់ពួកគាត់កាលពីយប់ថ្ងៃទី១០ខែមេសាឆ្នាំ២០២០។ លោក រឿង ប៊ុនរ៉េត ប្រធានមន្ទីរសុខាភិបាលខេត្តបាត់ដំបង បានមានប្រសាសន៍ឲ្យដឹងថា ពលករខ្មែរទាំងអស់ដែលបានដឹកមកទាំងយប់នេះមានចំនួន ២រថយន្ត ដោយធ្វើដំណើរមកដោយសុវត្ថិភាពនិងត្រូវបានពិនិត្យសុខភាពគ្រប់គ្នា មុននឹងបញ្ជូនទៅកាន់បណ្តាស្រុកឬខេត្តផ្សេងទៀត ដើម្បីដាក់ឲ្យនៅដោយឡែករយៈពេល ១៤ថ្ងៃ នៅតាមទីតាំងដែលអាជ្ញាធរស្រុកនិងខេត្តដទៃបានរៀបចំរួចស្រាច់ ។

លោក ផេង សិទ្ធី អភិបាលក្រុងបាត់ដំបង បានឲ្យដឹងថារថយន្តទាំង២គ្រឿង មានពលករចំនួន ៥៩នាក់ពួកគាត់សុទ្ធរស់នៅក្នុងខេត្តបាត់ដំបង។រថយន្តជើងទី១ មកដល់នៅពេលព្រលប់ មានពលករចំនួន ១៧នាក់ ត្រូវ

បានបញ្ជូនទៅតាមបណ្ដាស្រុកនិងរថយន្តជើងទី២ ត្រូវឲ្យពួកគាត់សម្រាកនៅតាមបន្ទប់ ដែលបានរៀបចំរួចរាល់ក្នុងវិទ្យាល័យព្រះមុនីវង្ស ដើម្បីត្រៀមពិនិត្យសុខភាពនៅពេលព្រឹក មុននឹងបញ្ជូនទៅកាន់បណ្ដាស្រុកផ្សេងទៀត។

យោងតាមរបាយការណ៍របស់រដ្ឋបាលខេត្តបាត់ដំបង បានបង្ហាញថា ចាប់តាំងពីមានការបិទព្រំដែនរវាងកម្ពុជា ថៃមក មានពលរដ្ឋ និងពលករខ្មែរនៅក្នុងខេត្តបាត់ដំបង មកដល់ត្រឹមថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ ដែលវិលត្រឡប់មកស្រុកកំណើតវិញចំនួន ១៤.៩០៦នាក់ (ស្រី ចំនួន៦.៨៦៦នាក់ )៕ដោយៈអ៊ុងសារុំ

## ពលរដ្ឋខ្មែរ ដែលឆ្លងដែនមកពីប្រទេសថៃ គាំទ្រនូវវិធានការ របស់រាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់ជំងឺកូវីត១៩

https://www.cen.com.kh/ April 12, 2020

បាត់ដំបងៈ ពលរដ្ឋ និងពលករខ្មែរ ដែលទើបឆ្លងដែនចេញពីថៃ តាមច្រកនានា ជាប់នឹងខេត្តបាត់ដំបង បានសម្តែងការគាំទ្រ នូវវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ ១៩ របស់រាជរដ្ឋាភិបាល ដែលចុះជួយពិនិត្យសុខភាពពួកគាត់ មុននឹងអនុញ្ញាត ឲ្យត្រឡប់មកស្រុកកំណើតរៀងៗខ្លួន កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០។

ពលរដ្ឋ និងពលករខ្មែរ បាននិយាយលើកឡើងថា មុនឆ្លងមកទឹកដីកម្ពុជាវិញ ពួកគាត់ត្រូវបានអាជ្ញាធរខ្មែរជួយសម្របសម្រួលជាមួយភាគីថៃ ឲ្យចេញមកដោយរលូន ហើយពេលមកដល់ខាងទឹកដីកម្ពុជា ត្រូវបានសមត្ថកិច្ចធ្វើការពិនិត្យកម្តៅយ៉ាងល្អិតល្អន់ត្រឹមត្រូវ នៅជិតច្រកព្រំដែន ទើបអនុញ្ញាតឲ្យឡើងរថយន្ត។ ក្រោយពីជីកចេញពីច្រកព្រំដែន ពួកគាត់ត្រូវបានប្តូរ ឲ្យទៅជិះរថយន្តរបស់កងទ័ព បន្តទៅកាន់ស្រុកកំណើតរៀងៗខ្លួន មិនមានការយកប្រាក់កាសអ្វីនោះទេ ហើយការធ្វើដំណើរគឺប្រកបដោយសុវត្ថិភាព។

លោកឧត្តមសេនីយ៍ទោ អ៊ុច សុខុន ស្នងការនគរបាលខេត្តបាត់ដំបង បានមានប្រសាសន៍ថា ពលរដ្ឋខ្មែរឆ្លងដែនមកពីថៃនេះ គឺគាត់ចេញពីច្រកតូចៗមួយចំនួន នៅជិតច្រកទ្វារអន្តរជាតិដូង និងជិតច្រកទ្វារអន្តរជាតិភ្នំដីហើយការវិលត្រឡប់ ចាប់ពីពេលភាគីថៃបិទមក។ ពលរដ្ឋ មិនមានការទៀងទាត់នោះទេ គឺថ្ងៃខ្លះមានឆ្លង និងថ្ងៃខ្លះទៀត ក៏មិនមានឆ្លង ដោយនៅពេលច្រកព្រំដែន មានសភាពបែបនេះ និងការឆ្លងដែននេះ ក៏ពុំមានបញ្ហាអសន្តិសុខអ្វីនោះទេ។

លោក ណាង សារី មន្ត្រីចត្តាលីស័កប្រចាំនៅច្រកដូង បានមានប្រសាសន៍លើកឡើងថា ចាប់តាំងពីមានការបិទច្រកព្រំដែនកម្ពុជា ថៃនៅជិតជាប់ខេត្តបាត់ដំបង។ នៅមានការឆ្លងដែន របស់ពលរដ្ឋ និងពលករខ្មែរ ចេញពីថៃមកនោះ មន្ត្រីជំនាញបានចុះជួយពិនិត្យសុខភាព រកជំងឺកូវីដ១៩ ដោយមានការសង្ស័យលើ ៦ករណី ត្រូវបាននាំសំណាកទៅពិនិត្យនៅភ្នំពេញ ជាលទ្ធផលមិនមានរកឃើញនោះទេ។ ដើម្បីបង្កភាពងាយស្រួល ក្នុងការវាស់កម្តៅរបស់ពលរដ្ឋនៅច្រកទ្វារអន្តរជាតិដូង ក៏ចាប់ផ្តើមរៀបចំដំឡើងម៉ាស៊ីនវាស់កម្តៅស្វ័យប្រវត្តផងដែរ។

គួរបញ្ជាក់ផងដែរថា ចាប់ពីមានការបិទច្រកព្រំដែនកម្ពុជា ថៃ មានពលរដ្ឋនិងពលករខ្មែរ នៅក្នុងខេត្តបាត់ដំបង វិលត្រឡប់មកពីប្រទេសថៃ និងប្រទេសនានា គិតត្រឹមថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០ សរុបមានចំនួន ១៥.៣៣៣នាក់( ស្រី៧ ០៥៨នាក់) ៕ដោយ ៖ អ៊ុងសារុំ

## អាជ្ញាធរខេត្តសុរិន្ទរបស់ថៃប្រកាសហាមពលករខ្មែរឆ្លងកាត់ខេត្តនេះព្រោះខ្លាចឆ្លងជំងឺកូវីដ-១៩

https://www.rfa.org/khmer/ ដោយ ខែ សុណាង 2020-04-11

អាជ្ញាធរខេត្តសុរិន្ទរបស់ថៃប្រកាសហាមរថយន្តគ្រប់ប្រភេទដឹកពលករខ្មែរឆ្លងកាត់ខេត្តនេះ ទៅព្រំដែនកម្ពុជា-ថៃ ដើម្បីការពារកុំឱ្យឆ្លងរាលដាលជំងឺកូវីដ-១៩។ ទោះជាបែបនេះក្តី ក៏មានពលករខ្មែរជាច្រើននាក់នៅតែបន្តឆ្លងដែនទៅកម្ពុជាវិញជាបន្តបន្ទាប់ដែរ។ អាជ្ញាធរខេត្តសុរិន្ទដែលមានព្រំដែនជាប់ខេត្តឧត្តរមានជ័យរបស់កម្ពុជា បានចេញសេចក្តីប្រកាសនៅថ្ងៃទី៩ មេសា ហាមឃាត់រថយន្តដឹកពលករបរទេសគ្រប់ប្រភេទឆ្លងកាត់ខេត្តមួយនេះ

ចាប់ពីថ្ងៃទី១០ មេសាតទៅ។ អាជ្ញាធរថៃថា ប្រសិនបើជនណាល្មើសនឹងបម្រាមនេះ ត្រូវមានទោសជាប់គុក ១ឆ្នាំ និងពិន័យជាប្រាក់ ១០ម៉ឺនបាត ឬប្រមាណ ៣ពាន់ដុល្លារអាមេរិក។ ប្រភពដដែលបន្តថា ការហាមឃាត់មិនឱ្យពលករបរទេសឆ្លងកាត់ខេត្តនេះ គឺជាវិធានការមួយក្នុងចំណោមវិធានការដទៃ ដើម្បីការពារកុំឱ្យរាតត្បាតជំងឺកូវីដ-១៩ ចូលមកក្នុងខេត្តនេះ ពីព្រោះមួយរយៈនេះមានពលករខ្មែរជាច្រើននាក់បានសម្រុកឆ្លងដែនត្រឡប់ទៅស្រុកកំណើតវិញ ហើយឆ្លងកាត់និងស្នាក់នៅក្នុងខេត្តសុរិន្ទជារៀងរាល់ថ្ងៃ។ ក្នុងនោះពលករមួយចំនួនមិនបានអនុវត្តតាមការណែនាំរបស់អាជ្ញាធរថៃ ដើម្បីការពារឆ្លងជំងឺកូវីដ១៩នោះឡើយ។ កាលពីថ្ងៃទី៥ មេសា ថ្មីៗ នេះ អាជ្ញាធរខេត្តស្រះកែវរបស់ថៃក៏បានហាមឃាត់រថយន្តដឹកពលករខ្មែរឆ្លងកាត់ខេត្តនេះដែរ និងមានពលករខ្មែរជាច្រើននាក់ត្រូវបានចាប់ខ្លួនដោយសារតែពួកគេល្មើសនឹងបម្រាមនេះ។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកក ទទួលបន្ទុកផ្នែកពលករខ្មែរ លោក គឹម ចំរើន និងអ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ ដើម្បីសុំអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេនៅថ្ងៃទី១០ មេសា ដោយទូរស័ព្ទចូលជាច្រើនដងពុំមានអ្នកទទួល។

ប៉ុន្តែគេហទំព័រស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក ចុះផ្សាយនៅថ្ងៃទី១០ មេសាថា ដោយបច្ចុប្បន្នប្រទេសថៃស្ថិតក្នុងគ្រាអាសន្ន និងមានបម្រាមគោចរ ដូចនេះស្ថានទូតស្នើឱ្យពលរដ្ឋខ្មែរដែលកំពុងស្នាក់នៅប្រទេសថៃ មេត្តាសហការជាមួយអាជ្ញាធរថៃ និងចូលរួមអនុវត្តឱ្យបានខ្ជាប់ខ្ជួនដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩។

ទោះជាយ៉ាងនេះក្តី ក៏មានពលករខ្មែររាប់រយនាក់នៅតែបន្តឆ្លងដែនត្រឡប់ទៅស្រុកកំណើតវិញដដែលដោយសារពួកគេមិនមានការងារធ្វើនៅក្នុងប្រទេសថៃ។ អាជ្ញាធរខេត្តឧត្តរមានជ័យបានបញ្ចេញរថយន្តទាហានជាច្រើនគ្រឿងដឹកពលករខ្មែរពីច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ទៅតាមបណ្តាខេត្តរៀងៗខ្លួននៅព្រឹកថ្ងៃទី១០ មេសា។ គេហទំព័រអគ្គនាយកដ្ឋានអន្តោប្រវេសន៍ឱ្យដឹងថា អាជ្ញាធរបានពិនិត្យសុខភាពពលករទាំងនោះរួចហើយទើបអនុញ្ញាតឱ្យពួកគេឡើងរថយន្តត្រឡប់ទៅផ្ទះ។

ទាក់ទងបញ្ហានេះមន្ត្រីអង្គការសង់ត្រាល់ ទទួលបន្ទុកផ្នែកពលករ លោក ឌី ថេហូយ៉ា មានប្រសាសន៍ថា ពលករខ្មែរដែលត្រឡប់ទៅកម្ពុជាវិញនោះ ភាគច្រើនធ្វើការក្រៅប្រព័ន្ធ ដែលពុំទទួលបានប្រាក់ឧបត្ថម្ភ ៥០ភាគរយពីរដ្ឋាភិបាលថៃ ក្នុងពេលដែលថៅកែរបស់ពួកគេផ្អាកការងារមួយរយៈនោះទេ។ លោកបន្ថែមថា ប្រសិនបើវិបត្តិជំងឺកូវីដ១៩ នៅតែបន្តអូសបន្លាយទៅមុខទៀត នោះនឹងធ្វើឱ្យពលករខ្មែរកាន់តែច្រើនបន្ថែមទៀតនាំគ្នាត្រឡប់ទៅស្រុកកំណើតវិញ ដោយសារពួកគេគ្មានប្រាក់ចាយវាយប្រចាំថ្ងៃនៅក្រៅប្រទេស៖ «ហើយមួយទៀតពាក់ព័ន្ធនឹងស្ថានភាពរីកវរ នៃការរាតត្បាតរោគអីចឹងជម្រើសរបស់គាត់ គឺធ្វើម៉េចឱ្យមកដល់ផ្ទះសិន ព្រោះគាត់នៅស្រុកគេវាហេលហាល ទីមួយអត់មានលុយចិញ្ចឹមជីវភាព បង់ថ្លៃបន្ទប់នៅថ្លៃហូបចុក បារម្ភពីការរីករាលដាលមេរោគហ្នឹង ធ្វើឱ្យគាត់អត់អាចទៅណាបាន ប្រសិនបើគាត់មកផ្ទះ គាត់ដើរតែរវក្តាម រាវខ្យងក៏អាចរស់បានដែរ។ ហើយជាធម្មតាមនុស្សបើអត់មានអីចិញ្ចឹមក្រពះទោះបីជាច្បាប់ហ្នឹងអាចតឹងជាងហ្នឹងក៏មិនអាចឃាត់ឃាំងពួកគាត់បានដែរ បើតាមយើងមើលសន្ទុះរបស់ពលករសព្វថ្ងៃ»។

លោក ឌី ថេហូយ៉ា បន្តថា ដើម្បីដោះស្រាយបញ្ហានេះ គឺរដ្ឋាភិបាលកម្ពុជា និងថៃ គួរតែសហការគ្នាផ្តល់ស្បៀងអាហារ និងប្រាក់បង់ថ្លៃបន្ទប់ជួលដល់ពួកគេ ដើម្បីឱ្យបានស្នាក់នៅប្រទេសថៃបន្តទៀត។ របាយការណ៍អង្គការសង់ត្រាល់ឱ្យដឹងថា ពលករខ្មែរធ្វើការខុសច្បាប់ និងស្របច្បាប់នៅក្នុងប្រទេសថៃ មានប្រមាណ ២លាននាក់។ ថ្មីៗ នេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា មានពលករខ្មែរជាង ៦ម៉ឺន (៦០.០០០) នាក់ហើយ ដែលបានត្រឡប់ទៅដល់ស្រុកកំណើតវិញ អំឡុងពេលជំងឺកូវីដ១៩ រាតត្បាតនៅលើពិភពលោក៕

# ពលករខ្មែរមួយក្រុមបន្តធ្វើការងារនៅថៃក្នុងថ្ងៃបុណ្យចូលឆ្នាំ ដើម្បីរកប្រាក់ដោះស្រាយជីវភាព

https://www.rfa.org/khmer/ ដោយ ទីន ហ្សាការីយ៉ា 2020-04-12

ពលករខ្មែរមួយក្រុមមានគ្នាប្រមាណ ២០០នាក់នឹងបន្តធ្វើការងារនៅប្រទេសថៃ ក្នុងរដូវបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ដើម្បីរកប្រាក់ចំណូលផ្ញើទៅឱ្យគ្រួសារនៅស្រុកកំណើត ដើម្បីដោះស្រាយជីវភាព មន្ត្រីអង្គការសង្គមស៊ីវិល លើកឡើងថា អំឡុងពេលនេះក្រុមពលករក៏គួរតែតាមដានស្ថានការណ៍និងបទបញ្ជារបស់អាជ្ញាធរថៃឱ្យបានញឹកញាប់ដែរ ដើម្បីកុំឱ្យមានការល្មើសច្បាប់ក្នុងពេលស្នាក់នៅប្រទេសថៃ។

ពលការិនីខ្មែរម្នាក់មានស្រុកកំណើតនៅខេត្តព្រៃវែង កញ្ញា និច សារិន ថ្លែងនៅព្រឹកថ្ងៃទី១២ មេសាថា បងប្អូនរបស់កញ្ញាចំនួន ៥នាក់ ក្នុងចំណោមពលករខ្មែរប្រមាណ២០០នាក់ដែលកំពុងធ្វើការសំណង់នៅកណ្ដាលទីក្រុងបាងកកប្រទេសថៃនោះ ពុំបានទៅចូលរួមបុណ្យចូលឆ្នាំប្រពៃណីខ្មែរនៅស្រុកកំណើតនោះទេ។ កញ្ញាបញ្ជាក់ថា នេះជាលើកទីមួយហើយនៅក្នុងជីវិត ដែលត្រូវប្រឹងធ្វើការរកប្រាក់ ដោយមិនឈប់សម្រាកក្នុងថ្ងៃបុណ្យសំខាន់របស់ជាតិ ហើយមិនបានត្រឡប់ទៅជួបឪពុកម្ដាយនោះ។ កញ្ញាបន្តថា មូលហេតុដែលមិនបានទៅលេងផ្ទះ ដោយសារតែថៅកែប្រកាសឱ្យធ្វើការងារជាធម្មតា ហើយប្រសិនបើអ្នកណាត្រឡប់ទៅស្រុកកំណើតក្នុងពេលនេះ ថៅកែនឹងមិនទទួលឱ្យចូលធ្វើការវិញឡើយ។ ដូច្នេះកញ្ញា និងសាច់ញាតិក៏សម្រេចនាំគ្នាបន្តធ្វើការនៅស្រុកគេរកប្រាក់ផ្ញើទៅឱ្យឪពុកម្ដាយប្រសើរជាងទៅផ្ទះហើយត្រឡប់មកវិញអត់ការងារធ្វើ៖ «ខ្ញុំមានអារម្មណ៍ថានឹកផ្ទះចង់ទៅផ្ទះដែរ តែធ្វើម៉េចបើយើងជីវភាពខ្វះខាត ហើយអ្នកផ្ទះជំពាក់លុយធនាគារ ហើយត្រូវឡើងការប្រាក់ឱ្យគេរាល់ខែ។ ខ្ញុំធ្វើការគេគិតឱ្យធម្មតាមិនមានគុណជា២ទេ បើរាល់ឆ្នាំពេលចូលឆ្នាំបើធ្វើការមួយថ្ងៃគេគិតថ្លៃឈ្នួលឱ្យ ២ថ្ងៃ តែដល់ពេលមានមេរោគកូវីដ១៩មក ឱ្យធ្វើការធម្មតាគេលើកថ្ងៃចូលឆ្នាំ ហើយប្រាក់ឈ្នួលធម្មតា»។

ស្រដៀងគ្នានេះដែរ ពលការិនីខ្មែរធ្វើការសំណង់នៅទីក្រុងបាងកកម្នាក់ទៀត លោកស្រី រុន សាតា ឱ្យដឹងថា ក្រៅអំពីមិនបានទៅលេងផ្ទះ ក្នុងថ្ងៃបុណ្យចូលឆ្នាំហើយ លោកស្រីក៏មិនបានទៅវត្តធ្វើបុណ្យដូចឆ្នាំកន្លងទៅដែរ ព្រោះខ្លាចឆ្លងជំងឺកូវីដ១៩។ លោកស្រីបន្តថា នឹងប្រឹងធ្វើការនៅពេលនេះ ដើម្បីសន្សំប្រាក់ផ្ញើឱ្យបងប្អូននៅស្រុកខ្មែរចាយវាយ និងសងបំណុលធនាគារ។ ទោះជាយ៉ាងណាលោកស្រីបន្ថែមថា នៅថ្ងៃបុណ្យចូលឆ្នាំខ្មែរនេះ លោកស្រី បានត្រៀមផ្លែឈើនំចំណីបន្តិចបន្តួចសម្រាប់ថ្វាយទេវតា និងដុតធូបទៀនសុំសេចក្ដីសុខនៅក្នុងបន្ទប់រៀងៗខ្លួន ដោយមិនហ៊ានជួបជុំគ្នាលេងកម្សាន្តនោះទេ៖ «អារម្មណ៍វាអួលណែនវាក្ដុកក្ដួលក្នុងចិត្ត នឹកផ្ទះក៏មិនបានទៅជីវិតត្រូវមកលំបាកមកធ្វើការឱ្យគេ ខ្ញុំនិយាយចង់អួលដើមក ចង់ទឹកភ្នែកមិនអាចរៀបរាប់អារម្មណ៍មួយហ្នឹងចេញបាន ដោយសារជីវភាពហ្នឹងឯង។ យើងមករកស៊ីនេះផ្ដល់ប្រាក់ទៅឱ្យដូចថាទប់ស្កាត់មិនបានសោះ ព្រោះគ្រួសារបងប្អូននៅតូចៗ ហើយអ្នកផ្ទះគាត់ធ្វើស្រែ និងដាំដំណាំក៏គ្មានអ្នកណាគេទិញ ហើយរំពឹងលុយខ្ញុំរកម្នាក់ឯងផ្ដល់ឱ្យគាត់»។

កាលពីថ្ងៃទី៣ មេសា រដ្ឋាភិបាលថៃបានប្រើច្បាប់ប្រកាសអាសន្ន ហាមឃាត់ប្រជាពលរដ្ឋធ្វើដំណើរចេញក្រៅផ្ទះចាប់ពីម៉ោង ១០យប់ ដល់ម៉ោង៤ទៀបភ្លឺ និងហាមប្រមូលផ្ដុំគ្នាជាក្រុម ដើម្បីទប់ទល់ការរាតត្បាតជំងឺលោកផ្លូវដង្ហើមថ្មី។ ប្រសិនជនណាល្មើសនឹងបម្រាមនេះ អាចត្រូវជាប់ពន្ធនាគាររហូត ២ឆ្នាំ និងពិន័យជាប្រាក់ ៤ម៉ឺនបាត (៤០,០០០) ឬប្រមាណ ១ពាន់ ៣០០ដុល្លារអាមេរិក។

ថ្មីៗនេះស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកក ក៏បានជូនដំណឹងដល់ប្រជាពលរដ្ឋខ្មែរដែលកំពុងស្នាក់នៅប្រទេសថៃ សហការតាមការណែនាំរបស់រដ្ឋាភិបាលថៃឱ្យបានខ្ជាប់ខ្ជួន ដើម្បីការពារកុំរាលដាលឆ្លងជំងឺកូវីដ១៩ ហើយប្រសិនបើពលរដ្ឋណាមានបញ្ហាអំឡុងពេលនេះ ពួកគាត់ អាចទាក់ទងតាមរយៈហ្វេសប៊ុករបស់ស្ថានទូត ឬទូរស័ព្ទលេខ ០៩២៨០៥០ ៥៦១។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក(Adhoc) ខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា យល់ថា ពលករខ្មែរដែលមិនត្រឡប់ទៅផ្ទះអំឡុងពេលនេះ ភាគច្រើនដោយសារតែជីវភាពគ្រួសាររបស់ពួកគាត់ក្រី

ក្រ ទើបជំរុញឱ្យពួកគាត់បង្ខំចិត្តស្នាក់នៅស្រុកគេ ដើម្បីរកប្រាក់ផ្គត់ផ្គង់គ្រួសារ។ លោកបន្ថែមថា ក្រុមពលករក៏ត្រូវតែតាមដានព័ត៌មាននៅក្នុងប្រទេសថៃឱ្យបានជិតដល់ដែរ ដើម្បីសម្របទៅតាមច្បាប់របស់ថៃ៖ «ទីមួយសុវត្ថិភាពមិនត្រូវបានគេចាប់ចង ទី២សុវត្ថិភាពរួចផុតអំពីជំងឺរាតត្បាតដែលឆ្លងមកដល់ពួកគាត់។ អីចឹង គាត់អាចទាក់ទងទៅស្ថានទូតបាន ដើម្បីឱ្យគេទំនាក់ទំនងទៅរដ្ឋាភិបាលនិងរដ្ឋាភិបាល ហើយគាត់នឹងត្រូវទទួលបានអ្វីមកវិញ។ប៉ុន្តែបើសិនគាត់ធ្វើអ្វីដែលខុសពីហ្នឹងគាត់មិនអាចទទួលលទ្ធផលណាមួយបានទេ ពីព្រោះថា នៅក្នុងប្រទេសដែលដាក់គ្រាមានអាសន្ន ត្រូវតែធ្វើយ៉ាងណាប្រយ័ត្នប្រយែងដល់ខ្លួនឯងផង ដល់អ្នកដទៃផង»។

ថ្មីៗនេះអាជ្ញាធរថៃបានហាមឃាត់រថយន្តដឹកពលករខ្មែរឆ្លងកាត់ខេត្តស្រះកែវ និងខេត្តសុរិន្ទហើយ ប្រសិនជនណាល្មើសបម្រាមនេះនឹងត្រូវជាប់គុក ១ឆ្នាំ និងពិន័យជាប្រាក់ប្រមាណ ១០ម៉ឺនបាត ឬស្មើនឹង៣ពាន់ដុល្លារទៀតផង។ ជាមួយគ្នានេះអាជ្ញាធរថៃ ក៏បានចាប់ពលករខ្មែរជាច្រើននាក់បញ្ជូនទៅតុលាការរួចមកហើយដែរ ដោយសារពួកគេល្មើសនឹងបម្រាមគោចររបស់ថៃ៕

## ថៃ អនុញ្ញាតឲ្យពលរដ្ឋខ្មែរដែលជាប់គាំងក្នុងប្រទេសខ្លួន បន្តស្នាក់នៅដោយគ្មានការផាកពិន័យ

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 13 April 2020 | 10:22 ICT

**ភ្នំពេញៈ** ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃឲ្យដឹងថា ភាគីថៃអនុញ្ញាតឲ្យពលរដ្ឋខ្មែរដែលកំពុងជាប់គាំងក្នុងប្រទេសខ្លួន ដោយសារការរឹតត្បិតក្នុងការធ្វើដំណើរអាចបន្តស្នាក់នៅក្នុងប្រទេសនេះដោយគ្មានការផាកពិន័យរហូតដល់ស្ថានភាពនៃជំងឺកូវីដ១៩មានភាពស្ងប់ស្ងាត់។ សេចក្ដីជូនដំណឹងរបស់ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃចុះថ្ងៃទី ៩ មេសា ឲ្យដឹងថា ដើម្បីសម្រួលដល់បងប្អូនដែលជាប់នៅប្រទេស ថៃ ដោយសារការរឹតត្បិតការធ្វើដំណើរទាំងផ្លូវគោក ផ្លូវទឹក រួមទាំង ផ្លូវអាកាស ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ រាជរដ្ឋាភិបាលថៃបានផ្ដល់ការអនុគ្រោះឲ្យពលរដ្ឋខ្មែរបន្តស្នាក់នៅបណ្ដោះអាសន្ន ដោយស្វ័យប្រវត្តិ ដោយមិនចាំបាច់ធ្វើដំណើរទៅស្នើសុំនៅការិយាល័យអន្តោប្រវេសន៍ថៃនោះទេ។ ស្ថានទូតកម្ពុជាបញ្ជាក់ថា៖ «សម្រាប់បងប្អូនដែលប្រើប្រាស់ទិដ្ឋាការប្រភេទទេសចរណ៍ ១៤ ថ្ងៃ និងទិដ្ឋាការផ្សេងៗ ហើយបានផុតសុពលភាពចាប់ពីថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០២០ ត្រូវបានអនុញ្ញាតឲ្យបន្តស្នាក់នៅដោយស្វ័យប្រវត្តិរហូតដល់ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២០ ដោយមិនមានការផាកពិន័យ។ សម្រាប់បងប្អូនដែលប្រើប្រាស់បណ្ណព្រំដែនចូលក្នុងប្រទេសថៃ សេចក្ដីជូនដំណឹងរបស់ស្ថានទូតបន្តថា គឺត្រូវបានអនុញ្ញាតឲ្យបន្តស្នាក់នៅរហូតដល់ពេលព្រំដែនបើកវិញ។ បន្ទាប់មកភាគីថៃតម្រូវឲ្យពលរដ្ឋខ្មែរត្រូវចាកចេញយ៉ាងយូរក្នុងរយៈពេល ៧ ថ្ងៃ។ ដោយឡែកពលរដ្ឋខ្មែរដែលប្រើប្រាស់ទិដ្ឋាការស្នាក់នៅរយៈពេលវែង អាជ្ញាធរថៃតម្រូវឲ្យទៅដាក់ពាក្យស្នើបន្តសុពលភាពសម្រាប់ការស្នាក់នៅនៅការិយាល័យអន្តោប្រវេសន៍ថៃដដែល។

លោក ឌី ថេហូយ៉ា មន្ត្រីកម្មវិធីផ្នែកសិទ្ធិពលករចំណាកស្រុកនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារកម្ពុជា (សង់ត្រាល់) លើកឡើងថា វិធានការនេះក៏ជាវិធានការល្អ ដើម្បីអាចឲ្យពលរដ្ឋខ្មែរដែលកំពុងជាប់នៅប្រទេសថៃអាចស្នាក់នៅទីនោះមួយរយៈសិន។ លោកថា ការគិតគូរពីសុខទុក្ខពលរដ្ឋខ្មែរដែលកំពុងជាប់គាំងដូចជាការជួយ ការហូបចុកប្រចាំថ្ងៃនោះក៏ជារឿងមួយដែលរដ្ឋាភិបាលគួរតែគិតគូរផងដែរ។ ព្រោះពេលនេះមានពលរដ្ឋខ្មែរ ដែលមិនអាចត្រឡប់មកវិញជាច្រើនកំពុងប្រឈមនឹងការខ្វះខាត។ លោកថា៖ «ចំពោះចំណុចដែលសំខាន់ដែលពួកគាត់ប្រឈមគឺប្រឈមអត់មានការងារធ្វើ អត់ប្រាក់ចំណូលដែលគាត់មិនអាចរស់បាន។ ព្រោះបើសម្រួលតែឯកសារគោលការណ៍នេះគឺការជួយបណ្ដោះអាសន្នដែលពួកគាត់ នៅតែប្រឈមលើស្បៀងអាហារ និងការរស់នៅប្រចាំថ្ងៃដែរ។ ដូច្នេះត្រូវមើលទៅលើបញ្ហាប្រឈមរបស់ពួកគាត់ធ្វើយ៉ាងម៉េចសហការជាមួយអាជ្ញាធរថៃឲ្យបាន និងអនុវត្តឲ្យមានប្រសិទ្ធភាព បើសិនជាមេរោគកូវីដនេះ បន្តអូសបន្លាយ»។

កញ្ញា ជា បូរ៉ា ពលករចំណាកស្រុកម្នាក់ប្រាប់ភ្នំពេញប៉ុស្ដិ៍តាមហ្វេសប៊ុកពីម្សិលមិញថា កញ្ញាមិនអាចវិលត្រឡប់ទៅផ្ទះនៅប្រទេសកម្ពុជាបានទេ ព្រោះការដើរហើរក្នុងប្រទេសនេះបានបិទ ម្យ៉ាងព្រោះតែខ្លាចជំងឺរាតត្បាត។

កញ្ញាថា ការសម្រេចមិនត្រឡប់ទៅវិញនេះក៏ព្រោះតែមិនចង់នាំទុក្ខដល់ក្រុមគ្រួសារ។ ម្យ៉ាងទៀតបើទៅដល់ផ្ទះក៏ត្រូវស្នាក់នៅម្នាក់ឯងរយៈពេល ១៤ ថ្ងៃដដែល ដូច្នេះមិនទៅល្អជាង។ កញ្ញា បូ៉ា និយាយថា៖ «ឆ្នាំនេះវាលំបាករឿងជំងឺហ្នឹង ហើយបើទៅត្រឡប់មកគេឲ្យសម្រាក ១៤ ថ្ងៃ។ អ៊ីចឹងខ្ញុំក៏អត់បានទៅ ទៅ។ គ្រាន់ខ្ញុំនៅថៃនេះគឺធ្វើការធម្មតាទេ។ តែសេដ្ឋកិច្ចថៃធ្លាក់ខ្លាំងដែរ ដូច្នេះមានពលរដ្ឋខ្មែរខ្លះ គាត់ក៏លំបាកដែរ»។ បើតាមកញ្ញា បូ៉ា រដ្ឋាភិបាលថៃប្រកាសដាក់ប្រទេសក្នុងភាពអាសន្ន ក្នុងពេលនេះពលរដ្ឋទាំងអស់មិនអាចដើរចេញក្រៅក្នុងអំឡុងម៉ោង ១០ យប់ដល់ម៉ោង ៤ ជិតភ្លឺ។ ក្នុងនោះមានពលរដ្ឋខ្មែរមួយចំនួនត្រូវធ្វើការវេនយប់ក៏ត្រូវបាត់បង់ការងារផងដែរ។ តាមកញ្ញាដឹង អ្នកដែលអាចធ្វើការបានធម្មតាគឺមានតែពលរដ្ឋខ្មែរដែលកំពុងធ្វើការផ្នែកម្ហូបអាហារប៉ុណ្ណោះ។

តាមលោក ពេជ្រ វណ្ណា ប្រធានការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ ប្រាប់ភ្នំពេញប៉ុស្តិ៍ថ្ងៃទី ៨ មេសា ថាគិតត្រឹមថ្ងៃទី ៦ មេសាមានពលរដ្ឋខ្មែរប្រមាណជាង ៦ ម៉ឺននាក់វិលត្រឡប់ចូលកម្ពុជា៕

## ប្រជាជនថៃបានប្តឹងទៅអាជ្ញាធរថៃថា.នៅកន្លែងកសាងមានពលករខុសច្បាប់ធ្វើការអត់មានឯកសារអ្វីទាំងអស់

https://www.facebook.com/LABOURKHMER/ 12-04-2020 ទឹកចិត្ត ពលករ ឆ្លងដែន

ប្រជាជនថៃបានប្តឹងទៅអាជ្ញាធរថៃថា. នៅកន្លែងកសាងមានពលករខុសច្បាប់ធ្វើការអត់មានឯកសារអ្វីទាំងអស់ ទើបអាជ្ញាធរថៃចុះមកត្រួតចាប់បានពលករខុសច្បាប់ចំនួន8នាក់ ក្នុងនោះមានពលករជនជាតិភូមា6នាក់ និងពលករខ្មែរ2នាក់ នាមឈ្មោះនៅខាងក្រោម៖

1.ពលករខ្មែរឈ្មោះ បឿល ភេទប្រុសអាយុ40ឆ្នាំ

2.ពលករខ្មែរឈ្មោះ សន ភេទប្រុសអាយុ20ឆ្នាំ

3.ពលករជនជាតិភូមាឈ្មោះ ណៃ ភេទប្រុសអាយុ30ឆ្នាំ

4.ពលករជនជាតិភូមាឈ្មោះ ដែង ភេទប្រុសអាយុ 19ឆ្នាំ

5.ពលករជនជាតិភូមាឈ្មោះ វី ភេទប្រុសអាយុ20ឆ្នាំ

6.ពលករជនជាតិភូមាឈ្មោះ នុច ភេទស្រីអាយុ40ឆ្នាំ

7.ពលករជនជាតិភូមាឈ្មោះ ភិរ ភេទប្រុសអាយុ19 ឆ្នាំ

8.ពលករជនជាតិភូមាឈ្មោះ ម៉ូ ភេទស្រីអាយុ35 ឆ្នាំ

ពលករទាំងអស់នេះត្រូវអាជ្ញាធរថៃចាប់ក្នុងករណីធ្វើការខុសច្បាប់ ហេតុការណ៍បានកើតឡើងនៅខេត្តប៉ាថុមថានី ប្រទេសថៃ (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន) 12-4-2020

# ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០

## ពលករប្រុសស្រីចំនួន៥នាក់ត្រូវបានអាជ្ញាធរខេត្តក្រចេះបញ្ជូនមកឱ្យស្នាក់នៅដាច់ដោយឡែកពីក្រុមគ្រួសាររយៈពេល១៤ថ្ងៃ

http://ppd-news.net/ ថ្ងៃចេញផ្សាយ: April 13, 2020

**ខេត្តក្រចេះ ៖** នាព្រឹកថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០នេះ លោក ប៉ែន លីណាត អភិបាលរងខេត្តក្រចេះ និងជាអនុប្រធានគណៈកម្មប្រយុទ្ធប្រឆាំងជំងឺកូវីត១៩ និងលោកអភិបាលក្រុងក្រចេះ លោកចៅសង្កាត់អូឬស្សី រួមនិងមន្ត្រីសុខាភិបាល បានបញ្ជូនពលករប្រុស ស្រីចំនួន៥នាក់ដែលត្រឡប់ពីប្រទេសថៃឲ្យរស់នៅដាច់ដោយឡែកពីសមាជិកក្រុមគ្រួសាររបស់ពួកគាត់រយៈពេល១៤ថ្ងៃសិន ដើម្បីទប់ស្កាត់ ការពារ នូវការឆ្លងវីរុសកូវីដ១៩ ដែលជាគោលការណ៍របស់ក្រសួងសុខាភិបាលតម្រូវឲ្យអ្នកទាំងនោះ ដើម្បីឲ្យគ្រូពេទ្យពិនិត្យតាមដានស្វែងរករោគសញ្ញា។

លោក ឈឹន រិទ្ធ ចៅសង្កាត់អូឬស្សី បានបញ្ជាក់ថា ពលករទាំងនេះ មានស្រុកកំណើតនៅក្នុងស្រុកឆ្លូង ចំនួន៣នាក់ នៅស្រុកស្នួលចំនួន២ នាក់ជាប្តីប្រពន្ធ។ លោកបញ្ជាក់ទៀតថា បច្ចុប្បន្ននេះ យើងឲ្យពួកគាត់ស្នាក់នៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលស្ថិតនៅក្នុងសង្កាត់អូរឫស្សី២ ក្រុងក្រចេះខេត្តក្រចេះ ដើម្បីតាមដានស្វែងរកនូវរោគសញ្ញាកូវីដ១៩ ប្រសិនជាពួកគាត់មានផ្ទុកនោះ។

សូមបញ្ជាក់ថា នៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនេះ មានគ្រែសម្រាប់ឲ្យពួកគាត់ស្នាក់នៅបានស្រួល ដោយមានទឹក.ភ្លើងប្រើប្រាស់គ្រប់គ្រាន់ មានអាហារហូបចុក និងមានក្រុមគ្រូពេទ្យប្រចាំការនៅទីនោះផងដែរ។ ចំពោះខេត្តក្រចេះ មកទល់នឹងថ្ងៃនេះ យើងសង្កេតឃើញ អាជ្ញាធរខេត្ត ស្រុក ក្រុង ឃុំ សង្កាត់បានរួមសហការគ្នាបានល្អ ហើយកំណត់ យកទីតាំងចំនួន៥កន្លែង ក្នុងទីរួមខេត្តធ្វើជាទីតាំងសម្រាប់ឱ្យពលករ ដែលវិលត្រឡប់មកពីធ្វើការនៅក្រៅប្រទេសបានស្នាក់នៅក្នុងរយៈពេល១៤ថ្ងៃសិន មុននឹងឲ្យពួកគាត់ទៅរស់នៅជាមួយក្រុមគ្រួសារពួកគាត់វិញ ការធ្វើបែបនេះគឺដើម្បីការពារសុវត្ថិភាព និងការទប់ស្កាត់ បញ្ចៀសនូវការឆ្លងរីករាលដាលនៃវីរុសកូវីត១៩។

សូមបញ្ជាក់ផងដែរថា សម្រាប់ខេត្តក្រចេះ មកទល់នឹងថ្ងៃទី១៣ ខែមេសានេះគឺពុំទាន់មានអ្នកឆ្លងវីរុស កូវីត១៩នោះទេ។ ទាំងនេះគឺជាការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់អាជ្ញាធរខេត្ត ដែលមានលោក វ៉ា ថន ជាអភិបាលនៃគណៈអភិបាលខេត្តក្រចេះ និងជាប្រធានគណៈកម្មការប្រយុទ្ធប្រឆាំងនឹងជំងឺ រាតត្បាតកូវីដ១៩ ក៏ដូចជាមានការយកចិត្តទុកដាក់ខ្ពស់ ពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេចតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី ដែលលោកតែងគិតគូរពីសុខទុក្ខ និងសុខមាលភាពរបស់ប្រជាពលរដ្ឋគ្រប់រូប មិនឲ្យពលរដ្ឋណាម្នាក់ដែលស្លាប់ដោយជំងឺនេះដោយមិនបានព្យាបាលនោះទេ។ ព្រមទាំងមានបទបញ្ជារដល់កងកម្លាំង សមត្ថកិច្ចដែលពាក់ទាំងអស់ ចូលរួមការពារការធ្វើដំណើរឆ្លងកាត់ពីខេត្តមួយទៅខេត្តមួយទៀត និងការជួបជុំគ្នាមានច្រើនក៏ត្រូវហាមឃាត់ដែរ។ ការធ្វើបែបនេះ នឹងការពារនូវសុខសុវត្ថិភាពជូនប្រជាពលរដ្ឋ និងដើម្បីបញ្ចៀសបាននូវការឆ្លងវីរុសកូរ៉ូណា (កូវីដ១៩) ទាំងអស់គ្នា៕ ដោយ ៖ ស៊ាន ចន្ទ័ដា

## ពលរដ្ឋខ្មែរមកពីថៃជាង៥០០នាក់ត្រូវដឹកទៅដាក់អគារបំរុង ដើម្បីពិនិត្យរកកូវីដ១៩

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០២០ ម៉ោង ១៤:២៤ ប៊ុន ធឿន

ខេត្តបន្ទាយមានជ័យ ៖ បើតាមសេចក្តីរាយការណ៍បានឱ្យដឹងថា រថយន្តក្រសួងការពារជាតិបានដឹកពលករខ្មែរជាង៥០០នាក់តាមបន្ទាត់ព្រំដែន ទៅដាក់នៅអគារវិទ្យាល័យសិរីសោភ័ណ ដើម្បីពិនិត្យរកវីរុសកូវីដ១៩ រយៈពេល៣ថ្ងៃ ហូតដល់ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០ ស្ថិតនៅក្រុងសិរីសោភ័ណ។

បើតាមលោក អ៊ាវ ដារ៉ាវុធ ប្រធានមន្ទីរពេទ្យបង្អែកក្រុងសិរីសោភ័ណ បានប្រាប់ថា នៅក្រុងសិរីសោភ័ណ ដោយបានការយកចិត្តទុកដាក់ពីអភិបាលខេត្ត បានត្រៀមបម្រុងអគារនៅក្នុងក្រុងសិរីសោភ័ណ ចំនួន៣កន្លែង សម្រាប់ដាក់ពលករខ្មែរដែលត្រូវទទួលមកពីតាមបន្ទាត់ព្រំដែនមកពីច្រកឡែម ខេត្តបាត់ដំបង និងច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យ ព្រមទាំងច្រកអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យផងដែរ។ លោកបានបញ្ជាក់ថា ជាក់ស្តែងនៅវិទ្យាល័យសិរីសោភ័ណ ស្ថិតក្រុងសិរីសោភ័ណ ដែលរថយន្តក្រសួងការពារជាតិដឹកពលករពីតាមបន្ទាត់ព្រំដែន មកដាក់នៅកន្លែងត្រៀមបម្រុងអគារវិទ្យាល័យសិរីសោភ័ណរយៈពេល៣ថ្ងៃនេះ មានប្រមាណជាង៥០០នាក់។ ក្រោយពេលពិនិត្យក្រុមគ្រូពេទ្យ (ចត្តាឡីស័ក) មន្ទីរពេទ្យបង្អែកហើយ បើគ្មានជាប់សង្ស័យឆ្លងវីរុសកូវីដ១៩ទេ ត្រូវរថយន្តនឹងដឹកពលរដ្ឋទាំងអស់ដាក់តាមបណ្តាខេត្ត និងស្រុករបស់ខ្លួន ដែលអាជ្ញាធរទទួលយកដាក់តាមទីតាំងត្រៀមបម្រុងទុក ដើម្បីបង្ការ និងទប់ស្កាត់ការពាររាតត្បាតដោយវីរុសកូវីដ១៩ ដែលមានរយៈពេល១៤ថ្ងៃនៅឆ្ងាយពីសាច់ញាតិ។

លោក ហ៊ឹល រ៉ាយ៉ា អភិបាលក្រុងសិរីសោភ័ណ បានថ្លែងអំណរគុណចំពោះក្រសួងការពារជាតិ ដែលបានផ្តល់រថយន្តសម្រាប់ដឹកពលករខ្មែរដែលមកពីថៃ ដាក់តាមកន្លែងត្រៀមបម្រុង ដើម្បីធ្វើការពិនិត្យដោយគ្រូពេទ្យជំនាញចត្តាឡីស័ក ក្រោយពេលពិនិត្យហើយត្រូវបានបញ្ជូនទៅតាមមូលដ្ឋានរបស់ខ្លួន។ ហើយការស្នាក់ពិនិត្យ គឺអភិបាលខេត្តបន្ទាយមានជ័យ បានត្រៀមបម្រុងទុកកន្លែងស្នាក់នៅ និងម្ហូបអាហារសម្រាប់ពលករដែលត្រូវបញ្ជូនមកដាក់កន្លែងពិនិត្យ ដោយគ្រូពេទ្យដែលធ្វើការ២៤ម៉ោង។ លោកបានអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ក្រោយពេលត្រឡប់ពីប្រទេសថៃ ត្រូវនៅឱ្យឆ្ងាយពីគ្រួសារឱ្យបាន១៤ថ្ងៃ ហើយមិនត្រូវឆ្លងកាត់ពីខេត្តមួយទៅខេត្ត និងឱកាសបុណ្យឆ្នាំថ្មីខាងមុខនេះ មិនត្រូវជួបជុំគ្នា ដើម្បីបង្កា និងទប់ស្កាត់ការពារវីរុសកូវីដ១៩ ហើយត្រូវចូលធ្វើអនាម័យ និងលាងដៃដោយសាប៊ូ ឬអាកុល ត្រូវពាក់ម៉ាសឱ្យបានគ្រប់ៗគ្នា៕ (កែសម្រួលដោយ ៖ បុប្ផា)

## ពលករទើបត្រឡប់មកពីក្រៅប្រទេស ក្នុងខេត្តត្បូងឃ្មុំ ត្រូវដាក់ខ្លួននៅដាច់ដោយឡែក១៤ថ្ងៃ ដើម្បីខ្លួនឯង និងក្រុមគ្រួសារ

http://kampucheathmey.com/ 13/4/2020 2:33 Pm

ត្បូងឃ្មុំ ៖ លោក ចេង ប៊ុណ្ណារ៉ា អភិបាលរងខេត្តត្បូងឃ្មុំ តំណាងលោកបណ្ឌិត ជាម ច័ន្ទសោភ័ណ អភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ បានលើកឡើងក្នុងពិធីសំណេះសំណាលសួរសុខទុក្ខ ជាមួយនឹងបងប្អូនប្រជាពលករ២១នាក់បន្ថែមទៀត ដែលទើបវិលត្រឡប់មកពីធ្វើការ នៅប្រទេសថៃ កាលពីយប់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ នាមន្ទីរពេទ្យបង្អែកព្រះនរោត្តមសីហនុត្បូងឃ្មុំ ដែលស្ថិតនៅក្រុងសួង ខេត្តត្បូងឃ្មុំ ថា ត្រូវដាក់ខ្លួននៅដាច់ដោយឡែក១៤ថ្ងៃ ដើម្បីខ្លួនឯង និងក្រុមគ្រួសារ ចៀសឆ្ងាយជំងឺកូវីដ-១៩។ ថ្លែងនាឱកាសនោះលោក ចេង ប៊ុណ្ណារ៉ា បានសំណូមពរដល់បងប្អូនប្រជាពលករទាំងអស់ សូមដាក់ខ្លួនឲ្យនៅដាច់ដោយឡែក រយៈពេល១៤ថ្ងៃ និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវ តាមការណែនាំរបស់អាជ្ញាធរមូលដ្ឋាន មន្ត្រីជំនាញសុខាភិបាល ដើម្បីរួមគ្នាទប់ស្កាត់ជំងឺកូវីដ-១៩។

ជាងនេះទៅទៀត លោកក៏បានផ្តាំផ្ញើឲ្យបងប្អូនត្រូវខិតខំអនុវត្តតាមវិធានការរបស់ក្រសួងសុខាភិបាល ដែលបានអប់រំណែនាំ ជាពិសេស គឺសូមបងប្អូនប្រជាពលរដ្ឋឲ្យយល់ពីបទបញ្ជារបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញនាពេលនេះ ក្នុងគោលបំណងសុខសុវត្ថិភាព សម្រាប់ទាំងអស់គ្នា ដើម្បីចាកឆ្ងាយពីជំងឺកូវីដ-១៩ ដែលកំពុងរាតត្បាតនេះ។ ក្នុងឱកាសនោះ លោកបានក្រើនរំលឹកដល់អាជ្ញាធរមូលដ្ឋាន ក៏ដូចជាប្រជាពលរដ្ឋ ត្រូវមានវិធានការទប់ស្កាត់ ការរីករាលដាល នៃជំងឺ កូវីដ-១៩ ពីព្រោះថា ការប្រុងប្រយ័ត្ននេះ ជាការឆ្លើយតបនឹងជំងឺឆ្លងថ្មីនេះ ដែលបានកំពុងរីករាលដាលជាសកល បង្កឲ្យមនុស្សឈឺ និងស្លាប់ ជាបន្តបន្ទាប់។ ដោយឡែកប្រទេសកម្ពុជា នៅតែបន្តរកឃើញនូវជំងឺឆ្លងថ្មីជាបន្តបន្ទាប់គួរឲ្យព្រួយបារម្ភផងដែរ៕ អត្ថបទ ៖ ឧត្តរ៉ា

## ថ្នាក់ដឹកនាំខេត្តត្បូងឃ្មុំ ចុះពិនិត្យទីតាំងត្រៀមដាក់ពលករមកពីប្រទេសថៃ ដាច់ដោយឡែក១៤ថ្ងៃ ក្នុងស្រុកតំបែរ

https://grandnewsasia.com/ 13-04-2020

ត្បូងឃ្មុំ៖ លោក ចេង ប៊ុណ្ណារ៉ា អភិបាលរងខេត្តតំណាងលោក ជាម ច័ន្ទសោភ័ណ អភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ បានដឹកនាំក្រុមការងារចុះពិនិត្យទីតាំងសាលារៀនចំនួន ០៤ ក្នុងស្រុកតំបែរ រួមមាននៅឃុំចុងជាច ឃុំនាងទើត ឃុំត្រពាំងព្រីង និងឃុំគោកចារ ដើម្បីរៀបចំដាក់ពលករដែលមកពីប្រទេសថៃឲ្យស្នាក់នៅដាច់ដោយឡែកចំនួន ១៤ថ្ងៃ។ លោក ចេង ប៊ុណ្ណារ៉ា បានផ្តាំផ្ញើ និងជំរុញដល់

ក្រុមការងារដែលទទួលខុសត្រូវ សម្របសម្រួលបងប្អូនប្រជាពលរដ្ឋមកពីប្រទេសថៃ ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ត្រូវចុះតាមខ្នងផ្ទះ ដែលប្រជាពលរដ្ឋទើបមកពីប្រទេសថៃ ដោយណែនាំ ពួកគាត់ឲ្យដាក់ខ្លួនដាច់ដោយឡែករយៈពេល១៤ថ្ងៃ ស្របតាមនីតិវិធីកំណត់របស់ក្រសួងសុខាភិបាល និងបង្កើនសកម្មភាពផ្សព្វផ្សាយអំពីវិធីបង្ការ និងទប់ស្កាត់ការឆ្លងវីរុសកូវីដ១៩ នៅតាមមូលដ្ឋានរៀងៗខ្លួនផងដែរ។ បន្ទាប់មកលោកចេង ប៊ុណ្ណារ៉ា រួមជាមួយសមាគមន៍នារីដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្ត ដឹកនាំដោយលោកស្រី នី ចាន់ធីតា អភិបាលរងខេត្ត រួមជាមួយអាជ្ញាធរស្រុក ឃុំ នាំយកនូវទេយ្យវត្ថុ និងបច្ច័យប្រគេនព្រះសង្ឃចំនួន ២វត្ត ព្រមទាំងចុះសួរសុខទុក្ខជំទប់ទី២ ឃុំត្រពាំងព្រីង ក្នុងស្រុកតំបែរ ដែលកំពុងសម្រាកព្យាបាលជម្ងឺផងដែរ ៕

## ខេត្តសៀមរាបមានពលករខ្មែរមកពីថៃជាង ១ ម៉ឺននាក់ គិតចាប់ពីថ្ងៃទី១០ ខែមីនា ដល់ ១៣ ខែមេសា

---

http://kampucheathmey.com/ 14/4/2020 9:43 Am

ពលករខ្មែរដែលមកពីប្រទេសថៃចូលមកកម្ពុជា ចាប់ពីថ្ងៃទី១០ ខែមីនា មកទល់ថ្ងៃទី១៣ ខែ មេសា ឆ្នាំ ២០២០ មានចំនួន ជាង១ម៉ឺននាក់ នៅទូទាំងខេត្តសៀមរាប។ នេះបើតាមរបាយការណ៍របស់អាជ្ញាធរខេត្ត ដែលកម្ពុជាថ្មីទទួលបាន។ ពលកទាំងអស់មកតាមច្រក ទី១ច្រកដូង ក្នុងខេត្តបាត់ដំបង ទី២អូស្មាច់ និងទី៣ប៉ោយប៉ែត ក្នុងខេត្តបន្ទាយមានជ័យ។ អាជ្ញាធរខេត្តសៀមរាបបានត្រៀមលក្ខណៈជាបន្តបន្ទាប់ ក្នុងការដាក់ប្រជាពលរដ្ឋទាំងនោះដាច់ដោយឡែក ដើម្បីការពារឆ្លងរីករាលដាលនៃ Covid-19។ រាយការណ៍៖ គឿន វេត

## ពលករ១៣នាក់ ឆ្លងដែនមកពីថៃ កម្តៅឡើងខុសប្រក្រតី ត្រូវអាជ្ញាធរដាក់ឲ្យនៅដាច់ដោយឡែក

---

http://kampucheathmey.com/ 14/4/2020 11:30 Am

ឧត្តរមានជ័យ ៖ ពលករចំណាកស្រុកមកពីប្រទេសថៃចំនួន១៣នាក់ ត្រូវបានអាជ្ញាធរដាក់ឲ្យនៅដាច់ដោយឡែក ព្រោះកម្តៅឡើងខុសប្រក្រតី។ សមត្ថកិច្ចបានឲ្យដឹងថា កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង១៣និង៤០នាទី មានពលករចំណាកស្រុកមកពីប្រទេសថៃចំនួន១៣នាក់ ស្រី០៦នាក់ ក្មេងចំនួន០៤នាក់ ហើយ បានវាស់កម្តៅពិនិត្យសុខភាព និងដាក់ឲ្យរស់នៅដាច់ដោយឡែករយៈពេល១៤ថ្ងៃ ដើម្បីតាមដានសុខភាព។ ពលករចំណាកស្រុកមកពីប្រទេសថៃចំនួន១៣នាក់ រួមមាន ៖

១. លោក យូ បញ្ញា ភេទប្រុស អាយុ៣៦ឆ្នាំ(ប្តី) រស់នៅភូមិអូរជាសែនជ័យ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កម្តៅ៣៧.៦អង្សា ចេញមកច្រកម៉ាឡៃ។ ២.ឈ្មោះ ហៀប ម៉ៅ ភេទស្រី អាយុ៤០ឆ្នាំ(ប្រពន្ធ) រស់នៅភូមិអូរថាសែនជ័យ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កម្តៅ៣៦.៩អង្សា ចេញមកច្រកម៉ាឡៃ ។ ៣.ឈ្មោះ ភ ស ម៉ ភេទស្រី អាយុ០៤ឆ្នាំ(កូន) រស់នៅភូមិអូរជាសែនជ័យ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កម្តៅ៣៦.៩អង្សា ចេញមកពីច្រកម៉ាឡៃ។

៤.ឈ្មោះ យូ រាក ( ប្តី )រស់នៅភូមិអូរជាសែនជ័យឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កម្តៅ ៣៦.៩អង្សា ចេញមកពីច្រកម៉ាឡៃ។ ៥.ឈ្មោះ ឆាន់ ណារី ភេទស្រី អាយុ៣៨ឆ្នាំ (ប្រពន្ធ) រស់នៅភូមិអូជាសែនជ័យ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ ៦.ឈ្មោះ ភ ស ល ភេទ ប្រុស អាយុ០៥ឆ្នាំ(កូន) រស់នៅភូមិអូរជាសែនជ័យ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កម្តៅ៣៧.៨អង្សា ចេញមកពីច្រកម៉ាឡៃ។ ៧.

ឈ្មោះ ភ ព ភេទ(ប្រុស) អាយុ១៥ឆ្នាំ (កូន)រស់នៅភូមិអូរជាសែនជ័យ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កម្តៅ៣៧.៤អង្សា។

៨.ឈ្មោះ អិន ជា ភេទប្រុស អាយុ៣៤ឆ្នាំ (នៅលីវ)រស់នៅភូមិអូរជាសែនជ័យ ឃុំអំពិលស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កម្តៅ៣៧.២អង្សា។ ៩. ឈ្មោះ អិន រីត ភេទស្រី អាយុ៣៣ឆ្នាំ (មេម៉ាយ)រស់នៅភូមិអូរជាសែនជ័យ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កម្តៅ៣៦.៦អង្សា។ ១០- ឈ្មោះ អ ដ ភេទស្រី អាយុ០៩ឆ្នាំ(កូន) រស់នៅភូមិអូរជាសែនជ័យ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កម្តៅ៣៦.៨អង្សា។ ១១- ឈ្មោះ អ វ ភេទប្រុស អាយុ០៣ឆ្នាំ( កូន) រស់នៅភូមិអូរជាសែនជ័យ ឃុំគឃុំអំពិលស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កម្តៅ៣៦.៥អង្សា។ ១២- ឈ្មោះ ប្រា ប្រុញ ភេទប្រុស អាយុ២៤ឆ្នាំ (ប្តី) រស់នៅភូមិប្រសាទវំដួល ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កម្តៅ៣៧.១អង្សា។ ១៣-ឈ្មោះ ប៊ុន ស្រីអ៊ុយ ភេទស្រី អាយុ២០ឆ្នាំ ប្រពន្ធ រស់នៅភូមិ ប្រសាទវំដួល ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កម្តៅ៣៧.១អង្សា។

សូមបញ្ជាក់ថា ពលករទាំង១៣នាក់ខាងលើ បានឆ្លងដែនចេញចូលតាមច្រកម៉ាឡៃ៕ អត្ថបទ ៖ ចាន់ ជី

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ០៨នាក់

https://www.facebook.com/GDIOfficial General Department of Immigration-GDI 13-04-2020

នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ០៨នាក់៕

# ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០

## ពលករខ្មែរមកពីថៃចំនួន១៤៦នាក់ត្រូវដាក់ឲ្យនៅដាច់ដោយឡែកក្នុងខេត្តកោះកុង

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០២០ ម៉ោង ១៤:៣៥ គុច ណារ៉េន

កោះកុង ៖ គិតត្រឹមថ្ងៃទី ១៤ ខែមេសាឆ្នាំ២០២០ នេះពលករខ្មែរត្រឡប់មកពីប្រទេសថៃចូលតាមច្រកព្រំដែននៃទឹកដីខេត្តកោះកុងត្រូវបានមន្ទីរសុខាភិបាលខេត្តរៀបចំឲ្យពួកគាត់នៅដាច់ដោយឡែករយៈពេល ១៤ ថ្ងៃតាមវិធានចត្តាឡីស័កដើម្បីទប់ស្កាត់នូវការឆ្លងរាតត្បាតវីរុសកូវីដ ១៩ ។ នេះបើយោងតាមមន្ត្រីនៃមន្ទីរសុខាភិបាលខេត្តកោះកុង ។ ប្រភពដដែលបានបន្តទៀតថា នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ ពលករមកពីប្រទេសថៃ ចំនួន ១៤នាក់ ដែលបានដាក់ឱ្យរស់នៅដាច់ដោយឡែក ក្នុងវិទ្យាល័យហ៊ុនសែនចាំយាម ស្រុកមណ្ឌលសីមា បានបញ្ជូនទៅខេត្តផ្សេងៗតាមគោលដៅរបស់ពលករម្នាក់ៗ ដោយមានអាជ្ញាធរតាមខេត្តនីមួយៗដឹងលឺ និងធ្វើការតាមដានបន្តនិងដាក់ពួកគាត់ឱ្យនៅដាច់ដោយឡែក ១៤ថ្ងៃ ។ ជាមួយគ្នានោះផងដែរ មានបងប្អូនពលករខ្មែរមកពីថៃមួយចំនួនគឺមិនទាន់ផុតវិធានចត្តាឡីស័កនៅឡើយទេ ។ យ៉ាងណាមិញបងប្អូនពលករខ្មែរត្រឡប់មកពីថៃនិងត្រូវបានដាក់ឲ្យនៅដាច់ដោយឡែកចំនួន ១៤ ថ្ងៃនោះ គឺមកពីខេត្តផ្សេងៗគ្នាដែលខ្លះមកពី កោះកុង កំពត បាត់ដំបង ព្រៃវែង និងខេត្ត តាកែវជាដើម ៕

## ពលករដែលនៅដាច់ដោយឡែករយៈពេលជាច្រើនថ្ងៃ ត្រូវបានបញ្ជូនទៅកាន់ស្រុកកំណើតវិញហើយ

http://cambodiapolice.com/policekh/ 12:54 pm 14 មេសា 2020

ខេត្តកោះកុង៖ ថ្ងៃទី១៣ ខែ មេសា ឆ្នាំ ២០២០ ក្រោយពីស្នាក់នៅដាច់ដោយឡែករយៈពេលជាច្រើនថ្ងៃ ដោយមានការត្រួតពិនិត្យ ក្រោមការយកចិត្តទុកដាក់ របស់រដ្ឋបាលស្រុកមណ្ឌលសីមា ថ្ងៃនេះបងប្អូនពលករដែលត្រឡប់មកពីប្រទេសថៃ ត្រូវបានស្នងកាដ្ឋាននគរបាលខេត្ត បានជួយសម្រួលដល់មធ្យោបាយធ្វើដំណើរ ដោយចាត់កងកម្លាំងជូនទៅកាន់ស្រុកកំណើតវិញ ក្នុងនោះមាន ៖

- ខេត្តកំពត ២ នាក់
- ខេត្តព្រៃវែង ៥ នាក់
- ស្រុកបូទុមសាគរ ១នាក់ (ខេត្តកោះកុង) ៕ សម្រួលដោយ៖ អនុ.ទោ.រឿង សុវណ្ណដែត

## តើនៅតែមានពលករខ្មែរនៅថៃវិលមកស្រុកកំណើតតាមច្រករបៀងតូចៗ ក្រោយពេលបិទច្រកធំៗ?

https://crosscheckwmc.com/ Keo Sokha 15 April 2020

បន្ទាយមានជ័យ៖ ទំព័រហ្វេសប៊ុកព័ត៌មានពលករឆ្លងដែនបានបង្ហោះរូបភាព និងឃ្លីបវីដេអូ ពលករខ្មែរសម្រុកចេញពីប្រទេសថៃ តាមច្រករបៀបព្រៃភ្នំតូចៗជាប់ព្រំដែនកម្ពុជា-ថៃ ស្ថិតក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ។ រូបភាពបានបង្ហាញឱ្យឃើញសកម្មភាពពលករខ្មែរវិចស្ពាយបង្វេចខោអាវ និងសម្ភារៈប្រើប្រាស់ខ្លះៗ ព្រមជាមួយកូនតូចៗដើរកាត់ព្រៃសំដៅចូលមកស្រុកកំណើត ខណៈរោងចក្រ ក្រុមហ៊ុន ឬហាងនានាក្នុងប្រទេសថៃជាទីដែលកម្មករខ្មែរធ្លាប់ធ្វើការត្រូវបានបិទជាបណ្ដោះអាសន្នព្រោះបញ្ហាជំងឺ Covid-19។ រូបភាពពលករខ្មែររត់មកកម្ពុជាវិញតាមច្រករបៀងដែលបានបង្ហោះលើទំព័រហ្វេសប៊ុកព័ត៌មានឈ្មោះថា ទឹកចិត្តពលករឆ្លងដែន តែរូបភាពនេះត្រូវបានរដ្ឋបាលខេត្តឧត្តរមានជ័យ និងបន្ទាយមានជ័យច្រានចោលថា ជាព័ត៌មានមិនពិត។ រូបភាពពីហ្វេសប៊ុកទឹកចិត្តពលករឆ្លងដែន។

លោក ស៊ុំ ចាន់គា មន្ត្រីអង្គការអាដហុកប្រចាំខេត្តបន្ទាយមានជ័យប្រាប់ឱ្យដឹងថា ខណៈប្រទេសថៃ បានបិទទ្វារព្រំដែនជាមួយកម្ពុជា ពលករខ្មែរដែលចង់មកស្រុកកំណើតវិញពេលនេះ គឺគ្មានជម្រើសអ្វី ត្រឡប់ចូលស្រុកខ្មែរតាមច្រករបៀងតូចៗនេះទេ។ លោកបញ្ជាក់ថា ប៉ុន្មានថ្ងៃនេះ មានពលករខ្មែរជា ច្រើន ចូលមកកម្ពុជាដោយដើរកាត់ព្រៃភ្នំព្រោះក្នុងប្រទេសថៃអត់មានការងារឱ្យពួកគេធ្វើការទៀត នោះទេ។

ទាក់ទងករណីនេះលោក ឈឿន ក្រៃយ៉ុង នាយករដ្ឋបាល និងជាអ្នកនាំពាក្យសាលាខេត្ត បន្ទាយមាន ជ័យច្រានចេញករណីនេះ ដោយថាជាព័ត៌មានមិនពិត។ លោកបញ្ជាក់ថា នៅតាមច្រកទ្វារព្រំដែនមួយ ចំនួនក្នុងខេត្តបន្ទាយមានជ័យ នៅតែចំហរឱ្យពលករខ្មែរចូលមកជាធម្មតា ប៉ុន្តែពួកគេត្រូវបានត្រួតពិនិត្យ សុខភាព និងឱ្យនៅដាច់ដោយឡែករយៈពេល១៤ថ្ងៃ។ អាជ្ញាធរកំពុងពិនិត្យសុខភាពពលករដែលទើបត្រឡប់ចូលមកកម្ពុជានិងបានដាក់ឱ្យនៅដាច់ដោយឡែកចំនួន១៤ថ្ងៃ។

អ្នកស្រី ហៀប នីកា ជាពលករធ្វើការក្នុងរោងចក្រសាច់មាន់ក្នុងប្រទេសជាង ៥ឆ្នាំ បច្ចុប្បន្នក្នុងកំពុងស្នាក់ដាក់ដោយឡែកក្នុងផ្ទះរបស់ខ្លះក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ។ អ្នកស្រីឱ្យដឹងថា អ្នកស្រីមកស្រុក កំណើតវិញតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត ព្រោះអ្នកស្រីជាពលករស្របច្បាប់មានលិខិតឆ្លងដែន ត្រឹមត្រូវ។ យ៉ាងណាអ្នកស្រី ហាក់ពុំដឹងថា មានករណីពលករខ្មែរចូលមកកម្ពុជាតាមច្រករបៀងព្រៃភ្នំ នេះទេ។

ដោយឡែកលោក ជា ពិសិដ្ឋ នាយករដ្ឋបាល និងជាអ្នកនាពាក្យសាលាខេត្តឧត្តរមានជ័យ គូសបញ្ជាក់ថា នាពេលថ្មីៗនេះមានពលករខ្មែរដែលធ្វើការក្នុងប្រទេសថៃទាំងស្របច្បាប់ និងមិនស្របច្បាប់ បានសម្រុកចូលមកកម្ពុជាតាមច្រកព្រំដែនផ្លូវការ ពុំមានមកតាមច្រករបៀងហើយខេត្តឧត្តរមានជ័យ ក៏គ្មានច្រករបៀងដែរ។ លោកបន្ថែមថា អាជ្ញាធរប្រទេសទាំងពីរកម្ពុជា-ថៃ បានសហការគ្នាប្រើគោល ការណ៍យោគយល់ដោយឱ្យពលករខ្មែរចូលមកប្រទេសវិញតាមសន្តិវិធីមិនចាំបាច់រត់គេចពីអាជ្ញាធរនោះឡើយ។

ជាការកត់សម្គាល់ ប្រទេសថៃបានដាក់ខេត្តក្រុងមួយចំនួនក្នុងគ្រាអាសន្ន ផ្អាករាល់សកម្ម ភាពការងារ ការដើរហើរដោយសេរី ពិសេសបិទទ្វារព្រំដែន ដើម្បីជាវិធានការការពារការចម្លងរាលដាលជំងឺ Covid-19 ។ ការណ៍នេះបានធ្វើឱ្យពលករបរទេសដូចជា កម្ពុជា ឡាវ និងមាភូ សម្រុកមកស្រុកកំណើតវិញយ៉ាង ច្រើនកុះករ។

នាយករដ្ឋមន្ត្រីកម្ពុជាសម្តេច ហ៊ុន សែន កាលពីថ្ងៃទី១០ មេសា បានចេញបញ្ជាឱ្យថ្នាក់ដឹកនាំក្រសួងការពារជាតិ ប្រើរថយន្តកងទ័ពមកពីកងពលលេខ៩០ និងកងពលតូច ដឹកជញ្ជូនលេខ ៩៩ ដើម្បីដឹកជញ្ជូន ពលករខ្មែរដែលត្រឡប់មកពីប្រទេសថៃ ហើយត្រូវដាក់ឲ្យដាក់ដោយឡែករយៈពេល១៤ថ្ងៃ៕

## ពលករខ្មែរជាង១០០នាក់ វិលពីថៃ នាថ្ងៃទី២ នៃបុណ្យចូលឆ្នាំ នៅភាគពាយ័ព្យនិងភាគឧត្តរ

https://www.cen.com.kh/ April 15, 2020

ព្រំដែនកម្ពុជាថៃ៖ មានពលករខ្មែរជាង១០០នាក់ បន្តវិលពីថៃ នាថ្ងៃទី២ នៃបុណ្យចូលឆ្នាំខ្មែរឆ្នាំជូត ទោស័កពស២៥៦៤ ត្រូវនឹងថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០ នៅតាមព្រំដែនកម្ពុជា ថៃ ដែលស្ថិតនៅភូមិសាស្រ្តភាគពាយ័ព្យ និងភាគឧត្តរ ប្រទេសកម្ពុជា ។ មន្ត្រីយោធាយោធភូមិភាគទី៥ និងមន្ត្រីនគរបាលទិសស្រាលភូមិភាគ៥ ឲ្យដឹងកាលពីថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០ថា ៖ ក្នុងថ្ងៃទី១៤ ខែមេសា នៅមានពលករខ្មែរ វិលពីប្រទេសថៃ តាមច្រករបៀងព្រំដែន ក្នុងភូមិសាស្រ្តខេត្តបាត់ដំបង និងបន្ទាយមានជ័យ ចំនួន៧៦នាក់ដែរ ។

ចំណែកនៅច្រកព្រំដែនអូរស្មាច់ ខេត្តឧត្តរមានជ័យ ក៏មានពលករខ្មែរ ដែលសុំកងកម្លាំងថៃ ដើម្បីឆ្លងដែនមកកម្ពុជាវិញ រាប់សិបនាក់ដែរ កាលពីថ្ងៃទី១៤ ខែមេសា ។ ពលករខ្មែរទាំងនោះ ត្រូវបានមន្ត្រីអាជ្ញាធរ នៃខេត្តនានា នៃខេត្តលំនៅឋានពលករ អមដំណើរដឹកតាមរថយន្តកងទ័ពជើងគោក ទៅកាន់មជ្ឈមណ្ឌលសំចត និងចត្តាឡីស័ក ក្នុងសាលារៀនតាមខេត្ត ។

សម្រាប់ខេត្តបន្ទាយមានជ័យ ក្នុងអំឡុងពីមុន និងថ្ងៃចូលឆ្នាំខ្មែរឆ្នាំជូតនេះ មានពលករខ្មែរជាង២ម៉ឺននាក់ បានវិលពីប្រទេសថៃ ក្នុងពេលកន្លែងការងារពួកគេ បានបិទ ព្រោះតែការរីករាលដាល នៃមេរោគកូវីដ១៩ ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២០នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 04-04-2020

នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២០នាក់ ស្រី ០៦នាក់៕

# កុំចង់ខ្លាំងនៅថៃ! ប្រាប់ហើយមិនជឿ ឥឡូវតែកសត្រប់គ្នា ព្រោះដាច់ផឹកមិនបាន ផ្ដើននឹងបម្រាមរដ្ឋ

https://www.cen.com.kh/ April 15, 2020

ពលករខ្មែរមួយក្រុម ត្រូវបានអាជ្ញាធរថៃចាប់ខ្លួនចាត់ការតាមផ្លូវច្បាប់ បន្ទាប់ត្រូវបានរកឃើញកំពុងជួបជុំគ្នាផឹកស៊ីយ៉ាងសប្បាយ ដែលបំពានលើបម្រាមហាមឃាត់ទូទាំងប្រទេសរបស់រដ្ឋាភិបាលថៃ ដើម្បីទប់ស្កាត់ការរាតត្បាតពេគកូវីដ១៩ ។ បើតាមប្រភពសារព័ត៌មានថៃ เรื่องจริงผ่านเลนส์ បានឲ្យដឹងថា កាលពីវេលាម៉ោង ៥ និង ៣០ នាទី ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០ ពលករមកពីប្រទេសកម្ពុជាសរុបចំនួន ២៩ នាក់ (ប្រុស ១៧ នាក់ និង ស្រី ១២ នាក់ ក្នុងនោះ ៥ នាក់នៃពួកគេបានផឹក) ត្រូវបានចាប់ខ្លួនៅផ្ទះជួលមួយកន្លែង នៅក្នុង Khlong Luang ខេត្ត Pathum Thani ។

លោកវរសេនីយ៍ទោ Pichaya Piaraj ជាមន្ត្រីសន្តិសុខស្រុក បានបង្ហើបឱ្យដឹងថា ពលករខ្មែរទាំងនេះ គឺភាគច្រើនធ្វើការនៅតាមផ្សារ។ លោកបន្តថា ពួកគេនឹងត្រូវប្រឈមនឹងការអនុវត្តច្បាប់ហាមការប្រមូលផ្តុំសកម្មភាពជួបជុំផឹកស៊ី ដែលអាចបណ្តាលឱ្យមានលក្ខខណ្ឌមិនមានអនាម័យ និងអាចបណ្តាលឱ្យមានជំងឺឆ្លង ឬជំងឺរាតត្បាតរាលដាលរីករាលដាល ស្របតាមក្រឹត្យគ្រាអាសន្ន និងច្បាប់ស្តីពីជំងឺឆ្លង។

ដោយឡែក បើយោងតាមផេកហ្វេសប៊ុក "ទឹកចិត្ត ពលករ ឆ្លងដែន" បានបង្ហោះវីដេអូ និងរូបភាពនៃការចាប់ខ្លួននេះ ដោយបានបញ្ជាក់ឲ្យដឹងថា៖ "ថ្ងៃចូលឆ្នាំខ្មែរពលករខ្មែរនៅថៃបាននាំគ្នាផឹកស៊ីបំពានច្បាប់របស់រាជរដ្ឋាភិបាលថៃប្រកាសហាមផឹកស៊ីជួបជុំគ្នាដើម្បីទប់ស្កាត់រីករាតត្បាតពេគកូវីដ១៩។ ពលករខ្មែរទាំងអស់នេះត្រូវអាជ្ញាធរថៃចាប់យកទៅដំណើកាតាមផ្លូវច្បាប់ ។ សូមបងប្អូនពលករខ្មែរនៅថៃកុំផឹកស៊ីជួបជុំគ្នាឲ្យសោះ ព្រោះថៃកំពុងបន្តឹងច្បាប់ដើម្បីទប់ស្កាត់ឆ្លងជំងឺពេគកូវីដ១៩ (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន) 15-4-2020" ។

នេះសបញ្ជាក់ឲ្យឃើញថា រដ្ឋាភិបាលប្រទេសគេ គឺពិតជាតឹងរ៉ឹងណាស់ មិនមែនដូចប្រទេសយើង រាជរដ្ឋាភិបាលលោកនៅមានក្តីអនុគ្រោះឲ្យមានការផឹកស៊ី មិនដាច់អហង្កាជ្រុលពេកទេ ប៉ុន្តែ មនុស្សមួយចំនួនមិនបានយល់ពីទឹកចិត្តរបស់រាជរដ្ឋាភិបាល ដែលបាននិងកំពុងខិតខំប្រឹងយ៉ាងសស្រាក់សស្រាំ ដើម្បីទប់ស្កាត់ការរាលដាលជំងឺនេះនោះទេ ៕ ដោយ៖ លឹម ហុង

## ប្រទះឃើញបុរសជនជាតិខ្មែរម្នាក់រត់ឆ្លងដែន ចូលស្រុកទាំងដៃជាប់ខ្នោះ

https://www.facebook.com/VD7news/ VD7NEWS 15-04-2020

ខេត្តកោះកុង៖ (ព័ត៌មានបឋម) នៅព្រឹកថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០នេះ កម្លាំងនគរបាលស្រុកមណ្ឌលសីមាបានជួបបុរសម្នាក់ដើរកាត់ព្រៃពីប្រទេសថៃ(ខេត្តត្រាត)មកកម្ពុជា(ខេត្តកោះកុង)ដោយដៃមានជាប់ខ្នោះ និងមានរបួសផងដែរ កម្លាំងនគរបាលស្រុកមណ្ឌលសីមាបានសហការជាមួយកម្លាំងស្នងការដ្ឋាននគរបាលខេត្ត ធ្វើការដោះខ្នោះដែលមានរបួសនៅកដៃ និងលាងសំអាតរបួសដើម្បីសាកសួរនៅព័ត៌មានផ្សេងៗមាន៖

បុរសខាងលើមានឈ្មោះ រស់ រឿន ភេទ ប្រុស អាយុ ៣៤ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ ស្រុកកំណើត ភូមិតាគោក ឃុំ តាគោក ស្រុក តាគោក ខេត្តកំពង់ធំ។ ទីលំនៅបច្ចុប្បន្ន ភូមិព្រៃស្វា ឃុំ ជ្រៃឃ្មុំ ស្រុកគន្ធកណ្តាល ខេត្តព្រៃវែង មុខរបរចុះទូកនេសាទនៅប្រទេសថៃ៕

## ប្រតិភូខេត្តកំពង់ធំ ធ្វើដំណើរទៅតំបន់ព្រំដែនកម្ពុជា-ថៃ ដើម្បីទទួលពលករមកពីថៃ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត

http://www.freshnewsasia.com/ 2020-04-15

**(កំពង់ធំ)៖** នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០នេះ គណៈប្រតិភូខេត្តកំពង់ធំដឹកនាំដោយលោក ព្រឹម រដ្ឋា អភិបាលរងខេត្តកំពង់ធំ អមដំណើរដោយថ្នាក់ដឹកនាំ តាមបណ្តាមន្ទីរពាក់ព័ន្ធនានា បានអញ្ជើញធ្វើដំណើរមកតំបន់ព្រំដែនកម្ពុជា-ថៃ នៅច្រកទ្វាអន្តរជាតិប៉ោយប៉ែត ដើម្បីរង់ចាំទទួលនៃការវិលត្រឡប់នៃពលករពលការិនី ដែលបានវិលត្រឡប់មកស្រុកកំណើតនៅខេត្តកំពង់ធំ ចាប់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ ២០២០។

ក្នុងឱកាសរង់ចាំពលករដែលទើបត្រឡប់ពីប្រទេសថៃ នាពេលនោះលោក ព្រឹម រដ្ឋា បានលើកឡើងថា បញ្ហាពលករចំណាកស្រុកមកពីថៃ គឺជាកង្វល់របស់រាជរដ្ឋាភិបាលដូចជាអាជ្ញាធរខេត្តកំពង់ធំ ដើម្បីធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋរួចចាកផុតអំពីជំងឺកូវីដ១៩ ដោយមានសកម្មភាពដូចជាការត្រួតពិនិត្យឱ្យបានត្រឹមត្រូវ តាមរយៈគ្រូពេទ្យជំនាញណែនាំប្រជាពលរដ្ឋឱ្យអនុវត្តតាមការណែនាំ របស់ក្រសួងសុខាភិបាល ហើយមន្រ្តីជំនាញរបស់សុខាភិបាល និងអាជ្ញាធរខេត្តនីមួយៗ យកចិត្តទុកដាក់ចំពោះពលករ បានន័យថា ត្រូវយកគាត់ មកពិនិត្យសុខភាពឱ្យបានល្អិតល្អន់ការត្រួតពិនិត្យ នេះទៀតសោត គឺធ្វើជាច្រើនលើកច្រើនសារមុន និងអនុញ្ញាតឱ្យធ្វើដំណើរ ទៅកាន់ស្រុកកំណើតរៀងៗ ខ្លួន។ លោក ព្រឹម រដ្ឋា ក៏បានអប់រំណែនាំដល់បងប្អូនពលករខ្មែរ ដែលទើបវិលត្រឡប់មកពីប្រទេសថៃ ត្រូវចូលរួមថែរក្សាសុខភាព ដោយប្រកាន់ឱ្យខ្ជាប់ខ្ជួនអនាម័យ ពាក់ម៉ាស់ឱ្យបានត្រឹមត្រូវលាងដៃ និងសាប៊ូឱ្យបានញឹកញាប់ ប្រសិនបើមានរោគសញ្ញាមួយចំនួនដូចជា៖ គ្រុនក្តៅយ៉ាងតិច ៣៨អង្សាសេ ក្អក ហៀរសំបោរ ឈឺបំពង់ក ពិបាកដកដង្ហើម ត្រូវទាក់ទងលេខទូរស័ព្ទ ១១៥ជាបន្ទាន់។ ការធ្វើបែបនេះ គឺដើម្បីចូលរួមទប់ស្កាត់ការរីករាដាល នៃមេរោគកូវីដ១៩ ដែលកំពុងតែកើតមានឡើងនៅក្នុងប្រទេសកម្ពុជា។

សូមបញ្ជាក់ផងដែរថា គណៈប្រតិភូខេត្តកំពង់ធំ បានរៀបចំទទួលពលករ ពលការិនីវិលត្រឡប់មកពីប្រទេសថៃ រួមមានច្រកអូស្មាច់ ខេត្តឧត្តមានជ័យ, ច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកដូងហៅឡែម ខេត្តបាត់ដំបង។ ជាលទ្ធផលគិតត្រឹមថ្ងៃទី១០ រហូតដល់ ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ នៅវេលាម៉ោង១២.៣០ នាទី មានបងប្អូនជាពលរដ្ឋវិលត្រឡប់ មកពីប្រទេសថៃ មានចំនួន១១៤នាក់ ស្រី៣៤នាក់៕

# ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០

## នាយករដ្ឋមន្ត្រី អំពាវនាវឲ្យពលករ-ពលការនីខ្មែរ គោរពតាមច្បាប់ និងបទបញ្ញត្តិរបស់អាជ្ញាធរថៃ

https://dap-news.com/national/ ByKD102 Posted on April 15, 2020

ភ្នំពេញ៖ ក្រោយពីឃើញបណ្តាញសារព័ត៌មាន មួយចំនួនបានចុះផ្សាយថា ពលករខ្មែរមួយក្រុមត្រូវបានអាជ្ញាធរថៃឃាត់ខ្លួនបន្ទាប់ពីពួកគេជួបជុំគ្នា ផឹកស៊ីយ៉ាងសប្បាយ ដែលបំពានទៅនឹងបម្រាមហាមឃាត់ ទូទាំងប្រទេសរបស់រដ្ឋាភិបាលថៃ ក្នុងការទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ-១៩នោះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានអំពាវនាវឲ្យ ពលករ-ពលការីខ្មែរ ដែលស្នាក់នៅនិងធ្វើការងារ នៅក្នុងប្រទេសថៃទាំងអស់ ចូលរួមគោរពតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយ ដែលបានដាក់ចេញដោយអាជ្ញាធរថៃ។

តាមរយៈបណ្តាញទំនាក់ទំនង សង្គមហ្វេសប៊ុក នៅថ្ងៃទី១៥ មេសានេះ សម្តេចតេជោ ហ៊ុនសែន បានផ្ញើសារជូនពរឆ្នាំថ្មីដល់បងប្អូនជនរួមជាតិ ទាំងក្នុងនិងក្រៅប្រទេស និងអរគុណចំពោះការយកចិត្តទុកដាក់ ធ្វើតាមការណែនាំ របស់រាជរដ្ឋាភិបាល ក៏ដូចជាការណែនាំ របស់ក្រសួងសុខាភិបាល ដើម្បីចូលរួមទប់ស្កាត់ ហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ នៅក្នុងប្រទេសយើង។ សម្តេចតេជោនាយករដ្ឋមន្ត្រីបញ្ជាក់ថា "សូមកូនក្មួយ កុំធ្វើអ្វីដែលខុសច្បាប់ នៅក្នុងប្រទេសគេ ដែលកំពុងដាក់ ក្នុងគ្រាអាសន្នអោយសោះ ។ ទន្ទឹមនឹងនេះដែរ សូមអំពាវនាវដល់បងប្អូនកូនក្មួយ និងពលករពលការនី ដែលកំពុងរស់នៅ ធ្វើការក្រៅប្រទេស ជាពិសេសនៅប្រទេសថៃ សូមគោរពតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយ ដែលប្រទេសគេបានដាក់ចេញ រួមទាំងច្បាប់បម្រាមគោចរ និងបម្រាមជួបជុំគ្នាជាក្រុម ឬជប់លៀងជាក្រុមដែលពេលនេះ ប្រទេសគេកំពុងមាន ការហាមឃាត់តឹងរឹងបំផុត ក្នុងការទប់ស្កាត់ ការចម្លងរោគកូវីដ-១៩។" សម្តេចបន្តថា សំខាន់ណាស់នៅពេលនេះ គឺសុវត្ថិភាពសុខភាព អាយុជីវិតបងប្អូនកូនក្មួយ ពលករពលការនីផ្ទាល់។ សូមបងប្អូនយោគយល់ និងគោរពច្បាប់ទាំងក្នុងប្រទេស និងក្រៅប្រទេស ជាពិសេស នៅក្នុងស្ថានភាពដែលប្រទេសភាគច្រើន បានដាក់ចេញនូវបទបញ្ញត្តិ និងបម្រាមដ៏តឹងរឹង ក្នុងការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩។ សម្តេចតេជោ ក៏បានបួងសួងសូមទេវតាឆ្នាំថ្មីនាំមកនូវសិរីសួស្តី និងលាភសំណាងដល់បងប្អូន និងកូនក្មួយទាំងអស់គ្នា ហើយសូមបានចៀសផុតពីជំងឺឆ្លងកូវីដ-១៩ គ្រប់ៗគ្នា៕

## ថ្ងៃទី២,ទី៣នៃបុណ្យចូលឆ្នាំហើយ ក៏នៅមានពលករខ្មែរបន្តវិលពីថៃ

http://www.rasmeinews.com/ April 15, 2020, 8:51 PM

ដោយៈប.ជ័យ/បន្ទាយមានជ័យៈ ថ្ងៃទី២ទី៣នៃបុណ្យចូលឆ្នាំហើយក៏នៅមានពលករខ្មែរបន្តវិលពីប្រទេសថៃតាមច្រកព្រំដែននៅភូមិសាស្ត្រខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ និងបាត់ដំបង។ ប៉ុន្តែរឿងដែលសោកសង្រេងនោះគឺពលករត្រូវចំណាយលើថ្លៃជិះឡាន និងការឆែកឆេរតាមផ្លូវក្នុងភូមិសាស្ត្រប្រទេសថៃ ក្នុងម្នាក់ពី១.៥០០ទៅ៣.០០០បាតប្រាក់ថៃ(ឬពី២០ទៅ៤០ម៉ឺនរៀល)។ នៅពេលឆ្លងកាត់ច្រកព្រំដែនខាងថៃចុងក្រោយ ត្រូវចំណាយម្នាក់ៗពី៣០០ទៅ៥០០បាតទៀត ។

មន្ត្រីយោធាមន្ត្រីនគរបាល និងអាជ្ញាធរដែនដីដែលទៅចាំទទួលពលករខ្មែរបានឱ្យដឹងកាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ថា ៖ទោះដល់ថ្ងៃទី១៤-១៥ ខែមេសាជាថ្ងៃទី២ និងទី៣ នៃបុណ្យចូលឆ្នាំប្រពៃណីខ្មែរ-ថៃទៅហើយក៏នៅមានពលករខ្មែរវិលពីប្រទេសថៃតាមច្រករបៀងព្រំដែនក្នុងភូមិសាស្ត្រខេត្តបាត់ដំបងនិងបន្ទាយមានជ័យចំនួន៧៦នាក់ដែរ។ ពលករទាំងនោះបានចេញមកតាមច្រកព្រំដែនអូរស្មាច់ខេត្តឧត្តរមានជ័យ។តាមច្រករបៀងនៅសងខាងឬជិតច្រកអន្តរជាតិក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង។គឺក្នុង១ថ្ងៃៗមានពលករជាង១០០នាក់ដែរ។ ពលករខ្មែរទាំងនោះត្រូវបានមន្ត្រីអាជ្ញាធរនៃខេត្តដែលទីកន្លែងលំនៅដ្ឋានពលកររស់នៅទទួលនិងរួមដំណើរដឹកតាមរថយន្តកងទ័ពជើងគោកទៅកាន់មជ្ឈមណ្ឌលសំចតនិងចត្តាឡីស័កក្នុងសាលារៀនតាមខេត្ត៕ទS/

## ឯកឧត្តម តូច ប៉ូលីវ៉ា បានអញ្ជើញសំណេះសំណាលសុខទុក្ខបងប្អូនពលករដែលទើបវិលត្រឡប់មកពីធ្វើការនៅប្រទេសថៃ

https://gdlf-kh.com// Kao sophy ខេត្តស្វាយរៀង 2020/04/16

ខេត្តស្វាយរៀង៖ នៅថ្ងៃពុធ ៨រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០នេះ ឯកឧត្តម តូចប៉ូលីវ៉ា អភិបាលរងខេត្តស្វាយរៀង និងជាអនុប្រធានគណៈកម្មការប្រយុទ្ធប្រឆាំងនឹងជំងឺ Covid-19ខេត្ត និងជាប្រធានក្រុមការងារទទួលខុសត្រូវ សម្របសម្រួល ក្នុងការដឹកនាំក្រុមការងារទទួលប្រជាពលរដ្ឋ មានទីលំនៅនៅខេត្តស្វាយរៀង ដែលវិលត្រលប់មកពីប្រទេសថៃ តំណាងឯកឧត្តម ម៉ែន វិបុល អភិបាល

ខេត្ត បានចុះពិនិត្យទីតាំងចត្តាឡីស័កគោលដៅទី២ តាមផ្លូវជាតិលេខ១៣ ឃុំអណ្តូងត្របែក ស្រុករមាសហែក ខេត្តស្វាយរៀង ជាប់ព្រំប្រទល់ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង និងបាននាំយកប្រសាសន៍របស់ឯកឧត្តមអភិបាលខេត្តមកសំណេះសំណាលសួរសុខទុក្ខបងប្អូនពលករ ដែលទើបវិលត្រឡប់មកពីធ្វើការនៅប្រទេសថៃនៅសាលាបឋមសិក្សាអណ្តូងត្របែក និងសាលាបឋមសិក្សាកំរ៉ែង ស្ថិតនៅក្នុងឃុំអណ្តូងត្របែក ស្រុករមាសហែក ខេត្តស្វាយរៀង។ ទន្ទឹមនេះ ឯកឧត្តម តូច ប៉ូលីវ៉ា បានផ្តោតសំខាន់ទៅលើការងារចត្តាឡីស័កនៅដាច់ដោយឡែក១៤ថ្ងៃ តាមការស្ម័គ្រដើម្បីតាមសុខភាពរបស់បងប្អូនពលករ ការសម្អាតអនាម័យខ្លួនប្រាណ លាងដៃជាមួយសាប៊ូជាប្រចាំ ការហាត់ប្រាណបំបាត់ភាពអប់សុខ ។ បន្ទាប់មកឯកឧត្តមក៏បានលើកឡើងថា "បងប្អូនទៅធ្វើការចោលប្រពន្ធកូន ក្រុមគ្រួសារ រាប់ខែរាប់ឆ្នាំបាន រឿងអីថាបងប្អូននៅដាច់ដោយឡែកតែ ១៤ថ្ងៃមិនបាន"។

## អភិបាលរងខេត្តកំពង់ឆ្នាំង បន្តសកម្មភាពចុះផ្សព្វផ្សាយដល់ពលករនៅតាមផ្ទះ និងត្រួតពិនិត្យទីតាំងនៅតាមវត្តអារាម

https://grandnewsasia.com/ 15-04-2020

កំពង់ឆ្នាំង៖ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០នេះ ដែលត្រូវជាថ្ងៃចូលឆ្នាំថ្ងៃទី៣ ថ្នាក់ដឹកនាំខេត្ត ដឹកនាំដោយលោក សាន់ យូ អភិបាលរងខេត្តកំពង់ឆ្នាំង និងថ្នាក់ដឹកនាំស្រុក ដឹកនាំដោយលោក សំ ចាន់ថន អភិបាលស្រុក រួមជាមួយលោក ហ៊ូ ប៊ុនថន អភិបាលរងស្រុក អាជ្ញាធរឃុំ បន្តសកម្មភាពចុះសំណេះសំណាលសួរសុខទុក្ខ និងផ្សព្វផ្សាយអំពីវិធានការបង្ការ និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ដល់ពលករនៅតាមផ្ទះ និងពិនិត្យមើលតាមទីវត្តអារាម នៅស្រុកកំពង់លែង ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី។ ក្នុងនោះ ក្រុមការងារបានចូលជួបព្រះសង្ឃ លោកអាចារ្យ និងពុទ្ធបរិស័ទ ដែលបានមករាប់បាត្រ នៅតាមបណ្តាវត្ត ក្នុងស្រុកកំពង់លែង និងបន្តជួបបងប្អូនពលករដែលទើបត្រឡប់មកពីប្រទេសថៃ ដោយបានធ្វើការណែនាំ និងផ្តាំផ្ញើដល់តាជី យាយជី ដែលមានវត្តមានក្នុងវត្ត និងនៅតាមគេហដ្ឋាន ពិសេសបងប្អូនដែលទើបបានវិលមកពីបម្រើការងារនៅក្រៅប្រទេស ឱ្យលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នខ្ពស់ធ្វើអនាម័យលាងដៃនឹងសាប៊ូ ឬទឹកអាល់កុលឱ្យបានញឹកញាប់ជាប្រចាំ។ ក្នុងឱកាសនោះផងដែរ លោកអភិបាលរងខេត្តក៏បានចូលជាបច្ច័យដល់វត្តចំនួន ៤ ក្នុងមួយវត្តៗចំនួន ៨០.០០០រៀល និងម៉ាស់មួយចំនួនផងដែរ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ០៤នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration-GDI 15-04-2020

នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ០៤នាក់ ស្រី ០២នាក់៕

# ក្នុងខេត្តសៀមរាប មានពលករខ្មែរមកពីក្រៅប្រទេស ១១៥៤៥ នាក់ គិតត្រឹមថ្ងៃទី១៥ មីនា ដល់ ១៥ មេសា ២០២០

http://kampucheathmey.com/ 16/4/2020 9:32 Am

នៅទូទាំងខេត្តសៀមរាប មានពលករខ្មែរមកពីក្រៅប្រទេស ១១៥៤៥ នាក់ គិតត្រឹមថ្ងៃទី១៥ ខែមីនា ដល់ថ្ងៃទី ១៥ មេសា ២០២០។ នេះបើយោងតាមរបាយការណ៍របស់ស្នងការនគរបាលខេត្តសៀមរាប។ ពលករដែលទើបវិលត្រលប់កាលពីពេលថ្មីៗ នេះត្រូវបានរដ្ឋបាលខេត្តរៀបចំឱ្យនៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃ ដើម្បីការពារការឆ្លង Covid-19។ គិតត្រឹមព្រឹកថ្ងៃទី ១៦ ខែមេសានេះ មានអ្នកឆ្លង Covid-19 សរុប ១២២ នាក់ ខណៈព្យាបាលជាសះស្បើយ ៩៨នាក់៕

## ថៃចាប់ខ្លួនពលរដ្ឋស្រីប្រុស ១២នាក់ ដែលជួបជុំគ្នាផឹកស៊ីបំពានបំរាមរបស់រដ្ឋាភិបាល

https://khmernote.com.kh/ April 15, 2020 lyda

ថៃ៖ យ៉ាងហោចណាស់មានមនុស្ស ១២ នាក់ ត្រូវបានអាជ្ញាធរថៃធ្វើការចាប់ខ្លួន ព្រោះតែពួកគេបានជួបជុំគ្នាផឹកស៊ីយ៉ាងសប្បាយ ដែលឥរិយាបថនេះគឺជាការប្រព្រឹត្តិផ្ទុយនឹងបំរាមរបស់រដ្ឋាភិបាលថៃ ដែលបានហាមមិនឲ្យពលរដ្ឋធ្វើការជួបជុំគ្នាឬផឹកស៊ីគ្នាក្នុងចំណោមមនុស្សច្រើននោះទេ ដើម្បីកាត់បន្ថយអត្រានៃការចម្លងមេរោគកូវីដ ១៩ ក្នុងឱកាសដែលថៃត្រូវរៀបចំពិធីសង្រ្កានឆ្នាំថ្មីនេះ ។ ការចាប់ខ្លួននេះបានធ្វើឡើងនៅម៉ោងប្រមាណជា ៩ យប់ ក្នុងបន្ទប់ស្នាក់នៅមួយកន្លែងក្នុងខេត្តបូរីរុំ ភាគខាងជើងប្រទេសថៃ។ ក្នុងចំណោមពលរដ្ឋគឃ្លើនទាំងអស់ ១២ នោះ មាន២នាក់គឺជាមនុស្សស្រីផងដែរ ហើយពេលនេះពួកគេទាំងអស់ត្រូវយកទៅដាក់អប់រំនៅឯស្ថានីយ៍ប៉ូលិស។ សូមរម្លឹកជូនថា អាជ្ញាធរថៃបានសម្រេចដាក់ចេញនូវវិធានការក្តៅជាច្រើន ដើម្បីទប់ស្កាត់ការរីករាលដាលនៃមេរោគកូវីដ ១៩ រហូតមានទាំងការបិទខេត្តខ្លះទាំងមូលទៀតផង ហើយពលរដ្ឋណាដែលមិនព្រមធ្វើតាមបំរាមរបស់រដ្ឋាភិបាលនឹងត្រូវទទួលទោសយ៉ាងធ្ងន់ធ្ងរ តួយ៉ាងដូចក្នុងករណីខាងលើនេះអីចឹង។ សូមបញ្ជាក់ផងដែរថា គិតមកទល់នឹងពេលនេះថៃមានអ្នកឆ្លងមេរោគកូវីដចំនួន ២ ៦១៣ ករណី ស្លាប់ ៤១ ករណី និងជាសះស្បើយចំនួន ១ ៤០៥ ផងដែរ៕

# ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០

## ពលករខ្មែរធ្វើការលើទូកនេសាទថៃរត់គេចចូលមកកម្ពុជាវិញ ទាំងដៃជាប់ខ្នោះ

https://www.postkhmer.com/ យុត សុភចរិយា | Publication date 17 April 2020 | 09:23 ICT

**កោះកុង៖** ពលករខ្មែរម្នាក់ធ្វើការនៅលើទូកនេសាទមួយក្នុងប្រទេស ថៃ បានរត់គេចខ្លួនត្រឡប់មកកម្ពុជាវិញទាំងដៃជាប់ខ្នោះ ហើយត្រូវបានសមត្ថកិច្ចនគរបាលស្រុកមណ្ឌលសីមា ខេត្តកោះកុងប្រទះឃើញ និងឃាត់ខ្លួនកាលពីព្រឹកថ្ងៃពុធ ដើម្បីសួរនាំ។ នេះបើតាមការប្រាប់ពីមន្ត្រីនគរបាលមូលដ្ឋានពីម្សិលមិញ។

លោក ជា សារិន អធិការនគរបាលស្រុកមណ្ឌលសីមាប្រាប់ភ្នំពេញប៉ុស្តិ៍ថា ពលករខ្មែរដែលរត់គៀសខ្លួនពីប្រទេសថៃទាំងដៃជាប់ខ្នោះខាងលើនេះ ឈ្មោះ រស់ រឿន អាយុ ៣៤ ឆ្នាំ មានលំនៅភូមិព្រៃស្វា ឃុំជ្រៃឃ្មុំ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង មានមុខរបរជាកម្មករបម្រើការងារតាមទូកនេសាទនៅក្នុងប្រទេសថៃ។ លោក សារិន បញ្ជាក់ថា៖ «គាត់ [រស់ រឿន] ត្រូវបានកម្លាំងនគរបាលយើងប្រទះឃើញនៅចំណុចព្រៃរបោះមួយក្បែរច្រកចាំយាម ខណៈគាត់កំពុងដើរឆ្លងកាត់ព្រំដែនពីខេត្តត្រាតប្រទេស ថៃ ចូលមកក្នុងទឹកដីកម្ពុជា ដោយដៃខាងស្តាំរបស់គាត់មានជាប់ខ្នោះ និងមានរបួសហើមលឺបក្លាយជាដំបៅទៀតផង»។ បើតាមលោក សារិន ក្រោយការឃាត់ខ្លួនពលករខាងលើ

នេះក្រុមសមត្ថកិច្ចនគរបាលកម្ពុជាបានទាក់ទងសួរនាំទៅកាន់ភាគីថៃ។ ប៉ុន្តែភាគីថៃបានរាយការណ៍ថា ក្នុងរយៈពេលប៉ុន្មានថ្ងៃនេះមិនមានបទល្មើសអ្វីកើតឡើងនោះទេ។ លោកបន្ថែមថា៖ «ដោយពិនិត្យឃើញខ្នោះដៃនោះរឹតដៃគាត់រហូតដល់ក្លាយជាដំបៅ សមត្ថកិច្ចយើងបានសម្រេចជួយដោះខ្នោះដៃនោះចេញដោយយករណារអារដែកមកអារ និងបានជួយព្យាបាលរបួសនោះឲ្យគាត់។ បន្ទាប់មកយើងបញ្ជូនគាត់ទៅកាន់ស្នងការដ្ឋាននគរបាលខេត្តកោះកុងដើម្បីសួរនាំគាត់បន្ថែម និងចាត់វិធានការបន្ត»។

ក្រោយពីការសួរនាំដោយមន្ត្រីនគរបាលជំនាញ នៃការិយាល័យព្រហ្មទណ្ឌ នៃស្នងការដ្ឋាននគរបាលខេត្តកោះកុងលោក រស់ រឿន រៀបរាប់ថាកាលពីចុងខែមីនា ឆ្នាំ ២០២០ នៅពេលទូកនេសាទដែលគាត់បានបម្រើការជាមួយនោះចូលចត ដើម្បីនាំយកត្រី បង្គា មឹក និងក្តាមទៅឲ្យអតិថិជន នៅឯកំពង់ផែមួយក្នុងខេត្តត្រាតប្រទេសថៃ ពេលនោះគាត់ស្នើសុំបើកលុយពីថៅកែទូក ដើម្បីវិលត្រឡប់ទៅលេងផ្ទះនៅឯខេត្តព្រៃវែងវិញ។ ប៉ុន្តែថៅកែទូកនោះមិនអនុញ្ញាតក៏មានការឈ្លោះប្រកែកគ្នា ហើយថៅកែនោះបានប្រើអំពើហិង្សាឲ្យកម្មករផ្សេងទៀតមកចាប់វាយដាក់ខ្នោះដៃគាត់ថែមទៀត។ តែគាត់បានរើបម្រះរួច ហើយរត់គេចខ្លួនដោយមិនទទួលបានប្រាក់ឈ្នួលអ្វីទាំងអស់។ នេះបើតាមសម្តីរបស់លោក ឃឹម សាណោ ស្នងការរងខេត្តកោះកុងទទួលបន្ទុកផ្នែកព្រហ្មទណ្ឌពីម្សិលមិញ។

លោក សាណោ និយាយថា៖ «យោងតាមសេចក្តីរាយការណ៍ពីភាគីថៃប្រចាំខេត្តត្រាត លោក រស់ រឿន មិនធ្លាប់មានប្រវត្តិប្រព្រឹត្តបទល្មើសក្នុងប្រទេសថៃនោះទេ។ ចំពោះករណីដែលគាត់បានរៀបរាប់នេះ សមត្ថកិច្ចថៃសន្យាថា នឹងជួយអន្តរាគមន៍ស្វែងរកយុត្តិធម៌ជូនគាត់វិញប្រសិនបើគាត់វិលត្រឡប់ទៅប្រទេសថៃ ដើម្បីដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់នោះ»។ លោក សាណោ បានបន្ថែមថាដោយសារតែគាត់ទើបឆ្លងដែនពីប្រទេសថៃ និងមានរបួសជាប់ខ្លួន ដូច្នេះគាត់ត្រូវបានកម្លាំងសមត្ថកិច្ចនាំយកទៅកាន់មជ្ឈមណ្ឌលសំចតដែលរៀបចំដោយគណៈកម្មការប្រយុទ្ធប្រឆាំងជំងឺកូវីដ ១៩ដើម្បីឲ្យគាត់ស្នាក់នៅដាច់ដោយឡែករយៈពេល ១៤ ថ្ងៃ តាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល។ ក្នុងរយៈពេល ២ សប្តាហ៍នេះ គាត់គ្មានរោគសញ្ញាណាមួយពាក់ព័ន្ធការឆ្លងជំងឺកូវីដ ១៩ គាត់នឹងត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅជួបជុំគ្រួសារនៅឯខេត្តព្រៃវែង៕

## លោក តូច ប៉ូលីវ៉ា ចុះពិនិត្យទីតាំងទី២របស់មន្ទ្រីចត្តាឡីស័កនៅស្រុករមាសហែក ដែលពលករវិលមកពីប្រទេសថៃ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 16/04/2020

ស្វាយរៀង៖កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០នេះ លោក តូច ប៉ូលីវ៉ា អភិបាលរងខេត្តស្វាយរៀងនិងជាអនុប្រធានគណៈកម្មការប្រយុទ្ធប្រឆាំងនឹងជំងឺ Covid-19ខេត្ត និងជាប្រធានក្រុមការងារទទួលខុសត្រូវសម្របសម្រួល ក្នុងការដឹកនាំក្រុមការងារទទួលប្រជាពលរដ្ឋ មានទីលំនៅនៅខេត្តស្វាយរៀង ដែលវិលត្រលប់មកពីប្រទេសថៃ តំណាងលោក ម៉ែន វិបុល អភិបាលខេត្ត បានចុះពិនិត្យទីតាំងចត្តាឡីស័កគោលដៅទី២ តាមផ្លូវជាតិលេខ១៣ ឃុំអណ្តូងត្របែក ស្រុករមាសហែក ខេត្តស្វាយរៀង ជាប់ព្រំប្រទល់ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង និងបាននាំយកប្រសាសន៍របស់លោកអភិបាលខេត្តមកសំណេះសំណាលសុខទុក្ខបងប្អូនពលករដែលទើបវិលត្រឡប់មកពីធ្វើការនៅប្រទេសថៃ នៅសាលាបឋមសិក្សាអណ្តូងត្របែក និងសាលាបឋមសិក្សាកំរ៉ែង ស្ថិតនៅក្នុងឃុំអណ្តូងត្របែក ស្រុករមាសហែក ខេត្តស្វាយរៀង ។ ទន្ទឹមនេះលោក តូច ប៉ូលីវ៉ា បានផ្តោតសំខាន់ទៅលើការងារចត្តាឡីស័កនៅដាច់ដោយឡែក១៤ថ្ងៃ តាមការស្នើគ្រដើម្បីតាមសុខភាពរបស់បងប្អូនពលករ ការសម្អាតអនាម័យខ្លួនប្រាណ លាងដៃជាមួយសាប៊ូជាប្រចាំ ការហាត់ប្រាណបំបាត់ភាពអប់សុខ ។ បន្ទាប់មកលោកក៏បានលើកឡើងថា "បងប្អូនទៅធ្វើការចោលប្រពន្ធកូន ក្រុមគ្រួសារ រាប់ខែរាប់ឆ្នាំបាន រឿងអីថាបងប្អូននៅដាច់ដោយឡែកតែ ១៤ ថ្ងៃបានអោយរស់នៅជាមួយក្រុមគ្រួសារវិញ៕គឹមសេង

## ពលករចំណាកស្រុក មកពីប្រទេសថៃចំនួន២២នាក់ បានមកមណ្ឌលសុខភាព ដើម្បីចូលពិនិត្យសុខភាព

http://cambodiapolice.com/ 9:50 am 16 មេសា 2020

ខេត្តកំពង់ឆ្នាំង៖ ពលករចំណាកស្រុក មកពីប្រទេសថៃចំនួន២២នាក់ បានមកដល់មណ្ឌលពិនិត្យសុខភាព របស់សាលាបឋមសិក្សាគំរូ ក្រុង ដើម្បីចូលពិនិត្យសុខភាព កាលពីវេលាម៉ោង១៦និង៣០នាទី ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ ។ ក្នុងចំនួនពលករ ២២នាក់គឺជាមនុស្សប្រុស ហើយមានទីលំនៅស្រុកកំពង់ត្រឡាច ចំនួន១៥នាក់ ស្រុករលាប្អៀរចំនួន ០៧នាក់ ។ ក្រោយពីការពិនិត្យសុខភាពរួចពលករទាំង២២នាក់មានសុខភាពធម្មតា ហើយត្រូវបានក្រុមគ្រូពេទ្យអនុញ្ញាតិអោយវិលត្រឡប់ទៅមូលដ្ឋានវិញរៀងៗខ្លួន៕ សម្រួលដោយ៖ អនុ.ទោ.រឿង សុវណ្ណដែត

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ០៧នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration-GDI 16-04-2020

នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ០៧នាក់ ស្រី ០២នាក់៕

## ពលករខ្មែរយ៉ាងហោចណាស់ចំនួន ០៤នាក់ និងពលករភូមា ១៧នាក់ ត្រូវបានកម្លាំងសមត្ថកិច្ចថៃចាប់ខ្លួន

https://www.facebook.com/prakpheaktraofficial/ 16-04-2020

យោងតាមរបាយការណ៍ពីខេត្តប៉ាធុមថានីបានអោយដឹងថា កម្លាំងសមត្ថកិច្ចថៃក្នុងខេត្តប៉ាធុមថានី បានចុះឃាត់ខ្លួនពលករប្រទេសទាំងខ្មែរនិងភូមាសរុបចំនួន២១នាក់ បន្ទាប់ពីពលករទាំងអស់នោះបានប្រជុំគ្នាលេងបាល់ទះ ហេតុការណ៍ខាងលើនេះបានកើតឡើងកាលពីវេលាម៉ោង០៥:១០នាទី ល្ងាចថ្ងៃព្រហស្បតិ៍ ទី១៦ ខែមេសា ឆ្នាំ ២០២០ នេះ នៅម្ដុំច្រកខ្លងលួង៥៤ ស្ថិតក្នុងសង្កាត់ខ្លងនឹង ស្រុកខ្លងលួង ខេត្តប៉ាធុមថានី ប្រទេសថៃ ។

ឈ្មោះពលករខ្មែរ៖

1.ឈ្មោះ ប៊ី យុង ភេទប្រុស អាយុ ៣១ ឆ្នាំ សញ្ជាតិខ្មែរ

2.ឈ្មោះ SOPHANNA ភេទប្រុស អាយុ ២០ឆ្នាំ សញ្ជាតិខ្មែរ

3.ឈ្មោះ NAK RA ភេទប្រុស អាយុ ប្រុស ២០ឆ្នាំ សញ្ជាតិខ្មែរ

4.ឈ្មោះ PRONH ភេទប្រុស អាយុ ២២ឆ្នាំ សញ្ជាតិខ្មែរ

តាមការបញ្ជាក់របស់សមត្ថកិច្ចថៃពលករបរទេសទាំងអស់បានបំពានសេចក្ដីប្រកាសរបស់រាជរដ្ឋាភិបាលថៃហាមប្រមូលផ្ដុំប្រជុំគ្នាគ្រប់ទីកន្លែង អាចបង្កឲ្យឆ្លងជំងឺកូវីដ១៩ បច្ចុប្បន្នពលករបរទេសទាំងអស់ត្រូវសមត្ថកិច្ចថៃបញ្ជូនទៅកាន់អធិការដ្ឋានតម្រួតប៉ុស្តិ៍ខ្លងលួងដើម្បីចាត់វិធានការតាមច្បាប់។ ភគ្រា ពលករខ្មែរ

## ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០

## ពលករចំណាកស្រុកក្រៅប្រទេស វិលត្រឡប់មកស្រុកកំណើត នៅស្រុកកោះអណ្តែត មានជាង៣០០នាក់ ហើយត្រូវបានសរសេរបដាដាក់មុខផ្ទះ

https://www.cen.com.kh/ April 17, 2020

តាកែវ៖ នៅក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនិងជំងឺកូវីដ១៩នេះ លោក គិន ភក្តី អភិបាលស្រុកកោះអណ្តែត រួមជាមួយក្រុមការងារ បានចុះទៅដល់ខ្នងផ្ទះ របស់បងប្អូនប្រជាពលរដ្ឋ ដើម្បីធ្វើការសួរសុខទុក្ខ និងធ្វើការណែនាំដល់ ពលករចំណាកស្រុក ដែលទើបត្រឡប់មកពីក្រៅប្រទេសជាង ៣០០នាក់ ឲ្យពួកគាត់ទាំងអស់ចេះ អនាម័យលើខ្លួនឯង និងឲ្យពួកគាត់រស់នៅ ដាច់ដោយឡែកពីក្រុមគ្រួសារចំនួន ១៤ថ្ងៃសិន។ ថ្លែងប្រាប់ក្រុមអ្នកសារព័ត៌មាន នាព្រឹកថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០នេះ លោក គិន ភក្តី បានបញ្ជាក់ថា ជារៀងរាល់ថ្ងៃ អាជ្ញាធរស្រុករួមជាមួយនឹងក្រុមការងារ នៅតែបន្តចុះផ្សព្វផ្សាយ អប់រំដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ នៅទូទាំង ៦ឃុំក្នុងស្រុក អំពីការអំពាវនាវឲ្យបងប្អូនប្រជាពលរដ្ឋ ចូលរួមទាំងអស់គ្នា ទប់ស្កាត់ឲ្យបាននៅការឆ្លងរីករាលដាល ជាសហគមន៍នៃជំងឺកូវីដ ១៩នេះ ជាពិសេសក្រុមការងារ របស់យើងផ្តោតសំខាន់ ទៅលើបងប្អូនដែលទើបវិលត្រឡប់ មកស្រុកកំណើត ជាពលករចំណាកស្រុកក្រៅប្រទេស ដោយបានណែនាំឲ្យពួកគាត់ សរសេរបដា ដាក់នៅមុខផ្ទះ និងឲ្យពួកគាត់រស់នៅដាច់ដោយឡែកមួយរយៈសិន និងជំរុញឲ្យក្រុមគ្រូពេទ្យចុះពិនិត្យ និងវាស់កម្តៅជាប្រចាំដល់ពួកគាត់ លើការតាមដានសុខភាពជាចាំបាច់ ដើម្បីទប់ស្កាត់នៅជំងឺកូវីដ១៩នេះ ។

លោកអភិបាលស្រុកបន្តថា ដោយមើលឃើញពីភាពលំបាក របស់អាជ្ញាធរ ក៏ដូចជាសមត្ថកិច្ចពាក់ព័ន្ធនានា យើងឃើញថា មានសប្បុរសជន ក៏ដូចជាព្រះសង្ឃ ដែលគង់នៅវត្តស្ថិតនៅក្នុងបរិវេន នៃស្រុកកោះអណ្តែត បានចូលរួមជួយដល់អាជ្ញាធរស្រុក ដោយនាំមកនៅជាអំណោយ គ្រឿងឧបភោគបរិភោគ អាល់កុល ម៉ាសបិតមុខ និងថវិកាមួយចំនួន ដើម្បីជាជំនួយឧបត្ថម្ភ គាំទ្រលើយុទ្ធនាការប្រយុទ្ធប្រឆាំង នឹងជំងឺកូវីដ១៩នេះ មិនឲ្យមាននៅក្នុងមូលដ្ឋានរបស់ខ្លួន ៕ ដោយ៖ តាកែវ

## ពលរដ្ឋខ្មែរ ជិត២០នាក់ចាកចេញពីថៃ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់

https://www.cen.com.kh/ April 19, 2020

ព្រំដែនកម្ពុជាថៃ៖ ទោះបីជាអាជ្ញាធរថៃបន្តបិទច្រកព្រំដែន អន្តរជាតិ ផង ចម ខេត្តសុរិន្ទ ឈមនឹងច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ក៏នៅតែមានប្រជាពលករខ្មែរប្រមាណ២០នាក់ បន្តធ្វើដំណើរចាកចេញពីទឹកដីថៃ វិលត្រឡប់មកចូលកម្ពុជាវិញ ក្នុងពេលដែលប្រទេសថៃ បានផ្អាកការងារ និងបិទប្រទេស ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ ១៩ ដែលធ្វើពលករខ្មែរ បាត់បង់ការងារ ដូច្នេះមានតែត្រូវបង្ខំចិត្តវិលត្រឡប់ មកស្រុកកំណើតវិញ ដើម្បីស្វែងការងារធ្វើនៅស្រុកកំណើតវិញ ព្រោះថាកម្ពុជា មិនបានបិទប្រទេស និងនៅបន្តធ្វើអាជីវកម្ម រកស៊ីជាធម្មតា។

អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានឲ្យដឹងថា នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀ

ងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨នាក់ ស្រី ០៧នាក់៕ ដោយៈបញ្ញាស័ក្តិ

## ពលករខ្មែរមួយចំនួនមិនទាន់ត្រឡប់ទៅប្រទេសថៃវិញព្រោះមិនមានការងារធ្វើ

https://www.rfa.org/khmer/ ដោយ ជាតិ ចំណាន 2020-04-17

ពលករខ្មែរមួយចំនួនដែលបានទៅលេងស្រុកកំណើតអំឡុងពេលបុណ្យឆ្នាំខ្មែរនោះ មិនទាន់ត្រឡប់ទៅធ្វើការងារនៅប្រទេសថៃវិញទេ ដោយសារថៅកែជនជាតិថៃមិនទាន់បើកឱ្យធ្វើការវិញនៅឡើយ។ ជាមួយគ្នានេះ នៅច្រកទ្វារព្រំដែនកម្ពុជា-ថៃ នៅតែបន្តបិទទ្វារព្រំដែនដោយពុំទាន់បើកឱ្យដំណើរឡើងវិញដែរ។

ពលករមកខេត្តកំពង់ធំលោក ជា ខន ថ្លែងនៅថ្ងៃទី១៧ មេសា ថា លោកនិងអ្នកភូមិជិតខាងប្រមាណ១០នាក់មកពីថៃ កាលពីដើមខែមេសានោះមិនទាន់បានត្រឡប់ទៅកន្លែងធ្វើការវិញ ដោយសារគ្មានការងារធ្វើ៖ «ឥឡូវនេះខ្ញុំនៅខ្មែរសិន បើទៅក៏អត់មានការងារធ្វើដែរ ទាល់តែថៅកែបើក បានខ្ញុំទៅធ្វើការតែម្តង។ ខ្ញុំខ្វល់ខ្វាយមកនៅខ្មែរអត់ការងារធ្វើ ហើយលុយក៏គ្មានអីចឹងខ្ញុំបន់ឱ្យតែគេបើដំណើរវិញ អាងទៅធ្វើការវិញព្រោះសព្វថ្ងៃប្រពន្ធក៏នៅកូនខ្ចីមិនបានរកស៊ីអី ហើយប្តីក៏នៅដេកស៊ីមិនបានរកអីចូលមានតែចេញព្រឹកល្ងាចមានអ្នកណាចេញទៅរកអីបានទេ»។

ពលរដ្ឋម្នាក់ទៀតនៅខេត្តសៀមរាបលោកស្រី វ៉ាន់ ហៀវ ឱ្យដឹងថា បងប្អូនរបស់លោកស្រី ៣នាក់មកពីធ្វើការប្រទេសថៃជាង ១ខែ ហើយមិនទាន់ត្រឡប់ទៅធ្វើការវិញនៅឡើយទេ ព្រោះខ្លាចឆ្លងជំងឺកូវីដ១៩ផង និងដោយសារអាជ្ញាធរកម្ពុជា និងថៃបានបិទច្រកទ្វារព្រំដែន។ លោកស្រីបន្ថែមថា អ្នកភូមិនៅតំបន់លោកស្រីប្រមាណ៥០នាក់ ក៏មិនទាន់បានត្រឡប់ទៅប្រទេសថៃវិញដែរ ដោយពួកគាត់រង់ចាំឱ្យតែស្ថានភាពជំងឺរលាកផ្លូវដង្ហើមថ្មីបានធូរស្រាលសិន៖ «ស្រុកខ្ញុំមកទាំងអស់គ្នាក៏នៅដេកស៊ីទាំងអស់គ្នាហ្នឹងឯងមិនមានអ្នកចេញទៅថៃរួចទេ អ្នកណាមកក្រោយគេឃាំង១៤ថ្ងៃ នៅសាលារៀនតែខ្ញុំមកមុនមិនបានដាក់នៅដាច់ដោយឡែកទេ។ ខ្ញុំបន់ឱ្យតែគេបើព្រំដែនវិញខ្ញុំចង់ទៅធ្វើការវិញណាស់ខ្ញុំមិនដឹងរកអីទេស្រុកខ្មែរបើបានទៅប្រទេសថៃមានអីរកប្រាក់បានខ្លះ។ ធ្វើការនៅណាក៏ខ្ញុំធ្វើដែរឱ្យតែមានការងារធ្វើបានប្រាក់សងធនាគារ»។

អនុប្រធានការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា លោក លឹម តិច ប្រាប់អាស៊ីសេរីថា អាជ្ញាធរថៃបន្តបិទច្រកទ្វារព្រំដែនជាប់កម្ពុជារហូតដល់ថ្ងៃទី១ ឧសភាជាមួយគ្នានេះនៅតាមព្រំដែនប្រទេសកម្ពុជា ក៏ទាន់មានពលករខ្មែរត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញនៅឡើយទេ៖ «ទៅម៉េចកើតវាពិបាកចេញទៅណាស់ព្រោះគ្មានសេវាដឹកជញ្ជូនត្រឡប់ទៅថៃវិញ វាមិនងាយទេ។ បើចូលស្រុកខ្មែរចេះតែចូលបានហើយ»។

អាជ្ញាធរកម្ពុជា និងថៃបានសហការគ្នាបិទច្រកទ្វារព្រំដែនរវាងប្រទេសថៃ ចាប់ពីថ្ងៃទី២២ មីនារហូតមកដើម្បីការពារកុំឱ្យរាតត្បាតជំងឺកូវីដ១៩។ ប៉ុន្តែកាលពីដើមខែមេសា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែនបានប្រកាសថាមានពលករខ្មែរជាង ៦ម៉ឺននាក់ហើយដែលបានត្រឡប់មកពីធ្វើការនៅប្រទេសថៃវិញ។

មន្ត្រីអង្គការសង់ត្រាល់ទទួលបន្ទុកផ្នែកពលករចំណាកស្រុកលោក ឌី ថេហូយ៉ា សម្តែងក្តីបារម្ភថា ប្រសិនបើស្ថានការណ៍រាតត្បាតជំងឺកូវីដ១៩នៅតែបន្តអូសបន្លាយយូរទៀត នឹងធ្វើឱ្យពលករនៅថៃរាប់ម៉ឺននាក់នឹងវិលត្រឡប់ទៅកម្ពុជាវិញ ដោយសារថៅកែរបស់ពួកគេបានផ្អាកធ្វើការបណ្តោះអាសន្ន។ បច្ចុប្បន្នមានពលករខ្មែរប្រមាណ២លាននាក់កំពុងធ្វើការងារនៅប្រទេសថៃ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៤នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 19-04-2020

នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ធង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៤នាក់ ស្រី ០៦នាក់៕

## ពលករមកពីថៃ ៩ ម៉ឺននាក់ មានករណីសង្ស័យជាង ៤00 ត្រូវបានធ្វើតេស្ត

http://kampucheathmey.com/ 20/4/2020 11:59 Am

លោក លី សុវ៉ាន់ មន្ត្រីជាន់ខ្ពស់របស់ក្រសួងសុខាភិបាលប្រាប់ថា ក្នុងចំណោមពលករដែលវិលត្រឡប់មកពីប្រទេសថៃ ក្នុងអំឡុងចូលឆ្នាំជាង ៩ ម៉ឺននាក់ មានករណីសង្ស័យ ៤១០ នាក់ត្រូវបានធ្វើតេស្ត ប៉ុន្តែពុំរកឃើញលទ្ធផលវិជ្ជមាននោះទេ។ មន្ត្រីជាន់ខ្ពស់ ដែលកាន់តួនាទីជាប្រធាននាយកដ្ឋានប្រឆាំងជំងឺឆ្លងបានអះអាងថា រាល់ពលករដែលវិលត្រឡប់មកវិញ ត្រូវបានត្រួតពិនិត្យសុខភាពនៅច្រកចេញតាមព្រំដែន និងក៏បន្តតាមដានជាប់ជានិច្ចដោយមានការសហការជាមួយអាជ្ញាធរនិងមន្ត្រីសុខាភិបាលតាមមូលដ្ឋាន ដើម្បីបង្ការទប់ស្កាត់ការរីកសាយភាយមេរោគកូវីដ ១៩ ការនៅក្នុងសហគមន៍៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 18-04-2020

នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ធង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨នាក់ ស្រី ០៧នាក់៕

## សេចក្តីណែនាំស្តីពីការវិលត្រលប់ចូលម្តងទៀតចំពោះពលករដែលកាន់វីសា E-9

http://khmerinkorea.com/ April 20, 2020

ព័ត៌មាននៃប្រព័ន្ធអនុញ្ញាតការងារ (EPS) ចុះនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ បានចាកចេញពីកូរ៉េបណ្តោះអាសន្នក្នុងអំឡុងពេលផ្លាស់ប្តូរការងារដើម្បីការពារពីជំងឺកូរ៉ូណា យោងតាមស្ថានភាពបែបនេះចំពោះអ្នកដែលវិលចូលប្រទេសកូរ៉េទាំងអស់ ដែលកំពុងធ្វើការសហការយ៉ាងមុតមាំ ដើម្បីដាក់ខ្លួនឱ្យនៅដាច់ដោយឡែកក្នុងរ

យៈពេល២អាទិត្យ និងមិនអនុញ្ញាតិឱ្យត្រលប់ចូលក្នុងប្រទេសកូរ៉េចំពោះករណីដែលមិនអាចធ្វើការដាក់ខ្លួនឱ្យនៅដាច់ដោយឡែកបាន។ ដោយបែបនេះក្រសួងការងាររបស់សាធារណរដ្ឋកូរ៉េសូមណែនាំឱ្យពិនិត្យសុខភាពមុនពេលត្រលប់ចូលក្នុងប្រទេសកូរ៉េទៅកាន់ពលករពលការនីដែលកាន់វីសា E9 របស់កម្ពុជាដែលមានឈ្មោះក្នុងបញ្ជីដែលកំពុងវិលត្រលប់ចូលមកប្រទេសកម្ពុជាក្នុងរយៈពេលបណ្តោះអាសន្នអំឡុងពេលវិស្សមកាល រឺយៈពេលផ្លាស់ប្តូរកន្លែងធ្វើការនេះ។

ដូច្នេះហើយមុនពេលដែលពលករពលការនីត្រលប់ចូលក្នុងប្រទេសកូរ៉េ ពលករពលការនីកម្ពុជាដែលកំពុងវិលត្រលប់ចូលមកប្រទេសកម្ពុជាក្នុងរយៈពេលបណ្តោះអាសន្នអំឡុងពេលវិស្សមកាល រឺយៈពេលផ្លាស់ប្តូរកន្លែងធ្វើការងារជាដើម។ល។ ត្រូវតែពិនិត្យមើលស្ថានភាពសុខភាពរបស់ខ្លួនមុនជាដាច់ខាតទើបអាចចាកចេញមកបាន។ លើសពីនេះទៀត! យើងសុំស្នើរឱ្យអ្នកទាំងអស់គ្នាយកចិត្តទុកដាក់ជាពិសេសដើម្បីចៀសវាងពីគុណវិបត្តិនៃការបណ្តេញចេញពីប្រទេសកូរ៉េ ពីព្រោះអ្នកនឹងត្រូវដាក់ខ្លួនឱ្យនៅដាច់ដោយឡែកនៅកន្លែងមួយដែលមិនច្បាស់លាស់បន្ទាប់ពីអ្នកបានចូលមកក្នុងប្រទេសកូរ៉េ។ នេះជាគោលនយោបាយបណ្តោះអាសន្នរបស់រដ្ឋាភិបាលកូរ៉េដើម្បីទប់ស្កាត់ការរីករាលដាលនៃកូរ៉ូណា១៩។

○ផែនការដែលនឹងត្រូវអនុវត្តៈ ចាប់ពីថ្ងៃទី ១៥ ខែមេសា ឆ្នាំ ២០២០ សម្រាប់ពលករកម្ពុជាតាមរយៈប្រព័ន្ធអនុញ្ញាតិការងារដែលកំពុងវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ។ (សូមមើលឈ្មោះក្នុងតារាង)

○ព័ត៌មានៈ ពលករកម្ពុជាដែលមានឈ្មោះក្នុងបញ្ជីនៃអ្នកវិលត្រឡប់ចូលប្រទេសកូរ៉េជាបណ្តោះអាសន្ននៅពេលបច្ចុប្បន្ននេះ មុនពេលចាកចេញពីប្រទេសពលករពលការនីត្រូវតែពិគ្រោះយោបល់ជាមួយម្ចាស់អាជីវកម្មជាមុនសិន មុនពេលចូលប្រទេសកូរ៉េម្តងទៀត ដើម្បីធានាទទួលបានកន្លែងសម្រាប់ដាក់ខ្លួនឯងដាច់ដោយ ឡែករយៈពេល២សប្តាហ៍ ដែលត្រូវតែបំពេញតាមលក្ខខណ្ឌដូចខាងក្រោមនេះ

–អាសយដ្ឋានត្រូវតែច្បាស់លាស់និងត្រូវស្ថិតនៅដាច់ដោយឡែកខ្លួនឯងរយៈពេល ២ សប្តាហ៍

–បន្ទាប់ពីចូលទៅក្នុងប្រទេសហើយ ត្រូវស្ថិតនៅដាច់ដោយឡែកតែឯងហើយបង់ថ្លៃស្នាក់នៅរយៈពេល២សប្តាហ៍។

– ក្នុងអំឡុងពេលដាក់ដាច់ដោយឡែក អ្នកអាចតេរទូរស័ព្ទទាក់ទងទៅកាន់មន្ត្រីមូលដ្ឋានបានគ្រប់ពេល។

○ការប្រុងប្រយ័ត្ន

–អ្នកមិនអាចចូលទៅក្នុងប្រទេសកូរ៉េបានទេបើសិនជាអ្នកគ្មានកន្លែងសម្រាប់ដាក់ខ្លួនឯងដាច់ដោយឡែក។

–អ្នកមិនអាចកំណត់យកទីលំនៅរបស់មិត្តភក្តិរបស់អ្នក ជាទីលំនៅដាច់ដោយឡែកពីគេបានទេ

–កន្លែងសម្រាប់ដាក់ឱ្យនៅដាច់ដោយឡែកដូចជាទីសាធារណៈជាដើមគឺមិនអនុញ្ញាតបានទេ ហើយសណ្ឋាគារនិងកន្លែងស្នាក់នៅផ្សេងទៀត ក៏មិនអាចត្រូវបានកំណត់ថាជាកន្លែងដាច់ដោយឡែកពីគេបានផងដែរ។

–អ្នកអាចនឹងត្រូវបានគេដាក់ទោស ប្រសិនបើអ្នកចេញទៅក្រៅ ឬក៏គេមិនអាចទាក់ទងជាមួយអ្នកក្នុងអំឡុងពេលដាក់ដោយឡែកតែឯង។

○សូមសាកសួរព័ត៌មានលម្អិតតាមរយៈ

–អង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ (HRD-Korea): 023-997-822

–គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលកវទៅបរទេស (MTOSB): 023-6525-777

បញ្ជីរាយនាមពលករកម្ពុជាតាមប្រព័ន្ធ EPS ដែលវិលត្រលប់ចូលប្រទេសវិញ (ថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០២០)

# ពលរដ្ឋខ្មែរដែលជាប់នៅម៉ាឡេស៊ីជួបការលំបាកផ្នែកជីវភាព

https://www.rfa.org/khmer/news/ ដោយ ហេង រស្មី 2020-04-17

ពលរដ្ឋខ្មែរដែលជាប់នៅម៉ាឡេស៊ី ត្អូញត្អែរថា ពួកគេជួបការលំបាកក្នុងជីវភាព និងនៅតែស្នើសុំឱ្យរដ្ឋាភិបាលកម្ពុជា អនុញ្ញាតឱ្យពួកគេបានវិលត្រឡប់ចូលប្រទេសវិញ។ មន្ត្រីសង្គមស៊ីវិល យល់ថា ជម្រើសល្អបំផុត គឺរដ្ឋាភិបាល ត្រូវតែបើកផ្លូវឱ្យពួកគាត់បានវិលត្រឡប់មកខ្មែរវិញ។ ពលរដ្ឋខ្មែរដែលជាប់នៅម៉ាឡេស៊ី ប្រាប់អាស៊ីសេរីនៅថ្ងៃ ១៧ ខែមេសា ថា ពួកគាត់មិនទាន់ទទួលបាន ដំណឹងពីខាងស្ថានទូតកម្ពុជា ឬពីខាងរដ្ឋាភិបាល ពាក់ព័ន្ធនឹងការជួយសម្របសម្រួលឱ្យពួកគាត់ បានវិលត្រឡប់ទៅកម្ពុជាវិញនៅឡើយទេ។

និស្សិតខ្មែររៀននៅប្រទេសម៉ាឡេស៊ីម្នាក់ គឺលោក ស្លេះ សាព្រី រៀបរាប់ថា លោក និងពលរដ្ឋខ្មែរដទៃទៀត នៅតែមានបំណងចង់ទៅកម្ពុជាវិញឆាប់ៗដដែល ព្រោះថា ប្រទេសម៉ាឡេស៊ី បិទសាលារៀនបណ្ដោះអាសន្ន និងបិទកន្លែងការងារ បន្តទៅមុខទៀត ដើម្បីទប់ស្កាត់និងបង្ការជំងឺកូវីដ-១៩។ លោកបន្តថា សម្រាប់លោកជានិស្សិតមិនសូវជួបការលំបាកទេ ដោយសារបានជួលកន្លែងស្នាក់នៅ រយៈពេលមួយឆ្នាំ និងមានជនជាតិម៉ាឡេស៊ី ជួយផ្ដល់អាហារហូបចុក ប៉ុន្តែលោកថា សម្រាប់ប្រជាពលករវិញ គឺជួបការលំបាកខ្លាំង ដោយសារពួកគេ គ្មានការងារធ្វើដើម្បីបានប្រាក់ចំណូលសម្រាប់ចិញ្ចឹមជីវិតឡើយ៖ «ខ្ញុំសួរទៅកន្លែងទិញសំបុត្រយន្តហោះ គេថា ទាល់តែខាងខ្មែរបើកឱ្យទៅ បានយើងទៅបាន។ ខ្ញុំដឹងតែប៉ុណ្ណឹង។ នៅពេលនេះ ខ្ញុំនៅតែចង់ទៅ ប៉ុន្តែបើសិនជា កៀកថ្ងៃទៀត ខ្ញុំអត់ទៅទេ ព្រោះទៅគេឃុំយើង១៤ថ្ងៃទៀត ដូច្នេះដល់ពេលល្មមមករៀននៅម៉ាឡេស៊ីវិញ»។

រីឯពលការិនីមួយរូប ដែលកំពុងធ្វើការនៅប្រទេសម៉ាឡេស៊ី កញ្ញា ខុន ស្រីមុំ ថ្លែងថា រដ្ឋាភិបាល ម៉ាឡេស៊ី បានផ្អាកការងារស្ទើរគ្រប់ទីកន្លែង ហើយមិនដឹងពេលណាបើកដំណើរធម្មតាវិញនោះទេ។ កញ្ញាថា បញ្ហានេះធ្វើឱ្យពលករខ្មែរប្រមាណ៨០ភាគរយជួបការលំបាកខ្លាំងក្នុងជីវភាព និងការរស់នៅ។ កញ្ញា រៀបរាប់បន្តថា សម្រាប់កម្មករដែលធ្វើការតាមរោងចក្រ អាចនៅទទួលបានប្រាក់ខែខ្លះ ប៉ុន្តែសម្រាប់ កម្មករដែលធ្វើការតាមផ្ទះ តាមភោជនីយដ្ឋាន និងតាមទូកនេសាទ គឺភាគច្រើនមិនទទួលបាន ប្រាក់ខែនោះទេ។ កញ្ញា ស្នើសុំឱ្យរដ្ឋាភិបាល និងស្ថានទូតសម្របសម្រួលបញ្ជូនពលករណាដែលមានបំណងចាកចេញពីប្រទេសម៉ាឡេស៊ីទៅកម្ពុជាវិញ៖ «រដ្ឋាភិបាល ត្រូវនាំអ្នក១៥០នាក់ទៅខ្មែរវិញ ព្រោះមិនត្រូវបោះបង់គ្នាចោលនៅនេះទេ។ ខាងស្ថានទូតទាល់តែគេបុកខ្លាំងណាស់ បានមកជួបពួកគាត់នៅ ព្រលានយន្តហោះម៉ោង១២ យប់ ហើយបានឱ្យលុយគាត់ទៅកន្លែងស្នាក់នៅវិញ ។ចុះបើគាត់ទៅកន្លែងស្នាក់នៅហើយដាច់ប៉ាស្ព័រ ហើយអត់ការងារធ្វើ តើឱ្យគាត់រស់នៅ បែបម៉េច។ រដ្ឋាភិបាលធ្វើបែបនេះអត់ល្អហ្មង»។

កាលពីថ្ងៃទី៧ ខែមេសា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសផ្អាកជើងយន្តហោះដឹកពលរដ្ឋខ្មែរ ១៥០នាក់ពីប្រទេសម៉ាឡេស៊ី ក្រោមហេតុផលថា ដើម្បីទប់ស្កាត់ និងការពារជំងឺឆ្លងកូវីដ-១៩។ លោក ណែនាំឱ្យពលរដ្ឋខ្មែរ ទ្រាំរស់នៅក្នុងប្រទេសម៉ាឡេស៊ី បន្តទៀត ដោយលោក យល់ថា មិនលំបាកដល់ថ្នាក់ស្លាប់នោះទេ។

ទោះជាយ៉ាងណា គណបក្សសង្គ្រោះជាតិ បានចាត់ទុកការសម្រេចរបស់លោក ហ៊ុន សែន នេះ ថាបង្ហាញពីភាពទន់ខ្សោយ ការមិនទទួលខុសត្រូវ និងជាទង្វើអមនុស្សធម៌ មកលើពលរដ្ឋខ្លួនឯង ដែលផ្ទុយពីមេដឹកនាំដទៃទៀតនៅលើពិភពលោក។

អាស៊ីសេរី មិនអាចសុំការឆ្លើយតបរឿងនេះពីអ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា លោក កុយ គួង និងប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាល លោក ផៃ ស៊ីផាន បានទេ នៅថ្ងៃទី១៧ ខែមេសា ដោយទូរស័ព្ទចូលពុំមានអ្នកទទួល។ ចំណែកលេខទូរស័ព្ទសម្រាប់កិច្ចការពលករ និងកិច្ចការកុងស៊ុល របស់ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី ក៏មិនមានអ្នកទទួលដែរ។ ទោះជាយ៉ាងណា ទំព័រហ្វេសប៊ុករបស់ស្ថានទូត បានបង្ហោះសារលិខិតថ្លែងអំណារ

គុណដល់ជនជាតិម៉ាឡេស៊ី ដែលបានជួយឧបត្ថម្ភស្បៀងអាហារ និងកន្លែងស្នាក់នៅដល់ពលករខ្មែរមួយចំនួននៅរដ្ឋស្លាង់រ (Selangor) និងក្នុងរដ្ឋចូហូ (Johor)។

មន្ត្រីកម្មវិធីផ្នែកទេសន្តរប្រវេសន៍នៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល់ (CENTRAL) លោក ឌី ថេហូយ៉ា នៅតែយល់ថា ការអនុញ្ញាតឱ្យពលរដ្ឋទាំងនោះ បានវិល ចូលប្រទេសកម្ពុជាវិញ គឺជាជម្រើសល្អបំផុត ព្រោះថា ពេលនេះកម្ពុជា មានតួលេខល្អក្នុងការព្យាបាលអ្នកជំងឺកូវីដនិងមិនមានករណីថ្មីកើនឡើងនោះទេ៖ «ពួកគាត់ ទី១ អត់ការងារធ្វើ ទី២ អត់ប្រាក់ចំណូល ទី៣ គាត់ឈប់ជួលផ្ទះ ឬបន្ទប់គេហើយ និងត្រូវត្រឡប់ទៅរកបន្ទប់ជួលវិញ វាគឺជាឧបសគ្គ ទី៤ គាត់បានចំណាយលុយទិញសំបុត្រយន្តហោះអស់ហើយ ហើយអ្នកខ្លះមានបញ្ហាសុខភាពអីផ្សេងៗ ដូច្នេះខ្ញុំគិតថា នេះគឺជាបញ្ហាចាំបាច់បំផុតហើយសម្រាប់ជីវិតរបស់ពួកគាត់។ មែនទែន គោលការណ៍ នៅក្នុងពិភពលោក ប្រទេសដែលមានប្រជាពលរដ្ឋ ឬជាតិសាសន៍របស់ខ្លួនទៅរស់នៅកន្លែងណាក៏ដោយ នៅពេលដែលចង់ត្រឡប់ទៅប្រទេសគេវិញ គឺគេអត់ហាមឃាត់ទេ គេមានតែលើកទឹក ចិត្តត្រឡប់ទៅមាតុប្រទេសវិញ ដើម្បីរដ្ឋនៅពេលនឹង ការពារ និងថែទាំក្នុងនាមជាផ្តល់សេវា បម្រើសេវាផង និងជាអាណាព្យាបាលផង»។

តួលេខផ្លូវការរបស់ក្រសួងការងារបង្ហាញថា ពលករខ្មែរដែលកំពុងធ្វើការនៅប្រទេសម៉ាឡេស៊ីមានជាង ៣ម៉ឺននាក់ ក្នុងឆ្នាំ២០១៩ ប៉ុន្តែតាមការប៉ាន់ស្មានក្រៅផ្លូវការរបស់អង្គការសង់ត្រាល់ (CENTRAL) ចំនួនពលករខ្មែរដែលកំពុងធ្វើការនៅប្រទេសម៉ាឡេស៊ី មានមិនក្រោម ១០ម៉ឺននាក់នោះទេ ដោយរាប់ទាំងពលករស្របច្បាប់ និងមិនស្របច្បាប់។ ពួកគេភាគច្រើនធ្វើការងារតាមរោងចក្រ ធ្វើការងារតាមផ្ទះ និងខ្លះទៀតធ្វើការនៅលើទូកនេសាទ។

មាត្រា៣៣នៃរដ្ឋធម្មនុញ្ញ ចែងថា ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅនៅឯបរទេស ត្រូវបានរដ្ឋគាំពារ។ ចំណែកមាត្រា៣៥ ចែងថា សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយដោយហ្មត់ចត់ដោយអង្គការរដ្ឋ៕

## ២៥៦៣ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០

### ពលករខ្មែរឆ្លងដែនពីថៃចូលមកកម្ពុជា ពី១៥០ទៅ៣០០នាក់ ក្នុង១ថ្ងៃៗ

http://kampucheathmey.com/ 20/4/2020 5:09 Pm

ភ្នំពេញ៖ លោកស្រីវេជ្ជបណ្ឌិត យក់ សម្បត្តិ រដ្ឋលេខាធិការក្រសួងសុខាភិបាលបានប្រាប់ឲ្យដឹងថា ពលករខ្មែរធ្វើការនៅប្រទេសថៃ នៅតែបន្តឆ្លងដែនត្រឡប់ចូលមកប្រទេសកម្ពុជាវិញជាបន្តបន្ទាប់ ដោយក្នុង១ថ្ងៃៗមានពលករប្រមាណពី១៥០ ទៅ៣០០នាក់ ដែលឆ្លងដែនតាមច្រកព្រំដែនដូង ច្រកអូរស្មាច់ និងច្រកទ្វារអន្តរជាតិប៉ោយប៉ែត។ លោកស្រីបានបន្តថា «ដើម្បីការពារការឆ្លងរាលដាលជំងឺកូវីដ-១៩ យើងធ្វើការវាស់កម្ដៅដល់ពលករ ដែលមកពីប្រទេសថៃចំនួន២ដង គឺទី១យើងវាស់កម្ដៅនៅព្រំដែន និងទី២វាស់កម្ដៅនៅពេលដឹកជញ្ជូនពួកគាត់ពីព្រំដែនយកទៅដាក់នៅតាមខេត្ត។ ក្នុងករណី មានការសង្ស័យលើពលករណាម្នាក់នោះ យើងនឹងបញ្ជូនទៅធ្វើតេស្តនៅមន្ទីរពេទ្យ និងទុករយៈពេល១៤ថ្ងៃនៅទីតាំងខេត្តដែលបានត្រៀមទុករួចជាស្រេច។» លោកស្រីបានបន្តថា «ដោយឡែកពលករដែលមិនមានការសង្ស័យទេយើងបន្តបញ្ជូនទៅតាមភូមិរបស់គាត់ ប៉ុន្តែត្រូវដាក់ឲ្យនៅដាច់ដោយឡែកពីក្រុមគ្រួសាររយៈពេល១៤ថ្ងៃដូចគ្នា។» លោកស្រីបានបន្ថែមថា ពលករដែលមកពីប្រទេសថៃ គឺភាគច្រើនយើងបញ្ជូនទៅកាន់ភូមិកំណើតរបស់គាត់រៀងៗខ្លួនវិញ ពោលគឺមានចំនួនតិចតួចទេដែលត្រូវបញ្ជូនទៅធ្វើតេស្តរកមេរោគកូវីដ១៩។

លោកវេជ្ជបណ្ឌិត លី សូវ៉ាន់ អ្នកនាំពាក្យក្រសួងសុខាភិបាលបានបញ្ជាក់ថា «ក្នុងចំណោមពលករដែលវិលត្រឡប់មកពីប្រទេសថៃជាង ៩ ម៉ឺននាក់ មានករណីសង្ស័យជំងឺកូវីដ១៩ចំនួន ៤១០ នាក់ ហើយត្រូវបានយកសំណាកទៅធ្វើតេស្ត ប៉ុន្តែលទ្ធផលបង្ហាញថា គឺអវិជ្ជមានទាំងអស់៕»អត្ថបទ៖ សំអឿន

## លោក ម៉ម ប៊ុនហេង៖ «ពលករមកពីថៃមួយចំនួនអាចនឹងមានហានិភ័យកូវីដ១៩»

http://www.rfi.fr/km/ 20/04/2020 ដោយ៖ញឹម សុផល

លោក ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានថ្លែងថាគេនៅពុំទាន់រកឃើញថាមានពលករណាម្នាក់មានវីរុសកូវីដ១៩នៅឡើយទេ ក្នុងចំណោមពលករខ្មែរចំនួន៩ម៉ឺននាក់ដែលត្រលប់មកពីប្រទេសថៃ។ ការថ្លែងរបស់លោករដ្ឋមន្ត្រីដូច្នេះ ធ្វើឡើងនៅក្នុងឱកាសនៃសន្និសីទកាសែតនៅថ្ងៃចន្ទនេះ រៀបចំឡើងនៅក្រសួងសុខាភិបាលស្តីពីស្ថានភាពនៃការវិវត្តចុងក្រោយនៃវីរុសកូវីដ១៩នៅកម្ពុជា។ តាមលោក ម៉ម ប៊ុនហេង ថ្វីត្បិតតែមិនមានវិជ្ជមានកូវីដ១៩ មែនពិត ក៏ប៉ុន្តែមានករណីសង្ស័យមួយចំនួនក្នុងចំណោមពលករ ដែលត្រលប់មកពីថៃទាំងនោះ ដែលលោកគិតថាអាចនឹងមានហានិភ័យ។

## ពលករមកពីថៃជាង៤០០នាក់ ដែលសង្ស័យមានកូវីដ-១៩ បានធ្វើតេស្តអវិជ្ជមានទាំងអស់

https://thmeythmey.com/ 21, Apr 2020 , 9:45 am

ភ្នំពេញ៖ ពលករមកពីប្រទេសថៃជាង ៤០០នាក់ ដែលសង្ស័យឆ្លងជំងឺកូវីដ១៩ ត្រូវបានធ្វើតេស្ត ដោយទទួលបានលទ្ធផលអវិជ្ជមានទាំងអស់។ នេះបើតាមការបញ្ជាក់របស់លោកវេជ្ជបណ្ឌិត លី សូវ៉ាន់ ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង នៅក្នុងសន្និសីទសារព័ត៌មានស្តីពីបច្ចុប្បន្នភាពកូវីដ-១៩ កាលពីថ្ងៃទី២០មេសា។ ក្នុងចំណោមពលករ ៩ម៉ឺននាក់ ដែលធ្វើដំណើរមកពីប្រទេសថៃ មានពលករជាង ៤០០នាក់ សង្ស័យមានកូវីដ១៩។ ពលករជាង៤០០នាក់នេះ ត្រូវបានយកសំណាកទៅពិនិត្យ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានទាំងអស់។ លោក លី សូវ៉ាន់ បញ្ជាក់យ៉ាងដូច្នេះ៖ «រហូតមកដល់ពេលនេះ គឺយើងតេស្តអ្នកដែលសង្ស័យកូវីដ១៩ ជាពលករដែលមកពីប្រទេសថៃបានជាង ៤១០ករណី។ ប៉ុន្តែលទ្ធផលដែលយើងយកចេញពីច្រកទាំងបី និងករណីស្នាក់នៅចត្តាឡីស័ក គឺលទ្ធផលអវិជ្ជមានទាំងអស់»។

សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី២១ មេសានេះ កម្ពុជាមានអ្នកឆ្លងកូវីដ-១៩សរុបចំនួន ១២២នាក់ ក្នុងនោះកម្ពុជាបានព្យាបាលអ្នកជំងឺឲ្យ ជាសះស្បើយចំនួន ១១០នាក់ ស្មើនឹង ៩០.១៦ភាគរយ៕

## អាជ្ញាធរថៃបញ្ជូនពលរដ្ឋខ្មែរម្នាក់មកស្រុកកំណើតវិញ បន្ទាប់ពីដោះលែងពីពន្ធនាគារ

http://www.rasmeinews.com/ April 20, 2020, 3:28 PM

ដោយបាយ័ន/ឧត្តរមានជ័យ: ប្រជាពលរដ្ឋខ្មែរម្នាក់ត្រូវបានអាជ្ញាធរថៃបញ្ជូនមកស្រុកកំណើតវិញ បន្ទាប់ពីដោះលែងពីពន្ធនាគារ ពីបទឆ្លងដែនដោយខុសច្បាប់ចូលទៅកាប់ឈើគ្រញូងក្នុងទឹកដីថៃ។ ពិធីប្រគល់និងទទួលបានធ្វើឡើងកាលពីវេលាម៉ោង១២និង៤៥នាទី ថ្ងៃទី២០ ខែមេសាឆ្នាំ២០២០ នេះ ស្ថិតនៅច្រកអន្តរជាតិជាំស្រងាំ ក្នុងទឹកដីស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សមត្ថកិច្ចនគរបាលប្រចាំច្រកអន្តរជាតិជាំស្រងាំបាននិយាយថាប្រជាពលរដ្ឋខ្មែរ ដែលត្រូវបានអាជ្ញាធរថៃបញ្ជូនមកគឺមានឈ្មោះម៉ែនបួនភេទប្រុសអាយុ២៤ឆ្នាំរស់នៅភូមិសន្តិភាពឃុំត្រពាំងប្រិយ៍ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។សមត្ថកិច្ចបានបន្តថា ជនឈ្មោះ ម៉ែន បួន ត្រូវបានថៃចាប់ខ្លួនថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០១៧កន្លងទៅនេះពីបទឆ្លងដែនខុសច្បាប់ចូលកាប់ឈើក្រញូងក្នុងទឹកដីថៃដោយចូលតាមច្រក

វាលខ្សាច់ រួចយកទៅដាក់ពន្ធនាគារនៅខេត្តស៊ីសាកេត ប្រទេសថៃ រហូតដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០នេះ ទើបដោះលែងរួចបញ្ជូនមកស្រុកកំណើតវិញ៕ទ/

## គិតដល់ថ្ងៃ២០ មេសា ប្រជាពលរដ្ឋខ្មែរ មកពីបរទេស ចូលតាមច្រកទាំងបីមានចំនួន ១២,០៦៧នាក់

http://nokorwatnews.com/ 20-04-2020

ភ្នំពេញ៖ គិតចាប់ពីថ្ងៃទី១០ ខែមីនា មកដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០នេះ តួលេខសរុបដែលបានទទួលប្រជាពលរដ្ឋខ្មែរ ចូលតាមច្រកទាំងបីមានចំនួន ១២,០៦៧នាក់ ក្នុងនោះ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃរបស់អាជ្ញាធរខេត្តសៀមរាប នៅថ្ងៃចន្ទ ទី២០ ខែមេសា ឆ្នាំ ២០២០នេះ នៅតែទៅបន្តរង់ចាំទទួលប្រជាពលរដ្ឋខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃដដែល។ អាជ្ញាធរបានឲ្យដឹងថា៖ ថ្ងៃនេះទទួលបានចំនួនសរុប ៤៨នាក់ ស្រីចំនួន ១៨នាក់ ដែលចូលមកតាមច្រកដូង ខេត្តបាត់ដំបង, តាមច្រកប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យ ។

សូមបញ្ជាក់ថា៖ គិតចាប់ពីថ្ងៃទី១០ ខែមីនា មកដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០នេះ តួលេខសរុបដែលបានទទួលប្រជាពលរដ្ឋខ្មែរ ចូលតាមច្រកទាំងបីខាងលើមានចំនួន ១២,០៦៧នាក់ ស្រីចំនួន ៥,២២៤នាក់ ក្នុងនោះបានពិនិត្យសុខភាពបឋមបានចំនួន១២,០៦៧នាក់ ស្រី ៥,២២៤នាក់ គឺពិនិត្យសុខភាពបានទាំងអស់។

តាមរយៈការយកចិត្តទុកខ្ពស់ពីរាជរដ្ឋាភិបាល ប្រជាពលរដ្ឋខ្មែរ មកពីបរទេស បានដាក់អោយនៅដាច់ដោយឡែក រយៈពេល១៤ ថ្ងៃ តាមទីតាំងមូលដ្ឋាន ដែលគាត់រស់នៅ និងតាមដានពីសុខភាពពីក្រុមគ្រូពេទ្យ។ នៅរាជធានីភ្នំពេញ ក្រសួងការងារ បានរៀបចំកន្លែង មណ្ឌលចត្តាឡីស័ក១០កន្លែង អោយកម្មករស្នាក់នៅ រយៈពេល១៤ថ្ងៃ ក្រោយពីពួកគាត់ត្រឡប់មកពីចូលឆ្នាំនៅស្រុកកំណើត៕ សហការី

## ពលករចំណាកស្រុកពីប្រទេសថៃប្រឈមអត់ការងារធ្វើនិងជំពាក់បំណុលគេ ក្រោយវិលត្រឡប់មកស្រុកកំណើត

https://khmer.voanews.com/ 21 មេសា 2020 គង់ មេត្តា

ស្រុកបាទី ខេត្តតាកែវ៖ លោក មិន សារុន និង អ្នកស្រី នាង ចន្ទ្រា ដែលត្រូវជាប្តីប្រពន្ធ បានមកដល់ច្រកអន្តរជាតិភូមិឡែម ខេត្តចាន់ថាបូរី ប្រទេសថៃ កាលពីថ្ងៃទី២ ខែមេសា ដើម្បីមកស្រុកកំណើតនៅខេត្តតាកែវ។ ពួកគាត់ត្រឡប់មកវិញក្នុងគោលបំណងទៅមើលម្តាយដែលកំពុងសម្រាកឈឺនៅផ្ទះ ប៉ុន្តែពួកគាត់មិនអាចឆ្លងតាមច្រកនេះបានទេ ដោយសារអាជ្ញាធរថៃបានបិទច្រកព្រំដែន ដើម្បីទប់ស្កាត់ការរីករាលដាលមេរោគកូរ៉ូណា។ ដើម្បីឆ្លងមកបានពួកគាត់ត្រូវដើរក្នុងព្រៃ ប្រហែល៣គីឡូម៉ែត្រ ហើយត្រូវចំណាយថ្លៃការធ្វើដំណើរជាង៩០ដុល្លារ ដើម្បីទៅមកដល់ទឹកដីខ្មែរ។ លោក មិន សារុន បានថ្លែងប្រាប់ VOA នៅផ្ទះរបស់លោកក្នុងខេត្តតាកែវថា៖ «គេបិទផ្លូវ ប៉ុន្តែឡានគេជូនមកតាមផ្លូវកាត់។ អ៊ីចឹងយើងត្រូវចំណាយលុយច្រើនដែរ។ យើងដើរប្រហែល៣គីឡូម៉ែត្រ ចេញ ១៥០០បាតក្នុងមួយនាក់»។ លោកបន្ថែម៖ «ទាហាននៅជាយដែនពិនិត្យខ្ញុំ៣ដងសរសេរក្រដាសពេទ្យ ពិនិត្យម៉ាស្អាតបានគេឲ្យមក ប្រហែលជា៣ម៉ោង ។ យើងជិះឡាន ។ ក្តួយទៅយក។ យើងជិះ៥នាក់ទាំងតែកុងអត់យកពីណាមកចូលទៀតទេ សុទ្ធតែបងប្អូនឯង»។ លោក មិន សារុន និងអ្នកស្រី នាង ចន្ទ្រា ជាពលករក្នុងចំណោមពលករខ្មែរចំណាកស្រុកមកពីថៃ ប្រមាណ៩ម៉ឺននាក់ ដែលបានប្រញាប់វិលមកស្រុកកំណើតវិញ កាលពីចុងខែមីនា ដើម្បីចៀសវាងជាប់ក្នុងប្រទេសថៃ ដែលរដ្ឋាភិបាលប្រកាសបិទច្រកព្រំដែន ដើម្បីទប់ស្កាត់ការរាតត្បាតជំងឺកូវីដ១៩។

កាលពីថ្ងៃទី៧ខែមេសា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង បានថ្លែងថា ពលករខ្មែររាប់ពាន់នាក់បានសម្រុកមកប្រទេសកម្ពុជាវិញ ហើយអាជ្ញាធរកម្ពុជានៅតាមច្រកមិនអាចពិនិត្យសុខភាពកម្មករទាំងអស់បានទេ។ ប្រជាពលរដ្ឋខ្មែរប្រមាណមួយលាន២០ម៉ឺននាក់កំពុងរស់នៅ និងធ្វើការនៅប្រទេសថៃ ហើយរដ្ឋាភិបាលកម្ពុជាប៉ាន់ប្រមាណថា ពួកគេច្រើនគួរសមគឺជាពលករមិនស្របច្បាប់។

របាយការណ៍របស់អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ឆ្នាំ២០១៩ ឲ្យបានដឹងថា មួយភាគបីនៃពលករចំណាកស្រុក ដែលត្រូវបានគេសាកសួរព័ត៌មាន គឺពុំមានការងារធ្វើក្នុងស្រុកទេ មុនពេលពួកគេចេញពីកម្ពុជា ហើយជិតពាក់កណ្តាល គឺគ្មានចំណូលនិងប្រហែលពីរភាគបីបានសម្រេចចិត្តទៅប្រទេសថៃស្វែងរកការងារ ដោយសារពុំមានឱកាសការងារនៅក្នុងស្រុក និងដោយសារចង់បានចំណូលប្រសើរជាងមុន។ របាយការណ៍បង្ហាញថា ចំនួនពាក់កណ្តាលនៃអ្នកដែលត្រូវបានសម្ភាស បានផ្ញើប្រាក់ត្រឡប់ទៅស្រុកដល់ទៅ១២២៨ដុល្លារ ក្នុងមួយឆ្នាំ ហើយថាប្រាក់ទាំងនេះ គឺជាប្រាក់ចំណូលចម្បងសម្រាប់ទំនុកបម្រុងគ្រួសារនៅប្រទេសកម្ពុជា ឬក៏ដើម្បីប្រើប្រាស់ធ្វើឲ្យជីវភាពប្រសើរឡើង។

លោក មិន សារុន និង អ្នកស្រី នាង ចន្ទ្រា កំពុងអង្គុយនៅក្រោមផ្ទះពេលដែលអ្នកសារព័ត៌មានVOAបានចុះសម្ភាសជាមួយពួកគាត់នៅក្នុងស្រុកបាទី ខេត្តតាកែវហើយវាគឺជាថ្ងៃទីបីនៃការរស់នៅដាច់ដោយឡែករយៈពេល១៤ថ្ងៃរបស់ពួកគាត់។ ប្តីប្រពន្ធទាំងពីរមានផ្ទះសមរម្យ ផ្ទះពីរទន្ទឹមគ្នា។ ផ្ទះមួយធ្វើពីឈើ នៅចំកណ្តាលដីភូមិ។ ម្តាយរបស់ពួកគាត់និងកូនប្រុសរបស់ពួកគាត់បានទៅរស់នៅផ្ទះសាច់ញាតិបណ្តោះអាសន្ន។ ពួកគាត់សម្រាកនៅខាងក្រោមផ្ទះថ្មបែងចែកដាច់ពីគ្នាដោយកំណាត់វាំងនន។

អ្នកស្រី នាង ចន្ទ្រា ប្រាប់ឲ្យដឹងថា មន្ត្រីសុខាភិបាលបានចុះមកពិនិត្យសុខភាពនៅផ្ទះរបស់គាត់នៅថ្ងៃដំបូង ចំនួនបីដងដោយមន្ត្រីបានពិនិត្យមើល កំដៅឬនិងអាការៈទាក់ទងនឹងជំងឺកូវីដ១៩ហើយការណែនាំរបស់គេសង្កត់ធ្ងន់គឺឲ្យពួកគាត់នៅដាច់ដោយឡែកពីគ្នា។ អ្នកស្រី នាង ចន្ទ្រា បន្តថា៖ «យើងអត់បានជួបគាត់។ អ្នកភូមិគេអត់ហ៊ានសួរសុខទុក្ខយើង»។

សម្រាប់ លោក មិន សារុន ការធ្វើដំណើរដ៏ប្រថុយប្រថាន និងការចំណាយលើថ្លៃធ្វើដំណើរត្រឡប់មកប្រទេសកម្ពុជាវិញគឺសំខាន់ ដោយសារត្រូវទៅថែទាំម្តាយកំពុងមានជំងឺ។ លោកបញ្ជាក់ថា៖ «ខ្ញុំគិតថា ល្អ បើខ្ញុំនៅនោះមានលុយផ្ញើឲ្យគាត់ គឺល្អ។ ប៉ុន្តែដោយសារគាត់ឈឺ គ្មានអ្នកណាថែគាត់ គឺមិនល្អសម្រាប់ខ្ញុំទេ។ម្តាយខ្ញុំឈឺនៅផ្ទះគ្មានអ្នកណាថែគាត់ អ៊ីចឹងខ្ញុំត្រូវតែមកវិញដើម្បីថែគាត់ ។ទោះបីអត់លុយមានលុយក៏ដោយ ខ្ញុំត្រូវតែមក»។ ពេលធ្វើការនៅរោងចក្រសាច់មាន់ នៅប្រទេសថៃតាំងពីចុងឆ្នាំ២០១៧មកនោះ ប្តីប្រពន្ធនេះរកប្រាក់ចំណូលបានប្រមាណ៤៣០ដុល្លារក្នុងមួយខែ។ ពួកគាត់ត្រូវផ្ញើទៅផ្ទះប្រមាណ១៥០ដុល្លារក្នុងមួយខែ និងបង់ការប្រាក់៦១ដុល្លារសម្រាប់បំណុលប្រមាណ២ពាន់ដុល្លារ ដែលពួកគាត់បានខ្ចីពីឈ្មួញចងការប្រាក់កាលពីពីរបីឆ្នាំមុន។ ពួកគាត់បានយកប្រាក់នោះដើម្បីចំណាយធ្វើលិខិតឆ្លងដែន និងការត្រៀមរៀបចំធ្វើដំណើរទៅប្រទេសថៃ។

បើទោះបីជាបានមកដល់ផ្ទះនិងបានជួបជុំគ្រួសារក៏ដោយ ក៏ពួកគាត់ទាំងពីរនាក់មានក្តីសង្ឃឹមបន្តិចបន្តួចប៉ុណ្ណោះសម្រាប់ពីរបីខែខាងមុខនៅពេលពួកគេបញ្ចប់ការរស់នៅដាច់ដោយឡែករបស់ពួកគេ។ លោក មិន សារុន មានក្តីបារម្ភក្នុងការស្វែងរកការងារដែលជាមូលហេតុជំរុញឲ្យគាត់ធ្វើចំណាកស្រុក តាំងពីដំបូងមក។ លោក មិន សារុនបានសុំឲ្យបងប្រុសរបស់គាត់ជួយបង់ប្រាក់ជំពាក់គេក្នុងខែមេសា។ លោកមានប្រសាសន៍ថា៖ «ពិបាកដោយសារពេលយើងមកផ្ទះ វាអត់ទាន់មានការងារច្បាស់លាស់ ដែលយើងត្រូវធ្វើ ដោះស្រាយទៅមុខទៀតហើយមកបង្ខាំងអ៊ីចឹងទៀត វាពិបាកបណ្តោយ។ វារកដំណោះស្រាយមិនចេញ បើពីរបីខែទៀត»។ ឈ្មួញចងការប្រាក់ឯកជនក្នុងភូមិ ដែលមិនបានចុះឈ្មោះផ្លូវការត្រឹមត្រូវនិងគ្មានការត្រួតពិនិត្យតាមផ្លូវច្បាប់ គឺជាប្រភពកម្ចីដែលមានការប្រាក់ខ្ពស់សម្រាប់ប្រជាជនកម្ពុជាបើទោះបី មានការរីកដុះដាលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏ដោយ។

ខណៈពេលដែលឈ្មួញចងការប្រាក់ឯកជន គឺជាប្រភពកម្ចីនោះរបាយការណ៍ឆ្នាំ២០១៥ របស់អង្គការសហប្រតិបត្តិការហិរញ្ញវត្ថុអន្តរជាតិ បានចង្អុលបង្ហាញថា ប្រហែលជាប្រជាជនទៅខ្ចីលុយពីក្រុមឈ្មួញចងការប្រាក់ឯកជនដើម្បីយកទៅបង់ការប្រាក់បន្ថែមឲ្យស្ថាប័នមីក្រូហិរញ្ញវត្ថុ ជាហេតុធ្វើឲ្យការប្រាក់ក្នុងវិស័យហិរញ្ញវត្ថុស្ថិតក្នុងកម្រិតទាប។ កាលពីឆ្នាំមុនអង្គការលីកាដូ និងសមាគមជាងត្នោត បានបញ្ចេញរបាយការណ៍ដែលបានផ្ទុះបញ្ចាំងការរំលោភបំពានសិទ្ធិដែលពាក់ព័ន្ធនឹងវិស័យមីក្រូហិរញ្ញវត្ថុ ជាពិសេស សិទ្ធិកាន់កាប់ដី ការធ្វើចំណាកស្រុកដោយបង្ខំ និងការជួញដូរកម្លាំងពលកម្មកុមារ។ ករណីសិក្សានៅក្នុងរបាយការណ៍នេះក៏បានលើកឡើងផងដែរថា ពលរដ្ឋដែលត្រូវបានសម្ភាសបានប្រើប្រាស់កម្ចីពីឈ្មួញចងការប្រាក់ឯកជន ដើម្បីសងការប្រាក់តម្កល់របស់មីក្រូហិរញ្ញវត្ថុ។

ត្រឡប់ទៅស្រុកបាទី ខេត្តតាកែវវិញ ពលរដ្ឋផ្សេងទៀត ដូចជាអ្នកស្រី សៀង ណារ័ត្ន និងស្វាមីឈ្មោះសេង រ៉ា បានត្រឡប់មកប្រទេសកម្ពុជាវិញ កាលពីថ្ងៃ២៤ ខែមីនា ចំពេលដែលច្រកអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យត្រូវបានបិទ។ ពួកគេនិងពលរដ្ឋខ្មែររាប់រយនាក់ទៀតដែលមានបំណងត្រឡប់ទៅស្រុកកំណើតបានជាប់នៅក្នុងប្រទេសថៃ។ ក្រោយពីការពិនិត្យសុខភាពជាច្រើនសាររបស់អាជ្ញាធរថៃ និងកម្ពុជា ប្តីប្រពន្ធទាំងពីរនាក់បានឆ្លងផុតព្រំប្រទល់ចូលមកកម្ពុជា ហើយបានជួលរថយន្តឈ្នួលជិះទៅផ្ទះភ្លាមៗ។ មកដល់ផ្ទះ អ្នកស្រីសៀង ណារ័ត្ន បាននិយាយថា ប៉ូលិសរួមមានប្រធានភូមិ និងបុគ្គលិកសុខាភិបាលបានចុះមកចាំដល់ផ្ទះរបស់ស្រីធ្វើឲ្យអ្នកភូមិមានការភ្ញាក់ផ្អើល។ អ្នកស្រីបញ្ជាក់ថា៖ «យើងមកដល់ផ្ទះប្រហែលម៉ោង៧។ គ្រាន់តែមកដល់ ទាំងប៉ូលិសទាំងប្រធានភូមិ អី គេមកពិនិត្យយើង។ ពេលព្រលឹមឡើងគេមកភ្លាមចូលផ្អើលពេញភូមិ។ គេផ្អើលគេខ្លាចយើង។ គេផ្អើលថា ខាងថៃ គេកើតច្រើន»។ ទើបតែបញ្ចប់ការរស់នៅដាច់ដោយឡែករយៈពេល១៤ថ្ងៃ អ្នកស្រី សេង ណារ័ត្ន បានប្រាប់ថាគាត់និងស្វាមី មិនមែនត្រឡប់មក ដោយសារការខ្លាចវីរុសកូរ៉ូណានោះទេ។ ពួកគេមានបំណងមកលេងកូនប្រុសនិងមកលេងស្រុកកំណើត មុនចូលឆ្នាំខ្មែរ និងជួបជុំក្រុមគ្រួសារ មុនពេលត្រឡប់ទៅប្រទេសថៃវិញ នាចុងខែមេសា។

អ្នកស្រីធ្លាប់ធ្វើការងាររោងចក្រកាត់ដេរក្នុងប្រទេសកម្ពុជា មុនពេលធ្វើចំណាកស្រុកទៅប្រទេសថៃ ដោយទទួលបានប្រាក់ខែ ប្រហែល២០០ដុល្លារ។ អ្នកស្រី សៀង ណារ័ត្ន ចង់បានជីវិតប្រសើរឲ្យកូនប្រុសអាយុបីឆ្នាំរបស់គាត់ ហេតុនេះហើយបានជាអ្នកស្រីបានសម្រេចចិត្តខ្ចីលុយពីឈ្មួញចងការ ដើម្បីចំណាយថ្លៃឯកសារ និងថ្លៃធ្វើដំណើរទៅប្រទេសថៃ។ កម្ចីនេះ អ្នកស្រីអាចយកបានដោយមិនចាំបាច់ដាក់ប្លង់ដីនោះទេ។ នៅក្នុងប្រទេសថៃ អ្នកស្រី សៀង ណារ័ត្ន និងស្វាមី អាចរកចំណូលរួមគ្នា បានប្រហែល៩២០ដុល្លារក្នុងមួយខែ ប៉ុន្តែត្រូវផ្ញើទៅផ្ទះសងលុយគេប្រហែល១០០ដុល្លារក្នុងមួយខែ ។

ស្វាមីរបស់អ្នកស្រី គឺលោក សេង រ៉ា ក៏បានប្រាប់ថា ពួកគេបានបង់សងគេរយៈពេលជិតពីរឆ្នាំមក ហើយនិងនៅជំពាក់ប្រាក់ឈ្មួញប្រហែល១០០០ដុល្លារទៀត។ ការត្រឡប់មកជួបកូននិងគ្រួសារក្នុង ឱកាសចូលឆ្នាំ បានធ្វើឲ្យប្តីប្រពន្ធទាំងពីរ ត្រូវជួបនូវសុបិនអាក្រក់ ទាក់ទងនឹងបញ្ហាថវិកា។ លោកបញ្ជាក់ថា៖ «យើងពិបាក។យើងមកដល់នេះ យើងទៅរកការងារធ្វើ ក៏វាពិបាក។យើងមកដល់នេះ អ្នកភូមិគេមិនហ៊ានមកក្បែរយើង។ អត់ទាន់ដឹងថា...ព្រោះអត់មានការងារធ្វើផង ថាទៅវិញហ្នឹង ថា ធ្វើការបានផ្ញើលុយទៅឲ្យគេ ... មានលុយបង់ឲ្យគេ.... ព្រោះតែអត់មានការងារធ្វើ យើងបារម្ភ»។ ដោយមានទឹកមុខក្រៀមក្រំ ដោយមិនបាននៅស្និទ្ធស្នាលជាមួយកូនប្រុសរយៈពេល១៤ថ្ងៃ អ្នកស្រី សៀង ណារ័ត្ន មានប្រសាសន៍ថា៖« គ្រាន់ចុះមកវិញ បាញ់អាល់កុល ហើយលាងដៃ លាងជើង ហើយឱបកូនភ្លាមហ្មង»។

លោក យុន ថារ៉ូ មន្ត្រីសម្របសម្រួលកម្មវិធីនៃមជ្ឈមណ្ឌលសម្ព័នភាពការងារ និងសិទ្ធិមនុស្ស(CENTRAL) បាននិយាយថា ដោយសារតែ ប្រឈមមុខនឹងបំណុលដ៏ច្រើន ពលករខ្មែរចំណាកស្រុក ពិតជាងាយរងគ្រោះអំឡុងពេលស្ថានភាពសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង ដោយសារវីរុសកូរ៉ូណា។ លោកបានថ្លែងប្រាប់VOAថា នេះគឺធ្វើឲ្យ

ស្ថានភាពកាន់តែអាក្រក់ដោយសាររដ្ឋាភិបាលអសមត្ថភាពក្នុងការអនុវត្តគោលនយោបាយសារពើពន្ធ គោលនយោបាយគាំទ្រសង្គម ដូចជាទទួលបានអត្ថប្រយោជន៍ពេលកម្មករអត់ការងារ ដើម្បីប៉ះប៉ូវក្នុងគ្រាមានផលប៉ះពាល់ដោយសេដ្ឋកិច្ចដែលកម្មករជួបនៅអំឡុងប៉ុន្មានខែខាងមុខនេះ។ លោកបន្ថែមថា៖ «ពលករចំណាកស្រុកកម្ពុជាដែលបានត្រឡប់មកសហគមន៍របស់ពួកគេវិញ ឬក៏មានគម្រោងនឹងត្រឡប់មកវិញ ពួកគាត់ គឺមានភាពងាយរងគ្រោះខ្លួនឯងផ្ទាល់ប៉ះពាល់គ្រួសារគាត់ និងសហគមន៍ ហើយអត់មានសេវាសង្គមដើម្បីជួយពួកគេទេ»។

លោក អ៊ុច ភា អភិបាលខេត្តតាកែវ មានប្រសាសន៍ថា រដ្ឋបាលខេត្តបានជួយសម្រួលប្រជាពលរដ្ឋខ្មែរត្រឡប់មកពីថៃ ហើយបានចុះអប់រំពលរដ្ឋ។ លោកមានប្រសាសន៍ថា៖ «យើងមានការបារម្ភ ដូច្នេះហើយបានយើងចុះអប់រំបងប្អូនកម្មករតាមរយៈការប្រើប្រាស់ផ្ទាំងរូបភាពសារ ការអប់រំ ប្រើប្រាស់វិទ្យុ និងការប្រើប្រាស់ឧបករណ៍មេក្រូចល័តចាក់ ដោយសារយើងឃើញថា គាត់នៅតែបន្តត្រឡប់មកពីថៃវិញ»។

ត្រឡប់មកលោក មិន សារុន នៅផ្ទះរបស់គាត់នៅស្រុកបាទី ខេត្តតាកែវ ។ ពួកគាត់កំពុងទន្ទឹងរង់ចាំការបញ្ចប់ការដាក់រស់នៅដាច់ដោយឡែក ដើម្បីបានរស់នៅជុំជាមួយគ្រួសារ និងកូន ហើយទោះបីជាយ៉ាងណាពួកគេរីករាយត្រឡប់មករស់នៅជុំគ្នាវិញទោះបីមានការរំខានក្តី។ ទោះជាយ៉ាងណា លោក មិន សារុន នៅតែបារម្ភពុំមានប្រាក់៦១ដុល្លារសម្រាប់សងគេ ដែលវាក៏អាចផ្តល់ការលំបាកដល់គ្រួសារគាត់ផងដែរ។ លោកបញ្ជាក់ថា៖«តិចច្រើនសំខាន់បាននៅជិតកូន នៅនេះក៏ល្អម្យ៉ាង។ សំខាន់យើងមានការងារចិញ្ចឹមកូនយើងបាន។យើងនៅនេះវិញ ល្អជាងតែបើសិនខ្ញុំនៅនេះ រកការងារអត់បាន...»។ លោកបន្ថែមថា៖ «ឈប់ទៅហើយ! ម៉ែពិបាកអ៊ីចឹងព្រោះថា ម៉ែកាន់តែចាស់ ។ ហើយកូនគាត់អត់មានអ្នកមើល»៕

## ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣នាក់

https://www.facebook.com/GDIOfficial General Department of Immigration - GDI 21-04-2020

នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣នាក់ ស្រី ០៩នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលរដ្ឋខ្មែរចំនួន ០២នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial General Department of Immigration - GDI *21-04-2020*

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ នារសៀលថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ បានទទួលពលរដ្ឋខ្មែរចំនួន ០២នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រក អូរហាសិប ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ៕

## ការត្រឡប់មកពីថៃរបស់ពលរដ្ឋខ្មែរ តាមច្រកនានាក្នុងខេត្តបាត់ដំបង មានការថយចុះ

http://btv.com.kh/nation-news/ 21/04/2020

បាត់ដំបង ៖ ការត្រឡប់មកស្រុកកំណើតវិញ របស់ប្រជាពលរដ្ឋ និងពលករខ្មែរ ពីប្រទេសថៃ ឆ្លងកាត់តាមច្រក នានា នៅក្នុងខេត្តបាត់ដំបង បានថយចុះជាបន្តបន្ទាប់ ក្រោយពីអាជ្ញាធរថៃ កាន់តែដាក់បម្រាមមិនឲ្យមានការធ្វើដំណើរដោយសេរីដូចពេលមុន ដោយសារបញ្ហាជំងឺកូវីដ១៩។

លោក សឿម ប៊ុនរិទ្ធ អភិបាលរង និងជាអ្នកនាំពាក្យសាលាខេត្តបាត់ដំបង បានឲ្យដឹងថា កាលពី មុនពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ពលករខ្មែរ មកពីថៃ ក្នុងមួយថ្ងៃ តាមច្រកនានា ក្នុងខេត្តបាត់ដំបង ជាប់ នឹងព្រំដែនថៃ មានប្រមាណជាង៣០០ទៅ៤០០នាក់ និងពេលខ្លះឡើងដល់ជាង៥០០នាក់ ប៉ុន្តែបច្ចុប្បន្ន បន្ទាប់ពីចូលឆ្នាំរួច ក្នុងមួយថ្ងៃៗ គឺថយចុះមកត្រឹមជាង១០០នាក់ ឬក្រោម១០០នាក់ ខណៈ រថយន្ត របស់កងកម្លាំងកងពលតូចដឹកជញ្ជូនលេខ៩៩ ប្រមាណ១៥គ្រឿង ត្រូវបានដាក់ពង្រាយចាំដឹកពលករ ទាំងនោះទៅស្រុក ដែលកាលពីមុនមានចំនួន៥០គ្រឿង។ លោក សឿម ប៊ុនរិទ្ធ បានបញ្ជាក់ថា ទោះបីនាពេលកន្លងមក នៅមិនទាន់មានបញ្ហាអសន្តិសុខអ្វីកើតឡើង នៅពេលមានពលករខ្មែរវិលត្រឡប់មកស្រុកកំណើតវិញ ក្នុងខណៈពេលពិភពលោក កំពុងជួប បញ្ហាការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ យ៉ាងក៏ដោយ ក៏អាជ្ញាធរខេត្ត នៅតែសហការជាមួយមន្ទីរជំនាញ និងកងកម្លាំងពាក់ព័ន្ធ ត្រៀមបង្ការទប់ស្កាត់ជានិច្ច នូវបញ្ហាជំងឺកូវីដ និងបញ្ហាអសន្តិសុខ។

ពលករ ដែលមានទីលំនៅក្នុងខេត្តបាត់ដំបង បានវិលត្រឡប់ពីថៃ ចូលតាមច្រកក្នុងខេត្ត និងក្រៅ ខេត្ត ក្នុងថ្ងៃទី២០ ខែមេសា នេះ មានចំនួន៣០នាក់ ហើយពលករ ដែលមានទីលំនៅតាមបណ្តារាជធានី /ខេត្ត ដែលចូលមកវិញតាមច្រកទ្វារព្រំដែនក្នុងខេត្តបាត់ដំបង ក្នុងថ្ងៃដូចគ្នានេះ មានចំនួន៥៨នាក់៕

## រដ្ឋមន្ត្រីៈ មិនទាន់រកឃើញវិជ្ជមានកូវីដ ១៩ ក្នុងពលករ ៩ ម៉ឺននាក់ដែលមកពីថៃទេ

https://www.postkhmer.com/ នៀម ឆេង | Publication date 21 April 2020 | 10:24 ICT

**ភ្នំពេញៈ** រដ្ឋមន្ត្រីក្រសួងសុខាភិបាលលោក ម៉ម ប៊ុនហេង បានថ្លែងថា រហូតមកដល់ពេលនេះពលករកម្ពុជាដែលត្រឡប់មកពីប្រទេសថៃមានប្រមាណ ៩ ម៉ឺននាក់។ ប៉ុន្តែក្រសួងមិនទាន់រកឃើញករណីវិជ្ជមានជំងឺកូវីដ ១៩ លើពលករណាម្នាក់ទេ។ ក្រសួងសុខាភិបាលបានចំណាយថវិកាសរុបជាង ១០ លានដុល្លារ ដើម្បីការប្រយុទ្ធនឹងជំងឺកូវីដ ១៩។ ការលើកឡើងរបស់លោករដ្ឋមន្ត្រីបានធ្វើឡើងក្នុងសន្និសីទប្រចាំសប្តាហ៍នៅទីស្តីការក្រសួងសុខាភិបាលកាលពីម្សិលមិញ ដើម្បីធ្វើបច្ចុប្បន្នភាពអំពីការវិវត្តនៃជំងឺកូវីដ ១៩។ លោក ប៊ុនហេង ថ្លែងថាក្នុងចំណោមពលករមានតែអ្នកដែលគួរឲ្យសង្ស័យតែតាមការធ្វើតេស្តពួកគេមិនមានផ្ទុកមេរោគនេះទេ។ ទោះយ៉ាងណាហានិភ័យអាចនឹងកើតមានពីសំណាក់ពួកគេ។ លោក ប៊ុនហេង បានថ្លែងថាៈ «ពលករពីថៃ ៩ ម៉ឺននាក់ យើងកំពុងតាមដានដល់ពេលនេះមិនទាន់មានអ្នកផ្ទុកទេ យើងគិតថានឹងអាចមានហានិភ័យ សភាពការណ៍យើងនៅផុយស្រួយ»។

លោក លី សុវ៉ាន់ ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងក៏បានថ្លែងក្នុងសន្និសីទដែរថា ក្នុងចំណោមពលករដែលមកពីប្រទេសថៃចំនួនប្រមាណ ៩ ម៉ឺននាក់ មាន ៤១០ នាក់ត្រូវបានធ្វើតេស្ត តែលទ្ធផលអវិជ្ជមានទាំងអស់។

លោកស្រី យក់ សម្បត្តិ រដ្ឋលេខាធិការក្រសួងសុខាភិបាលបានថ្លែងថា ក្រសួងបានរៀបចំធ្វើការពិនិត្យសុខភាពពលករត្រឡប់ពីប្រទេស ថៃ តាមច្រកចំនួន ៣ រួមមាន ច្រកប៉ោយប៉ែត ច្រកដូង និងច្រកអូរស្មាច់។ គណៈកម្មការប្រយុទ្ធប្រឆាំងកូវីដ ១៩ បានរៀបចំតង់នៅតាមច្រក រៀបចំថវិកាដល់មន្ត្រីពេទ្យ និងអាហារសម្រាប់ពលករពេលរង់ចាំ។ ក្រៅពីនេះខាងកងទ័ពក៏បានរៀបចំការដឹកជញ្ជូនពលករពីច្រកព្រំដែនទាំងនោះទៅកាន់ខេត្តក្រុងទាំង២៥។ ស្របពេលជាមួយគ្នានេះលោកស្រី យក់ សម្បត្តិ បានធ្វើបច្ចុប្បន្នភាពថវិកា និងការចំណាយដើម្បីប្រយុទ្ធនឹងជំងឺនេះដោយលោកស្រីថ្លែងថា ថវិកាដែលទទួលបានពីសប្បុរសជនមានសរុប ១៣ លានដុល្លារ។ ក្នុងចំនួននេះក្រសួង

បានដកចំនួន ៥ លានដុល្លារសម្រាប់ទិញសម្ភារផ្សេងៗជាពិសេសម៉ាស់។ ថវិកាចំនួន ១ លានដុល្លារដែលនឹងត្រូវផ្ទេរទៅក្រសួងការងារនឹងបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ទ្រទ្រង់ និងព្យាបាល ធ្វើតេស្តដល់កម្មករដែលត្រឡប់មកពីស្រុកក្នុងពេលបុណ្យចូលឆ្នាំ។

ចំណែកថវិការជ្ជដែលបានគ្រោងទុកសរុបចំនួន ៣០ លានដុល្លារ ក្រសួងបានចំណាយអស់ ៤,៥ លានដុល្លារ ហើយទៅលើការទិញសម្ភារផ្គត់ផ្គង់ទៅគ្រប់ខេត្តក្រុង និងមន្ទីរពេទ្យខ្មែរ-សូវៀត និងមន្ទីរពេទ្យចាក់អង្រែ។ លោកស្រីបានពន្យល់ថា ការចំណាយសម្រាប់ព្យាបាលអ្នកជំងឺម្នាក់ៗមានចន្លោះពី ២ ០០០ ទៅ ២ ៥០០ ដុល្លារសម្រាប់ការស្នាក់នៅមន្ទីរពេទ្យចាប់ពី ១០ ថ្ងៃឡើងទៅ។ លោកស្រីបញ្ជាក់ថា៖ «នៅប៉ាស្ទ័រ តេស្តមួយតម្លៃប្រហែលជា ១០០ ទៅ ១២០ ដុល្លារ តាមបទពិសោធពី Westerdam។ ដូច្នេះតេស្តមាន ២ យ៉ាងគឺតេស្តខ្លះអ្នកជំងឺមានរោគសញ្ញា តេស្តខ្លះលើអ្នកជំងឺគ្មានរោគសញ្ញា។ ដូច្នេះប្រែប្រួលពី ២០ ទៅ ៣០ ដុល្លារក្នុងតេស្តមួយ។ ជាសរុបតេស្តមួយពី ១០០ ទៅ ១២០ ដុល្លារ ហើយប្រសិនបើគាត់ស្នាក់នៅរយៈពេល ១០ ថ្ងៃ យើងឃើញថា គ្រាន់តែតេស្តនៅមន្ទីរពិសោធន៍គឺ ១ ០០០ ដុល្លារ»។ លោកស្រីបន្តថា៖ «បើគិតដល់ការព្យាបាល ថ្នាំ បើគាត់អស់កម្លាំងត្រូវដាក់សេរ៉ូមត្រូវបំប៉នវីតាមីនផ្សេងៗទៀត ថ្នាំព្យាបាលទៅតាមរោគសញ្ញាផ្សេងៗទៀត គិតជាមធ្យមសម្រាប់បរទេស និងអាហារហូបចុករបស់គាត់ទៀត។ ដូច្នេះខ្ញុំគិតជាមធ្យមសម្រាប់អ្នកដែលសម្រាកចាប់ពី ១០ ថ្ងៃឡើងទៅ ប្រហែលពី ២ ០០០ ទៅ ២ ៥០០ ដុល្លារអាមេរិក ក្នុង ១ ករណី»។

ក្រៅពីថវិកានេះលោកស្រីថា មានដៃគូអភិវឌ្ឍន៍ពីប្រទេសផ្សេងៗដែលផ្តល់ថវិកាតាមរយៈគម្រោងមានសរុប ២០ លានដុល្លារ។ ការផ្តល់ជំនួយនេះមានក្នុងរូបភាពផ្សេងៗដូចជា រថយន្តសង្គ្រោះបន្ទាន់ចំនួន ៦០ គ្រឿង និងម៉ាស៊ីនជំនួយដល់ការដកដង្ហើម (វ៉ង់ទីឡាទ័រ)។ លោកស្រីថា សព្វថ្ងៃកម្ពុជាមាន វ៉ង់ទីឡាទ័រចំនួន ១២៤ គ្រឿងនៅតាមមន្ទីរពេទ្យនានា ហើយថ្មីៗកម្ពុជាបានទទួល វ៉ង់ទីឡាទ័រថ្មី ចំនួន ២៥ គ្រឿង។ នៅចុងខែនេះ វ៉ង់ទីឡាទ័រចំនួន ៣៥ ទៀតនឹងមកដល់។ ធនាគារពិភពលោកក៏នឹងផ្តល់ជូនបន្ថែមប្រមាណ ៥០ គ្រឿងទៀត៕

## ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០

## រាជរដ្ឋាភិបាលកំពុងគិតគូរដល់ពលករចំណាកស្រុក

http://www.rasmeinews.com/ April 22, 2020, 7:31 PM

*ដោយៈ មុនីរ័ត្ន/ភ្នំពេញៈ* សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានដឹកនាំកិច្ចប្រជុំ ពិគ្រោះយោបល់ដើម្បីពិនិត្យលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរយៈពេលខ្លី មធ្យម និងវែងរបស់ពលករចំណាកស្រុកក្នុងស្ថានភាពរីករាលដាលនៃជំងឺកូវីដ១៩ (Covid-19) កាលពីព្រឹកថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ។ សម្តេចក្រឡាហោម ស ខេង បានថ្លែងថា កិច្ចប្រជុំថ្ងៃនេះ គឺធ្វើឡើងតាមការប្រគល់ភារកិច្ចពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាស្វែងរកគន្លឹះសំខាន់ៗ ក្នុងការដោះស្រាយបញ្ហានានាក្នុង ស្ថានភាពនៃវិបត្តិកូវីដ១៩ ដើម្បីរក្សាស្ថិរភាពសុវត្ថិភាពសង្គម ក្នុងរយៈពេលខ្លី មធ្យម និងវែងទៅមុខទៀត ។ តាមរយៈកិច្ចប្រជុំនេះ បញ្ហាទេសន្តប្រវេសន៍ពាក់ព័ន្ធនឹងពលករ ដែលបានវិលត្រឡប់មកបណ្តាប្រទេសនានា ពិសេសពលករដែលបានវិលមកពីប្រទេសថៃ ចូលកម្ពុជាវិញមុនពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ដែលគិតមកដល់ ពេលនេះ មានចំនួនប្រមាណ ៨៥.០០០នាក់ ដែលភាគច្រើនអាចផ្គត់ផ្គង់ជីវភាពគ្រួសារបានក្នុងរយៈពេលខ្លីប៉ុណ្ណោះ ។

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានដឹកនាំកិច្ចប្រជុំ ពិគ្រោះយោបល់ដើម្បីពិនិត្យលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរយៈពេលខ្លី មធ្យម និងវែង របស់ពលករចំណាកស្រុកក្នុងស្ថានភាពរីករាលដាលនៃជំងឺកូវីដ១៩ (Covid-19) សម្តេចក្រឡាហោម បានបញ្ជាក់ថា ជាទូទៅ ពួកគាត់រំពឹងថានឹងត្រឡប់ទៅប្រទេសថៃវិញដើម្បីធ្វើការងារបន្ទាប់ពីបញ្ចប់ពិធីបុណ្យចូលឆ្នាំ។ ប៉ុន្តែនៅក្នុងស្ថានភាព

បច្ចុប្បន្ន ទាំងកម្ពុជា និងថៃបានរឹតបន្តឹងការឆ្លងកាត់ព្រំដែន ពិសេសគឺថៃកំពុងមានការរាតត្បាតជំងឺកូវីដ១៩ក្នុងស្ថានភាពធ្ងន់ធ្ងរនៅឡើយ ហេតុបានដាក់ប្រទេសស្ថិតក្នុងគ្រាអាសន្នដោយមិនទាន់កំណត់ពេលត្រូវបើកឡើងវិញនៅឡើយទេ ។ សម្តេចក្រឡាហោមបានបន្តថា ក្នុងបេសកកម្មប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មការជាតិដឹកនាំដោយសម្តេចតេជោនាយករដ្ឋមន្ត្រី និងបង្កើតគណៈកម្មការអន្តរក្រសួងដឹកនាំដោយរដ្ឋមន្ត្រីក្រសួង សុខាភិបាល ដោយបានបង្កើតក្រុមការងារប្រតិបត្តិចំនួនពីរ គឺក្រុមការងារប្រតិបត្តិការបច្ចេកទេស និងផ្គត់ផ្គង់ និងក្រុមការងារប្រតិបត្តិអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ ៕*សរ*

## សម្តេចក្រឡាហោម ស ខេង ដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីពិនិត្យលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរយៈពេលខ្លី មធ្យម និងវែង របស់ពលករចំណាកស្រុក ក្នុងស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩ (Covid-19)

http://cambodiapolice.com/policekh/ 4:06 pm 22 មេសា 2020

រាជធានីភ្នំពេញ ៖ នាព្រឹកថ្ងៃពុធ ទី២២ ខែមេសា ឆ្នាំ២០២០នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីពិនិត្យលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរយៈពេលខ្លី មធ្យម និងវែង របស់ពលករចំណាកស្រុក ក្នុងស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩ (Covid-19) ប្រារព្ធនៅទីស្តីការក្រសួងមហាផ្ទៃ ។ ក្រោមអធិបតីភាព សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី កិច្ចប្រជុំដ៏មានសារៈសំខាន់នេះ មានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវជារដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ ឯកឧត្តមរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងអគ្គនាយកនៃក្រសួងមហាផ្ទៃ និងមកពីបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ ព្រមទាំងមានការអញ្ជើញចូលរួមពីតំណាងភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ។

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ថា កិច្ចប្រជុំថ្ងៃនេះ គឺធ្វើឡើងតាមការប្រគល់ភារកិច្ចពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាស្វែងរកគន្លឹះសំខាន់ៗ ក្នុងការដោះស្រាយបញ្ហានានាក្នុងស្ថានភាពនៃវិបត្តិកូវីដ១៩ ដើម្បីរក្សាស្ថេរភាព សុវត្ថិភាពសង្គម ក្នុងរយៈពេលខ្លី មធ្យម និងវែងទៅមុខទៀត ។ សម្តេចបានបន្តថាតាមរយៈកិច្ចប្រជុំនេះ បញ្ហាទេសន្តប្រវេសន៍ពាក់ព័ន្ធនឹងពលករ ដែលបានវិលត្រឡប់មកបណ្តាប្រទេសនានា ពិសេសពលករដែលបានវិលមកពីប្រទេសថៃចូលកម្ពុជាវិញមុនពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ដែលគិតមកដល់ពេលនេះ មានចំនួនប្រមាណ ៨៥០០០នាក់ ដែលភាគច្រើនអាចផ្គត់ផ្គង់ជីវភាពគ្រួសារបានក្នុងរយៈពេលខ្លីប៉ុណ្ណោះ ។ សម្តេចក្រឡាហោម បានគូសបញ្ជាក់ទៀតថាជាទូទៅ ពួកគាត់រំពឹងថានឹងត្រឡប់ទៅប្រទេសថៃវិញដើម្បីធ្វើការងារបន្ទាប់ពីបញ្ចប់ពិធីបុណ្យចូលឆ្នាំ ប៉ុន្តែនៅក្នុងស្ថានភាពបច្ចុប្បន្ន ទាំងកម្ពុជា និងថៃបានរឹតបន្តឹងការឆ្លងកាត់ព្រំដែន ពិសេសគឺថៃកំពុងមានការរាតត្បាតជំងឺកូវីដ១៩ក្នុងស្ថានភាពធ្ងន់ធ្ងរនៅឡើយ ហេតុបានដាក់ប្រទេសស្ថិតក្នុងគ្រាអាសន្នដោយមិនទាន់កំណត់ពេលត្រូវបើកឡើងវិញនៅឡើយទេ ។

សម្តេចឧបនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា ក្នុងបេសកកម្មប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគណៈកម្មការជាតិដឹកនាំដោយសម្តេចតេជោនាយករដ្ឋមន្ត្រី និងបង្កើតគណៈកម្មការអន្តរក្រសួងដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ដោយបានបង្កើតក្រុមការងារប្រតិបត្តិចំនួន២ គឺក្រុមការងារប្រតិបត្តិការបច្ចេកទេស និងផ្គត់ផ្គង់ និងក្រុមការងារប្រតិបត្តិអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ ។ រាជរដ្ឋាភិបាលក៏បានបង្កើតក្រុមការងារចំពោះកិច្ចចំនួន៤ទៀត ដើម្បីដោះស្រាយបញ្ហាប្រឈមសំខាន់ៗ គឺក្រុមការងារគ្រប់គ្រង ថ្លៃទំនិញយុទ្ធសាស្ត្រ ក្រុមការងាររៀបចំគ្រប់គ្រងយន្តការជំនួយសង្គម ក្រុមការងាររៀបចំគោល

នយោបាយថវិកា និងជំនួយសង្គម និងក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីសិក្សារៀបចំដាក់ចេញកញ្ចប់វិធានការហិរញ្ញវត្ថុ និងធនាគារដើម្បីដោះស្រាយផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ១៩ ។

នៅក្នុងឱកាសនោះ សម្តេចបានមានប្រសាសន៍ថា ភ្នាក់ងារអង្គការសហប្រជាជាតិបានបង្ហាញការប្តេជ្ញាចិត្តគាំទ្ររាជរដ្ឋាភិបាល និងចូលរួមអនុវត្តយន្តការដែលមានស្រាប់រួចមកហើយ ។ ប៉ុន្តែសម្រាប់កិច្ចប្រជុំនៅថ្ងៃនេះ សម្តេចនៅតែបន្តចង់បានមតិយោបល់ទាំងពីតំណាងក្រសួងស្ថាប័ន និងភ្នាក់ងារអង្គការសហប្រជាជាតិបន្ថែមទៀត ថាតើវិធានការ និងយន្តដែលមានស្រាប់នោះ គ្រប់គ្រាន់ហើយឬនៅ ឬនៅមានចន្លោះខ្វះខាត ដែលត្រូវបំពេញបន្ថែម ។

តំណាងភ្នាក់ងារអង្គការសហប្រជាជាតិ បានបញ្ចេញមតិគ្រប់ៗគ្នាជូនទៅសម្តេចក្រឡាហោម ស ខេង និងអង្គប្រជុំដោយបានបង្ហាញការគាំទ្រទាំងស្រុងចំពោះយន្តការ ដែលរាជរដ្ឋាភិបាលកំពុងអនុវត្តក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ និងបានថ្លែងប្តេជ្ញាចិត្តជាថ្មីទៀតក្នុងការសហការគាំទ្រការអនុវត្តជាមួយក្រុមការងាររបស់រាជរដ្ឋាភិបាល ទៅតាមវិស័យជំនាញរៀងៗខ្លួន ។

អង្គប្រជុំក៏បានសម្តែងការវាយតម្លៃខ្ពស់ចំពោះការបំពេញភារកិច្ចប្រកបដោយការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ ក្នុងការងារប្រយុទ្ធទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ពិសេសការអប់រំផ្សព្វផ្សាយ និងការរៀបចំដាក់នៅដោយឡែក និងបានកោតសរសើរខ្ពស់ចំពោះថ្នាក់ដឹកនាំក្រសួងសុខាភិបាល ក្រុមគ្រូពេទ្យ និងកងកម្លាំងចម្រុះ ដែលបានរួមគ្នាបំពេញភារកិច្ចទទួលបានលទ្ធផលល្អប្រសើរ ក្នុងវិធានការចម្រុះនាន ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ ៕ សម្រួលដោយ៖ អនុ.ទោ.រឿង សុវណ្ណដែត

## កិច្ចប្រជុំ ពិគ្រោះយោបល់ ដើម្បីពិនិត្យលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការ រយៈពេលខ្លីម ធ្យម និងវែង របស់ពលករចំណាកស្រុក ក្នុងស្ថានភាពរីករាលដាល នៃជម្ងឺកូវីដ១៩

https://gdlf-kh.com/ 22/04/2020 Kim Sopha

ភ្នំពេញ ៖ នាព្រឹកថ្ងៃពុធ ១កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២២ ខែមេសា ឆ្នាំ ២០២០ នៅសាលប្រជុំក្រសួងមហាផ្ទៃ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ដឹកនាំកិច្ចប្រជុំ ពិគ្រោះយោបល់ ដើម្បីពិនិត្យលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការ រយៈពេលខ្លីមធ្យម និងវែង របស់ពលករចំណាកស្រុក ក្នុងស្ថានភាពរីករាលដាលនៃជម្ងឺកូវីដ១៩ (Covid-19) ពាក់ព័ន្ធការងារអន្តរក្រសួង និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)។ កិច្ចប្រជុំនេះបានប្រព្រឹត្តទៅដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ តំណាងអង្គការសហប្រជាជាតិ តំណាងអង្គទូត ស្ថាប័ន អង្គការអន្តរជាតិនានា ថ្នាក់ដឹកនាំ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អង្គភាព ស្ថាប័ន និងមន្ត្រីពាក់ព័ន្ធជាច្រើនផងដែរ។

ក្នុងឱកាសនោះ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ) បានថ្លែងថា ពលករវិល មកស្រុកខ្មែរវិញ នាពេលកន្លងទៅនេះ មានជាង៨ម៉ឺននាក់ពួកគេគ្មានឆ្លងជំងឺ កូវីដ-១៩ ទេ ហើយក្រសួង ក៏បានហាមឃាត់ពួកគាត់ មិនឲ្យវិលត្រឡប់ទៅក្រៅប្រទេសវិញ ដើម្បីទប់ស្កាត់ ការរីករាលដាលជំងឺ កូវីដ-១៩។

ក្រោយបញ្ចប់ កិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីពិនិត្យលទ្ធភាពក្នុងការឆ្លើយតប ទៅនឹងតម្រូវ ការរយៈពេលខ្លីមធ្យម និងវែង របស់ពលករចំណាកស្រុក ក្នុងស្ថានភាពរីករាលដាល នៃជំងឺ កូវីដ-១៩ នាថ្ងៃទី២២ ខែមេសា ឆ្នាំ ២០២០ លោកជំទាវ ជូ ប៊ុនអេង បានពន្យល់ថា នៅពេលពលករខ្មែរ ចូលដល់ព្រំដែនភ្លាម ភាគីពាក់ព័ន្ធ បានចុះ

ពិនិត្យ និង សួរប្រវត្តិពួកគាត់ ព្រមទាំង បញ្ជូនពួកគាត់ ទៅធ្វើចត្តាឡីស័ក ផងដែរ។ លោកជំទាវ មានប្រសាសន៍ថា «បើសិនយើងរកឃើញថា មានពលករយើងណាម្នាក់ មានកំដៅ ខុសពីធម្មតា គឺពួកគាត់ស្ថិតនៅការតាមដានបន្តអត់ទាន់បញ្ជូន គាត់ចេញមក ទេ។ចឹងនៅពេលនោះ មានជាបន្តបន្ទាប់ ដែលយើងស្នើសុំមន្ទីរពេទ្យបង្អែក ព្រំដែនត្រូវពិនិត្យ បន្ថែម ដើម្បីយកសំណាក ក្នុងការពិនិត្យយើងរកអត់ទាន់ឃើញ យើងគិតថា ពួកគាត់មានក្តៅ ដោយមូលហេតុផ្សេងៗ»។ លោកជំទាវ បន្តថា «នៅក្នុងការផ្សព្វផ្សាយរបស់ ក្រសួងសុខាភិបាលថា មានជាង៤០០នាក់ (ពលករ) ដែលបានសង្ស័យ ហើយយកសំណាកទៅពិនិត្យ ប៉ុន្តែមកដល់ពេលនេះ ការចេញ លទ្ធផលជាបន្តបន្ទាប់ ដូចជា មិនទាន់រកឃើញថា អ្នកដែលមានឆ្លងមេរោគ កូវីដ-១៩ នៅឡើយទេ»។

ឆ្លៀតឱកាសនោះដែរ លោកជំទាវ ជូ ប៊ុនអេង ក៏បានអំពាវនាវទៅដល់ប្រជាពលរដ្ឋទាំងអស់ ត្រូវមានការដាំដុះ បន្លែ ជាដើម ដើម្បីរកប្រាក់ចំណូល ក្នុងគ្រួសារបន្ថែមទៀត ជាពិសេស ត្រូវមានការអត់ធ្មត់ ចំពោះដំណាក់កាល ដែលកម្ពុជាកំពុងកើតមានឡើងជំងឺកូវីដ-១៩។ លោកជំទាវ មានប្រសាសន៍ បន្តថា «សូមមេត្តាកុំអាលវិលត្រឡប់ ទៅរកប្រទេសគោលដៅ វិញដោយសារប្រទេសគោលដៅហ្នឹង បច្ចុប្បន្ននេះ គឺមានអត្រាឆ្លងខ្ពស់ជាងយើងទៀត។ប្រសិនបើពួកគាត់វិលត្រឡប់ទៅពេលនេះ គឺជួបនឹងហានីភ័យខ្ពស់ណាស់ ហើយខាង ប្រទេសគេវិញ ក៏រឹតបន្តឹងដែរ អំពីការបិទ ព្រំដែនដែរ»។ លោកជំទាវ រំលឹកថា រាជរដ្ឋាភិបាល កំពុងតាមដានយ៉ាងយកចិត្តទុកដាក់ ចំពោះពលករ ពលរដ្ឋ សិស្ស និស្សិត នៅក្រៅប្រទេស តើកំពុងប្រឈមបញ្ហាអ្វីខ្លះ? ។ លោកស្រីថា រហូតដល់ពេលនេះ មិនទាន់មានសភាពធ្ងន់ធ្ងរ ចំពោះការឆ្លងកូវីដ-១៩ ទៅពលរដ្ឋខ្មែរ នៅក្រៅប្រទេសឡើយ។

សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ កម្ពុជាបានព្យាបាល អ្នកជាសះស្បើយពី ជំងឺ កូវីដ-១៩ ចំនួន១១០នាក់ ។ចំណែក អ្នកកំពុងសម្រាកព្យាបាលជំងឺកូវីដ ចំនួន១២នាក់ ហើយអ្នកឆ្លងសរុបទាំងអស់មានចំនួន១២២នាក់៕

## ក្រសួងមហាផ្ទៃ ហាមឃាត់ពលករខ្មែរប្រមាណជាង៨ម៉ឺននាក់ មិនឲ្យត្រឡប់ទៅក្រៅប្រទេសវិញ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩

https://www.cen.com.kh/ April 22, 2020

ភ្នំពេញ៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ) បានថ្លែងថា ពលករខ្មែរចំណាកស្រុក ដែលត្រឡប់មកស្រុកខ្មែរវិញ នាពេលកន្លងទៅនេះ មានប្រមាណជាង៨ម៉ឺននាក់ គឺមិនទាន់រកឃើញមានឆ្លងជំងឺ កូវីដ-១៩ នៅឡើយទេ ហើយក្នុងស្ថានភាពនេះដែរ ក្រសួងមហាផ្ទៃ ក៏បានហាមឃាត់ពលករទាំងនោះ មិនឲ្យវិលត្រឡប់ទៅក្រៅប្រទេសវិញ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩។ លោកជំទាវ មានប្រសាសន៍ថា សូមមេត្តាកុំអាលវិលត្រឡប់ ទៅរកប្រទេសគោលដៅវិញ ដោយសារប្រទេសគោលដៅហ្នឹង បច្ចុប្បន្ននេះគឺមានអត្រាឆ្លងខ្ពស់ជាងយើងទៀត។ អីចឹងប្រសិនបើពួកគាត់វិលត្រឡប់ទៅពេលនេះ គឺជួបនឹងហានិភ័យខ្ពស់ណាស់ ហើយខាងប្រទេសគេវិញក៏រឹតបន្តឹងដែរ អំពីការបិទព្រំដែនដែរ។

ក្រោយបញ្ចប់កិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីពិនិត្យលទ្ធភាពក្នុងការឆ្លើយតប ទៅនឹងតម្រូវការរយៈពេលខ្លី មធ្យមនិងវែងរបស់ពលករចំណាកស្រុក ក្នុងស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩ នាថ្ងៃទី២២ មេសា ឆ្នាំ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ លោកជំទាវ ជូ ប៊ុនអេង បានមានប្រសាសន៍ថា នៅពេលពលករខ្មែរចូលដល់ព្រំដែនភ្លាមៗ ភាគីពាក់ព័ន្ធទាំងអស់បានចុះពិនិត្យ និងសួរប្រវត្តិពួកគាត់ ព្រមទាំងបញ្ជូនទៅធ្វើចត្តាឡីស័កផងដែរ។ លោកជំទាវមានប្រសាសន៍ថា បើសិនយើងរកឃើញថា មានពលករយើងណាម្នាក់ មានកម្តៅ ខុសពីធម្មតា។ គឺពួកគាត់ស្ថិតនៅការតាមដានបន្តអត់ទាន់បញ្ជូនគាត់ចេញមកទេ។ អីចឹងនៅពេលនោះ មានជាបន្តបន្ទាប់ ដែលយើងស្នើសុំ

មន្ទីរពេទ្យបង្អែកព្រំដែន ត្រូវពិនិត្យបន្ថែម ដើម្បីយកសំណាកក្នុងការពិនិត្យអីចឹង យើងរកអត់ទាន់ឃើញ យើងគិតថាពួកគាត់មានក្ដៅដោយមូលហេតុផ្សេងៗ។ លោកជំទាវបន្តថា នៅក្នុងការផ្សព្វផ្សាយ របស់ក្រសួងសុខាភិបាល គឺមានជាង៤០០នាក់ (ពលករ) ដែលបានសង្ស័យ ហើយយកសំណាកទៅពិនិត្យ ប៉ុន្តែមកដល់ពេលនេះការចេញលទ្ធផលជាបន្តបន្ទាប់ ដូចជា មិនទាន់រកឃើញថា អ្នកដែលមានឆ្លងមេរោគ កូវីដ-១៩ នៅឡើយទេ។

ឆ្លៀតឱកាសនោះដែរ លោកជំទាវ ជូ ប៊ុនអេង ក៏បានអំពាវនាវ និងលើកទឹកចិត្តទៅដល់ប្រជាពលរដ្ឋទាំងអស់ ត្រូវមានការដាំដុះបន្លែបន្ថែម នៅតាមទីលំនៅរៀងៗខ្លួនជាដើម ដើម្បីរកប្រាក់ចំណូលក្នុងគ្រួសារបន្ថែមទៀត ជាពិសេសត្រូវមានការអត់ធ្មត់ចំពោះដំណាក់កាល ដែលកម្ពុជាកំពុងជួបប្រទះ បញ្ហាការរីករាលដាលនៃជំងឺកូវីដ-១៩នេះ។ លោកជំទាវបានរំលឹកថា រហូតដល់ពេលនេះ មិនទាន់មានសភាពធ្ងន់ធ្ងរណាមួយចំពោះការឆ្លងជំងឺកូវីដ-១៩ ទៅពលរដ្ឋខ្មែរនៅក្រៅប្រទេស នៅឡើយនោះទេ ប៉ុន្តែបើទោះជាយ៉ាងនេះក្ដី ក៏រាជរដ្ឋាភិបាលកំពុងតាមដានយ៉ាងយកចិត្តទុកដាក់ចំពោះ ពលករ ពលរដ្ឋ សិស្សនិស្សិតនៅក្រៅប្រទេសផងដែរ៕ដោយៈបញ្ញាស័ក្តិ

## កម្ពុជាហាមឃាត់មិនឱ្យពលករវិលត្រឡប់ទៅធ្វើការនៅក្រៅប្រទេសវិញ

http://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ: 22/04/2020 - 13:08 ដោយៈវណ្ណ សុគន្ធា

គិតមកដល់ពេលនេះ ពលករខ្មែរប្រមាណជាជាង៨ម៉ឺន៥ពាន់នាក់ បានវិលត្រឡប់ចូលក្នុងប្រទេសកំណើតវិញដោយសារបញ្ហារីករាលដាលនៃជំងឺកូវីដ-១៩។ ក្រសួងមហាផ្ទៃបានប្រកាសហាមឃាត់ពលករខ្មែរទាំងនេះមិនឱ្យវិលត្រឡប់ទៅកាន់ប្រទេសដែលខ្លួនធ្វើការវិញទេ ដើម្បីសុវត្ថិភាពពួកគេ។ ជាមួយនឹងការហាមឃាត់នេះ ក្រសួងមហាផ្ទៃក៏បានជំរុញឱ្យពួកគេធ្វើកិច្ចការផ្សេងៗនៅក្នុងស្រុក ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃក្នុងស្ថានភាពនៃការរីករាលដាលជំងឺកូវីដ-១៩នេះ។

លោកស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃកម្ពុជា បានប្រកាសឱ្យដឹងថា កម្ពុជាមិនអាចអនុញ្ញាតឱ្យពលករខ្មែរដែលវិលត្រឡប់មកពីបរទេសដូចយ៉ាងប្រទេសថៃ វិលទៅធ្វើការនៅក្នុងប្រទេសគោលដៅរបស់ខ្លួនវិញនោះទេនាពេលនេះ។ នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីពិនិត្យលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរយៈពេលខ្លី មធ្យម និងវែងរបស់ពលករចំណាកស្រុកក្នុងស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩នៅព្រឹកថ្ងៃពុធនេះ លោកស ខេង បានពន្យល់ដោយលើកឡើងពីប្រទេសថៃថា ពលករខ្មែរមិនអាចវិលទៅថៃវិញបានទេ ដោយសារតែថៃបានបិទព្រំដែន ហើយកំពុងដាក់ប្រទេសក្នុងភាពអាសន្ន ព្រោះតែស្ថានភាពជំងឺកូវីដ-១៩ នៅបន្តមានភាពធ្ងន់ធ្ងរនៅឡើយ។ ប៉ុន្តែ ក៏មានបញ្ហាប្រឈមដែរនៅពេលដែលពលករខ្មែរបន្តស្នាក់នៅក្នុងប្រទេស ពិសេស គឺនៅស្រុកកំណើតរបស់ខ្លួន។ បញ្ហានោះ បើតាមលោកស ខេង គឺពលករខ្លះអាចមានលទ្ធភាពផ្គត់ផ្គង់ការរស់នៅរបស់ខ្លួន និងក្រុមគ្រួសារបានយូរអង្វែង តែពលករខ្លះទៀតអាចផ្គត់ផ្គង់ក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ។ ចំពោះបញ្ហានេះ រដ្ឋាភិបាលកម្ពុជាបានរៀបចំបង្កើតនូវក្រុមការងារពីរក្រុមព្រមពេលគ្នា គឺក្រុមការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និង ក្រុមការងារសន្តិសុខស្បៀង។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៃក្រសួងមហាផ្ទៃ បានគូសបញ្ជាក់ឱ្យដឹងថា ក្រុមការងារទាំងពីរនេះនឹងធ្វើការជាមួយគ្នា ដើម្បីរៀបចំចេញជាគោលនយោបាយ ឬផែនការជាតិ ដើម្បីទប់ទល់បញ្ហាប្រឈមដែលកើតចេញពីជំងឺកូវីដ-១៩ក្នុងរយៈពេលយូរអង្វែងទៅពេលខាងមុខ។ ប៉ុន្តែ នៅចំពោះមុខនេះ លោកស្រីជូ ប៊ុនអេង បានអំពាវនាវឱ្យពលករខ្មែរទាំងអស់អត់ធ្មត់ឱ្យខ្លស់ ។ ជាមួយគ្នានេះ លោកស្រីបានជំរុញឱ្យពលករខ្មែរធ្វើការដាំដុះ ចិញ្ចឹមសត្វ ឬកែច្នៃមុខរបរផ្សេងៗ ដើម្បីកាត់បន្ថយការចំណាយ រកចំណូល និងមានស្បៀងគ្រប់គ្រាន់។

សូមបញ្ជាក់ថា គិតមកដល់ពេលនេះ ពលករខ្មែរប្រមាណជាង៨ម៉ឺន៥ពាន់នាក់បានចូលមកប្រទេសកម្ពុជាវិញ។ ពលករខ្មែរទាំងនេះ មិនទាន់រកឃើញមានអ្នកណាម្នាក់មានផ្ទុកជំងឺកូវីដ-១៩នោះទេ។ នេះបើតាមការបញ្ជាក់ របស់លោកស្រីជូ ប៊ុនអេង។ លោកស្រីជូ ប៊ុនអេង ក៏បានបន្ថែមឱ្យដឹងទៀតថា ចំពោះពលករខ្មែរនៅក្រៅប្រទេសវិញ ក៏មិនទាន់មានព័ត៌មានថា មានឆ្លងជំងឺកូវីដ-១៩នេះផងដែរ។ តែទោះយ៉ាងណាក៏ដោយ លោកស្រីថា រដ្ឋាភិបាលកម្ពុជាកំពុងតាមដានពីបញ្ហានេះ និង ត្រៀមខ្លួនក្នុងការជួយដោះស្រាយបញ្ហាប្រឈមរបស់ពួកគេ៕

## ក្រសួងមហាផ្ទៃ បញ្ជាក់ថា ពលករវិលមកស្រុកខ្មែរជាង៨ម៉ឺននាក់ នោះគ្មានឆ្លងជំងឺកូវីដ-១៩

https://dap-news.com/covid19/ BySKK106 Posted on April 22, 2020

ភ្នំពេញ ៖ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ) បានថ្លែងថា ពលករវិល មកស្រុកខ្មែរវិញ នាពេលកន្លងទៅនេះ មានជាង៨ម៉ឺននាក់ពួកគេគ្មានឆ្លងជំងឺ កូវីដ-១៩ ទេ ហើយក្រសួង ក៏បានហាមឃាត់ពួកគាត់ មិនឲ្យវិលត្រឡប់ទៅក្រៅប្រទេសវិញ ដើម្បីទប់ស្កាត់ ការរីករាលដាលជំងឺ កូវីដ-១៩។

ក្រោយបញ្ចប់ កិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីពិនិត្យលទ្ធភាពក្នុងការឆ្លើយតប ទៅនឹងតម្រូវ ការរយៈពេលខ្លី មធ្យម និងវែង របស់ពលករចំណាកស្រុក ក្នុងស្ថានភាពរីករាលដាល នៃជំងឺ កូវីដ-១៩ នាថ្ងៃទី២២ ខែមេសា ឆ្នាំ ២០២០ លោកស្រី ជូ ប៊ុនអេង បានពន្យល់ថា នៅពេលពលករខ្មែរ ចូលដល់ព្រំដែនភ្លាមៗ ភាគីពាក់ព័ន្ធ បានចុះពិនិត្យ និង សួរប្រវត្តិពួកគាត់ ព្រមទាំង បញ្ជូនពួកគាត់ ទៅធ្វើចត្តាឡីស័ក ផងដែរ។ លោកស្រី មានប្រសាសន៍ថា « បើសិនយើងរកឃើញថា មានពលករយើងណាម្នាក់ មានកម្ដៅ ខុសពីធម្មតា។គឺពួកគាត់ស្ថិតនៅការតាមដានបន្តអត់ទាន់បញ្ជូន គាត់ចេញមក ទេ។ចឹងនៅពេលនោះ មានជាបន្តបន្ទាប់ ដែលយើងស្នើសុំមន្ទីរពេទ្យបង្អែក ព្រំដែន ត្រូវពិនិត្យ បន្ថែម ដើម្បីយកសំណាក ក្នុងការពិនិត្យយើងរកអត់ទាន់ឃើញ យើងគិតថា ពួកគាត់មានក្ដៅ ដោយមូលហេតុផ្សេងៗ»។ លោកស្រី បន្តថា «នៅក្នុងការផ្សព្វផ្សាយរបស់ ក្រសួងសុខាភិបាលថា មានជាង៤០០នាក់ (ពលករ) ដែលបានសង្ស័យ ហើយយកសំណាកទៅពិនិត្យ ប៉ុន្តែមកដល់ពេលនេះ ការចេញ លទ្ធផលជាបន្តបន្ទាប់ ដូចជា មិនទាន់រកឃើញថា អ្នកដែលមានឆ្លងមេរោគ កូវីដ-១៩ នៅឡើយទេ»។

ឆ្លៀតឱកាសនោះដែរ លោកស្រី ជូ ប៊ុនអេង ក៏បានអំពាវនាវទៅដល់ប្រជាពលរដ្ឋទាំងអស់ ត្រូវមានការ ដាំដុះ បន្លែ ជាដើម ដើម្បីរកប្រាក់ចំណូល ក្នុងគ្រួសារបន្ថែមទៀត ជាពិសេស ត្រូវមានការអត់ធ្មត់ ចំពោះដំណាក់កាលដែលកម្ពុជាកំពុងកើតមានឡើងជំងឺកូវីដ-១៩។ លោកស្រី មានប្រសាសន៍ បន្តថា «សូមមេត្តាកុំអាលវិលត្រឡប់ទៅរកប្រទេសគោលដៅ វិញដោយសារប្រទេសគោលដៅហ្នឹង បច្ចុប្បន្ននេះ គឺមានអត្រាឆ្លងខ្ពស់ជាងយើងទៀត។ ប្រសិនបើពួកគាត់វិលត្រឡប់ទៅពេលនេះ គឺជួបនឹងហានីភ័យខ្ពស់ណាស់ ហើយខាង ប្រទេសគេវិញ ក៏រឹតបន្តឹងដែរ អំពីការបិទ ព្រំដែនដែរ»។ លោកស្រី រំលឹកថា រាជរដ្ឋាភិបាល កំពុងតាមដានយ៉ាងយកចិត្តទុកដាក់ ចំពោះ ពលករ ពលរដ្ឋ សិស្ស និស្សិត នៅក្រៅប្រទេស តើកំពុងប្រឈមបញ្ហាអ្វីខ្លះ? ។ លោកស្រីថា រហូតដល់ពេលនេ មិនទាន់មានសភាពធ្ងន់ធ្ងរ ចំពោះការឆ្លងកូវីដ-១៩ ទៅពលរដ្ឋខ្មែរ នៅក្រៅប្រទេសឡើយ។

សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ កម្ពុជាបានព្យាបាល អ្នកជាសះស្បើយពី ជំងឺ កូវីដ-១៩ ចំនួន១១០នាក់ ។ចំណែក អ្នកកំពុងសម្រាកព្យាបាលជំងឺកូវីដ ចំនួន១២នាក់ ហើយអ្នកឆ្លងសរុបទាំងអស់មានចំនួន១២២នាក់៕ ដោយ ៖ អេង ប៊ូឆេង

## មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ៖ រហូតមកដល់ពេលនេះ សំណាកពលករប្រមាណ ៤០០នាក់ ត្រូវបានយកទៅធ្វើតេស្ត តែមិនមានជំងឺកូវីដ១៩ឡើយ

http://www.freshnewsasia.com/ 2020-04-22

**(ភ្នំពេញ)៖** លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ) បានថ្លែងថា គិតមកដល់ពេលនេះ មានពលករខ្មែរធ្វើការងារនៅក្រៅប្រទេសជាង ៨ម៉ឺននាក់ បានធ្វើមាតុភូមិនិវត្តន៍ ហើយក្នុងចំណោមពលករទាំងនោះមាន ៤០០នាក់ត្រូវបានយកសំណាកទៅធ្វើតេស្ត ប៉ុន្តែមិនទាន់រកឃើញថា ឆ្លងជំងឺកូវីដ១៩ឡើយ។ ថ្លែងប្រាប់អ្នកសារព័ត៌មានក្រោយបញ្ចប់ កិច្ចប្រជុំពិគ្រោះ យោបល់ ដើម្បីពិនិត្យលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវ ការរយៈ ពេលខ្លី មធ្យម និងវែងរបស់ពលករចំណាកស្រុកក្នុងស្ថានភាពរីករាល ដាលនៃជំងឺកូវីដ-១៩ នាថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ លោកស្រី ជូ ប៊ុនអេង បានបន្ថែមថា នៅពេលដែលពលករខ្មែរចូលដល់ព្រំដែនភ្លាមៗ ភាគីពាក់ព័ន្ធទាំងអស់បានចុះពិនិត្យ និងសួរប្រវត្តិពួកគាត់ ព្រមទាំងបញ្ជូនទៅធ្វើចត្តាឡីស័កផងដែរ។ លោកស្រីបានបន្តថា នៅពេលមកដល់ព្រំដែន ពេលមានពលករណាម្នាក់មានកម្តៅខុសពីធម្មតា តម្រូវឲ្យពួកគាត់ស្ថិតនៅការតាមដានបន្ត ពោលមិនត្រូវអនុញ្ញាតឲ្យពួកគាត់ ធ្វើដំណើរបន្តទៅស្រុក ទៅភូមិទេ។ លោកស្រីថ្លែងថា មានជាបន្តបន្ទាប់ ដែលអាជ្ញាធរស្នើសុំមន្ទីរពេទ្យបង្អែកព្រំដែនត្រូវពិនិត្យពលករបន្ថែម ដើម្បីយក សំណាកក្នុងការពិនិត្យ។

លោកស្រីបានបញ្ជាក់យ៉ាងដូច្នេះថា៖ «**នៅក្នុងការ ផ្សព្វផ្សាយរបស់ក្រសួងសុខាភិបាល គឺមានជាង៤០០នាក់ ដែលបានសង្ស័យ ហើយយកសំណាកទៅពិនិត្យ។ ប៉ុន្តែមកដល់ពេលនេះ ការចេញលទ្ធផលជាបន្តបន្ទាប់ ដូចជាមិនទាន់រកឃើញថា អ្នកដែលមានឆ្លងមេរោគកូវីដ១៩ នៅឡើយទេ**»។ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ ក៏បានសំណូមពរដល់ពលករទាំងអស់ដែលទើបធ្វើមាតុភូមិនិវត្តន៍ សូមមេត្តាកុំអាលវិលត្រឡប់ ទៅរកប្រទេសគោលដៅវិញ ដោយសារប្រទេសគោលដៅទាំងនោះ មានអត្រាឆ្លងជំងឺកូវីដ១៩ ខ្ពស់ជាងកម្ពុជាយើងទៅទៀត។ អញ្ចឹងប្រសិនបើពួកគាត់ វិល ត្រឡប់ ទៅពេលនេះ អាចនឹងជួបហានិភ័យខ្ពស់ណាស់ ហើយខាងប្រទេសគេវិញក៏តែបន្តឹងការចល័ត និងការបិទព្រំដែនដែរ។ លោកស្រី ជូ ប៊ុនអេង ថែមទាំងបានអំពាវនាវ និងលើក ទឹកចិត្តទៅដល់ប្រជាពលរដ្ឋទាំងអស់ ត្រូវមានការដាំដុះបន្លែបន្ថែមនៅតាមទីលំនៅរៀងៗខ្លួនជាដើម ដើម្បីរកប្រាក់ចំណូលក្នុង គ្រួសារបន្ថែម ទៀត ជាពិសេសត្រូវមានការអត់ធ្មត់ចំពោះដំណាក់កាលដែល កម្ពុជាកំពុង ជួបប្រទះបញ្ហាការរីករាលដាលនៃជំងឺកូវីដ១៩នេះ៕

## ច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ពលករខ្មែរវិលមកវិញដោយសារថៃបញ្ជូន

http://www.rasmeinews.com/ April 22, 2020, 5:01 PM

ដោយ៖ប.ជ័យ+អូរស្មាច់៖ ពលករខ្មែរធ្វើការស៊ីឈ្នួលក្នុងប្រទេសថៃនៅតែបន្តវិលមកស្រុកបន្តទៀតតាមច្រកទ្វារព្រំដែនអន្តរជាតិឆងចមខេត្តសុរិន្ទ-អូរស្មាច់ ខេត្តឧត្តរមានជ័យគិតត្រឹមថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០។ ក្រុមគ្រូពេទ្យនឹងមន្ត្រីចត្តាឡីសក្ក័ប្រចាំនៅច្រកនោះក៏បានបន្តជំនាញស្ពែននិងឆ្លុះកម្តៅពួកគេដើម្បីបង្ការការពារសុខភាពពិសេសសជំងឺកូវីត-១៩។ ក្នុងនោះក៏សម្រាប់អ្នកសង្ស័យត្រូវដាក់ឱ្យនៅដាច់ដោយឡែកចំនួន១៤ថ្ងៃ។ លោកវេជ្ជបណ្ឌិតឈ្លោកហួតប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យបានដឹកនាំមន្ត្រីជំនាញធ្វើការងាររបស់ខ្លួនស្របតាមសភពការណ៍តម្រូវនិងតាមការណែនាំរបស់ថ្នាក់លើ ។

សូមបញ្ជាក់នៅច្រកព្រំដែនអន្តរជាតិផងចម-អូរស្មាច់នៅមានពលករខ្មែរដែលអាជ្ញាធរថៃអនុញ្ញាតឱ្យវិលមកប្រទេសកម្ពុជាវិញរាប់សិបនាក់ ក្នុង១ថ្ងៃៗ។ ពួកគេបង្ខំចិត្តចាកចេញពីប្រទេសថៃ ដោយសារកន្លែងធ្វើការងារបានផ្អាកឬបិទ។អាជ្ញាធរថៃក៏បន្តបិទប្រទេសដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីត-១៩៕S/

## ក្រុមការងារខេត្តសៀមរាប បន្តដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ

https://www.facebook.com/tvkchannel7 ទូរទស្សន៍ជាតិកម្ពុជា ទទក - TVK 22-04-2020

នៅថ្ងៃពុធ ទី២២ ខែមេសា ឆ្នាំ២០២០នេះ នៅតែទៅបន្តរង់ចាំទទួលប្រជាពលរដ្ឋខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃដដែល។ ថ្ងៃនេះទទួលបានចំនួនសរុប ៣៦នាក់ ស្រីចំនួន ១៧នាក់ ដែលចូលមកតាមច្រកដូង ខេត្តបាត់ដំបង, តាមច្រកប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យ ។

គិតចាប់ពីថ្ងៃទី១០ ខែមីនា មកដល់ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០នេះ តួលេខសរុបដែលបានទទួលប្រជាពលរដ្ឋខ្មែរ ចូលតាមច្រកទាំងបីខាងលើមានចំនួន ១២,១២៨នាក់ ស្រីចំនួន ៥,២៥២នាក់ ក្នុងនោះបានពិនិត្យសុខភាពបឋមបានចំនួន១២,១២៨នាក់ ស្រី ៥,២៥២នាក់គឺពិនិត្យសុខភាពបានទាំងអស់ ៕ ដោយ លីវ សុខុន

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២០នាក់

https://www.facebook.com/GDIOfficial General Department of Immigration - GDI *22-04-2020*

នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២០នាក់ ស្រី ០៩នាក់៕

## មន្ទីរសុខាភិបាលឧត្តរមានជ័យបានចុះពិនិត្យស្រាវជ្រាវជំងឺកូវីដ១៩លើពលករមកពីថៃតាមច្រកព្រំដែនទអូរស្មាច់បានចំនួន ៥១

https://www.facebook.com/tvkchannel7 ទូរទស្សន៍ជាតិកម្ពុជា ទទក - TVK 22-04-2020

នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ មន្ទីរសុខាភិបាលឧត្តរមានជ័យបានចុះពិនិត្យស្រាវជ្រាវជំងឺកូវីដ ១៩លើពលករមកពីថៃតាមច្រកព្រំដែនទអូរស្មាច់បានចំនួន ៥១ នាក់ ស្រី ២១នាក់ ។ មានពលកររស់ក្នុងខេត្តឧត្តរមានជ័យ ចំនួន០៤នាក់ ស្រី ០២នាក់។ ក្នុងនោះមានអ្នកក្ដៅខ្លួន ចំនួន០១នាក់។ពលករដែលវិលត្រឡប់មកពីប្រទេសថៃតាមច្រកអូរស្មាច់ខេត្តឧត្តរមានជ័យ មាន៖ ខេត្តចំនួន០៨គឺ៖

១.ខេត្តកំពង់ឆ្នាំងមានចំនួន០២នាក់ ស្រីចំនួន០១នាក់

២.ខេត្តស្វាយរៀងមានចំនួន០២នាក់ ស្រីចំនួន០១នាក់

៣.ខេត្តកំពង់ចាមមានចំនួន០៣នាក់ ស្រី០១នាក់

៤.ខេត្តកំពង់ធំមានចំនួន០៤នាក់ ស្រី០១នាក់

៥.ខេត្តបន្ទាយមានជ័យចំនួន០៤នាក់ ស្រី២នាក់
៦.ខេត្តព្រៃវែងមានចំនួន០៤នាក់ ស្រី០៣នាក់
៧.ខេត្តបាត់ដំបងមានចំនួន០៦នាក់ ស្រី០២នាក់
៨.ខេត្តសៀមរាបមានចំនួន២២នាក់ ស្រី០៨នាក់
ប្រភព មន្ទីរព័ត៌មានខេត្តឧត្តរមានជ័យ

## ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០

## រដ្ឋមន្ត្រីមហាផ្ទៃ៖ ពលករខ្មែរជាង៨ម៉ឺននាក់មិនមានសញ្ញាវីរុសកូរ៉ូណា តែរដ្ឋាភិបាលបារម្ភអំពីជីវភាពរបស់ពួកគេ

https://khmer.voanews.com/ 23 មេសា 2020 ស៊ុន ណារិន

ភ្នំពេញ៖ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង បានថ្លែងថា ពលករខ្មែរប្រមាណ ៨៦.០០០នាក់ ដែលវិលត្រឡប់មកពីប្រទេសថៃ មិនមានពេគសញ្ញានៃវីរុសកូរ៉ូណានោះទេ ប៉ុន្តែរដ្ឋាភិបាលបារម្ភអំពីជីវភាពរបស់ពួកគេដោយសារមិនមានការងារធ្វើ។ លោក ស ខេង បានថ្លែងបែបនេះ នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីពិនិត្យលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរយៈពេលខ្លីមធ្យម និងវែងរបស់ពលករចំណាកស្រុក ក្នុងស្ថានភាពរីករាលដាលនៃជំងឺកូវីដ១៩ កាលពីថ្ងៃពុធ។ លោក ស ខេង បានថ្លែងថា តាមរបាយការណ៍ដែលលោកប្រមូលបាន ពលករខ្មែរប្រមាណ ៨៦.០០០នាក់ បានវិលត្រឡប់មកពីប្រទេសថៃ ហើយក្នុងមួយថ្ងៃៗ ពួកគេប្រមាណ ១៥០ទៅ ២០០នាក់បន្តវិលត្រឡប់មកកម្ពុជា។ លោកបន្តថា ពលករជាង ៨ម៉ឺននាក់ នោះមិនមានពេគសញ្ញាសង្ស័យនៃជំងឺកូវីដ១៩នោះទេ ក្រោយពួកគេដាក់ខ្លួនឲ្យនៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃ។ លោក ស ខេង មានប្រសាសន៍ថា៖ «តាមលទ្ធភាពរបស់យើង យើងឃើញថា អ្នកហ្នឹងដាក់នៅ ១៤ថ្ងៃជំងឺហ្នឹង វាអត់ចេញ បើវាអត់ចេញ វាអត់ឲ្យពេគសញ្ញាហ្នឹងទេ ប្រែមកថា អ្នកហ្នឹងអត់មានជំងឺហ្នឹងទេ»។ បើតាមលោក ស ខេង នៅសល់ពលករខ្មែរប្រមាណ ៦០០នាក់ ទៀតដែលកំពុងដាក់ខ្លួនឲ្យនៅដាច់ដោយឡែក។ កន្លងទៅលោក ស ខេង មានប្រសាសន៍ថា រដ្ឋាភិបាលមិនមានលទ្ធភាពធ្វើតេស្តរកវីរុសកូរ៉ូណាលើពលករទាំងអស់នោះទេ។ អ្វីដែលរដ្ឋាភិបាលធ្វើបាន គឺការពិនិត្យសុខភាពទូទៅរបស់ពួកគេ ដូចជាកំដៅ និងពេគសញ្ញាមួយចំនួន តែមិនមែនយកសំណាកទៅធ្វើតេស្តរកជំងឺកូវីដនោះទេ។

កាលពីថ្ងៃច័ន្ទ អ្នកនាំពាក្យក្រសួងសុខាភិបាលលោក លី សូវ៉ាន់ មានប្រសាសន៍ថា ពលករដែលត្រឡប់ពីប្រទេសថៃប្រមាណ ៤១០នាក់ តែប៉ុណ្ណោះត្រូវបានធ្វើតេស្តរកវីរុសកូរ៉ូណា ហើយពួកគេមិនមានវីរុសនោះទេ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង កាលពីថ្ងៃពុធ ក៏បានបង្ហាញការព្រួយបារម្ភអំពីការលំបាករបស់ពលករទាំងនោះ ដោយសារពួកគេមិនមានការងារធ្វើ ដែលនឹងប៉ះពាល់ជីវភាពប្រចាំថ្ងៃ។ លោកមានប្រសាសន៍ថា៖ «ពលករដែលវិលត្រឡប់ទាំងនោះមួយចំនួន មិនមានលទ្ធភាពក្នុងការផ្គត់ផ្គង់ជីវភាពរយៈពេលវែងនោះទេ។ ប៉ុន្តែមួយចំនួនក៏គេមានលទ្ធភាព។ ជាទូទៅ ពួកគាត់តែងតែរំពឹងចង់ទៅវិញ ដើម្បីធ្វើការងារនិងបានប្រាក់ចំណូលសម្រាប់បន្ទុកគ្រួសារ។ តែក្នុងស្ថានភាពបច្ចុប្បន្ន យើងមិនអាចអនុញ្ញាតឲ្យពួកគាត់ចេញចូលឆ្លងកាត់ព្រំដែនបានឡើយ»។ ប៉ុន្តែ លោករដ្ឋមន្ត្រីមានប្រសាសន៍ថា ពួកគេប្រហែលជាមិនអាចវិលត្រឡប់ទៅប្រទេសថៃវិញបានលឿននោះទេ ដោយសារប្រទេសថៃបានបិទព្រំដែន។ លោកមានប្រសាសន៍ថា៖ «យើងអាចវាយតម្លៃដែរថា ក្រុមនេះក៏នឹងមិនងាយបានវិលត្រឡប់ទៅវិញឆាប់ៗទេ។ ហើយយើងមិនដឹងថាពេលណាដែលអាចទៅវិញបាន។ អ៊ីចឹងទេគឺថាក្នុងករណីដែលពួកគាត់ទៅមិនបានវិញ តើជីវភាពរបស់ពួកគាត់យ៉ាងម៉េច?» ប្រជាពលរដ្ឋខ្មែរប្រមាណមួយ

លាន ២០ម៉ឺននាក់ កំពុងរស់នៅនិងធ្វើការនៅប្រទេសថៃ ហើយរដ្ឋាភិបាលកម្ពុជាប៉ាន់ប្រមាណថា ពួកគេច្រើនគួរសមគឺជាពលករមិនស្របច្បាប់។

យោងតាមរបាយការណ៍របស់អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ឆ្នាំ២០១៩ មួយភាគបីនៃពលករចំណាកស្រុកដែលត្រូវបានគេសាកសួរព័ត៌មាន ពុំមានការងារធ្វើក្នុងស្រុក មុនពេលពួកគេចេញពីកម្ពុជា ហើយជិតពាក់កណ្ដាលគឺគ្មានចំណូល និងប្រហែលពីរភាគបី បានសម្រេចចិត្តទៅប្រទេសថៃ ស្វែងរកការងារដោយសារពុំមានឱកាសការងារនៅក្នុងស្រុក និងដោយសារចង់បានចំណូលប្រសើរជាងមុន។ របាយការណ៍បង្ហាញថា ចំនួនពាក់កណ្ដាលនៃអ្នកដែលត្រូវបានសម្ភាសបានផ្ញើប្រាក់ត្រឡប់ទៅស្រុកកំណើតប្រមាណ ១២២៨ដុល្លារក្នុងមួយឆ្នាំ ហើយថាប្រាក់ទាំងនេះ គឺជាប្រាក់ចំណូលចម្បងសម្រាប់ទំនុកបម្រុងគ្រួសារនៅប្រទេសកម្ពុជាឬក៏ដើម្បីប្រើប្រាស់ធ្វើឲ្យជីវភាពប្រសើរឡើង។

លោក ឃុន ថារ៉ូ មន្ត្រីសម្របសម្រួលការងារនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្សហៅកាត់ថា សង់ត្រាល់ (Central) មានប្រសាសន៍ថា ពលករទាំងនោះមិនអាចវិលត្រឡប់ទៅប្រទេសថៃនៅពេលនេះនោះទេ ហើយក៏មិនមានការងារធ្វើសម្រាប់ពួកគេនៅប្រទេសថៃដែរ។ លោកបន្តថា ផ្នែកកសិកម្មនៅកម្ពុជាក៏ពួកគេមិនអាចធ្វើបានដែរ ដោយសារពួកគេមិនមានដីអ្វីធំដុំដើម្បីធ្វើស្រែចម្ការ។ លោកមានប្រសាសន៍ថា៖ «ខ្ញុំគិតថា គ្មានការងារក្នុងស្រុកណានៅមានសម្រាប់ពួកគាត់ដែរ។ ប្រសិនបើយើងមើលវិស័យសំណង់ ទេសចរណ៍ សេវាកម្ម ភោជនីយដ្ឋានគឺមិនមានការងារអី សមស្របសម្រាប់ពួកគាត់ដែរ»។ លោក ថារ៉ូ ជំរុញឲ្យរដ្ឋាភិបាលបញ្ចេញសាច់ប្រាក់បម្រុងដើម្បីជួយដល់ប្រជាពលរដ្ឋងាយរងគ្រោះ ក្នុងនោះមានការផ្ដល់ជាអាហារគ្រឿងបរិភោគ ដែលជាតម្រូវការចាំបាច់សម្រាប់ពួកគេ។ មន្ត្រីដែលធ្វើការលើផ្នែកសិទ្ធិការងាររូបនេះបន្ថែមថា៖ «គ្មានអីក្រៅពីរដ្ឋទេ ដែលអាចជួយគាំពារគាត់ព្រោះកូវីដនេះជាជំងឺសាកល ហើយអាហ្នឹងគឺជាកាតព្វកិច្ចរបស់រដ្ឋ ហើយសម្រាប់គាំពារទៅដល់ប្រជាពលរដ្ឋជាពិសេសពលករដែលទើបត្រឡប់មកពីប្រទេសថៃហ្នឹង»។

ពលករម្នាក់ដែលមកពីប្រទេសថៃអ្នកនាង អាន់ ស្រីលីស អាយុ២៦ឆ្នាំ បានថ្លែងប្រាប់ VOAថា អ្នកនាងទៅធ្វើការនៅប្រទេសថៃជាង ៥ឆ្នាំមកហើយ ហើយបានត្រឡប់មកស្រុកកំណើតវិញក្នុងខេត្តតាកែវ ជាមួយស្វាមី កូនស្រីម្នាក់និងក្មួយប្រុសម្នាក់ កាលពីថ្ងៃទី ២២ ខែមីនា។ អ្នកនាងបន្តថា អ្នកនាងត្រូវបានអាជ្ញាធរណែនាំឲ្យរក្សាអនាម័យ និងដាក់ខ្លួនឲ្យនៅដាច់ដោយឡែក។ អ្នកនាងដែលរស់នៅក្នុងឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ មានប្រសាសន៍ថា អ្នកនាងមិនមានរោគសញ្ញានៃវីរុសកូរ៉ូណានោះទេ។ អ្នកនាងមានប្រសាសន៍ថា៖ «ព្រោះអីអត់មានអីពិបាកក្នុងខ្លួនផងព្រោះអីឡើងចូលមួយខែហើយ ព្រោះអីមានពេទ្យមកពិនិត្យដល់ផ្ទះ។ បើខ្ញុំ ពិនិត្យបីដងហើយ»។ អ្នកនាងកំពុងព្រួយបារម្ភអំពីជីវភាពដែលអ្នកនាងថា បច្ចុប្បន្ននៅសល់ថវិកាប្រមាណ ៥ម៉ឺនរៀលដែលសល់ពីប្រទេសថៃ ហើយជីវភាពពឹងផ្អែកលើម្ដាយដែលបេះផ្លែព្រីងលក់ជាប្រចាំថ្ងៃ។ ជាងនេះទៅទៀត អ្នកនាងក៏កំពុងព្រួយបារម្ភអំពីការសងបំណុលគេដែលត្រូវបង់មួយខែប្រមាណ ១២០ដុល្លារហើយត្រូវបង់ ៦ខែទៀត។ អ្នកនាងបញ្ជាក់ថា អ្នកស្រីចង់ធ្វើការជាកម្មកររោងចក្រមួយរយៈ ខណៈរង់ចាំការបើកច្រកទ្វារព្រំដែនឡើងវិញ។ អ្នកនាងបញ្ជាក់ថា៖ «ចង់ថាចូលរោងចក្រសិន។ បើអត់រកការងារធ្វើ អត់អីចាយ អត់មានលុយចាយ»។

ក្នុងកិច្ចប្រជុំកាលពីថ្ងៃពុធ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង បានបញ្ជាក់ថា ដោយសារផលប៉ះពាល់នៃវីរុសកូរ៉ូណា អត្រាភាពក្រីក្រនៅកម្ពុជាអាចកើនឡើង ក្រោយជំងឺដែលកំពុងរាតត្បាតជាសាកលនេះបាត់ទៅវិញ។ លោកមានប្រសាសន៍ថា៖ «ប៉ុន្តែក្នុងស្ថានភាពដែលកូវីដវាវាលដាលនេះប្រហែលជាអាចវាមានផលប៉ះពាល់បានន័យថា វាធ្វើឲ្យចំនួនអ្នកក្រហ្នឹង[កើនឡើង]ដែលចុងក្រោយយើងថា នៅសល់ប៉ុន្មាន ៩ភាគរយ។ ប៉ុន្តែដល់តែកូវីដទៅ តើវាឡើង ១០ភាគរយ ឬវានៅ ៩ភាគរយ?»លោករដ្ឋមន្ត្រីមានប្រសាសន៍ថា រដ្ឋាភិបាលកម្ពុជាមិនមានថវិកាចែកដល់ប្រជាពលរដ្ឋនោះទេ៕

## អាជ្ញាធរស្រុកក្រឡាញ់ បានបញ្ចប់ការធ្វើចត្តាឡីស័ក១៤ថ្ងៃដល់ប្រជាពលករចំណាកស្រុក ចំនួន៨២នាក់ ឲ្យទៅរស់នៅតាមគេហដ្ឋានរៀងៗខ្លួនៗវិញ

https://www.facebook.com/tvkchannel7 ទូរទស្សន៍ជាតិកម្ពុជា ទទក - TVK 23-04-2020

បន្ទាប់ពីដាក់ឲ្យដាច់ដោយឡែករយៈពេល ១៤ថ្ងៃ បងប្អូនប្រជាពលរដ្ឋ ដែលវិលត្រឡប់ពីប្រទេសជិតខាង ដើម្បីពិនិត្យសុខភាពលើបញ្ហាឆ្លងជំងឺផ្លូវដង្ហើមថ្មី (កូវីដ- ១៩ ) អាជ្ញាធរស្រុក បានរៀបចំអនុញ្ញាតឲ្យពួកគាត់ទៅកាន់លំនៅដ្ឋានវិញចំនួន៨២នាក់ បន្ទាប់ពីមិនបានរកឃើញមានវិជ្ជមានមេរោគ នាពីព្រឹកថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០នេះ ។

របាយការណ៍របស់រដ្ឋបាលស្រុកក្រឡាញ់ បង្ហាញថា ប្រជាពលរដ្ឋធ្វើចំណាកស្រុកសរុបចំនួន ១២,០៧៩ នាក់ ស្រី ៥,២៩២នាក់ ដោយស្ថានភាពជំងឺឆ្លងវីរុសកូរ៉ូណា (កូវីដ-១៩ ) កាន់តែរីករាលដាលខ្លាំងឡើងនៅប្រទេសជិតខាងបាន មានការបិទរោងចក្រ សហគ្រាស និងច្រកចេញចូលរវាងប្រទេសនិងប្រទេស បានធ្វើឲ្យប្រជាពលរដ្ឋក្នុងស្រុករបស់យើងត្រឡប់មកវិញយ៉ាងគំហុក ចាប់ពីថ្ងៃទី១៦ ខែមីនា ដល់ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ មានចំនួន ២,៩២១នាក់ ស្រី ១,៣៣៧ នាក់។ ចំនួនខាងលើនេះនៅសល់ពលករចំណាកស្រុកជាង ៨៣ន់នាក់ទៀត ដែលមិនទាន់បានវិលត្រឡប់មកវិញនៅឡើយ ។

លោកស្រី ម៉មនី រង្សី អភិបាលស្រុក និងជាប្រធានអនុគណៈកម្មការប្រយុទ្ធប្រឆាំងនឹងជម្ងឺកូវីដ១៩ ស្រុកក្រឡាញ់ បានជួបសំណេះសំណាល ថ្លែងអំណរគុណដល់បងប្អូនប្រជាពលរដ្ឋ ដែលមានការអត់ធ្មត់ តស៊ូ ក្នុងការអនុវត្តទៅតាមការណែនាំរបស់រាជរដ្ឋាភិបាល និង ការណែនាំរបស់ក្រសួងសុខាភិបាល ដែលការដាក់ឲ្យបងប្អូនដាច់នៅដោយឡែករយៈពេល១៤ថ្ងៃនេះដោយជោគជ័យ ។ លោកស្រី ក៏បានអំពាវនាវដល់ពួកគាត់ឲ្យបន្តថែទាំសុខភាពដោយធ្វើអនាម័យសំអាតនឹងសាប៊ូ អាល់កុល និងជៀងវាងការជួបជុំចំនួនមនុស្សច្រើឲ្យបានជាដាច់ខាតក្នុងការបង្ការ ទប់ស្កាត់ជំងឺនេះ ប៉ុន្តែបងប្អូនត្រូវចាប់ផ្តើមរៀបចំមធ្យោបាយបង្កបង្កើនផលពីព្រោះរដូវវស្សាជិតចូលមកដល់ហើយ ៕ អត្ថបទ និងរូបភាព: លោក យូ វង្ស កែសម្រួលដោយ លីវ សុខុន

## ពលករខ្មែរចំនួន៥២នាក់ បានត្រឡប់មកកម្ពុជា ត្រូវបានដឹកទៅស្រុកកំណើត ដើម្បីធ្វើចត្តាឡីស័ក មុនជួបគ្រួសារ

https://news.sabay.com.kh/ 23-04-2020 14:36

នៅមុននេះបន្តិច ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានសរសេរនៅលើហ្វេសប៊ុកផ្ទាល់ខ្លួនថា «នៅថ្ងៃទី២៣ ខែមេសានេះ មានពលករខ្មែរត្រឡប់មកកម្ពុជាវិញ តាមច្រកស្រុកកំរៀង ខេត្តបាត់ដំបង ចំនួន៥២នាក់ មានចំនួន១០ខេត្ត ក្នុងនោះខេត្តបាត់ដំបង មានចំនួន៩ នាក់។ ឯកឧត្តម បានឲ្យដឹងទៀតថា បងប្អូនទាំងអស់ត្រូវបានដឹកទៅកាន់ស្រុកកំណើត តាមរថយន្តកងយោធពលខេមរភូមិន្ទ និងស្នាក់នៅដោយឡែក ១៤ថ្ងៃ មុនជួបជុំគ្រួសារតាមការរៀបចំចត្តាឡីស័ក របស់រដ្ឋបាលស្រុក ក្រុង៕

## កូវីដ១៩៖ ថៃ ឲ្យពលរដ្ឋខ្មែរ បន្តស្នាក់នៅរហូតដល់ថ្ងៃ៣១ កក្កដា ដោយពុំផាកពិន័យ តែមិនអនុញ្ញាតឲ្យធ្វើការងារ

https://dap-news.com/national/ ByKD102 Posted on April 23, 2020

ភ្នំពេញ៖ ដើម្បីសម្រួលដល់ បងប្អូនប្រជាពលរដ្ឋខ្មែរ ដែលជាប់នៅក្នុងប្រទេសថៃ ដោយសារការរឹតត្បិត នៃការធ្វើដំណើរទាំងផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ក្នុងការទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ១៩ រដ្ឋាភិបាលថៃ បានសម្រេចផ្តល់ការអនុគ្រោះ ៣ចំណុចសំខាន់ៗ ដល់បងប្អូនប្រជាពលរដ្ឋខ្មែរ។ យោងតាមសេចក្តីជូនដំណឹង

របស់ ស្ថានទូតកម្ពុជា នៅថ្ងៃទី២៣ មេសានេះ បានឲ្យដឹងថា ៣ចំណុចសំខាន់ៗ ដែលរដ្ឋាភិបាលថៃ សម្រេចផ្តល់ការអនុគ្រោះនោះ រួមមានដូចខាងក្រោម៖

១.បងប្អូនប្រជាពលរដ្ឋខ្មែរ រួមទាំងពលករ ដែលអស់សុពលភាព ស្នាក់នៅចាប់ពីថ្ងៃទី២៦ មីនា ត្រូវបានអនុញ្ញាតឲ្យបន្តស្នាក់នៅ ដោយស្វ័យប្រវត្តិរហូតដល់ ថ្ងៃទី៣១ កក្កដា ដោយពុំមានការផាកពិន័យ លើការស្នាក់នៅលើសកំណត់ (Over Stay) ប៉ុន្តែមិនអនុញ្ញាតឲ្យធ្វើការនោះទេ ។

២.បងប្អូនពលករខ្មែរ ដែលនិយោជកបានបញ្ជូនបញ្ជីឈ្មោះ ទៅក្រសួង ឬមន្ទីរការងារក្រុង/ខេត្តថៃ តាមរយៈប្រព័ន្ធអនឡាញរួចរាល់ ត្រឹមថ្ងៃទី៣១ មីនា អាចបន្តធ្វើការជាបណ្តោះអាសន្ន រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០២០ ។

៣.បងប្អូនប្រជាពលរដ្ឋខ្មែរ រួមទាំងពលករ ដែលត្រូវទៅបង្ហាញខ្លួន ក្នុងរយៈពេល ៩០ថ្ងៃ ក្នុងចន្លោះថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០២០ ដល់៣១ ខែកក្កដា ឆ្នាំ២០២០ មិនតម្រូវឲ្យទៅបង្ហាញខ្លួននោះទេ រហូតដល់មានការជូនដំណឹងជាថ្មី ឡើងវិញ ។

ទន្ទឹមគ្នានោះដែរ ស្ថានទូតក៏បានអំពាវនាវ ដល់ប្រជាពលរដ្ឋខ្មែរ ទាំងអស់នៅក្នុងប្រទេសថៃ មេត្តាបន្តចូលរួមសហការអនុវត្តវិធានការនានា និងបម្រាមគោចរដែលដាក់ចេញ ដោយរដ្ឋាភិបាលថៃ ឲ្យមានប្រសិទ្ធភាព និងសូមរក្សាសុខភាពអនាម័យ ដើម្បីបង្ការ និងទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ១៩ ៕

## កម្ពុជាអាចបាត់ចំណូលពីការផ្ញើប្រាក់របស់ពលករប្រមាណ ៤០០ លានដុល្លារឆ្នាំនេះ

https://www.rfa.org/khmer/ ដោយ មាន ឫទ្ធិ 2020-04-23

កម្ពុជាអាចបាត់បង់ចំណូលបានមកពីការផ្ញើប្រាក់របស់ពលករចំណាកស្រុកនៅក្រៅប្រទេស ប្រមាណជិត ៤០០ លានដុល្លារ ក្នុងឆ្នាំ២០២០នេះ។ នេះបើផ្អែកតាមការគណនាត្រួសៗ ទៅលើការព្យាករណ៍របស់ ធនាគារពិភពលោក World Bank ដែលថា ទំហំនៃការផ្ញើប្រាក់របស់ពលករចំណាកស្រុកនៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ក្នុងឆ្នាំ២០២០នេះ នឹងធ្លាក់ចុះប្រមាណ ១៣% ធៀបនឹងឆ្នាំ២០១៩កន្លងទៅ។

កាលពីឆ្នាំ២០១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្លាប់អះអាងថា ពលករចំណាកស្រុកខ្មែរ នៅក្រៅប្រទេស ជាង១លាន២សែននាក់ បានផ្ញើប្រាក់មកក្នុងស្រុកវិញ សរុបប្រមាណ ២,៨ ប៊ីលានដុល្លារ។ នេះគេនៅមិនទាន់គិតពីករណីផ្ញើប្រាក់ក្រៅផ្លូវការ ឆ្លងព្រំដែន ឬតាមរយៈមធ្យោបាយផ្សេងៗទៀតនៅឡើយ។ ពលករចំណាកស្រុកខ្មែរ ដែលផ្ញើប្រាក់ច្រើនជាងគេ គឺមកពីប្រទេសថៃ និងប្រទេសកូរ៉េខាងត្បូង។

សេចក្តីថ្លែងការណ៍របស់ធនាគារពិភពលោក ផ្សាយនៅថ្ងៃទី២៣ មេសា ព្យាករណ៍ថា វិបត្តិកូវីដ១៩ និងការបិទសកម្មភាពសេដ្ឋកិច្ចស្ទើរតែគ្រប់ផ្នែកទាំងអស់ នឹងធ្វើឱ្យទំហំនៃការផ្ញើប្រាក់របស់ពលករចំណាកស្រុកនៅទូទាំងសាកលលោក ទៅកាន់ប្រទេសកំណើតរបស់ពួកគេរៀងៗខ្លួនវិញ ធ្លាក់ចុះខ្លាំង ក្នុងឆ្នាំ២០២០នេះ។ នៅទូទាំងសាកលលោក ការធ្លាក់ចុះនេះ ស្មើនឹងប្រមាណ ២០% បើធៀបនឹងឆ្នាំ២០១៩ ដែលមានទំហំទឹកប្រាក់ជាង ៥៥០ ប៊ីលានដុល្លារអាមេរិក។

ធនាគារពិភពលោកថា ការសិក្សានានាបានបង្ហាញថា ការផ្ញើប្រាក់ចេញរបស់ពលករចំណាកស្រុក បានជួយសម្រាលភាពក្រីក្រនៅតាមប្រទេសមានចំណូលទាប និងមធ្យម។ ការផ្ញើប្រាក់របស់ពលករចំណាកស្រុកនេះ ក៏បានចូលរួមចំណែក ធ្វើឱ្យអាហារូបត្ថម្ភមានភាពប្រសើរឡើង បង្កើនការចំណាយទៅលើវិស័យអប់រំ និងជួយកាត់បន្ថយពលកម្មកុមារនៅតាមគ្រួសារក្រីក្រ។ ផ្ទុយទៅវិញ ធនាគារពិភពលោកពន្យល់ថា ការធ្លាក់ចុះការផ្ញើប្រាក់នេះ នឹងជះផលមិនល្អទៅលើលទ្ធភាពចាយវាយរបស់ក្រុមគ្រួសារនានា ដោយសារតែគ្រួសារនីមួយៗ ត្រូវបង្វែរលុយ ទៅដោះស្រាយបញ្ហាខ្វះខាតស្បៀងអាហារ និងសេចក្តីត្រូវការបន្ទាន់ក្នុងជីវភាពរស់នៅជាមុនសិន។

នៅកម្ពុជា មួយភាគធំនៃចំណូលបានមកពីការផ្ញើប្រាក់របស់ពលករចំណាកស្រុកទាំងនេះ ត្រូវក្រុមគ្រួសារយកទៅចាយវាយ សងបំណុលមីក្រូហិរញ្ញវត្ថុ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃចំនួន ០១នាក់

https://www.facebook.com/GDIOfficial General Department of Immigration - GDI *23-04-2020*

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៦និង០០នាទី ថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃចំនួន ០១នាក់។ នគរបាលអន្តោប្រវេសន៍ប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរនេះមាន ឈ្មោះ មាស រដ្ឋា ភេទប្រុស អាយុ ៣៣ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ស្ថិតក្នុងភូមិចាំយាម ឃុំបាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង បន្ទាប់មកមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពផងដែល និងបានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

# ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០

## សម្តេចតេជោ អនុញ្ញាតអោយពលរដ្ឋខ្មែរ ដែលជាពលករនេសាទ និងជាអ្នកទោស នៅម៉ាឡេស៊ី ត្រឡប់មកខ្មែរវិញ តែតម្រូវអោយធ្វើតេស្តរកជំងឺកូវីដ១៩ នៅម៉ាឡេស៊ី សិន

https://khmernote.com.kh/ កូវីដ-១៩ April 27, 2020 Khmernote

យោងតាមប្រសាសន៍របស់ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាលកម្ពុជា បានមានប្រសាសន៍នៅក្នុងសន្និសិទសារព័ត៌មាននៅព្រឹកថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ នេះបានអោយដឹងថា ក្រុមការងារអន្តរក្រសួងបានប្រជុំគ្នា និងលើកស្នើទៅកាន់សម្តេចតេជោ នាយករដ្ឋមន្ត្រី ចំពោះពលរដ្ឋខ្មែរដែលជាពលករនេសាទនិងអ្នកទោសនៅម៉ាឡេស៊ី ត្រូវបានរួចទោសអោយត្រឡប់ចូលមកកម្ពុជាវិញ។

ក្នុងសំណើរបស់ក្រុមការងារអន្តរក្រសួងផងដែរ លោករដ្ឋមន្ត្រីក្រសួងសុខាភិបាលបានអោយដឹងដែរថា សម្តេចតេជោ ហ៊ុន សែន ប្រមុខរដ្ឋាភិបាលបានអនុញ្ញាតអោយពលករនេសាទ និងអ្នករួចទោសទាំងនោះអោយត្រឡប់ចូលមកកម្ពុជាវិញ ដោយមានលក្ខខណ្ឌមួយគឺតម្រូវអោយមានការធ្វើតេស្តរកមេរោគ កូវីដ-១៩ នៅប្រទេសម៉ាឡេស៊ីជាមុនសិន ហើយប្រសិនបើមានវិជ្ជមានគឺត្រូវព្យាបាលអោយជាសះស្បើយជាមុនសិន ទើបអនុញ្ញាតអោយត្រឡប់មកកម្ពុជាវិញ ហើយពេលដែលមកដល់កម្ពុជាក៏តម្រូវអោយធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃជាមួយក្រុមគ្រូពេទ្យ និងធ្វើចត្តាឡីស័កបន្តទៀតនៅផ្ទះ។ គួរបញ្ជាក់ផងដែរថា ពលរដ្ឋខ្មែរដែលជា អ្នកទោស ដែលរួចទោសមានចំនួន ៧៣នាក់ និងពលករនេសាទ ១៤៩នាក់ កំពុងស្នាក់នៅប្រទេសម៉ាឡេស៊ី នេះបើតាមការបញ្ជាក់របស់លោករដ្ឋមន្ត្រីក្រសួងសុខាភិបាល៕

## ពលករខ្មែរធ្វើការនៅថៃ បន្តវិលចូលមកក្នុងប្រទេសវិញជាបន្តបន្ទាប់

http://www.rasmeinews.com/ April 26, 2020, 2:31 PM

**ដោយ: គ្រញូង / បាត់ដំបង:** លោកវរសេនីយ៍ឯក អ៊ឹម កុសល ស្នងការរងខេត្តទទួលការងារឆ្លើយតបរហ័ស បានឲ្យដឹងថា សព្វថ្ងៃនេះនៅតែមានបងប្អូនប្រជាពលករបន្តវិលចូលមកក្នុងប្រទេសវិញជាបន្តបន្ទាប់ រីឯកងកម្លាំង និងសមត្ថកិច្ចពាក់ព័ន្ធនៅតែបន្តទទួលពិនិត្យ និងដឹកជញ្ជូនពួកគាត់ទៅតាមគោលដៅរៀងៗខ្លួន។ លោកស្នងការរងខេត្តបានបញ្ជាក់កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២០ លោកឧត្តមសេនីយ៍ទោ អ៊ុច សុខុន ស្នងការនគរបាលខេត្តបាត់ដំបង និងជាមេបញ្ជាការរងនគរបាលជាតិប្រចាំទិសភូមិភាគទី៥ និងក្រុមការងារបានអញ្ជើញចុះសំណេះ

សំណាលជាមួយប្រជាពលករខ្មែរ ដែលវិលមកពីប្រទេសថៃ នៅចំណុចទីបញ្ជាការវរសេនាតូចលេខ ៥០៤ (ហៅប្រាំសូន្យបួន) ចំណុះកងពលតូចថ្មើរជើងលេខ៥៣ ដែលឈរជើងក្នុងភូមិសាស្ត្រស្រុកកំរៀង ដើម្បីពិនិត្យកំដៅរួចជូនពួកគាត់ទៅស្រុកកំណើត រៀងៗខ្លួន។

លោកស្នងការខេត្តបានទៅពិនិត្យច្រករបៀងមួយចំនួនតាមបន្ទាត់ព្រំដែន ក្នុងភូមិសាស្ត្រស្រុកកំរៀងស្រុកភ្នំព្រឹក និងស្រុកសំពៅលូន ដើម្បីបានដឹងអំពីស្ថានភាពសន្តិសុខនៅទីនោះផងដែរ។ លោកស្នងការខេត្តបានឧបត្ថម្ភដល់អង្គភាពបញ្ជាការវរសេនាតូចលេខ៥០៤ ចំណុះកងពលថ្មើរជើងលេខ៥៣មានអង្ករ ចំនួន ២០០គីឡូក្រាមស្មើ ៤ការ៉ុង -មីចំនួន២កេសធំ ស្មើ ១២កេសតូច និងថវិកាចំនួន១ លានរៀល)៕ ល

## ពលករខ្មែរមួយក្រុមប្រថុយឆ្លងដែនទៅរកការងារធ្វើនៅថៃអំឡុងជំងឺកូវីដ១៩រាតត្បាត

https://www.rfa.org/khmer/ ដោយ សេក បណ្ឌិត 2020-04-26

ពលករខ្មែរមួយក្រុមមានគ្នាប្រមាណ៧០នាក់ ប្រថុយឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ អំឡុងពេលជំងឺកូវីដ១៩កំពុងរាតត្បាត។ ពលករមួយចំនួនធំមិនបានទៅដល់គោលដៅនោះទេ ដោយប៉ូលិសថៃដេញបាញ់ស្ទាក់ចាប់បានក្នុងពេលកំពុងធ្វើដំណើរ។ ជាមួយគ្នានោះក៏មានមនុស្ស៣នាក់ប៉ុណ្ណោះ បានរត់គេចខ្លួនរួចធ្វើដំណើរទៅដល់ទីក្រុងបាងកក។ តើក្រុមពលករខ្មែរទាំងនោះជួបការលំបាកយ៉ាងណាទើបនាំគ្នាឆ្លងដែនទៅប្រទេសថៃ។

លោក សេក បណ្ឌិត អំពីដំណើរផ្សងព្រេងរបស់ពលករខ្មែរឆ្លងដែនទៅប្រទេសថៃអំឡុងពេលដែលថៃដាក់ប្រទេសក្នុងគ្រាមានអាសន្នដូចតទៅ។ ពលរដ្ឋខ្មែរទាំង៣នាក់ដែលរត់គេចខ្លួនទៅដល់គោលដៅលើកឡើងស្រដៀងគ្នាថា ការឆ្លងដែនអំឡុងពេលជំងឺកូវីដ១៩កំពុងរាតត្បាតនេះ ប្រថុយនឹងគ្រោះថ្នាក់ដល់អាយុជីវិតខ្លាំងមិនធ្លាប់ជួបប្រទះឡើយ។ ពលករមានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ លោក ឈឿម រស្មី រៀបរាប់ថា ពួកគេឆ្លងទៅប្រទេសថៃតាមអូរព្រំដែនក្នុងស្រុកម៉ាឡៃតាមរយៈមេខ្យល់ ដោយបង់ប្រាក់ចំនួន ៣ពាន់បាត ឬប្រមាណ៩៥ដុល្លារអាមេរិកក្នុងម្នាក់។ ពលកររូបនេះ បន្តថា មេខ្យល់ជនជាតិខ្មែរ៣នាក់បាននាំពលករខ្មែរម្តងជាង២០នាក់ដើរកាត់ព្រៃនិងចម្ការដំឡូងមីរបស់ជនជាតិថៃ តាំងពីម៉ោង៦កន្លះល្ងាចរហូតដល់ម៉ោង ២រំលងអធ្រាត្រទើបដល់កន្លែងជិះរថយន្ត។ លោកបញ្ជាក់ថា ក្នុងពេលធ្វើដំណើរតាមផ្លូវនោះលោកមិនសង្ឃឹមថា នឹងមានជីវិតបានត្រឡប់ទៅខ្មែរវិញឡើយ ពីព្រោះប្រឈមនឹងទាហានថៃបាញ់ស្លាប់ និងភ័យខ្លាចប៉ូលិសថៃចាប់តាមផ្លូវ។លោកបន្តថា ពួកគេបានឡើងជិះរថយន្តចម្ងាយប្រហែល៣គីឡូម៉ែត្រប៉ុណ្ណោះ ស្រាប់តែជួបប៉ូលិសថៃដាក់ប៉ុស្តិ៍ត្រួតពិនិត្យ ក៏ប៉ុន្តែអ្នកបើករថយន្តជនជាតិថៃមិនបានឈប់ឱ្យប៉ូលិសត្រួតពិនិត្យនោះទេ ហើយបានបន្ថែមល្បឿនរថយន្តយ៉ាងលឿនដូចអ្នកបើករថយន្តក្នុងក្នុងរឿងកុន បណ្តាលឱ្យប៉ូលិសថៃបាញ់បែកកង់ឡាន។ លោកបន្ថែមថា ពេលនោះពួកលោកមានគ្នា ៣នាក់បានលោតចេញពីរថយន្តហើយនាំគ្នាស្ទុះរត់ចូលព្រៃ៖ «ប្រថុយណាស់ដូចយកជីវិតមកលេងសើចអីចឹងឯង ជិះឡាន់លឿនក៏លឿន បើសិនជាតម្រួតថៃបាញ់បែកកង់ឡានក្រឡាប់អាចគ្រោះថ្នាក់ដល់ជីវិតទៀត។ ខ្ញុំប្រាប់គេដែរឱ្យគេឈប់ឱ្យប៉ូលិសចាប់ទៅ វាមិនអីទេ វាអត់ឈប់។ខ្ញុំឡើងឡានបានមិនដល់៥នាទីផង ប៉ះគេអស់ជាច្រើនគ្រាប់ចំកង់ឡាន ហើយឡានបើករត់រហូតដល់អស់ខ្យល់បានឈប់ខ្ញុំក៏រត់ចូលព្រៃ។ រត់ដូចមនុស្សឆ្កើលអ្វីម្យ៉ាងអីចឹង រត់ចោលខោអាវខ្លះក៏យំខ្លះក៏ស្រែកពេញព្រៃ»។

លោកបន្តថា ពលករផ្សេងទៀតអាចត្រូវប៉ូលិសចាប់ខ្លួន ក៏ប៉ុន្តែពុំដឹងថា ប៉ូលិសថៃបញ្ជូនពលករទាំងនោះទៅកន្លែងណានោះទេ ហើយលោកក៏បន្តដំណើរទៅកន្លែងធ្វើការនៅទីក្រុងបាងកកនៅថ្ងៃទី២៤ មេសា។ លោកបន្ថែមថា ពលករខ្មែរទាំងនោះភាគច្រើនជាពលករធ្វើការស្របច្បាប់ ដែលបានឆ្លងដែនតាមច្រករបៀងត្រឡប់ទៅផ្ទះកាលពីខែមីនា។ លោកថា មូលហេតុដែលលោកសម្រេចចិត្តឆ្លងដែលទៅប្រទេសថៃ ដោយសារនៅផ្ទះពុំមានការងារធ្វើ ហើយថៅកែជនជាតិថៃបានទូរស័ព្ទឱ្យលោកត្រឡប់ទៅធ្វើការវិញ ពីព្រោះនៅកន្លែងធ្វើការពលករបានត្រ

ឡប់ទៅផ្ទះអស់ហើយ ដោយភ័យខ្លាចឆ្លងជំងឺកូវីដ១៩ ទើបបណ្តាលឱ្យមិនមានអ្នកធ្វើការ។ ទោះជាយ៉ាងណា លោកថា នេះជាលើកទីមួយដែលលោកប្រថុយនឹងគ្រោះថ្នាក់ក្នុងពេលឆ្លងដែនទៅប្រទេសថៃ៖ «ខ្ញុំឈប់ឆ្លងដែនបែបនេះទៀតហើយខ្លាចណាស់ ខ្ញុំមករាល់ដងមានលិខិតឆ្លងដែន (ប៉ាស្ព័រ) ត្រឹមត្រូវ បើមកបែបនេះវេទនាណាស់ ដើរកាត់ព្រៃរហូត ព្រោះពេលនេះថៃគេមិនឱ្យចូលប្រទេសគេ មានតែនាំគ្នាដើរកាត់ព្រៃ។ ខ្ញុំនៅផ្ទះអត់ការងារធ្វើផងណាមួយនៅផ្ទះគ្មានលុយចាយ និងគ្មានប្រាក់សងធនាគារ ហើយទៅធ្វើការសំណង់ក៏គេមិនយក អីចឹងហើយបានសម្រេចចិត្តឡើងទៅថៃវិញបណ្តោយទៅ»។

ចំណែកសកម្មជនគណបក្សសង្គ្រោះជាតិម្នាក់ដែលបានរួមដំណើរជាមួយពលករ លោក ទុំ ប៊ុនថន ថ្លែងថា ក្នុងពេលឆ្លងដែននោះលោកស្ទើរស្រក់ទឹកភ្នែក ពីព្រោះក្នុងចំណោលពលករទាំង៧០នាក់នោះ មានស្ត្រីដែលមានកូនខ្ចីអាយុ ៦ខែម្នាក់ផងបានបីកូនឆ្លងដែនក្នុងព្រៃទាំងកណ្តាលយប់។ លោកបន្ថែមថា នៅពេលនោះលោកឃើញវេទនាភ្នែកខ្លាំងពេកគាត់ក៏បានជួយលីការ៉ុងដាក់ខោអាវរបស់ស្ត្រីកូនខ្ចីម្នាក់នោះរហូតដល់កន្លែងជិះឡាន៖ «បីកូនបណ្តើរទឹកដោះគោកូនបៅបណ្តើរ ហើយមានប្អូនថ្លៃមួយហ្នឹងយកបើកកូនកង្ហារឱ្យកូនដេក ដើម្បីកុំឱ្យគាត់យំ គាត់ត្រូវការដេក ដល់ពេលយើងបីគាត់ទាំងយប់កាត់ព្រៃអីចឹងទៅ ដល់ពេលក្មេងយំម្តងៗខ្ញុំភ័យណាស់ ភ័យខ្លាចប៉ូលិសមកចាប់។ អីចឹងសង្គមនេះឯងធ្វើឱ្យអ្វីបាត់បង់ជាពិសេសធ្វើឱ្យពលករបង្ខំចិត្តឆ្លងដែនទៅប្រទេសថៃ។ ខ្ញុំបានសួរប្អូនស្រីដែលមានកូនខ្ចីហ្នឹងដែរ គាត់ថា បើមិនមកបានអីហូប បើផ្ទះអត់អីហូប ការងារអត់មាន ហើយគ្រួសារសង្ឃឹមលើគាត់ គាត់ថាមួយជំហានស្លាប់ក៏គាត់ត្រូវតែមកថៃដែរ»។

រហូតមកទល់ពេលនេះអាជ្ញាធរថៃនៅតែបន្តដាក់ប្រទេសក្នុងភាពអាសន្នដដែល ដោយហាមឃាត់ប្រជាពលរដ្ឋធ្វើដំណើរចាប់ពីម៉ោង ១០យប់ ដល់ម៉ោង៤ទៀបភ្លឺ ដើម្បីការពារកុំឱ្យរាតត្បាតជំងឺកូវីដ១៩ ។ ប្រសិនបើជនណាល្មើសបម្រាមនេះនឹងមានទោសជាប់ពន្ធនាគារ១ឆ្នាំ ឬពិន័យជាប្រាក់ប្រមាណ ៤ម៉ឺនបាត(៤០,០០០) ឬប្រហែល ១ពាន់ ៣០០ដុល្លា។

ថ្មីៗនេះស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក បានអំពាវនាវដល់ពលរដ្ឋខ្មែរទាំងអស់ដែលស្នាក់នៅប្រទេសថៃត្រូវសហការជាមួយអាជ្ញាធរថៃឱ្យបានខ្ជាប់ខ្ជួន ដើម្បីចូលរួមទប់ស្កាត់ជំងឺកូវីដ១៩។

ជាមួយគ្នានេះដែរ អាជ្ញាធរថៃបានឃាត់ពលករខ្មែរ១៣នាក់ ដែលឆ្លងដែនទៅធ្វើការងារខុសច្បាប់នៅស្រុកអារញ្ញយ៉ាប្រាថេត (Aranyaprathet) ខេត្តស្រះកែវ (Sra Kao) នៅព្រឹកថ្ងៃទី២៦ មេសា។ អាជ្ញាធរថៃបានបញ្ជូនក្រុមពលករទាំងនោះត្រឡប់ទៅកម្ពុជាវិញនៅរសៀលថ្ងៃដដែល។ ទាក់ទងនឹងបញ្ហានេះ មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក(Adhoc) បន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា មានប្រសាសន៍ថា ពលករដែលឆ្លងដែនទៅប្រទេសថៃអំឡុងពេលនេះប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិតផង និងប្រឈមនឹងថៃចាប់ដាក់គុកផង ព្រោះសព្វថ្ងៃថៃបានដាក់ប្រទេសក្នុងគ្រាអាសន្ននៅឡើយ ដើម្បីទប់ស្កាត់ការឆ្លងជំងឺរលាកផ្លូវដង្ហើមថ្មី៖ «យើងមានការព្រួយបារម្ភយ៉ាងខ្លាំងទាក់ទងរឿងហ្នឹង ហើយក៏សង្វេគយ៉ាងខ្លាំង ដោយសារតែពួកគាត់ប្រថុយជីវិតយ៉ាងនេះ។ នេះជាសារមួយដល់អ្នកដឹកនាំរដ្ឋ ដល់រដ្ឋាភិបាលកម្ពុជាគួរតែពិនិត្យទៅលើភាពដែលគ្មានការងារធ្វើទាក់ទងទៅលើទីផ្សារលក់កសិផលរបស់កសិករ ហើយនិងការដោះសាររបស់មន្ត្រីថ្នាក់ក្រោមមិនបានផ្តល់ភាពកក់ក្តៅដល់ប្រជាពលរដ្ឋ»។

របាយការណ៍អង្គការសង់ត្រាល់ឱ្យដឹងថា ពលករខ្មែរប្រមាណ២លាននាក់(២,០០០,០០០)ទៅធ្វើការនៅប្រទេសថៃ ហើយចាប់ពីផ្ទុះជំងឺកូវីដ១៩មក មានពលករខ្មែរជិត១០ម៉ឺននាក់(១០០,០០០)បានត្រឡប់ទៅស្រុកកំណើតវិញដោយសារនៅប្រទេសថៃអត់ការងារធ្វើ។

លោក ស៊ុំ ច័ន្ទគា ថ្លែងថា រដ្ឋាភិបាលកម្ពុជាគួរតែបញ្ចេញកញ្ចប់ថវិកាបម្រុងរបស់រដ្ឋដែលលោកនាយករដ្ឋមន្ត្រីហ៊ុន សែន បានប្រកាសថា មានប្រាក់ជិត ៣ពាន់លានដុល្លារអាមេរិក(៣,០០០)នោះ ជួយដល់ពលរដ្ឋឱ្យបាន

ឆាប់ ជាពិសេសពលរដ្ឋដែលមានជីវភាពក្រីក្រខ្លាំង ដើម្បីឱ្យពួកគាត់មានប្រាក់ទិញស្បៀងអាហារហូបចុក បណ្ដោះអាសន្ន ដោយមិនបាច់ឆ្លងដែនទៅប្រទេសថៃ អំឡុងពេលជំងឺកូវីដ១៩កំពុងតែរាតត្បាត៕

## ឧត្តមសេនីយ៍ទោ អ៊ុច សុខុន អញ្ជើញសំណេះសំណាលជាមួយ ពលរដ្ឋវិលមកពីប្រទេសថៃ ប្រមូលផ្ដុំនៅទីបញ្ជាការវរសេនាតូចលេខ៥០៤

http://cambodiapolice.com/policekh/ 8:29 am 26 មេសា 2020

បាត់ដំបង ៖ នាព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២០ ឯកឧត្តម ឧត្តមសេនីយ៍ទោ អ៊ុច សុខុន ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង និងជាមេបញ្ជាការរងនគរបាលជាតិ ប្រចាំទិសភូមិភាគទី៥ ព្រមទាំងគណៈប្រតិភូអមដំណើរ អញ្ជើញសំណេះសំណាលជាមួយប្រជាពលរដ្ឋ វិលមកពីប្រទេសថៃប្រមូលផ្ដុំនៅទីបញ្ជាការវរសេនាតូចលេខ៥០៤ (ហៅប្រាំសូន្យបួន) ចំណុះកងពលស្ទើជើងលេខ៥៣ ឈរជើងក្នុងភូមិសាស្ត្រស្រុកកំរៀង ដើម្បីពិនិត្យកំដៅរួចជូនពួកគាត់ទៅស្រុកកំណើតរៀងៗខ្លួន និងឧបត្ថម្ភ អង្ករ ចំនួន ២០០ គីឡូក្រាម ស្មើ៤ការ៉ុង , មី ចំនួន ២កេសធំ ស្មើ ១២ កេសតូច និងថវិកា ចំនួន ១.០០០.០០០ រៀល ដល់ទីបញ្ជាការវរសេនាតូចលេខ៥០៤(ហៅប្រាំសូន្យបួន) ចំណុះ កងពលស្ទើជើងលេខ៥៣ ឈរជើងក្នុងភូមិសាស្ត្រស្រុកកំរៀង ព្រមទាំងចុះពិនិត្យតាមបណ្ដាច្រកជាប់ព្រំដែនថៃ ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកកំរៀង ស្រុកភ្នំព្រឹក និងស្រុកសំពៅលូន ផងដែរ ៕

## ឃាត់ខ្លួនជនជាតិវៀតណាមម្នាក់ ចែកចាយបង្ហោះរូបភាពអាសអាភាស

http://cambodiapolice.com/policekh/ 9:35 am 26 មេសា 2020

ភ្នំពេញ ៖ ស្ត្រីជនជាតិវៀតណាមម្នាក់ បានផលិត ចែកចាយបង្ហោះរូបភាពអាសអាភាស បានសម្រេច ត្រូវបានកម្លាំងនគរបាលឃាត់ខ្លួន នៅចំណុច សិប្បកម្មធ្វើតុ-ទូ ភូមិតាងៅកណ្ដាល សង្កាត់ និរោធ ខណ្ឌច្បារអំពៅ កាលពីថ្ងៃទី២៤-០៤-២០២០ វេលាម៉ោង១៧និង០០នាទី។ ជនសង្ស័យឃាត់ខ្លួនឈ្មោះ ង្វៀង ធីម៉ាំង ភេទស្រី អាយុ២៥ឆ្នាំ ជនជាតិវៀតណាម មុខរបរ កម្មករធ្វើតុ-ទូ ស្នាក់នៅភូមិតាងៅកណ្ដាល សង្កាត់និរោធ ខណ្ឌច្បារអំពៅ។ ជនរងគ្រោះឈ្មោះ ជ ធម ភេទស្រី អាយុ១៦ឆ្នាំ ជនជាតិវៀតណាម មុខរបរ លក់កាហ្វេ ស្នាក់នៅភូមិ.សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ។

តាមរបាយការណ៍បានឲ្យដឹងថា មុនពេលកើតហេតុ ជនរងគ្រោះ បានឆែក Account Facebook ខ្លួនមើល ក៏ឃើញ Account Facebook ឈ្មោះ Ra Da (ជនសង្ស័យឈ្មោះ ង្វៀង ធីម៉ាំង) បានយករូបថតអាក្រាតកាយជនរងគ្រោះពេលងូតទឹក មកបង្ហោះរួចសរសេរជាភាសាវៀតណាម បកប្រែក្រៅផ្លូវការជាភាសាខ្មែរ មានន័យថា ជនសង្ស័យនិយាយបង្ខូចមើលងាយជនរងគ្រោះរឿង...អាក្រក់ខ្លាំងណាស់។ បន្ទាប់មកជនរងគ្រោះក៏យករឿងហេតុខាងលើប្រាប់ឪពុក។ លុះដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង២២និង០០នាទី ជនរងគ្រោះនិងក្រុមគ្រួសារឃើញជនសង្ស័យ នៅភូមិតាងៅកណ្ដាល សង្កាត់និរោធ ក៏ឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ច ចាត់ការតាមច្បាប់៕

## អភិបាលខេត្តតាកែវ អំពាវនាវឱ្យក្រុមពលករមកពីក្រៅប្រទេស បន្តស្នាក់នៅដាច់ដោយឡែក១៤ថ្ងៃ

http://btv.com.kh/nation-news/ 24/04/2020

តាកែវ ៖ បន្ទាប់ពីមានពលករ ធ្វើការនៅក្រៅប្រទេស ជាពិសេសប្រទេសថៃ បន្តសម្រុកចូលមកកាន់ខេត្តតាកែវ ជារៀងរាល់ថ្ងៃនោះ អភិបាលខេត្តតាកែវ បានធ្វើការអំពាវនាវដល់ពួកគេ ឱ្យស្នាក់នៅដាច់ដោយឡែក១៤ ថ្ងៃ

សិន មុននឹងចូលទៅរួមរស់ជុំក្រុមគ្រួសារ។ អភិបាលខេត្តតាកែវ ឯកឧត្តម អ៊ូច ភា បានធ្វើការអំពាវនាវដល់ក្រុមគ្រួសារ ដែលមានបងប្អូនមក ពីក្រៅប្រទេស ត្រូវរៀបចំដាក់ពួកគេឲ្យនៅដាច់ដោយឡែក១៤ថ្ងៃសិន ជាពិសេសត្រូវបន្តតាមដានសុខ ភាពឲ្យបានជាប់ជាប្រចាំ ដើម្បីធនាថាពួកគេ គ្មានផ្ទុកមេរោគកូវីដ១៩ ដែលនាំឱ្យឆ្លងរីករាលដាលដល់ សហគមន៍នោះទេ។ ឯកឧត្តម អភិបាលខេត្តតាកែវ បានធ្វើការអំពាវនាវបែបនេះ នៅព្រឹកថ្ងៃទី២៤ ខែមេសា នេះ ក្នុងពិធីចែកអំណោយដល់ប្រជាពលរដ្ឋ៩០គ្រួសារ នៅក្នុងស្រុកគីរីវង់។ ឯកឧត្តម បានឱ្យដឹងថា ហេូតមកដល់ពេលនេះ មានពលករខ្មែរ មកពីក្រៅប្រទេស ចូលមកដល់ ខេត្តតាកែវ ចំនួនជាង៣ពាន់នាក់ហើយ។ ពួកគេទាំងនោះ ត្រូវបានពិនិត្យសុខភាពជាមុន ដោយមន្ត្រីសុខា ភិបាល នៅព្រំដែន និងបន្តឆែកសុខភាព លើកទី២ ពេលមកដល់ខេត្តតាកែវ ទើបអនុញ្ញាតឲ្យទៅផ្ទះ។ ប៉ុន្តែពេលមកដល់ស្រុកកំណើត ត្រូវបន្តស្នាក់នៅដាច់ដោយឡែកពីគេ ១៤ថ្ងៃសិន ដើម្បីបន្តតាមដានសុខ ភាព ព្រោះជំងឺកូវីដ១៩ វាអាចនៅក្នុងខ្លួនមនុស្ស១៤ថ្ងៃ ទើបចេញរោគសញ្ញា។

ឯកឧត្តម អភិបាលខេត្តតាកែវ បានបន្តថា កន្លងមក អាជ្ញាធរខេត្ត បានរៀបចំបន្ទប់ប្រមាណជាង បីរយសម្រាប់ដាក់អ្នកជំងឺកូវីដ១៩ ឬអ្នកមានរោគសញ្ញាសង្ស័យ នៅក្នុងក្រុងដូនកែវ ក៏ប៉ុន្តែរហូតមកដល់ ពេលនេះ ខេត្តតាកែវ មិនទាន់មានអ្នកផ្ទុកជំងឺកូវីដ–១៩ ដែលត្រូវដាក់ឱ្យព្យាបាលនៅឡើយទេ បើទោះបីជា បានបញ្ជូនសំណាកជនសង្ស័យចំនួនជាង៤០នាក់ ទៅពិនិត្យនៅវិទ្យាស្ថានប៉ាស្ទ័រ ប៉ុន្តែលទ្ធផលចេញមក គឺអវិជ្ជមានទាំងអស់។ ឯកឧត្តម អ៊ូច ភា បានបញ្ជាក់ថា បើទោះបីជាខេត្តតាកែវ មិនទាន់អ្នកផ្ទុកមេរោគកូវីដ១៩យ៉ាង ណាក៏ដោយ ក៏អាជ្ញាធរខេត្ត បានធ្វើយុទ្ធនាការចុះផ្សព្វផ្សាយពីវិធានការអប់រំ របស់ក្រសួងសុខាភិបាល ដល់ប្រជាពលរដ្ឋ ឲ្យបានជាប់ប្រចាំ ជាពិសេសតាមដានសុខភាពរបស់ពលករ ដែលមកពីក្រៅប្រទេស បង្ការទប់ស្កាត់ការឆ្លងរីករាលដាលនៅក្នុងសហគមន៍៕

## ពលករចំណាកស្រុកពីប្រទេសថៃ ចំនួន ១៧ នាក់ទៀត បានវិលត្រឡប់មកដល់ស្រុកកំណើតនៅខេត្តតាកែវ

https://www.cen.com.kh/ April 27, 2020

តាកែវ៖ ពលករចំណាកស្រុកចំនួន ១៧នាក់ ត្រូវបានក្រុមគ្រូពេទ្យនៃមន្ទីរសុខាភិបាលខេត្តតាកែវ ធ្វើការពិនិត្យ និងតាមដានសុខភាពយ៉ាងយកចិត្តទុកដាក់ នៅទីតាំងចត្តាឡីស័ក នៅមជ្ឈមណ្ឌលគរុកោសល្យខេត្តតាកែវ ក្រោយពីពួកគាត់ត្រូវបានរថយន្តរបស់កងកម្លាំង ដឹកជញ្ជូនពួកគាត់ពីទល់ដែនប្រទេសថៃ ត្រឡប់មកស្រុកកំណើត នៅព្រឹកថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០២០ ។ នៅក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំង និងជម្ងឺកូវីដ១៩ នេះ ឯកឧត្តម អ៊ូច ភា អភិបាលខេត្តតាកែវ បានជំរុញឲ្យក្រុមគ្រូពេទ្យត្រូវតែយកចិត្តទុកដាក់លើការតាមដានសុខភាពរបស់ពលករចំណាកស្រុក ដែលវិលត្រឡប់ពីប្រទេសថៃ ហើយអាជ្ញាធរពាក់ព័ន្ធគ្រប់ស្រុកក្រុងទាំងអស់ត្រូវតែ ចុះជាប់ជាប្រចាំលើការអប់រំណែនាំដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ចូលរួមទាំងគ្នាក្នុងការរក្សានិងការពារសុខភាពរបស់ខ្លួន ជាមួយនិងការរចេះសម្អាតអនាម័យលើខ្លួនឯងចេះលាងដៃជាមួយអាល់កុល ឬសាប៊ូ ។

ចំពោះការវិលត្រឡប់របស់ពលករចំណាកស្រុកពីប្រទេសថៃនេះដែរ ពួកគាត់បាននិយាយថា ការវិលត្រឡប់មកនេះមិនមែនកន្លែងធ្វើការរបស់គាត់បិទនោះទេ តែរោងចក្រដែលពួកគាត់ធ្វើនៅក្រៅប្រទេសនោះ មិនបានលើកទឹកចិត្តអោយកម្មករនោះទេ ដោយពីមុនមានបុគ្គលិកចំនួន ២០នាក់ធ្វើការងារ តែលុះផ្ទុះនៅជំងឺកូវីដ១៩ បុគ្គលិកត្រូវបានកាត់បន្ថយ និងឈប់ជាបន្តបន្ទាប់ ហើយទំហំនិងបរិមាណនៃការងារ នៅតែប៉ុណ្ណឹងដដែល បើទោះបីជាបុគ្គលិកថយចុះជាង ៥០%ក៏ដោយ ។

លោក នុត ស៊ីណាត ប្រធានមន្ទីរសុខាភិបាលខេត្តតាកែវបានឲ្យដឹងថា មកទល់ពេលនេះនៅក្នុងទឹកដីខេត្តតាកែវ នៅមិនទាន់មានវត្តមាន នៃជំងឺកូវីដ១៩ ទេ ហើយក្រុមគ្រូពេទ្យនៅតែបន្តតាមដានសុខភាពរបស់ប្រជាពលរដ្ឋ ជាពិសេសពលករចំណាកស្រុកជាប្រចាំ ៕ **ដោយៈ តាកែវ**

## ពលរដ្ឋខ្មែរ ១៣នាក់ត្រូវបានអាជ្ញាធរថៃចាប់ខ្លួនក្រោយព្យាយាមចូលទៅក្នុងទឹកដីថៃ ដោយខុសច្បាប់ ដើម្បីស្វែងរកការងារធ្វើ

https://khmernote.com.kh/news/ អន្តរជាតិ April 27, 2020 lyda

ថៃៈ ពលរដ្ឋខ្មែរចំនួន ១៣នាក់ ប្រុស ៨នាក់និងស្រី ៥នាក់ ត្រូវបានអាជ្ញាធរថៃព័ន្ធចាប់ខ្លួននៅច្រកព្រំដែនខ្មែរ-ថៃ ព្រោះតែពួកគាត់ព្យាយាមចូលទៅក្នុងប្រទេសថៃដោយខុសច្បាប់ដើម្បីស្វែងរកការងារធ្វើ។ បើតាមសារព័ត៌មាន bangkokpost បានរាយការណ៍ថា ការចាប់ខ្លួនត្រូវបានធ្វើឡើងនៅម៉ោង ២ រំលងអធ្រាត្រ និងស្ថិតនៅក្នុងចំការអំពៅមួយកន្លែងក្នុងចន្លោះភូមិ Dong Ngu និង Pa Rai ក្នុងស្រុក Aranyaprathet ខេត្ត សាកែវ (SA KAEO) ប្រទេសថៃ។ ក្រោយការចាប់ខ្លួនពលរដ្ឋខ្មែរទាំង ១៣រូប បានសារភាពប៉ូលិសថៃថា ពួកគាត់បានបានចំណាយលុយម្នាក់ ២ ០០០ បាត (៦២ ដុល្លារអាមេរិក) ឲ្យបុរសជនជាតិខ្មែរម្នាក់ ដើម្បីនាំពួកគាត់ចូលទៅក្នុងប្រទេសថៃ តាមផ្លូវកាត់ដោយមិនចាំបាច់មានការត្រួតពិនិត្យពីអាជ្ញាធរថៃឡើយ។

ក្រោយចំណាយលុយឲ្យមេខ្យល់សម្រាប់ការនាំផ្លូវចូលក្នុងប្រទេសថៃរួច ពលរដ្ឋខ្មែរទាំង ១៣ នាក់ត្រូវបានគេនាំទៅលាក់ខ្លួននៅក្នុងចំការអំពៅ ហើយរង់ចាំគេយកយានជំនិះមករំដោះពួកគាត់ចេញពីចំការអំពៅនៅពេលជិតភ្លឺ។ យ៉ាងណាក្ដី មិនទាន់ដល់ភ្លឺស្រួលបួលផង អាជ្ញាធរថៃក៏បានលោមព័ន្ធចំការអំពៅ និងឈានដល់ការចាប់ខ្លួនពលរដ្ឋទាំង ១៣នាក់នោះតែម្ដង។ ពលរដ្ឋខ្មែរទាំង ១៣ នាក់បានអះអាងថា ការព្យាយាមចូលទៅក្នុងប្រទេសថៃនេះគឺដើម្បីស្វែងរកការងារធ្វើប៉ុណ្ណោះគ្មានបំណងអ្វីផ្សេងឡើយ ហើយគោលដៅដែលពួកគាត់ចង់ទៅនោះមានដូចជា ក្រុងបាងកក ខេត្តឈុនបូរី និងខេត្តសាមុតសាខន៕

## អភិបាលខេត្តសាមុតសាខនចុះសួរសុខទុក្ខពលករខ្មែរខ្វះខាតស្បៀងអាហារ និងកន្លែងស្នាក់នៅ

https://www.facebook.com/prakpheaktraofficial/ ប្រាក់ ភក្ត្រា Prak Pheaktra 26-04-2020

នៅព្រឹកថ្ងៃអាទិត្យ ទី២៦ ខែមេសា ឆ្នាំ២០២០ នេះលោកអភិបាលខេត្តសាមុតសាខន,ប្រទេសថៃ និងលោក Sompong Srakeaw អគ្គនាយកនៃអង្គការបណ្ដាញលើកកម្ពស់សិទ្ធិនិងគុណភាពជីវិតពលករហៅកាត់ថា (LPN)ចុះសួរសុខទុក្ខនិងនាំយកអំណោយចែកដល់ពលករខ្មែរម្នាក់ឈ្មោះ ជឹម ចាន់ណេង ភេទប្រុស អាយុ 26ឆ្នាំ មានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ ដែលកំពុងមានការខ្វះខាតស្បៀងបន្ទាប់ពីកន្លែងធ្វើការរបស់គាត់បានបិទដោយជំងឺកូវីដ-19 កាលពីពេលថ្មីៗកន្លងទៅនេះ។

សូមថ្លែងអំណរគុណដល់លោកអភិបាលខេត្តសាមុតសាខន និងជាពិសេសលោកអគ្គនាយក នៃអង្គការបណ្ដាញលើកកម្ពស់គុណភាពជីវិតពលករអិលភីអិន (LPN) ដែលតែងតែយកចិត្តទុកដាក់ជួយដោះស្រាយបញ្ហាដល់ពលករបរទេសដែលរងទុក្ខលំបាកក្នុងប្រទេសថៃ។ 26.04.20 ភក្ត្រា ពលករខ្មែរ

## ចាប់ពលករខ្មែរចំណាកស្រុកខុសច្បាប់ចូលប្រទេសថៃ

https://www.facebook.com/prakpheaktraofficial/ ប្រាក់ ភក្ត្រា Prak Pheaktra 26-04-2020

ពលករខ្មែរប្រុសស្រីចំនួន ១៣នាក់ ចំណាកស្រុកខុសច្បាប់ចូលមកស្វែងរកការងារក្នុងប្រទេសថៃ ត្រូវកម្លាំងសមត្ថកិច្ចទាហានការពារព្រំដែនថៃឃាត់ខ្លួនបន្ទាប់ពីពលករខ្មែរទាំងអស់នោះ ជួលឲ្យមេខ្យល់ខ្មែរនាំឆ្លងដែនចូលប្រទេសថៃតាមរយៈច្រករបៀងធម្មជាតិ ស្ថិតក្នុងស្រុកអារញ្ញយ៉ាប្រាថេត ខេត្តស្រះកែវ ប្រទេសថៃ កាលពីព្រឹកថ្ងៃអាទិត្យ ទី២៦ ខែមេសា ឆ្នាំ២០២០នេះ។ តាមការបញ្ជាក់៖ពលករខ្មែរទាំងអស់បានចំណាយប្រាក់អោយមេខ្យល់ក្នុងម្នាក់២០០០បាត ដោយមានរថយន្តខាងថៃចាំដឹកពួកគេយកទៅដាក់កន្លែងធ្វើការដូចជាខេត្តឈុនបុរី,សាមុតសាខននិងទីក្រុងបាងកក។ ក្រោយពេលឃាត់ខ្លួនពលករទាំងអស់ត្រូវបានសមត្ថកិច្ចថៃបញ្ជូនទៅកាន់អធិការដ្ឋានប៉ុស្តិ៍ខ្លងឡឹកធ្វើប្រវត្តិរូបរួចបញ្ជូនអោយវិលត្រឡប់ទៅប្រទេសកម្ពុជាវិញ។ 26.04.20 ភក្ត្រា ពលករខ្មែរ

## ពលករខ្មែរ ០២នាក់ស្នាក់នៅទីរួមខេត្តឈុនបុរី គ្មានការងារធ្វើ ព្រមទាំងខ្វះខាតស្បៀងអាហារ

https://www.facebook.com/prakpheaktraofficial/ ប្រាក់ ភក្ត្រា Prak Pheaktra 25-04-2020

ពលករខ្មែរ ០២នាក់ស្នាក់នៅទីរួមខេត្តឈុនបុរី គ្មានការងារធ្វើ ព្រមទាំងខ្វះខាតស្បៀងអាហារសម្រាបហូបចុក លឺថានៅប៉ាតាយ៉ាគេចែកអំណោយ បាននាំគ្នាធ្វើដំណើរមកប៉ាតាយ៉ា ប៉ុន្តែគ្មានសាហុយឡាន ពលរដ្ឋថៃឃើញអាណិតជួយឧបត្ថម្ភប្រាក់បន្តិចបន្តួចថ្លៃឡានដើម្បីអោយគាត់ធ្វើដំណើរបន្តមកប៉ាតាយ៉ា ។ ប្រសិនមានបងប្អូនណាស្គាល់ពលករខ្មែរទាំងពីនាក់នេះសូមទំនាក់ទំនងមកខ្ញុំបាទផងសូមអរគុណ ។ 25.04.20

## ពលករខ្មែរនៅថៃស្លាប់បាត់បង់ជីវិត ០២ នាក់

https://www.facebook.com/labourkhmer/ 25-04-2020

ករណីទី១៖ ប្រភពពីខេត្តរ៉ាក់យ៉ង មានករណីបុរសពលករខ្មែរម្នាក់ ឈ្មោះ សម្បត្តិ ភេទប្រុស អាយុ ២៨ឆ្នាំ ត្រូវខ្សែភ្លើងឆក់ស្លាប់ នៅក្នុងផ្សារណាតវត្តលុង ស្ថិតក្នុងសង្កាត់ថាប្រាក់ខូ ស្រុកមឿង ខេត្តរ៉ាក់យ៉ង ប្រទេសថៃ ហេតុការណ៍ខាងលើនេះបានកើតឡើងនៅវេលាម៉ោង ០៧ យប់ ថ្ងៃព្រហស្បតិ៍ ទី២៣ ខែមេសា ឆ្នាំ២០២០ បច្ចុប្បន្នសាកសពជនរងគ្រោះត្រូវសមត្ថកិច្ចថៃបញ្ជូនយកទៅរក្សាទុកនៅមន្ទីរពេទ្យខេត្តរ៉ាក់យ៉ង។

ករណីទី២៖ ប្រភពពីខេត្តត្រាត មានករណីបុរសពលករខ្មែរម្នាក់ ឈ្មោះ សុមផុង កែរឿង អាយុ ៤៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាកម្មករផ្សារដែក ស្លាប់បាត់បង់ជីវិតនៅបន្ទប់លេខ៧១ ស្នាក់នៅស្ថិតក្នុងភូមិ៦ សង្កាត់ខ្លងយ៉ៃ ស្រុកខ្លងយ៉ៃ ខេត្តត្រាត ប្រទេសថៃ ប្រទេសថៃ ហេតុការណ៍នេះបានកើតឡើងនៅថ្ងៃសុក្រ ទី២៤ ខែមេសា ឆ្នាំ ២០២០ បច្ចុប្បន្ន សាកសពជនរងគ្រោះត្រូវសមត្ថកិច្ចថៃបញ្ជូនយកទៅរក្សាទុកនៅមន្ទីរពេទ្យខ្លងយ៉ៃ។

# ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០

## ប្រមុខរាជរដ្ឋាភិបាលកម្ពុជាសម្តេចតេជោ ហ៊ុន សែន សូម អរគុណពលករខ្មែរនៅម៉ាឡេស៊ី ដែលយោគយល់ដល់វិធានការទប់ស្កាត់ជំងឺឆ្លងកូវីដ-១៩ នៅកម្ពុជា

https://www.facebook.com/tvkchannel7/ 27-04-2020

សម្តេចតេជោ ហ៊ុន សែន សូមអរគុណពលករជាង២០០ នាក់ ដែលក្នុងនោះក៏មានកូនក្មួយអ្នកទោសចំនួន ៧៣នាក់ផងដែរ ដែលត្រូវបានផ្អាកការធ្វើដំណើរវិលត្រឡប់មកកម្ពុជាកាលពីពេលថ្មីៗក្នុងពេលដែលដែលប្រទេសយើងកំពុងដាក់បម្រាមតឹងរឹងក្នុងការធ្វើដំណើរ។ សម្តេចបានបញ្ជាក់ថា៖ ប៉ុន្តែនៅពេលនេះបម្រាមការធ្វើដំណើរក្នុង

ប្រទេសក៏បានលើក ដូច្នេះរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចអោយពលករខ្មែរជាង២០០នាក់អាចវិលត្រឡប់មកកាន់មាតុប្រទេសវិញ។ ប៉ុន្តែសូមកូនក្មួយទុកពេលវេលាអោយខាងអាជ្ញាធរម៉ាឡេស៊ីគេធ្វើតេស្តសុខភាពសិន ដើម្បីបញ្ជាក់ថាកូនក្មួយគ្មានសញ្ញាវិជ្ជមាននៃជំងឺកូវីដ-១៩ ។

យើងទាំងអស់គ្នា ទាំងអ្នកនៅក្នុងប្រទេស និងក្រៅប្រទេស គឺត្រូវមានការប្រុងប្រយ័ត្នជានិច្ច កុំនាំពេគឆ្លងពីក្រៅចូលក្នុង និងពីម្នាក់ទៅម្នាក់ ព្រោះជំងឺកូវីដ-១៩ នេះ គឺងាយឆ្លងខ្លាំងណាស់។ សម្តេចតេជោបញ្ជាក់ទៀតថា៖ សូមពលករខ្មែរកុំបារម្ភអ្វី ប្រសិនបើគ្មានជំងឺឆ្លងកូវីដ-១៩ទេ គឺអាចវិលត្រឡប់មកកម្ពុជាវិញបានក្នុងពេលឆាប់ៗនេះ។ ផ្ទុយពីនេះ បើខាងម៉ាឡេស៊ីពិនិត្យឃើញមានកូវីដ-១៩ទៅលើពលករណា គឺត្រូវនៅសម្រាកព្យាបាលនៅទីនោះសិនរហូតដល់ជាសះស្បើយទើបអនុញ្ញាតឱ្យត្រឡប់មកកម្ពុជាវិញ។ ចំពោះពលករដែលនឹងមកដល់កម្ពុជាវិញ គឺត្រូវធ្វើចត្តាឡីស័ក១៤ថ្ងៃ (រស់នៅដាច់ដោយឡែក) សិន ដើម្បីតាមដានសុខភាពជាបន្ត ហើយក៏មានការធ្វើចត្តាឡីស័ក១៤ថ្ងៃទៀតនៅតាមផ្ទះផងដែរ៕

## ប្រជាពលរដ្ឋទៅធ្វើការនៅថៃ បន្តវិលត្រឡប់មកកាន់ស្រុកកំណើតវិញ

http://nokorwatnews.com/ 27-04-2020

ខេត្តសៀមរាប៖ បើតាមរបាយការណ៍រដ្ឋបាលខេត្តសៀមរាប បញ្ជាក់ថា៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃរបស់អាជ្ញាធរខេត្តសៀមរាប នៅថ្ងៃចន្ទ ទី២៧ ខែមេសា ឆ្នាំ២០២០នេះ នៅតែទៅបន្តរង់ចាំទទួលប្រជាពលរដ្ឋខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃដដែល។ ថ្ងៃនេះទទួលបានចំនួនសរុប ២៨នាក់ ស្រីចំនួន ១៤នាក់ ដែលចូលមកតាមច្រកដូង ខេត្តបាត់ដំបង, តាមច្រកប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យ ។

គិតចាប់ពីថ្ងៃទី១០ ខែមីនា មកដល់ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០នេះ តួលេខសរុបដែលបានទទួលប្រជាពលរដ្ឋខ្មែរ ចូលតាមច្រកទាំងបីខាងលើមានចំនួន ១២,២៨៥នាក់ ស្រីចំនួន ៥,៣២៥នាក់ ក្នុងនោះបានពិនិត្យសុខភាពបឋមបានចំនួន១២,២៨៥នាក់ ស្រី ៥,៣២៥នាក់គឺពិនិត្យសុខភាពបានទាំងអស់ ៕*ដោយ៖សិលា*

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ០៥នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 27-04-2020

នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ០៥នាក់ ស្រី ០៣នាក់៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៩នាក់

https://www.facebook.com/GDIOfficial/ April 26 at 3:46 PM

នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៩នាក់ ស្រី ០៨នាក់៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១នាក់

https://www.facebook.com/GDIOfficial/ April 26 at 3:46 PM

នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១នាក់ ស្រី ០៤នាក់៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ០៩នាក់

https://www.facebook.com/GDIOfficial/ April 24 at 3:46 PM

នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ០៩នាក់ ស្រី ០៥នាក់៕

### "អាជ្ញាធរថៃឃាត់ខ្លួនពលករខ្មែរចំណាកស្រុកខុសច្បាប់ចំនួន ២៥នាក់"

https://www.facebook.com/labourkhmer/ ប្រាក់ ភក្ត្រា Prak Pheaktra 27-04-2020

នៅថ្ងៃច័ន្ទ ទី២៧ ខែមេសា ឆ្នាំ២០២០នេះ កម្លាំងសមត្ថកិច្ចទាហានការពារព្រំដែនថៃប្រចាំស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ ប្រទេសថៃ ធ្វើការឃាត់ខ្លួនពលករខ្មែរប្រុសស្រីចំនួន ២៥នាក់ខណៈពេលដែលពលករទាំងនោះបានឆ្លងដែនខុសច្បាប់ចូលមកស្វែងរកការងារធ្វើក្នុងប្រទេសថៃ ។ តាមការបញ្ជាក់របស់សមត្ថកិច្ចពលករទាំងអស់ត្រូវសមត្ថកិច្ចបញ្ជូនទៅកាន់អធិការដ្ឋានប៉ុស្ត៍ខ្លងឡឹក ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។ ភក្ត្រា ពលករខ្មែរ

### ពលករខ្មែរ១៤នាក់ក្នុងចំណោម១៧នាក់ត្រូវបានអាជ្ញាធរថៃដោះលែង ក្រោយបង់ប្រាក់ពិន័យ

http://ppd-news.net/ ថ្ងៃចេញផ្សាយ: April 28, 2020

**ភ្នំពេញ ៖** អាជ្ញាធរថៃបានសម្រេចដោះលែងពលករខ្មែរចំនួន១៤នាក់ ក្នុងចំណោម១៧នាក់ ដែលពាក់ព័ន្ធបទល្មើសនឹងបម្រាមរបស់រដ្ឋាភិបាលថៃ ក្រោយពេលពួកគេយល់ព្រមបង់ប្រាក់ពិន័យចំនួន ៤ម៉ឺនបាត ឬស្មើជាង ១២០០ដុល្លារ សម្រាប់មនុស្សម្នាក់។ នេះបើយោងតាមការដកស្រង់សំដីមន្ត្រីក្រសួងការបរទេសកម្ពុជាដែលថ្លែងប្រាប់សារព័ត៌មានក្នុងស្រុក។

សូមជម្រាបថា ពលករខ្មែរសរុប១៧នាក់ ត្រូវបានសមត្ថកិច្ចខេត្តផាធុមថានី ប្រទេសថៃ ចាប់ខ្លួនពាក់ព័ន្ធនឹងបញ្ហាល្មើសបម្រាមប្រទេសថៃ ដែលមិនអនុញ្ញាតឱ្យសេពគ្រឿងស្រវឹងអំឡុងបុណ្យចូលឆ្នាំថ្មី ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ១៩ ខណៈដែលពួកគេបាននាំគ្នាផឹកស៊ី ហើយហ៊ោកញ្ច្រៀវថតសំញែងតាម Facebook ថៃមទៀត។

យ៉ាងណាក៏ដោយ មន្ត្រីក្រសួងការបរទេសកម្ពុជាបានបញ្ជាក់ថា ទោះបីមានការដោះលែងពលករខ្មែរ១៤នាក់ នោះក៏ដោយក៏នៅសល់ពលករខ្មែរចំនួន៣នាក់ទៀតមិនត្រូវបានដោះលែងនោះទេ ដោយសារតែពួកគេមិនមានប្រាក់គ្រប់គ្រាន់ ដើម្បីបង់ឲ្យអាជ្ញាធរថៃ៕

### អាជ្ញាធរកូរ៉េដាក់វិធានការបន្ទាន់ថ្មីសម្រាប់ពលករ E9 វិលចូលប្រទេសកូរ៉េ

http://khmerinkorea.com/ April 27, 2020

នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ ឥឡូវនេះនៅប្រទេសកូរ៉េកំពុងធ្វើការយ៉ាងយកចិត្តដាក់ដើម្បីការពារពីជំងឺកូរ៉ូណា១៩នេះ។ យោងតាមស្ថានភាពបែបនេះចំពោះអ្នកដែលវិលចូលប្រទេសកូរ៉េទាំងអស់ ដែលកំពុងធ្វើការសហការយ៉ាងមុតមាំដើម្បីដាក់ខ្លួនឱ្យនៅដាច់ដោយឡែកក្នុងរយៈពេល២អាទិត្យនិងមិនអនុញ្ញាត្តិឱ្យត្រលប់ចូលក្នុងប្រទេសកូរ៉េចំពោះករណីដែលមិនអាចធ្វើការដាក់ខ្លួនឱ្យនៅដាច់ដោយឡែកបាន។ ដោយបែបនេះក្រសួងការងាររបស់សាធារណរដ្ឋកូរ៉េ សូមណែនាំឱ្យពិនិត្យសុខភាពមុនពេលត្រលប់ចូលក្នុងប្រទេសកូរ៉េទៅកាន់ពលករពលការនីដែលកាន់វីសាE9 របស់កម្ពុជាដែលមានឈ្មោះក្នុងបញ្ជីដែលកំពុងវិលត្រលប់ចូលមកប្រទេសកម្ពុជាក្នុងរយៈពេលបណ្តោះអាសន្នអំឡុងពេលវិស្សមកាល រឺរយៈពេលផ្លាស់ប្តូរកន្លែងធ្វើការនេះ។ ដូច្នេះហើយមុនពេលដែលពលករពលការនីត្រលប់ចូលក្នុងប្រទេសកូរ៉េ ពលករពលការនីកម្ពុជាដែលកំពុងវិលត្រលប់ចូលមកប្រទេសកម្ពុជាក្នុងរយៈពេលបណ្តោះអាសន្នអំឡុងពេលវិស្សមកាល រឺរយៈពេលផ្លាស់ប្តូរកន្លែងធ្វើការងារជាដើម។ល។ ត្រូវតែពិនិត្យមើលស្ថានភាពសុខភាពរបស់ខ្លួនមុនជាដាច់ខាតទើបអាចចាកចេញមកបាន។

លើសពីនេះទៀត! យើងសុំស្នើរឱ្យអ្នកទាំងអស់គ្នាយកចិត្តទុកដាក់ជាពិសេស ដើម្បីចៀសវាងពីគុណវិបត្តិនៃការបណ្តេញចេញពីប្រទេសកូរ៉េ ពីព្រោះអ្នកនឹងត្រូវដាក់ខ្លួនឱ្យនៅដាច់ដោយឡែកនៅកន្លែងមួយដែលមិនច្បាស់

លាស់បន្ទាប់ពីអ្នកបានចូលមកក្នុងប្រទេសកូរ៉េ។ នេះជាគោលនយោបាយបណ្ដោះអាសន្នរបស់រដ្ឋាភិបាលកូរ៉េ ដើម្បីទប់ស្កាត់ការរីករាលដាលនៃកូរ៉ូណា១៩។

០ផែនការដែលនឹងត្រូវអនុវត្តៈ ចាប់ពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០២០ សម្រាប់ពលករកម្ពុជាតាមរយៈប្រព័ន្ធអនុញ្ញាតិការងារដែលកំពុងវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ។

០ព័ត៌មានៈ ពលករកម្ពុជាដែលមានឈ្មោះក្នុងបញ្ជីនៃអ្នកវិលត្រឡប់ចូលប្រទេសកូរ៉េជាបណ្ដោះអាសន្ននៅពេលបច្ចុប្បន្ននេះ មុនពេលចាកចេញពីប្រទេសពលករពលការនីត្រូវតែពិគ្រោះយោបល់ជាមួយម្ចាស់អាជីវកម្មជាមុនសិន មុនពេលចូលប្រទេសកូរ៉េម្ដងទៀត ដើម្បីធានាទទួលបានកន្លែងសម្រាប់ដាក់ខ្លួនឯងដាច់ដោយ ឡែករយៈពេល២សប្ដាហ៍ ដែលត្រូវតែបំពេញតាមលក្ខខណ្ឌដូចខាងក្រោមនេះ

–អាសយដ្ឋានត្រូវតែច្បាស់លាស់និងត្រូវស្ថិតនៅដាច់ដោយឡែកខ្លួនឯងរយៈពេល ២ សប្ដាហ៍

–បន្ទាប់ពីចូលទៅក្នុងប្រទេសហើយ ត្រូវស្ថិតនៅដាច់ដោយឡែកតែឯងហើយបង់ថ្លៃស្នាក់នៅរយៈពេល២សប្ដាហ៍។

–ក្នុងអំឡុងពេលដាក់ដាច់ដោយឡែក អ្នកអាចតេរទូរស័ព្ទទាក់ទងទៅកាន់មន្ត្រីមូលដ្ឋានបានគ្រប់ពេល។

០ការប្រុងប្រយ័ត្ន

–អ្នកមិនអាចចូលទៅក្នុងប្រទេសកូរ៉េបានទេបើសិនជាអ្នកគ្មានកន្លែងសម្រាប់ដាក់ខ្លួនឯងដាច់ដោយឡែក។

–អ្នកមិនអាចកំណត់យកទីលំនៅរបស់មិត្តភក្តិរបស់អ្នក ជាទីលំនៅដាច់ដោយឡែកពីគេបានទេ

–កន្លែងសម្រាប់ដាក់ឱ្យនៅដាច់ដោយឡែកដូចជាទីសាធារណៈជាដើមគឺមិនអនុញ្ញាតបានទេ ហើយសណ្ឋាគារនិងកន្លែងស្នាក់នៅផ្សេងទៀត ក៏មិនអាចត្រូវបានកំណត់ថាជាកន្លែងដាច់ដោយឡែកពីគេបានផងដែរ។

–អ្នកអាចនឹងត្រូវបានគេដាក់ទោស ប្រសិនបើអ្នកចេញទៅក្រៅ ឬក៏គេមិនអាចទាក់ទងជាមួយអ្នកក្នុងអំឡុងពេលដាក់ដោយឡែកតែឯង។

០សូមសាកសួរព័ត៌មានលម្អិតតាមរយៈ

–អង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ (HRD-Korea): 023-997-822

–គណៈកម្មាធិការបណ្ដុះបណ្ដាល និងបញ្ជូនពលករទៅបរទេស (MTOSB): 023-6525-777

## មានពលករខ្មែរ៥នាក់បានជាប់ នៅព្រលានយន្តហោះអ៊ិនឆន់ដោយសារអាជ្ញាធររឹតបណ្ដឹងបង្កាជំងឺកូវីដ១៩

http://khmerinkorea.com/ April 27, 2020

នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០២០ នេះ ពលករខ្មែរបម្រើការងារនៅប្រទេសកូរ៉េចំនួន ៥នាក់ដែលទើបវិលត្រឡប់ពីស្រុកកំណើតត្រូវបានជាប់នៅព្រលានយន្តហោះ ដោយសារតែថៅកែរោងចក្រ ឬក្រុមហ៊ុនមិនទាន់អនុញ្ញាតឱ្យចូលធ្វើការ និងចូលស្នាក់នៅ ព្រោះចាំបាច់ត្រូវដាក់ឱ្យនៅដាច់ដោយឡែករយៈពេល១៤ថ្ងៃជាមុនសិនទើបអាចចូលធ្វើការធម្មតាវិញបាន។ ពលករខ្មែរទាំង៥នាក់ មានកន្លែងធ្វើការ នៅតំបន់អានសាន ជីនជូ ហ្វាសង និងម៉ាសាន។ ក្រោយមានការសម្របសម្រួលពីក្រុមការងារស្ថានទូត ជាមួយមជ្ឈមណ្ឌលគាំពារ និងអាជ្ញាធរ ពលករខ្មែរទាំង៥នាក់ ត្រូវបានសមត្ថកិច្ចនៅព្រលានយន្តអនុញ្ញាតឱ្យចេញពីព្រលានយន្តហោះ តែតម្រូវឱ្យស្នាក់នៅដាច់ដោយឡែកពីគេរយៈពេល ១៤ថ្ងៃ ទើបអនុញ្ញាតឱ្យចូលរោងចក្រ កសិដ្ឋាន ឡើងវិញ។ គួរបញ្ជាក់ផងដែរថាសម្រាប់ពលករដែលពុំមានកន្លែងស្នាក់នៅជាក់លាក់ ត្រូវអាជ្ញាធរកូរ៉េយកទៅស្នាក់នៅមណ្ឌលត្រួតពិនិត្យនៅតាមបណ្ដាក្រុងនានា ហើយរាល់ការចំណាយផ្សេងៗជាបន្ទុករបស់សាមីខ្លួន។

កាលពីពេលកន្លងទៅ មុនពេលពិធីបុណ្យចូលឆ្នាំថ្មីចូលមកដល់ ក្រុមការងារស្ថានទូត និងឯកអគ្គរាជទូត ក៏ធ្លាប់បានអំពាវនាវដល់សហគមន៍ខ្មែរនៅប្រទេសកូរ៉េសូមកុំធ្វើដំណើរចេញក្រៅប្រទេស បើមិនមានការចាំបាច់បំផុតនោះទេ ដោយសារតែចង់រក្សាសុខសុវត្ថិភាព និងបង្ការការពារការរីករាលដាលមេរោគកូរ៉ូណា។ តែយើងនៅសង្កេតឃើញពលករ និងស្ត្រីដែលមានក្រុមគ្រួសារកូរ៉េ មួយចំនួននៅតែធ្វើដំណើរទៅស្រុកកំណើតក្នុងអំឡុងពេលបុណ្យចូលឆ្នាំថ្មី បើទោះដឹងថាពេលទៅនឹងត្រូវអាជ្ញាធរ តម្រូវដាក់ឱ្យនៅដាច់ដោយឡែកពីគេរយៈពេល ១៤ថ្ងៃក៏ដោយក្តី។ អត្ថបទ៖ករីថ្មគោល

## ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០

## ក្រសួងមហាផ្ទៃ អំពាវនាវភាគីពាក់ព័ន្ធ ទប់ស្កាត់ឲ្យបាន ពលករខ្មែរ ចង់វិលទៅថៃវិញ ខណៈមានមេខ្យល់ញុះញង់

https://dap-news.com/national/ ByKD102 Posted on April 29, 2020

ភ្នំពេញ៖ លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានធ្វើការអំពាវនាវដល់អាជ្ញាធរ និងភាគីពាក់ព័ន្ធ ទាំងអស់រួមគ្នាទប់ស្កាត់ ឲ្យបានចំពោះពលករខ្មែរ ដែលចង់វិលត្រឡប់ទៅកាន់ ប្រទេសថៃវិញ ខណៈមានមេខ្យល់កំពុងដើរ ឃោសនាឲ្យពួកគេវិលវិញ ។ ចំពោះករណីនេះ ត្រូវបានលោកស្រីអះអាងថា អាច នឹងធ្វើឲ្យពួកគេជួបហានិភ័យ ខ្ពស់ចំពោះការបញ្ហា មេរោគ កូវីដ-១៩។

យោងតាមសេចក្តីជូនដំណឹងរបស់ ស្ថានទូតកម្ពុជា ប្រចាំនៅថៃ កាលពីថ្ងៃទី១៨ មេសា បានឲ្យដឹងថា ក្នុងស្ថានភាពនៃការរាលដាលនៃជំងឺ កូវីដ-១៩ រាជរដ្ឋាភិបាលថៃ បានប្រកាសបន្តដាក់ប្រទេស ក្នុងគ្រាមានអាសន្ន រយៈពេល ១ខែទៀត ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០។

ក្នុងកិច្ចប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងអង្គការសហប្រជាជាតិ ទាក់ទងជនទេសន្តប្រវេសន៍ ស្តីពីកិច្ចសហការឆ្លើយតបវិបត្តិកូវីដ១៩ ក្នុងចំណោម ពលករចំណាកស្រុក និងសហគមន៍ នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ លោកស្រី ជូ ប៊ុនអេង បានលើកឡើងថា រហូតមកដល់ពេលនេះ ពលករខ្មែរ ដែលបានវិលត្រឡប់មកពីថៃវិញមានជិត ៩ម៉ឺននាក់ ដោយសារពួកគាត់មិនមានការងារធ្វើ និងខ្លះទៀតបានមកដោយសារ ចូលឆ្នាំខ្មែរប្រពៃណីជាតិ នាពេលកន្លងទៅ ។ ដូច្នេះអ្វីដែលសំខាន់សម្រាប់ពួកគាត់ ត្រូវ រួមគ្នាទប់ស្កាត់កុំឲ្យ ប្រញាប់ទៅវិញ ដោយសារតែ ប្រទេសដែលទៅនោះកំពុងផ្ទុះ ឡើងជាបន្តបន្ទាប់នូវមេរោគ កូវីដ-១៩។

លោកស្រីមានប្រសាសន៍ថា «សព្វថ្ងៃនេះមានជនខិលខូច ដែលហៅថាមេខ្យល់បាន ដើរ បំផុសបំផុលឬក៏ឃោសនាឲ្យពួកគាត់ (ពលករ) ឲ្យវិលត្រឡប់ទៅប្រទេសថៃវិញ ដោយប្រាប់ពួកគាត់ថា សំបូរការងារវិញ និងមានចេតនាចង់យកថ្លៃពីពួកគាត់ ដោយលួចដឹកតាមច្រកនានា ដែលមិនមែនជាច្រកអន្តរជាតិ និងផ្លូវការនោះ ។ ដូច្នេះយើងទាំងអស់គ្នាត្រូវរួមគ្នាទប់ ស្កាត់ពួកគាត់ឲ្យបាន ដើម្បីការពារនៃការរីក រាលដាលនូវមេរោគកូវីដ១៩ ដល់ពួកគាត់ក៏ដូចជា តាមសហគមន៍នានានោះ»។ លោកស្រីបន្តថា ពលករដែលបានវិលត្រឡប់មកពីថៃវិញ ភាគច្រើនកំពុងប្រឈមបញ្ហាសុខភាព និងជីវភាពរយៈពេលវែង តែយ៉ាងណាក៏ រាជរដ្ឋាភិបាល បានសហការជាមួយអាជ្ញាធរមូលដ្ឋាន ស្រង់ស្ថិតិដើម្បីស្វែងរក អ្នកក្រីក្រពិតប្រាកដសម្រាប់ជួយ និងទប់ស្កាត់កុំឲ្យប្រញាប់វិលត្រឡប់ ទៅកាន់ប្រទេសគោលដៅ ជាពិសេសថៃតែម្តង។

លោកស្រីបន្ថែមថា«ពេលនេះពួកគាត់កំពុងប្រឈម នឹងមិនធ្វើអ្វីទាំងអស់ ដោយសារតែពួកគាត់ទន្ទឹង រង់ចាំទៅប្រទេសគោលដៅ ឬប្រទេសថៃវិញ ដោយតាម រយៈមេ ខ្យល់ថាមានការងារធ្វើឡើងវិញនោះ។ ប៉ុន្តែស្ថានភាពវាអាចនឹងអូសបន្លាយវែង មកពីបញ្ហាមេរោគកូវីដ១៩ ដូច្នេះពួកយើងទាំងអស់គ្នា ស្ថាប័នពាក់ព័ន្ធ អង្គការជាដៃគូ

ត្រូវរកដំណោះស្រាយជូនពួកគាត់ ឲ្យបានទាន់ពេលវេលា ដោះស្រាយទាំងសុខភាព និងជីវភាពជូនពួកគាត់»។ បើតាមរដ្ឋលេខាធិការក្រសួងមហាផ្ទៃ បច្ចុប្បន្នពលរដ្ឋខ្មែរដែលកំពុង ធ្វើការនៅថៃមានជាង ១លាននាក់ ហើយចាប់តាំងពីចុងខែមិនា មករហូតដល់សព្វ ថ្ងៃបានវិលមកកម្ពុជាវិញ ជាបន្តបន្ទាប់ប្រហែលជាង ៨ម៉ឺននាក់។ យ៉ាងណាក៏ដោយ ចាប់ពីពេលនេះតទៅអាជ្ញាធរ និងអ្នកពាក់ព័ន្ធទាំងអស់មិនត្រូវ អនុញ្ញាតឲ្យពួកគាត់ វិលត្រឡប់ទៅវិញនោះទេ ដើម្បីបង្ការ និងទប់ស្កាត់ការរីករាលដាលនូវ មេរោគកូវីដ១៩។

សូមរំលឹកថា រហូតដល់ពេលនេះ ក្រសួងសុខាភិបាលកម្ពុជា បានអ្នកសះស្បើយពីជំងឺ កូវីដ-១៩ ចំនួន ១១៩នាក់ ចំណែកអ្នកកំពុងសម្រាកព្យាបាល នៅសល់តែ៣នាក់ប៉ុណ្ណោះ ខណៈអ្នកឆ្លងសរុប មានចំនួន ១២២ នាក់ ៕ ដោយៈ អេង ប៊ូធេង

## អ្នកនាំពាក្យសង្គមកិច្ចៈ មានអ្នកស៊ីកម្លាំងញើសឈាម លើជនពិការ និងអ្នកសុំទាន

https://thmeythmey.com/ 28, Apr 2020 ,  2:35 pm ដោយ: ជឿន បញ្ញាឬទ្ធិ

ភ្នំពេញ៖ ជនពិការ និងអ្នកសុំទានមួយចំនួនធំ ត្រូវបានជនទុច្ចរិត កេងប្រវ័ញ្ចកម្លាំងញើសឈាម តាមរយៈការប្រើពួកគេ ឱ្យដើរសុំប្រាក់ពីមហាជននៅតាមដងផ្លូវ។ នេះជាការបញ្ជាក់របស់លោក តូច ចាន់នី អ្នកនាំពាក្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា នៅក្នុងសន្និសីទកាសែតនាព្រឹកថ្ងៃទី២៨ មេសា។ លោក តូច ចាន់នី ដែលធ្លាប់ជួបករណីនេះផ្ទាល់បាននិយាយថា មានជនទុច្ចរិតខ្លះ ជិះសុទ្ធតែរថយន្តទំនើប បានប្រើមនុស្សចាស់ និងកុមារ ជាពិសេសជនពិការ ឱ្យច្រៀង ឬដើរសុំទានគេតាមដងផ្លូវ ជាថ្នូរនឹងអាហារ និងថវិកាខ្លះ ក្រោយចប់ភារកិច្ចសុំទាននេះ។ បើតាមលោក តូច ចាន់នី ក្រសួងកំពុងតាមដានករណីនេះ។

ឆ្លើយតបនឹងករណីអ្នកសុំទាន និងជនអនាថា នៅតាមដងផ្លូវនេះ លោក តូច ចាន់នី បានបកស្រាយថា ពួកគេទាំងនោះ មិនព្រមចូលរួមសហការជាមួយអាជ្ញាធរនោះទេ បើទោះជាក្រសួងព្យាយាមដោះស្រាយបញ្ហាពួកគេតាមរយៈរៀបចំកន្លែងឱ្យស្នាក់នៅក្តី។ បានន័យថា ពួកគេសុខចិត្តបន្តការដើរសុំទាន ។ ត្រង់ចំណុចនេះ អ្នកនាំពាក្យក្រសួងសង្គមកិច្ច ក៏បង្ហាញទស្សនផ្ទាល់ខ្លួនថា បើចង់លុបបំបាត់ជនអនាថា និងអ្នកសុំទាននោះ លុះត្រាតែមហាជន បញ្ឈប់សកម្មភាពឱ្យលុយទៅពួកគេ ព្រោះពួកគេទាំងនោះ ភាគច្រើនយករបរសុំទានធ្វើជាអាជីព ដែលនាំឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។

កាលពីខែតុលា ឆ្នាំ២០១៧ សមត្ថកិច្ច បានចាប់ខ្លួនមន្ត្រីជាប់កិច្ចសន្យា នៃមន្ទីរសង្គមកិច្ច និងបក្ខពួកសរុប ៣នាក់ ពាក់ព័ន្ធករណីកេងប្រវ័ញ្ចពលកម្ម កុមារ មនុស្សចាស់ជរា និងញុះញង់អនីតិជន ឲ្យដើរសុំទានគេតាមផ្លូវផងដែរ។ ពួកគេទាំង៣នាក់នោះ កំពុងស្ថិតនៅក្នុងពន្ធនាគារ។ នេះបើតាមលោក តូច ចាន់នី អ្នកនាំពាក្យក្រសួងសង្គមកិច្ច៕

## ក្រសួងការងារប្រាប់ពលករខ្មែរនៅក្រៅប្រទេសកុំអាលមកកម្ពុជាក្នុងពេលនេះ ព្រោះខ្លាចគេលុបទិដ្ឋាការចោល

http://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ: 28/04/2020 - 09:45 ដោយៈវណ្ណ សុគន្ធា

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅថ្ងៃអង្គារនេះបានអំពាវនាវដល់ពលករខ្មែរដែលកំពុងស្នាក់នៅ និងធ្វើការនៅកូរ៉េខាងត្បូង និង ប្រទេសផ្សេងទៀតកុំអាលមកលេងកម្ពុជាក្នុងពេលនេះ ព្រោះខ្លាចគេលុបទិដ្ឋាកាចោល។ ម្យ៉ាងវិញទៀត បើមក ក៏ត្រូវដាក់ដោយឡែករយៈពេល១៤ថ្ងៃសិនដែរ។ ការអំពាវនាវនេះ ធ្វើឡើងបន្ទាប់ពីរដ្ឋាភិបាលកម្ពុជាបានសម្រេចអនុញ្ញាតឱ្យពលរដ្ឋខ្មែរ២២២នាក់នៅម៉ាឡេស៊ីវិលត្រឡប់មកស្រុកវិញ តែតម្រូវឱ្យធ្វើតេស្តរកជំងឺកូវីដ១៩ជាមុនសិន។ «បើមកត្រូវដាក់ដោយឡែក១៤ថ្ងៃ ពេលទៅវិញគេឃាត់ ១៤ថ្ងៃ ហើយអាចគេលុបទិដ្ឋាការចោលទៀត អត់ធ្ងត់សិនទៅបងប្អូន!» នេះ គឺជាការលើកឡើងរបស់លោក

ហេង សួរ អ្នកនាំពាក្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនៅលើទំព័រហ្វេសប៊ុករបស់លោកនៅព្រឹកថ្ងៃអង្គារនេះ។ លោកហេង សួរ បានបន្តប្រាប់ពលករខ្មែរនៅកូរ៉េខាងត្បូង និង ប្រទេសផ្សេងទៀតថា ដំណាក់កាលការរីករាលដាលនៃជំងឺកូវីដ-១៩នេះ ត្រូវប្រយ័ត្នប្រយ៉ែង ហើយខំថែរក្សាការងារដែលមានក្នុងដៃឱ្យគង់។ នេះក៏ព្រោះថា ក្នុងដំណាក់កាលនេះ និយោជកខ្លះមានការលំបាក ហើយចង់តែកាត់បុគ្គលិកចោលទេ ។ ដូច្នេះហើយលោកហេង សួរ ដាស់តឿនដល់ពលករខ្មែរកុំផ្តល់លេសស្របច្បាប់ឱ្យទៅនិយោជក ហើយថា អនាគត គឺស្ថិតលើការសម្រេចចិត្តខ្លួនឯង បើសម្រេចចិត្តខុស កុំបន្ទោសគេ។

ពលករខ្មែរប្រមាណជាង៤ម៉ឺន៨ពាន់នាក់កំពុងស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសកូរ៉េខាងត្បូង ប៉ុន្តែមិនមានពលករខ្មែរណាម្នាក់បានឆ្លងជំងឺកូវីដ-១៩នោះទេ។ ក្នុងអំឡុងបុណ្យឆ្នាំខ្មែរកន្លងទៅនេះ មានពលករប្រមាណពី៣ទៅ៥%បានធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ហើយពេលទៅវិញត្រូវដាក់ដោយឡែករយៈពេល ១៤ថ្ងៃ។ នេះបើតាមការបញ្ជាក់ឱ្យដឹងរបស់លោកឡុង ឌីម៉ង់ ឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសកូរ៉េខាងត្បូង។ លោកបានគូសបញ្ជាក់ទៀតថា ក្នុងចំណោមពលករទាំងនេះ មានពលករខ្មែរពីរទៅបីករណីដែរដែលត្រូវបានបញ្ឈប់ពីការងារ។

ក៏ដូចក្រសួងការងារដែរ លោកឡុង ឌីម៉ង់បានអំពាវនាវដល់ពលករខ្មែរទាំងអស់កុំអាលធ្វើដំណើរមកប្រទេសកម្ពុជា ឬ ទៅកន្លែងណាផ្សេង ព្រោះមានបញ្ហាប្រឈមខ្លាំងណាស់។ ប្រឈមទី១ គឺអាចឆ្លងជំងឺកូវីដ-១៩ ទី២ នៅពេលត្រឡប់ទៅកូរ៉េខាងត្បូងវិញ នឹងត្រូវស្នាក់នៅដោយឡែកពីគេដោយត្រូវជួលកន្លែងស្នាក់នៅដោយខ្លួនឯង។ ជាងនេះទៅទៀត បើសិនពលករនៅចង់មកស្រុកខ្មែរមិនស្តាប់ការហាមឃាត់របស់ថៅកែរបស់ខ្លួន នោះពួកគេប្រឈមនឹងការបណ្តេញចេញពីការងារដែលនឹងធ្វើឱ្យពួកគេក្លាយជាពលករមិនស្របច្បាប់នៅក្នុងប្រទេសកូរ៉េខាងត្បូង។

សូមបញ្ជាក់ថា ស្របពេលដែលក្រសួងការងារអំពាវនាវបែបនេះ រដ្ឋាភិបាលកម្ពុជាកាលពីថ្ងៃចន្ទបានសម្រេចអនុញ្ញាតឱ្យអ្នកនេសាទ និងអ្នកទោសជនជាតិខ្មែរចំនួន២២២នាក់នៅម៉ាឡេស៊ីវិលត្រឡប់មកប្រទេសកម្ពុជាវិញ។ ប៉ុន្តែ ពួកគេត្រូវទៅធ្វើតេស្តរកជំងឺកូវីដ-១៩នៅម៉ាឡេស៊ីជាមុនសិន។ ម្យ៉ាងវិញទៀត ពេលពួកគេមកដល់ប្រទេសកម្ពុជា គឺនឹងត្រូវដាក់ឱ្យនៅដាច់ដោយឡែករយៈពេល១៤ថ្ងៃ ដើម្បីតាមដានសុខភាព និង ធ្វើតេស្តរកជំងឺកូវីដ-១៩៕

## ពលករខ្មែរនៅកូរ៉េ ប្រឈមការលុបទិដ្ឋាការបើត្រឡប់មកកម្ពុជាក្នុងពេលមានវិបត្តិកូវីដ១៩

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 28 April, 2020

ភ្នំពេញ ៖ លោក ហេង សួរ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានថ្លែងដោយទទូចស្នើឲ្យពលករខ្មែរដែលកំពុងធ្វើការនៅសាធារណរដ្ឋកូរ៉េ កុំទាន់ មកលេងស្រុកកំណើតនាពេលនេះ ព្រោះអាចប្រឈមនឹងការចោលលុបទិដ្ឋាការ ខណៈកម្ពុជា ក៏ដូចជាកូរ៉េ កំពុងអនុវត្តវិធានការតឹងរ៉ឹងក្នុងអំឡុងពេលកើតមាន កូវីដ-១៩។ លោករដ្ឋលេខាធិការ ហេង សួរ បានអះអាងថា បើបងប្អូនត្រឡបើមកនាពេលនេះ នឹងត្រូវដាក់ឲ្យនៅដោយឡែក ១៤ថ្ងៃ ហើយពេលត្រឡប់ទៅប្រទេសកូរ៉េវិញ គេនឹងឃាត់ទុកឲ្យនៅដោយឡែករយៈពេល ១៤ថ្ងៃដូចគ្នាបន្ថែមទៀត ហើយអាចត្រូវគេលុបចោលទិដ្ឋាការទៀតផង។

ការអំពាវនាវនេះ បានធ្វើឡើងនៅបន្ទាប់ពីមានពលករខ្មែរធ្វើការងារនៅប្រទេសកូរ៉េចំនួន ៥នាក់ ដែលទើបមកលេងស្រុកកំណើតក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ ហើយត្រឡប់ទៅវិញកាលពីថ្ងៃទី ២៧ ខែមេសា កន្លងទៅ ត្រូវបានជាប់គាំងនៅព្រលានយន្តហោះនៅប្រទេសកូរ៉េ ដោយសារតែថៅកែរោងចក្រមិនទាន់អនុញ្ញាតឱ្យចូលធ្វើការវិញ ហើយតម្រូវឲ្យដាក់ដាច់ដោយឡែករយៈពេល ១៤ថ្ងៃជាមុនសិន។ បើតាមលោក ហេង សួរ អ្នកនាំពាក្យក្រសួង

ការងារ បានលើកឡើងនៅក្នុងសន្និសីទសារព័ត៌មានដែលរៀបចំដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលកាលពីថ្ងៃម្សិលមិញ បង្ហាញថា មកដល់ពេលនេះ មានពលករខ្មែរដែលកំពុងធ្វើការងារក្រៅប្រទេសជាង ១លាននាក់ ហើយពុំមានអ្នកណាម្នាក់ឆ្លងជំងឺកូវីដ ១៩ នោះទេ ដោយឡែក ពលរដ្ឋកម្ពុជាដែលកំពុងរស់នៅ និងធ្វើការងារនៅប្រទេសកូរ៉េ មានប្រមាណ ៦ម៉ឺននាក់។

សូមជម្រាបថា ស្ថានទូតកម្ពុជាប្រចាំប្រទេសកូរ៉េ កាលពីព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ នេះ បានជូនដំណឹងថ្មីមួយដល់បងប្អូនពលករខ្មែរ ដែលកំពុងស្នាក់នៅប្រទេសកូរ៉េថា ដោយសារតែបញ្ហាការឆ្លងវីរុសកូរ៉ូណា (COVID-19) ក្រសួងការងារនៃសាធារណរដ្ឋកូរ៉េ បានចេញច្បាប់ថ្មី សម្រាប់ពលករគំរូ អាចពន្យារសុពលភាពបន្តស្នាក់ នៅកូរ៉េបានរហូតដល់៥០ថ្ងៃ ពីមុនបានតែជនជាតិថៃ, ចិន, និងវៀតណាមតែប៉ុណ្ណោះ ឥឡូវគឺអាចពន្យាបានទាំង១៦ប្រទេស ដែលបញ្ជូនពលករ មកបម្រើការងារនៅកូរ៉េ រួមទាំងប្រទេសកម្ពុជាផងដែរ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣៤នាក់

https://www.facebook.com/GDIOfficial/ April 28 2020

នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣៤នាក់ ស្រី ១៨នាក់៕

## ប្រធានមន្ទីរសុខាភិបាល ស្នើសុំអាជ្ញាធរមូលដ្ឋាន ចុះពន្យល់ពីការធ្វើចត្តាឡីស័ក ដល់ពលរដ្ឋ កុំផ្ដោតតែលើពលករ

https://www.cen.com.kh/ April 29, 2020

បាត់ដំបង ៖ លោកឱសថបណ្ឌិត រឿង ប៊ុនរេត ប្រធានមន្ទីរសុខាភិបាលខេត្តបាត់ដំបង បានស្នើសុំអាជ្ញាធរមូលដ្ឋាន ពេលចុះពន្យល់ពីការធ្វើចត្តាឡីស័ក ឬការដាក់ខ្លួនឲ្យនៅដាច់ដោយឡែក ចំនួនរយៈពេល១៤ថ្ងៃ ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ១៩ ដល់ប្រជាពលរដ្ឋ កុំផ្ដោតលើតែពលករមកពីក្រៅប្រទេស ត្រូវធ្វើឲ្យទូលំទូលាយក្នុងសហគមន៍ ពន្យល់ឲ្យបានច្បាស់លាស់ ដើម្បីឲ្យពួកគាត់អនុវត្តត្រូវតាមការណែនាំរបស់ក្រសួងសុខាភិបាល។ ការលើកឡើងបែបនេះ ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលតម្រង់ទិសស្តីពី ហានិភ័យនៃការប្រាស្រ័យទាក់ទង និងការចូលរួមរបស់សហគមន៍ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ នៅស្រុករុក្ខគិរី កាលពីរសៀលថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០។

លោក រឿង ប៊ុនរេត បានលើកឡើងថា ការយល់ដឹងពីការធ្វើចត្តាឡីស័ក ឬសេចក្តីណែនាំផ្សេងៗ របស់ក្រសួងសុខាភិបាល មិនតម្រូវសម្រាប់តែពលករនោះទេ គឺពលរដ្ឋនៅក្នុងសហគមន៍ក៏ត្រូវតែយល់ដឹងគ្រប់គ្នា ដើម្បីពួកគាត់ងាយស្រួលក្នុងការអនុវត្តន៍វិធានការទប់ស្កាត់ នៃការរីករាលដាលជំងឺកូវីដ១៩នេះ ។

គួរបញ្ជាក់ផងដែរថា បើគិតត្រឹមថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ ពលរដ្ឋ និងពលករនៅក្នុងខេត្តបាត់ដំបង បានវិលត្រឡប់មកពីប្រទេសនានា ក្នុងអំឡុងការរីករាលដាលខ្លាំងជំងឺកូវីដ១៩ មានចំនួន ១៦.២៥៤នាក់ ហើយ

ពលករខេត្តបាត់ដំបង បានឆ្លងដែនពីថៃ មកនៅថ្ងៃទី២៨ ខែមេសានេះ មានចំនួន ៤២នាក់ ស្រី ១៥នាក់ និងពលករ ដែលមានទីលំនៅតាមបណ្តារាជធានី/ខេត្ត ចូលមកវិញតាមច្រកទ្វារព្រំដែន ក្នុងខេត្តបាត់ដំបង មានចំនួន ៦៨នាក់ ស្រី ៣៣នាក់ ៕ដោយ ៖ អ៊ុងសារុំ

### ឃាត់ខ្លួនពលករខ្មែរចំណាកស្រុកខុសច្បាប់ចូលមកស្វែងរកការងារធ្វើក្នុងថ្ងៃប្រទេសថៃ

https://www.facebook.com/prakpheaktraofficial/ ប្រាក់ ភក្រ្តា Prak Pheaktra 28-04-2020

នៅថ្ងៃអង្គារ ទី២៨ ខែមេសា ឆ្នាំ២០២០ នេះកម្លាំងសមត្ថកិច្ចតម្រួតខ្លងឡឹក ស្រុកអារញ្ញយ៉ាប្រាថេត ខេត្តស្រះកែវ ប្រទេសថៃ ឃាត់ខ្លួនបុរសពលករខ្មែរ ០២នាក់ បានចំណាកស្រុកខុសច្បាប់ចូលប្រទេសថៃ ដើម្បីស្វែងរកការងារធ្វើ ទាំងស្ថានភាពប្រទេសថៃកំពុងស្ថិតក្នុងគ្រាអាសន្នដោយសារជំងឺកូវីដ១៩ ។ បច្ចុប្បន្នពលករខ្មែរទាំងពីរនាក់ត្រូវសមត្ថកិច្ចថៃបញ្ជូនទៅកាន់អធិការដ្ឋានប៉ុស្តិ៍ខ្លងឡឹកដើម្បីចាត់វិធានការទៅតាមផ្លូវច្បាប់។ ភក្រ្តា ពលករខ្មែរ

## ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០

### ពលករប្រុសស្រីចាស់ក្មេង៤៦នាក់ចាញ់បោកមេខ្យល់យកទៅបោះបង់ចោលកណ្តាលព្រៃ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 29/04/2020

ខេត្តបន្ទាយមានជ័យ ៖ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ ម៉ោង៥,១៥នាទី ច្រករបៀង ស្ថិតក្នុង ភូមិបឹងបេង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ មានពលករខ្មែរប្រុសនិងស្រីចំនួន៤៦នាក់ត្រូវបានយោធាឈុតខ្មៅថៃ នៅប៉ុស្តិ៍០៤ ចាប់បាន ក្នុងពេលដែលមេខ្យល់ នាំចូលពួកគេ ចូលក្នុងទឹកដីថៃ ដោយខុសច្បាប់ តាមច្រករបៀងចំណុចកែងអូរល្ហាជាប់ប្រទល់ស្រុកសំពៅលូន។

បើតាមការឲ្យដឹងពីពលករខ្មែរទាំង៤៦នាក់ថា ពួកគាត់បានបង់លុយអោយមេខ្យល់ក្នុង១នាក់២៥០០បាទជាថ្លៃឈ្នួលនាំចូលទៅបាងកក ប្រទេសថៃ ដែលទន្ទឹមនិងប្រទេសថៃមានការរឹតបណ្តឹងនៅមេរោគកូវីដ១៩ផងនោះក្រោយពីមេខ្យលប្រមូលលុយហើយក៏ដាក់មេផាយទុកពលករខ្មែរដាច់បាយក្នុងថៃតែម្តង។ បច្ចុប្បន្នពលករប្រុសស្រីខ្មែរទាំង៤៦នាក់ត្រូវបានទាហានឈុតខ្មៅថៃរៀបចំឯកសារបញ្ជូនឲ្យអាជ្ញាធរខ្មែរ ដើម្បីយកមកប្រទេសកម្ពុជាវិញ។ ហើយក៏សង្ឃឹមថា បងប្អូនពលករខ្មែរទាំងអស់ឈប់ចាញ់បោកមេខ្យល់បន្តទៀតទៅព្រោះថាបច្ចុប្បន្នប្រទេសថៃនាទីក្រុងបាងកកនិងកំពុងតែមានការរឹតបន្តឹងផ្នែកការរីករាលដាលនៅមេរោគកូវីដ១៩៕

### ពលករចាញ់បោកមេខ្យល់ ទៅប្រទេសថៃ ៣៤នាក់ ត្រូវបានកងទ័ពនៅព្រំដែន ជួយសង្គ្រោះ និងបញ្ជូនមកស្នាក់នៅមណ្ឌលចត្តាឡីស័ក ស្រុកស្វាយចេក

https://khmerpress.news/ 29-04-2020

(បន្ទាយមានជ័យ)៖ ក្រោយពីបានទទួលបទបញ្ជារបស់ លោកឧត្តមសេនីយ៍ឯក ឯក សំអូន មេបញ្ជាការរង កងទ័ពជើងគោក មេបញ្ជាការ យោធភូមិភាគទី៥ នាយប់ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ លោកឧត្តមសេនីយ៍ទោ ឈុន ម៉ៅ មេបញ្ជាការទិសទី១ បន្ទាយមានជ័យ បានដឹកនាំកម្លាំងយោធា ចុះទប់ស្កាត់ និងជួយសង្គ្រោះប្រជាពលរដ្ឋ ដែលចាញ់បោកមេខ្យល់ នាំចេញទៅធ្វើការនៅប្រទេសថៃ បានទាន់ពេលវេលា ហើយក៏បានបញ្ជូន ពលរដ្ឋទាំងនោះទៅស្នាក់នៅមណ្ឌលចត្តាឡីស័ក ស្រុកស្វាយចេក។

ប្រជាពលរដ្ឋដែលចាញ់បោកមេខ្យល់ បានឲ្យដឹងថា មេខ្យល់បានជានានាំពួកគាត់ ឆ្លងដែនទៅប្រទេសថៃ ដោយយកម្នាក់ៗ ចំនួន២៥០០បាត តែមកដល់ចំណុច ខាងលើភាគីថៃបានបិទព្រំដែន មិនឲ្យចូលស្របពេលដែលប្រទះឃើញកម្លាំងយើង ឈរជើងតាមបន្ទាត់ព្រំដែនផងនោះ មេខ្យល់ក៏បានគេចខ្លួនបាត់។ ប្រជាពលករ ដែលចាញ់បោកមេខ្យល់ ទាំង៣៤នាក់នោះ រស់នៅក្នុងខេត្តបន្ទាយមានជ័យ ចំនួន១១នាក់, ខេត្តបាត់ដំបង ចំនួន៤នាក់

, ខេត្តពោធិ៍សាត់ ចំនួន១០នាក់, ខេត្តព្រៃវែង ចំនួន៣នាក់, ខេត្តកំពង់ចាម ចំនួន២នាក់, ខេត្តកំពត ចំនួន៤នាក់។ សូមបញ្ជាក់ថា ថៃបានបន្តដាក់ប្រទេស ក្នុងភាពអាសន្ន១ខែបន្តទៀត ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០២០។ ផ្តល់សិទ្ធដោយ៖ Freshnews

## អាជ្ញាធរបញ្ជាឱ្យចាប់បន្ទាប់ពីមេខ្យល់បោកពលករជិត៥០នាក់ដាច់បាយក្រហាយទឹកក្នុងព្រៃ

http://www.rasmeinews.com/ April 30, 2020, 6:31 AM

ដោយ៖ប.ជ័យ/បន្ទាយមានជ័យ៖ មន្ត្រីអាជ្ញាធរនិងសមត្ថកិច្ចបញ្ជាឱ្យបង្ក្រាបបន្ទាប់ពីមេខ្យល់បោកពលករចម្រុះជិត៥០នាក់ដាច់បាយក្រហាយទឹកក្នុងព្រៃ។លោកអ៊ុំរាត្រីអភិបាលខេត្តបន្ទាយមានជ័យនិងលោកង៉ោម៉េងជ្រួនអភិបាលរងខេត្តបានពិគ្រោះគ្នាហើយដាក់បញ្ជាកាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ ។ លោកឱ្យសមត្ថកិច្ចកងកម្លាំងស្រាវជ្រាវតាមបង្ក្រាបមេខ្យល់ ដែលបោកប្រាស់លើពលករខ្មែរចំនួ៤៦នាក់ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០២០ ម៉ោង៥ និង,១៥នាទី ច្រករបៀងនៃព្រំដែនស្ថិតក្នុងភូមិបឹងបេង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

សូមរំលឹកថា មានពលករខ្មែរប្រុសស្រីចាស់ក្មេងចំនួន៤៦នាក់ ត្រូវបានទាហានឈុតខ្មៅថៃនៅប៉ុស្តិ៍០៤ទល់មុខឃុំបឹងបេងចាប់បានហើយបញ្ជូនមកកម្ពុជាវិញ។ពលករទាំងនោះជួបការលំបាកជីវភាពហើអន្ទះសារចង់វិលទៅរកការងារធ្វើនៅប្រទេសថៃ។ បើទោះជាប្រទេសបន្តបិទប្រទេសហើយបិទចោលការងាររាប់លានកន្លែងក្នុងបំណងទប់ស្កាត់និងប្រយុទ្ធនឹងជំងឺកូវីត១៩ ទៅហើយនោះ ។ ហេតុនេះពលករទាំងនោះត្រូវចាញ់បោកមេខ្យល់ដែលអះអាងថា នឹងនាំចូលពួកគេចូលក្នុងទឹកដីថៃតាមច្រករបៀងចំណុចកែងអូរល្មាក្នុងភូមិសាស្ត្រឃុំបឹងបេងស្រុកម៉ាឡៃខេត្តបន្ទាយមានជ័យជាប់ព្រំប្រទល់នឹងឃុំជ្រៃសីមាសជស្រុកស្រុកសំពៅលូនខេត្តបាត់ដំបងកាលពីថ្ងៃទី២៧ ខែមេសា ។ ក្នុងចំណោមពលករខ្មែរទាំង៤៦នាក់នោះពួកគេថាបានបង់លុយឱ្យមេខ្យល់ក្នុងម្នាក់២.៥០០បាតប្រាក់ថៃជាថ្នូរនឹងជាថ្លៃឈ្នួលនាំផ្លូវថ្លៃដឹកជញ្ជូន និងថ្លៃហូបចុកតាមផ្លូវក្នុងដំណើរផ្លូវវង់ឆ្ងាយពីច្រករបៀងព្រំដែនកម្ពុជាថៃរហូតដល់ការដ្ឋានការងារនៅក្រុងបាងកកប្រទេសថៃ។ប៉ុន្តែពេលនាំដល់ច្រករបៀងព្រំដែនខាងលើក៏បំបរបង់ពលករទុកចោលក្នុងព្រៃរបោះនៃតំបន់ព្រំដែនដេកទះមូសដាច់បាយក្រហាយទឹកដូច។

មន្ត្រីនគរបាលការពារព្រំដែននិងពលរដ្ឋនៅម្តុំនោះសម្តែងការអាណិតដល់ពលករដែលចាញ់បោកមេខ្យល់។ តែក៏បានស្តីបន្ទោសលើភាពលោភលន់ល្ងង់ខ្លៅភ្លើភ្លើខុសទំនងហើយហ៊ានហួសហេតុបរហន់ចង់បានការងារធ្វើខុសរឿងបែបនេះ ។ទោះជាយ៉ាងណាក៏សមត្ថកិច្ចកម្លាំងនៅខេត្តបន្ទាយមានជ័យឱ្យដឹងនៅព្រលប់ថ្ងៃទី២៩ខែមេសាថា៖សមត្ថកិច្ចមិនទាន់អាចចាប់ខ្លួនមេខ្យលធបោកលើពលករខ្មែរទាំង៤៦នាក់បាននៅឡើយ។S/

## រដ្ឋមន្ត្រីការងារ ប្រាប់ឱ្យពលករ ដែលមានបញ្ហាជីវភាពប្រចាំថ្ងៃ ទាក់ទងទៅអាជ្ញាធរមូលដ្ឋាន

https://thmeythmey.com/ 29, Apr 2020 , 10:29 pm ដោយ: ឡាយ សុភាវតី

ភ្នំពេញ៖ ពលករដែលវិលត្រឡប់ពីក្រៅប្រទេស ត្រូវទាក់ទងទៅអាជ្ញាធរមូលដ្ឋាន បើសិនមានបញ្ហាជីវភាពរស់នៅប្រចាំថ្ងៃ នៅអំឡុងពេលរាតត្បាតជំងឺកូវី-១៩។ នេះបើតាមសេចក្តីណែនាំរបស់ក្រសួងការងារ ចុះដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក អ៊ិត សំហេង ថ្ងៃទី២៩ មេសា ឆ្នាំ២០២០។ ក្រសួងការងារ បានបញ្ជាក់ថា ពលករខ្មែរ ដែលវិលត្រឡប់មកកម្ពុជាវិញ ហើយមានបំណងចង់ធ្វើការងារ ត្រូវទាក់ទងទៅមន្ទីរការងារ និងមជ្ឈមណ្ឌលការងារ រាជធានី-ខេត្ត ដើម្បីទទួលបានព័ត៌មានពីការងារ។ ជាមួយគ្នាដែរ ក្រសួងបានបញ្ជាក់ដល់ពលករថា៖ «សូមចូលរួមជួយ ក្រុមគ្រួសារដើម្បីធ្វើស្រែចម្ការ ដាំដុះ និងរបរកសិកម្មផ្សេងទៀត ក្នុងអំឡុងពេលចាំស្វែងរកការងារថ្មីនៅក្នុងស្រុក ឬចង់វិលទៅក្រៅប្រទេសវិញ»។ ចំពោះពលករដែលត្រឡប់មកវិញ

ហើយ មានបញ្ហាជីវភាពប្រចាំថ្ងៃ ត្រូវទាក់ទងទៅអាជ្ញាធរមូលដ្ឋាន ដើម្បីទទួលបានសេវាអន្តរាគមន៍។ នេះជាការបញ្ជាក់របស់ក្រសួងការងារ។

សារព័ត៌មានថ្មីៗ មិនអាចសុំការបកស្រាយបន្ថែមពីលោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ ដើម្បីលម្អិតព័ត៌មាននេះបានឡើយ ។ រីឯ ពលករខ្មែរ ដែលកំពុងស្នាក់នៅនិងធ្វើការនៅបរទេស ក្រសួងការងារណែនាំឲ្យ អនុវត្តតាមច្បាប់ បទបញ្ញា និងវិធានការសុខភាពនានា របស់អាជ្ញាធរនៃប្រទេសដែលពលករកំពុងធ្វើការ។ ទន្ទឹមនឹងនេះ ពលករខ្មែរត្រូវអនុវត្តតាមការណែនាំ របស់ស្ថានឯកអគ្គរាជទូតឬអគ្គកុងស៊ុលកម្ពុជាប្រចាំប្រទេស ដែលពលករកំពុងធ្វើការ ឬធ្វើការទាក់ទងទៅជាបន្ទាន់ក្នុងករណីមានបញ្ហា៕

## COVID-19៖ ពលករខ្មែរមកពីថៃ កំពុងប្រឈមការខ្វះខាត!

https://thmeythmey.com/ 29, Apr 2020 , 9:29 pm

ភ្នំពេញ៖ ពលករខ្មែរមកពីថៃខ្លះ កំពុងប្រឈមការខ្វះខាត ខណៈគ្មានការងារធ្វើនៅក្នុងអំឡុងពេលជំងឺកូវីដ ១៩ រាតត្បាត។ ពួកគេខ្លះ ចាយវាយប្រចាំថ្ងៃទាំងក្បិតក្បៀត ឯខ្លះទៀតកំពុងពឹងអាស្រ័យលើសាច់ញាតិ ដើម្បីដោះស្រាយបញ្ហាជីវភាព។ ជិត១ខែហើយ ដែលលោក ភី សំប៉ាយ និងភរិយា បន្តស្នាក់នៅទីកំណើតខ្លួន ក្នុងស្រុកវ៉ារិន ខេត្តសៀមរាប ក្រោយត្រឡប់ពីធ្វើការងារនៅប្រទេសថៃ ។ មិនខុសពីពលករខ្មែរដទៃទៀតទេ លោក សំប៉ាយ និងភរិយា សម្រេចមកកម្ពុជាវិញនេះ ដោយសារភ័យខ្លាចការឆ្លងរីករាលនៃជំងឺកូវីដ-១៩ នៅក្នុងប្រទេសថៃ ដែលកំពុងកើនឡើងជាបន្តបន្ទាប់។ មុនមកដល់កម្ពុជា ប្តីប្រពន្ធមួយគូនេះ ទទួលបានប្រាក់ខែចុងក្រោយ នៃការងារសំណង់ជាង៧០០ដុល្លារ ប៉ុន្តែពួកគេបានផ្ញើប្រាក់មកអ្នកផ្ទះមុន អស់ជាង៤០០ដុល្លារ ដោយសល់៣០០ដុល្លារ ទុកសម្រាប់ថ្លៃធ្វើដំណើរមកស្រុកកំណើត។ ធ្វើដំណើរពីប្រទេសថៃមកដល់ព្រំដែនកម្ពុជា ពីរនាក់ប្តីប្រពន្ធនេះ បានចំណាយជិត២៥០ដុល្លារ លើការហូបចុក និងថ្លៃមធ្យោបាយដឹកជញ្ជូនពីមួយទៅមួយ ក្រោយថៃរឹតបន្តឹង ការចេញ-ចូល។

«ប្រាក់ក៏អស់ ការងារក៏គ្មានធ្វើ»។ វាជាបញ្ហាធំមួយទៀត របស់លោក ភី សំប៉ាយ និងភរិយា ដែលកំពុងអាស្រ័យជីវភាពលើឪពុកម្តាយ និងសាច់ញាតិ ទម្រាំមានការងារវិញ។ លោក ភី សំប៉ាយ ដែលបានអនុវត្តកាតព្វកិច្ចចត្តាឡីស័ក១៤ថ្ងៃហើយនេះ បានប្រាប់សារព័ត៌មានថ្មីៗ តាមទូរសព្ទដូច្នេះថា៖«រាល់ថ្ងៃនេះ សុំលុយម្តាយក្មេកចាយ ហើយគាត់ឱ្យអង្ករហូបទៀត។ ខ្ញុំកំពុងខ្វះខាត ជួនកាលមានអីហូបហ្នឹង ជួនការបេះបន្លែជិតៗផ្ទះ ហើយពេលបានលុយពីម៉ែមក យកទិញត្រី១គីឡូមក ហូបព្រឹកល្ងាច បាន២ទៅ៣ថ្ងៃទៅ។ ខ្ញុំកំពុងរកការងារធ្វើដែរ តែមិនទាន់រកបាន មានតែទ្រាំខ្លះ ទ្រាំអត់ តាមដំណើរសិន មិនដឹងធ្វើយ៉ាងម៉េចទេ»។ បើតាមពលករសំណង់ ដែលទើបមកពីថៃរូបនេះ រាល់ថ្ងៃម្តាយក្មេក ជាអ្នកផ្គត់ផ្គង់ និងចិញ្ចឹមមើលថែកូនស្រីរបស់លោក ដែលទើបមានអាយុ៦ឆ្នាំ។

មិនមែនមានតែប្តីប្រពន្ធលោក ភី សំប៉ោយ ទេ ដែលកំពុងជួបបញ្ហាខ្វះខាតនោះ ។លោក ប៉ុក សំណាង ដែលបម្រើការងារ៨ឆ្នាំនៅថៃ ក៏កំពុងប្រឈមនឹងបញ្ហាហិរញ្ញវត្ថុក្នុងគ្រួសារ ក្រោយគ្មានការងារធ្វើ ខណៈដែលប្រពន្ធទើបសម្រាលកូនបាន៣ខែទៀត។ វាជាអម្រែកធ្ងន់មួយ សម្រាប់លោក ប៉ុក សំណាង។ កម្មករផ្នែកជំឡើងម៉ាស៊ីនកាត់ដេររោងចក្ររូបនេះ បាននិយាយដូច្នេះថា៖« ក្នុងគ្រួសារខ្ញុំ កំពុងភ័យខ្លាចអត់មានលុយ ព្រោះគ្មានការងារ។ រាល់ថ្ងៃទិញម្ហូបមិនឱ្យលើសពី១ម៉ឺនរៀលឡើយ ព្រោះលុយដែលសល់មកពីថៃជិតអស់ហើយ»។ បើតាមលោក សំណាង អ្វីដែលអាចធ្វើបានពេលនេះ គឺកាត់បន្ថយការចំណាយមិនចាំបាច់ ព្រោះគ្រួសារលោកកំពុងមានកូនតូចៗ។ « បើសិនមានកន្លែងការងារធ្វើការ ខ្ញុំនឹងចូលធ្វើភ្លាម ដើម្បីបានប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារ»។ នេះជាក្តីរំពឹងរបស់ពលករខ្មែរ ដែលទើបមកថៃ។

ដើមខែមេសានេះ ពលករខ្មែរជាង៨ម៉ឺននាក់ បានសម្រុកចូលមកកម្ពុជា ដោយសារបារម្ភពីការរីករាលដាល នៃជំងឺកូវីដ-១៩ នៅក្នុងប្រទេសថៃ។ ពលករទាំងនេះគ្មានអ្នកណាម្នាក់មានជំងឺកូវីដ១៩ ក្រោយក្រសួងសុខាភិបាល បានធ្វើតេស្តលើសំណាកពួកគេជាង៤០០នាក់ និងអនុវត្តវិធានការចត្តាឡីស័ក១៤ថ្ងៃលើពួកគេ។ ដ្បិតគ្មានជំងឺ មែន ប៉ុន្តែបញ្ហាក្រពះ គឺជារឿងធំ។ សម្តេច ស ខេង ដែលបានដឹងពីបញ្ហានេះ បានសង្កត់ធ្ងន់ថា ពលករជាង៨ម៉ឺន នាក់ ភាគច្រើនអាចផ្គត់ផ្គង់ជីវភាពគ្រួសារ បានរយៈពេលខ្លីប៉ុណ្ណោះ។

ដើម្បីដោះស្រាយបញ្ហាជីវភាពនេះ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានស្នើឱ្យពលរដ្ឋ ទាំងអស់ ត្រូវដាំដុះបន្លែនៅតាមទីលំនៅរៀងៗខ្លួន ដើម្បីរកប្រាក់ចំណូលក្នុងគ្រួសារបន្ថែម ពិសេសត្រូវមានការអត់ ធ្មត់ ចំពោះដំណាក់កាលដែលកម្ពុជាជួបប្រទះបញ្ហារីករាលដាលនៃជំងឺកូវីដ-១៩នេះ។

ត្រង់ចំណុចនេះ លោក មឿន តុលា ប្រធានមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សនៃអង្គការ សង់ ត្រាល់ បាននិយាយថា រដ្ឋាភិបាលគួរពិចារណាលើកត្តា២ រួមមាន ទី១ រដ្ឋគួរតែបញ្ចេញកញ្ចប់ថវិកាជាតិដែលបម្រុង ទុក យកមកជួយពលរដ្ឋឱ្យប្រាកដថា ពួកគេមានស្បៀងអាហារហូបគ្រប់គ្រាន់ និងស្នាក់នៅបណ្តោះអាសន្ន ទម្រាំ ពួកគេអាចត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញ និងចុងក្រោយ គឺជួយដល់វិស័យឯកជន ជាពិសេសអាជីវកម្មខ្នាត តូចនិងមធ្យមតែម្តង។ បើតាមលោក មឿន តុលា រដ្ឋាភិបាលគួរពិចារណា លើវិធីសាស្ត្រកាត់បន្ថយការចំណាយ របស់ពលរដ្ឋ ដូចជាការបញ្ចុះតម្លៃទឹក ភ្លើងជាដើមផងដែរ។

កន្លងមករដ្ឋាភិបាល ក៏បានដាក់ចេញវិធានការកាត់បន្ថយ និងលើកលែងពន្ធ ដល់សណ្ឋាគារ ផ្ទះសំណាក់ អាជីវកម្មទេសចរណ៍ រួមទាំងស្នើឱ្យធនាគារ និងមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ជួយសម្រាលការលំបាកពលរដ្ឋតាមរយៈ ការពន្យាពេលសង ឬបញ្ចុះថ្លៃសងជាដើម។ មិនតែប៉ុណ្ណោះរដ្ឋាភិបាល ក៏បានជួយសម្រាលទុក្ខលំបាកកម្មករ ដែល គ្មានការងារធ្វើ នៅពេលរោងចក្រព្យួរ តាមរយៈការផ្តល់ថវិកា៧០ដុល្លារ ដោយក្នុងនោះរដ្ឋឧបត្ថម្ភ៤០ដុល្លារ ហើយ ភាគីរោងចក្រចំណាយ៣០ដុល្លារលើកម្មករ។ល។

## ត្រៀមថវិកា៣០០លានដុល្លារ ជួយទ្រទ្រង់ពលករខ្មែរដែលមិនអាចត្រឡប់ទៅធ្វើការនៅបរទេស

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 29 April, 2020

ភ្នំពេញ ៖ រាជរដ្ឋាភិបាលកម្ពុជា ត្រៀមកញ្ចប់ថវិកាប្រមាណ ៣០០លានដុល្លារអាមេរិក សម្រាប់ជួយទ្រទ្រង់ ការខ្វះខាតរបស់ពលករខ្មែរចំណាកស្រុក ក្នុងពេលពួកគាត់មិនអាចត្រឡប់ទៅធ្វើការនៅក្រៅប្រទេសវិញបាន ចន្លោះពេលពិភពលោកមានវិបត្តិកូវីដ-១៩។

នេះជាការបញ្ជាក់របស់លោកស្រី ជូ ប៊ុនអេង នៅទី២៩ ខែមេសា ឆ្នាំ២០២០ ក្នុងឱកាសកិច្ចប្រជុំគណៈ កម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ នៅទីស្តីការ ក្រសួងមហាផ្ទៃ ដោយមានការចូលរួមពីទីភ្នាក់ងារអង្គការ សហប្រជាជាតិ ថ្នាក់ដឹកនាំនិងមន្ត្រីនៃអង្គការ IOM ព្រម ទាំងស្ថាប័ន អង្គការដៃគូជាតិ អន្តរជាតិពាក់ព័ន្ធជាច្រើន។ លោកស្រីបញ្ជាក់ថា ថវិកាប្រហែល ៣០០លានដុល្លារអា មេរិកនេះ សម្រាប់បម្រុងជាជំនួយគាំពារសង្គម ក៏ដូចជាសន្តិសុខស្បៀង ដែលគ្រោងនឹងដំណើរការអនុវត្តន៍នៅចុង ខែឧសភា ឬដើមខែមិថុនា ឆ្នាំនេះ។

ទោះជាយ៉ាងនេះក្តី លោកស្រី បានពន្យល់បន្ថែមថា ការផ្តល់ជូនការឧបត្ថម្ភនេះ គ្រាន់តែជាការដោះស្រាយ បញ្ហាជួយសម្រាល ប៉ុន្តែពលករខ្វះខាតត្រូវតែគិតគូរអំពីលទ្ធភាពផ្ទាល់ខ្លួនឲ្យបានគ្រប់គ្រាន់ ដើម្បីជានាផ្គត់ផ្គង់ខ្លួន ឯងបន្ថែមនៅក្នុងការរស់នៅប្រចាំថ្ងៃក្នុងកាលៈទេសៈនេះ៕

## ក្រសួងការងារ ស្នើឱ្យពលករដែលទើបមកពីបរទេស ជួយក្រុមគ្រួសារធ្វើស្រែចំការ ដាំដុះ

https://kleykley.sabay.com.kh/ 29-04-2020

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអំពាវនាវឱ្យពលករខ្មែរដែលបានវិលត្រឡប់មកកម្ពុជា ចូលរួមជួយក្រុមគ្រួសារដើម្បីធ្វើស្រែចំការ ដាំដុះ និងរបរកសិកម្មផ្សេងទៀត ក្នុងអំឡុងពេលរង់ចាំស្វែងរកការងារថ្មីធ្វើនៅក្នុងស្រុក ឬចង់វិលត្រឡប់ទៅក្រៅប្រទេសវិញ។ នេះបើតាមសេចក្តីណែនាំរបស់ក្រសួងការងារ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០។ ក្រសួងបញ្ជាក់ថា ពេលពលករខ្មែរត្រឡប់មកវិញ ត្រូវអនុវត្តតាមការណែនាំរបស់អាជ្ញាធរនៅតាមច្រកទ្វារព្រំដែនដើម្បីអនុវត្តវិធានការត្រួតពិនិត្យសុខភាពនិងចត្តាឡីស័ក១៤ថ្ងៃ នៅពេលទៅដល់ស្រុកកំណើតវិញ ស្របតាមនីតិវិធីដែលកំណត់ដោយក្រសួងសុខាភិបាល និងក្រុមការងាររាជធានី-ខេត្ត នៃក្រសួងមហាផ្ទៃ។ ក្រសួងការងារបន្តថា ក្នុងករណីបងប្អូនពលករ មានបញ្ហាជីវភាពរស់នៅប្រចាំថ្ងៃក្នុងអំឡុងពេលការរាតត្បាតជំងឺកូវីដ១៩ ត្រូវទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋានរបស់ខ្លួន ដើម្បីទទួលបានសេវាអន្តរាគមន៍។ ករណីមានបំណងស្វែងរកការងារថ្មីធ្វើ ត្រូវទាក់ទងទៅមន្ទីរការងារថ្មីធ្វើនៅក្នុងស្រុក ឬចង់វិលត្រឡប់ទៅក្រៅប្រទេសវិញ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃចំនួន ០៧នាក់

https://www.facebook.com/GDIOfficial/ April 29 2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៥និង៥០នាទី ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីសមត្ថកិច្ចថៃចំនួន ០៧នាក់។ នគរបាលអន្តោប្រវេសន៍ប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៧នាក់ ស្រី ០២នាក់ មាន ១. ឈ្មោះ សង លាភ ភេទប្រុស អាយុ ៣៥ឆ្នាំ ទីលំនៅបច្ចុប្បន្ន ស្ថិតក្នុងភូមិអន្លង់ស្វាយ ឃុំតាក្រាម ស្រុកបាណន់ ខេត្តបាត់ដំបង, ២. ឈ្មោះ រិន ទៀរុន ភេទប្រុស អាយុ ២១ឆ្នាំ ទីលំនៅបច្ចុប្បន្ន ភូមិអន្លង់ស្វាយ ឃុំតាក្រាម ស្រុកបាណន់ ខេត្តបាត់ដំបង, ៣. ឈ្មោះ ប៊ុន រិទ្ធ ភេទប្រុស អាយុ ៣១ឆ្នាំ ទីលំនៅ បច្ចុប្បន្ន ភូមិអន្លង់ស្វាយ ឃុំតាក្រាម ស្រុកបាណន់ ខេត្តបាត់ដំបង, ៤. ឈ្មោះ ម៉ៅ ដែន ភេទស្រី អាយុ ៣៤ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ភូមិអន្លង់ស្វាយ ឃុំតាក្រាម ស្រុកបាណន់ ខេត្តបាត់ដំបង, ៥. ឈ្មោះ រិទ្ធ ពេជ្រ ភេទប្រុស អាយុ ០៧ឆ្នាំ ទីលំនៅ បច្ចុប្បន្ន ភូមិអន្លង់ស្វាយ ឃុំតាក្រាម ស្រុកបាណន់ ខេត្តបាត់ដំបង, ៦. ឈ្មោះ រិទ្ធ ដារ៉ា ភេទស្រី អាយុ ០៤ឆ្នាំ ទីលំនៅបច្ចុប្បន្ន ភូមិអន្លង់ស្វាយ ឃុំតាក្រាម ស្រុកបាណន់ ខេត្តបាត់ដំបង និង៧. ឈ្មោះ ហេង ពិសី ភេទប្រុស អាយុ ៣៨ឆ្នាំ ទីលំនៅបច្ចុប្បន្ន ភូមិព្រៃទទឹង ឃុំព្រៃទទឹង ស្រុកស្រីសន្ធកណ្តាល ខេត្តព្រៃវែង។ ក្នុងនេះដែរ ក៏មានការចូលរួមពីមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពផងដែរ កម្លាំងនគរបាលប៉ុស្តិ៍បានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ពលរដ្ឋខ្មែរ ចូលប្រទេសតាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ មានចំនួន ០៤នាក់

https://www.facebook.com/GDIOfficial/ April 29 2020

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រំ នៅបន្តបិទមិនអនុញ្ញាតឲ្យអ្នកដំណើរ មធ្យោបាយ និងទំនិញ ចូល-ចេញ ឆ្លងកាត់ច្រកទ្វារនេះបាន។ ដោយឡែកមានពលរដ្ឋខ្មែរ ចូលប្រទេសតាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ មានចំនួន ០៤នាក់ ស្រី ០២នាក់ ក្មេង ០២នាក់ បន្ទាប់មកក្រុមចត្តាឡីស័ក វាស់កំដៅពុំមានសញ្ញាអ្វី គួរឲ្យកត់សំគាល់ និងបានធ្វើការអប់រំណែនាំ ដល់ពួកគាត់ពីវិធីបង្ការ ទប់ស្កាត់ ក្នុងការចម្លងមេរោគកូវីដ-១៩ រួចក៏ឲ្យប្រជាពលរដ្ឋទាំងនោះ វិលទ្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៦នាក់

https://www.facebook.com/GDIOfficial/ April 29 2020

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆងចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៦នាក់ ស្រី ០៨នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលរដ្ឋខ្មែរ០៤នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial/ April 29 2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ នារសៀលថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ បានទទួលពលរដ្ឋខ្មែរចំនួន ០៤នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអានសេះ ខេត្តព្រះវិហារ៕

## ពលរដ្ឋខ្មែរ រួមទាំងពលករ នៅប្រទេសថៃដែលអស់សុពលភាពទិដ្ឋាការស្នាក់នៅ ចាប់ពីថ្ងៃទី ២៦ ខែមីនានោះ ត្រូវបានអនុញ្ញាតឲ្យបន្តស្នាក់នៅដោយស្វ័យប្រវត្តិ

https://www.cen.com.kh/ April 30, 2020

ភ្នំពេញ៖ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានចេញសេចក្តីជូនដំណឹងស្តីពីការអនុគ្រោះបន្តឲ្យស្នាក់នៅ និងធ្វើការជាបណ្តោះអាសន្ន សម្រាប់បងប្អូនប្រជាពលរដ្ឋនិងពលករខ្មែរនៅប្រទេសថៃ ក្នុងស្ថានភាពនៃជំងឺកូវីដ-១៩។ គណៈរដ្ឋមន្ត្រីថៃ បានសម្រេចអនុគ្រោះបន្តសុពលភាពនៃការស្នាក់នៅសម្រាប់ជនបរទេសដែលអាចសម្រួលដល់ពលរដ្ឋ សិស្ស-និស្សិត និងពលករខ្មែរនៅក្នុងប្រទេសថៃ ដូចតទៅ៖

–ពលរដ្ឋខ្មែរ រួមទាំងពលករ ដែលអស់សុពលភាពទិដ្ឋាការស្នាក់នៅ ចាប់ពីថ្ងៃទី២៦ ខែមីនានោះ ត្រូវបានអនុញ្ញាតឲ្យបន្តស្នាក់នៅដោយស្វ័យប្រវត្តិ រហូតដល់ថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ ២០២០ ដោយពុំមានការផាកពិន័យលើការស្នាក់នៅលើសកំណត់ ប៉ុន្តែ មិនអនុញ្ញាតឲ្យធ្វើការនោះទេ។

–ពលករខ្មែរដែលនិយោជកបានបញ្ជូនបញ្ជីឈ្មោះទៅក្រសួងឬមន្ទីរការងារក្រុង/ខេត្ត តាមប្រព័ន្ធអនឡាញរួចរាល់ត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ អាចបន្តធ្វើការជាបណ្តោះអាសន្ន រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០២០។

–ប្រជាពលរដ្ឋខ្មែររួមទាំងពលករ ដែលត្រូវបង្ហាញខ្លួនក្នុងរយៈពេល៩០ថ្ងៃ ចន្លោះពីថ្ងៃទី២៦ ខែមីនា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ មិនតម្រូវឲ្យទៅបង្ហាញខ្លួនទេ រហូតដល់មានការជូនដំណឹងជាថ្មី។

សូមស្វែងយល់បន្ថែមពីវិធានការនានារបស់ប្រទេសជាសមាជិកអាស៊ានដទៃទៀត ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ៕ **ដោយៈកូឡាប**

# ថៃ បញ្ជូនពលករខ្មែរ ៣នាក់ ទៅតុលាការ ដោយសារមិនព្រមបង់ពិន័យ លើការល្មើសបម្រាមទប់ស្កាត់ កូវីដ១៩

https://dap-news.com/national/ ByPH104 Posted on April 29, 2020

ភ្នំពេញ ៖ ពលករខ្មែរ ៣នាក់ ក្នុងចំណោម ១៧នាក់ ដែលនាំគ្នាជួបជុំផឹកស៊ីសប្បាយ មិនអនុវត្តតាមបម្រាម ដើម្បីទប់ស្កាត់ជំងឺកូវីដ១៩ របស់អាជ្ញាធរថៃ កាលពីអំឡុងបុណ្យចូលឆ្នាំខ្មែរនោះ ត្រូវបានអាជ្ញាធរថៃ រៀបចំនីតិវិធីបញ្ជូនទៅតុលាការ ដោយសារមិនព្រមបង់ប្រាក់ តាមការពិន័យ ។ នេះបើតាមការបញ្ជាក់ របស់លោក កុយ គួង អ្នកនាំពាក្យ ក្រសួងការបរទេសខ្មែរ ។ សូមរំលឹកថា កាលពីថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០កន្លងទៅ អាជ្ញាធរថៃ បានឃាត់ខ្លួនពលករខ្មែរចំនួន ១៧នាក់ ក្រោយធ្វើបំពានបម្រាមហាមឃាត់ មិនឲ្យមានការជួបជុំគ្នា ក្នុងដំណាក់កាល ដែលថៃកំពុងប្រយុទ្ធប្រឆាំង ជាមួយជំងឺកូវីដ១៩ ។

ថ្លែងប្រាប់អ្នកសារព័ត៌មាន ក្រោយជំនួបរវាងលោក ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសខ្មែរ និងលោក អ៊ីមែនែហ្ស៊ីលដូ គូប៉ា ឡូប៉េស (Ermenegildo Kupa Lopes) ឯកអគ្គរដ្ឋទូតទីម័រឡេស្ត នាព្រឹកថ្ងៃទី២៩ មេសានេះ លោក កុយ គួង បានបញ្ជាក់ថា «ខ្ញុំសូមបញ្ជាក់ផងដែរ កន្លងមក ដែលគេប្រកាសដាក់ប្រទេស ក្នុងគ្រាមានអាសន្ននេះ គេហាមមានការជួបជុំគ្នាច្រើន ហើយកន្លងមកនេះពលរដ្ឋយើង ១៧នាក់ ត្រូវបានឃាត់ខ្លួន ដោយសារគាត់ជួបជុំ ទទួលទានគ្រឿងស្រវឹង ហើយក្នុងច្បាប់ថៃ កាលណា បំពានច្បាប់ គេត្រូវតែបង់ពិន័យ ហើយពិន័យតាមខ្ញុំដឹង ៤ម៉ឺនបាត ដូច្នេះក្នុងចំណោម ១៧នាក់នេះ ១៤នាក់ បានបង់រួច ហើយត្រូវបានដោះលែង ឲ្យមកកន្លែងស្នាក់នៅវិញ រីឯ ៣នាក់ទៀត នៅតែមិនព្រមបង់ ដូច្នេះគេរៀបចំនីតិវិធីទៅតុលាការ» ។ លោកបន្ថែមថា ស្ថានទូតកម្ពុជាប្រចាំនៅថៃ កំពុងតែតាមដានរឿងនេះ ប៉ុន្តែទោះបីជាយ៉ាងណា លោកយល់ថា បើតុលាការថៃសម្រេចយ៉ាងណា ក៏ប្រហែលមិនហួសពី ៤ម៉ឺនបាត នេះដែរ ។

សូមបញ្ជាក់ផងដែរថា ពាក់ព័ន្ធបញ្ហានេះកាលពីពេលកន្លងទៅ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា ក៏បានអំពាវនាវដល់ពលករ ពលការ នីដែលកំពុងរស់នៅធ្វើការក្រៅប្រទេស ជាពិសេសនៅប្រទេសថៃ ត្រូវគោរពតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយ ដែលប្រទេសគេបានដាក់ចេញ រួមទាំងច្បាប់បម្រាមគោចរ និងបម្រាមជួបជុំគ្នាជាក្រុម ឬជប់លៀងជាក្រុមដែលពេលនេះ ប្រទេសគេកំពុងមានការហាមឃាត់ តឹងរឹងបំផុតក្នុងការទប់ស្កាត់ ការចម្លងរោគកូវីដ-១៩ ៕ ដោយ៖ ខា ដា

---